ធម្មបទគាថា

ការផ្សាយរបស់ **មណ្ឌលពុទ្ធិត្រៃគុណ**

(ផ្សព្វផ្សាយជាធម្មទាន ដោយ**ធម្មាមកជន** សហគមន៍ធម្មទាន)

ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ព្រះសមណគោតម ព្រះបរមសាស្តា

យោ ធម្មំ បស្សតិ សោ មំ បស្សតិ

អ្នកណាឃើញធម៌ អ្នកនោះឃើញតថាគត

ធម្មបូជាពីក្រុមធម្មមាមកៈ
ឆ្នាំ មមី ឆស័ក ព.ស.២៥៥៨

ធម្មបទគាថា

(ព្រះគាថាធម្មបទ)

The Dhammapada

(ស្រង់ចាក សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ : បិ. ៥២)

ព្រហ្ម-មេត្តា គតបណ្ឌិតោ (ហៅ ជយទរិន្ទ)

រចនា រៀបរៀង និង ផ្ទៀងផ្ទាត់

(បោះពុម្ពលើកទី៣)

បោះពុម្ពផ្សព្វផ្សាយជាធម្មទាន

ដោយ មូលបុញ្ញនិធិ កល្យាណីសិរីលក្ខិណា

ក្រុមធម្មាមកជន សហគមន៍ធម្មទាន ក្នុង និង ក្រៅប្រទេស

ការផ្សាយរបស់មណ្ឌលពុទ្ធិត្រៃគុណា

ឆ្នាំច សំរិទ្ធិស័ក ព.ស. ២៥៦២

គ.ស. 2018

ធម្មបទគាថា

ឃ្លាំងមរតកអរិយសច្ចធម៌

កំណប់មហាសាលនៃពុទ្ធិគតិបណ្ឌិត

សម្រាប់អប់រំជីវិតឱ្យបានប្រកបដោយគុណធម៌

The Dhammapada

The Buddha's Path of Wisdom

Treasury of Truth

a Practical Guide to Right Living

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការក្រាបថ្វាយបង្គំ **ព្រះមានព្រះភាគ**

ព្រះអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ !

* ***I go for refuge to the Buddha*** **(the Teacher).**
* ***I go for refuge to the Dhamma*** **(the Teaching).**
* ***I go for refuge to the Sangha*** **(the Taught).**

ប្រារព្ធកថា

ព្រះគាថាធម្មបទ (ឬ **ធម្មបទគាថា**) ជា **ពុទ្ធភាសិត** សុទ្ធតែជាគាថាទាំងអស់ គឺជា **ព្រះពុទ្ធវចនៈ** ដ៏បរិសុទ្ធ ដែល **ព្រះដ៏មានព្រះភាគ ព្រះបរមសាស្ដា** ព្រះពុទ្ធអង្គទ្រង់ប្រកបដោយ**សព្វញ្ញុតញ្ញាណ** និង ព្រះទ័យមេត្តា-ករុណាដ៏ជ្រាលជ្រៅ ទ្រង់បានត្រាស់សម្ដែងប្រារព្ធយោងទៅតាមឧបនិស្ស័យ នៃពុទ្ធសាវ័កនីមួយ ៗ រឿង ៗ ខ្លួន ម្នាក់ ៗ ។ ក្រោយពេលដែលបានត្រងត្រាប់ស្ដាប់ សិក្សាដោយយោនិសោមនសិការ ទេវតាទាំងឡាយ បរិស័ទទាំងឡាយ គ្រប់ទិសទី គ្រប់ឋានៈ គ្រប់ស្រទាប់ជាន់ថ្នាក់ ដែលបានមកប្រជុំគ្នាស្ដាប់ បានសម្រេចនូវមគ្គ-ផល ជាបន្តបន្ទាប់ គួរដល់ការជ្រះថ្លាដ៏ក្រៃលែង អាស្រ័យដោយធម្មរស និង ធម្មា-នុភាព នៃព្រះសម្មាសម្ពុទ្ធ បានជ្រួតជ្រាបចូលទៅក្នុងសន្ដាន រំលាយនូវគំនរងងឹត គឺអវិជ្ជា កាត់ផ្ដាច់នូវចំណងនៃតណ្ហា ទិដ្ឋិ មានះ ឧបាទាន ហើយបានប្រកបដោយវិជ្ជាសម្បទា បញ្ញាញាណដ៏ភ្លឺថ្លា ចូលដល់ជំរៅនៃខ្លឹមសច្ចធម៌ (**ធម្មសារ**) បានសម្រេចនូវលោកុត្តរធម៌ លែងវិលវល់ត្រឡប់ត្រឡិន លិចលង់ក្នុងមហាសាគរ នៃវដ្តៈនេះ តទៅទៀត ។

សូមសាធុជនទាំងឡាយ អារាធនានូវ **ព្រះពុទ្ធគាថា ព្រះពុទ្ធវចនៈ ព្រះពុទ្ធដីកា ព្រះពុទ្ធឱវាទ** បញ្ចូល បញ្ជ្រួតបញ្ជ្រាប ទៅក្នុងសន្ដានចិត្ត ដើម្បីបានជាឧបនិស្ស័យ នៃការរំលត់រំលាយឱ្យអស់ទៅ

នូវអាសវក្កិលេស សន្សំនូវគុណធម៌ដ៏បវរ ត្រាច់ចរចាកចេញពីអន្លង់វដ្តៈ ដ៏ប្រកបដោយសេចក្តីទុក្ខ ដ៏ឥតត្រើយត្រាណនេះ ។

សូមសាធុជនទាំងឡាយ រីករាយជ្រះថ្លាក្នុងការសិក្សា នូវព្រះធម្មបទគាថានេះ ដើម្បីញុំាងនូវធម្មបីតិឱ្យកើតឡើង ជ្រួតជ្រាបទៅក្នុងសន្តាន បានជាគំនរនៃបញ្ញា ប្រហារបង់នូវគំនរអវិជ្ជា ដែលជាប្រភពនៃគំនរសេចក្តីទុក្ខសោកសៅទាំងឡាយ !

- សូមឱ្យសាសនាព្រះសម្ពុទ្ធ រុងរឿងបំផុតអស់កាលយូរ !
- សូមព្រះសទ្ធម្មព្រះបរមគ្រូ ឋិតថេរនៅយូរគ្រប់ ៥.០០០ (ព្រះវស្សា)
- សូមឱ្យព្រះពុទ្ធសាសនា រុងរឿងចម្រើន !
- សូមឱ្យព្រះពុទ្ធសាសនា ផ្សាយទូទៅពេញសកលលោក !
- សូមឱ្យលោកទាំងមូល បានប្រកបដោយសន្តិភាព !
- **ព្រះសក្យមុនីសម្ពុទ្ធ** ទ្រង់ត្រាស់ថា **នត្ថិ សន្តិ បរំ សុខំ**
  ពុំមានសេចក្តីសុខដទៃក្រៅអំពីសេចក្តីស្ងប់ឡើយ !

ដោយសេចក្តីគោរពជ្រះថ្លា និង សេចក្តីមេត្តា ដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ ជាអ្នករចនា_រៀបរៀង និង លោក_អ្នក ជាម្ចាស់នៃការឧប--ត្ថម្ភនូវថវិកា ទ្រទ្រង់ការបោះពុម្ព សម្រាប់ផ្សព្វផ្សាយនូវធម្មទាននេះ !

សូមអនុមោទនា រីករាយជ្រះថ្លាទ្រទ្រង់នូវព្រះពុទ្ធវចនៈ និង ធម្មប្បដិបត្តិ !

ឆ្នាំ ច សំរិទ្ធិស័ក **ព.ស.២៥៦២**

(2018)

The Dhammapada

The Buddha's Path of **Wisdom**

A Practical Guide to Right Living

ឈ្មោះវគ្គ .... **លេខទំព័រ**

១.. យមកវគ្គ (*The Twin Verses*) -- ទំព័រ ២៧
២.. អប្បមាទវគ្គ (*Heedfulness*) -- ទំព័រ ៣៨
៣.. ចិត្តវគ្គ (*Mind*) -- ទំព័រ ៤៥
៤.. បុប្ផវគ្គ (*Flowers*) -- ទំព័រ ៥១
៥.. ពាលវគ្គ (*Fools*) -- ទំព័រ ៥៩
៦.. បណ្ឌិតវគ្គ (*The Wise*) -- ទំព័រ ៦៨
៧.. អរហន្តវគ្គ (*The Worthy*) -- ទំព័រ ៧៥
៨.. សហស្សវគ្គ (*Thousands*) -- ទំព័រ ៨២
៩.. បាបវគ្គ (*Evil*) -- ទំព័រ ៩១
១០.. ទណ្ឌវគ្គ (*The Rod or Punishment*) -- ទំព័រ ៩៩
១១.. ជរាវគ្គ (*Old Age*) -- ទំព័រ ១០៧
១២.. អត្តវគ្គ (*The Self*) -- ទំព័រ ១១៣
១៣.. លោកវគ្គ (*The World*) -- ទំព័រ ១១៩
១៤.. ពុទ្ធវគ្គ (*The Buddha*) -- ទំព័រ ១២៦
១៥.. សុខវគ្គ (*Happiness*) -- ទំព័រ ១៣៤

១៦.. បិយវគ្គ *(Affection)* ---------- ទំព័រ ១៤០

១៧.. កោធវគ្គ *(The Anger)* ---------- ទំព័រ ១៤៦

១៨.. មលវគ្គ *(Impurities or Taints)* ---------- ទំព័រ ១៥២

១៩.. ធម្មដ្ឋវគ្គ *(The Just or Righteous)* ---------- ទំព័រ ១៦២

២០.. មគ្គវគ្គ *(The Way or The Path)* ---------- ទំព័រ ១៧០

២១.. បកិណ្ណកវគ្គ *(Miscellaneous)* ---------- ទំព័រ ១៧៨

២២.. និរយវគ្គ *(The Woeful State)* ---------- ទំព័រ ១៨៦

២៣.. នាគវគ្គ *(The Elephant)* ---------- ទំព័រ ១៩៣

២៤.. តណ្ហាវគ្គ *(The Craving)* ---------- ទំព័រ ២០១

២៥.. ភិក្ខុវគ្គ *(The Monk / The Bhikkhu or Mendicant)* - ទំព័រ ២១៥

២៦.. ព្រាហ្មណវគ្គ *(The Holy Man = The Brāhmaṇa)* ---------- ទំព័រ ២២៤

ព្រះគាថាធម្មបទ : មាន **២៦** វគ្គ,

មាន **៤២៣** គាថា

មាន **៣០២** រឿងប្រាវព្ធ ...

* **ឯកនគ្គ** បាលី_ប្រែ ---------- ទំព័រ ២៤៥

* **សន្ធម្មទគ្គ** ---------- ទំព័រ ២៦០

ធម្មបទគាថា ចែកជា ២៦ វគ្គ, មាន ៤២៣ គាថា (= ៣០២ រឿង)		
វគ្គទី ១ : **យមកវគ្គ**, មាន ២០ គាថា = ១៤រឿង,		
ល.រ.	លេខគាថា (ទី ...)	ប្រារព្ធនាក់ទងនឹងរឿងរបស់ ...
១	គាថាទី **១**	ព្រះចក្ខុបាលត្ថេរ
២	គាថាទី **២**	មដ្ឋកុណ្ឌលី
៣	គាថាទី **៣, ៤**	តិស្សត្ថេរ
៤	គាថាទី **៥**	កាឡីយក្ខិនី
៥	គាថាទី **៦**	ភិក្ខុកោសម្ពី
៦	គាថាទី **៧, ៨**	ព្រះចុល្លកាល-មហាកាលត្ថេរ
៧	គាថាទី **៩, ១០**	ភិក្ខុទេវទត្ត
៨	គាថាទី **១១, ១២**	សញ្ជ័យបរិព្វាជក
៩	គាថាទី **១៣, ១៤**	ព្រះនន្ទត្ថេរ
១០	គាថាទី **១៥**	នាយចុន្ទសូករិក
១១	គាថាទី **១៦**	ធម្មិកឧបាសក
១២	គាថាទី **១៧**	ភិក្ខុទេវទត្ត
១៣	គាថាទី **១៨**	នាងសុមនាទេវី
១៤	គាថាទី **១៩, ២០**	ភិក្ខុពីរអង្គជាសម្លាញ់នឹងគ្នា
វគ្គទី ២ : **អប្បមាទវគ្គ**, មាន ១២ គាថា = ៩រឿង,		
១៥	គាថាទី **២១,២២,២៣**	ព្រះនាងសាមាវតី

១៦	គាថាទី **២៤**	**កុម្ភឃោសកសេដ្ឋី**
១៧	គាថាទី **២៥**	**ចូឡបន្ថកត្ថេរ**
១៨	គាថាទី **២៦, ២៧**	**នក្ខត្តឫក្សរបស់ជនពាល**
១៩	គាថាទី **២៨**	**ព្រះមហាកស្សបត្ថេរ**
២០	គាថាទី **២៩**	**សហាយកភិក្ខុ** (ភិក្ខុពីរអង្គជាសម្លាញ់នឹងគ្នា)
២១	គាថាទី **៣០**	**សក្កទេវរាជ**
២២	គាថាទី **៣១**	**អញ្ញតរភិក្ខុ** (ភិក្ខុមួយរូប)
២៣	គាថាទី **៣២**	**ព្រះនិគមវាសីតិស្សត្ថេរ**
វគ្គទី ៣ : **ចិត្តវគ្គ**, មាន ១១ គាថា = ៩ រឿង,		
២៤	គាថាទី **៣៣, ៣៤**	**ព្រះមេឃិយត្ថេរ**
២៥	គាថាទី **៣៥**	**អញ្ញតរភិក្ខុ-មាតិកមាតា**
២៦	គាថាទី **៣៦**	**ឧក្កណ្ឋិតភិក្ខុ** (ភិក្ខុអផ្សុកមួយរូប)
២៧	គាថាទី **៣៧**	**ព្រះភាគិនេយ្យសង្ឃរក្ខិតត្ថេរ**
២៨	គាថាទី **៣៨, ៣៩**	**ព្រះចិត្តហត្ថត្ថេរ**
២៩	គាថាទី **៤០**	**អារទ្ធវិបស្សកភិក្ខុ** (ភិក្ខុអ្នកប្រារព្ធវិបស្សនា)
៣០	គាថាទី **៤១**	**ព្រះបូតិគត្តតិស្សត្ថេរ**
៣១	គាថាទី **៤២**	**នាយនន្ទគោបាល**
៣២	គាថាទី **៤៣**	**ព្រះសោរេយ្យត្ថេរ**
វគ្គទី ៤ : **បុប្ផវគ្គ**, មាន ១៦ គាថា = ១២ រឿង,		
៣៣	គាថាទី **៤៤, ៤៥**	**បឋវីកថាបសុតបញ្ចសតភិក្ខុ**

៣៤	គាថាទី **៤៦**	**មរីចិកម្មដ្ឋានិកត្ថេរ**
៣៥	គាថាទី **៤៧**	**ព្រះបាទវិឌូឌភៈ**
៣៦	គាថាទី **៤៨**	**នាងបតិបូជិកា**
៣៧	គាថាទី **៤៩**	**មច្ឆរិយកោសិយសេដ្ឋី**
៣៨	គាថាទី **៥០**	**បាដិកាជីវក**
៣៩	គាថាទី **៥១, ៥២**	**ឆត្តបាណិឧបាសក**
៤០	គាថាទី **៥៣**	**នាងវិសាខាមិគារមាតា**
៤១	គាថាទី **៥៤, ៥៥**	**អានន្ទត្ថេរបញ្ហា**
៤២	គាថាទី **៥៦**	**ព្រះមហាកស្សបត្ថេរបិណ្ឌបាតទាន**
៤៣	គាថាទី **៥៧**	**គោធិកត្ថេរបរិនិព្វាន**
៤៤	គាថាទី **៥៨, ៥៩**	**នាយគរហទិន្ន**
វគ្គទី ៥ : **ពាលវគ្គ**, មាន ១៦ គាថា = ១៥ រឿង,		
៤៥	គាថាទី **៦០**	**ព្រះបាទបសេនទិកោសល** និង ទុគ្គតបុរស
៤៦	គាថាទី **៦១**	**មហាកស្សបសទ្ធិវិហារិក**
៤៧	គាថាទី **៦២**	**អានន្ទសេដ្ឋី**
៤៨	គាថាទី **៦៣**	**គណ្ឋិភេទកចោរ**
៤៩	គាថាទី **៦៤**	**ព្រះឧទាយិត្ថេរ**
៥០	គាថាទី **៦៥**	**បាឋេយ្យកភិក្ខុ** (ភិក្ខុអ្នកក្រុងបាវាប្រមាណ៣០អង្គ)
៥១	គាថាទី **៦៦**	**សុប្បពុទ្ធកុដ្ឋិ**

៥២	គាថាទី **៦៧**	**នាយកសិករ** (បុរសអ្នកភ្ជួរស្រែម្នាក់)
៥៣	គាថាទី **៦៨**	**នាយសុមនមាលាការ**
៥៤	គាថាទី **៦៩**	**នាងឧប្បលវណ្ណាថេរី**
៥៥	គាថាទី **៧០**	**ជម្ពុកាជីវក**
៥៦	គាថាទី **៧១**	**អហិប្រេត**
៥៧	គាថាទី **៧២**	**សដ្ឋិកូដប្រេត**
៥៨	គាថាទី **៧៣, ៧៤**	**សុធម្មត្ថេរ**
៥៩	គាថាទី **៧៥**	**ព្រះវនវាសីតិស្សត្ថេរ**
វគ្គទី ៦ : **បណ្ឌិតវគ្គ**, មាន ១៤ គាថា = ១១ រឿង,		
៦០	គាថាទី **៧៦**	**ព្រះរាធត្ថេរ**
៦១	គាថាទី **៧៧**	**ភិក្ខុអស្សជិ និង បុនព្វសុកភិក្ខុ**
៦២	គាថាទី **៧៨**	**ព្រះឆន្នត្ថេរ**
៦៣	គាថាទី **៧៩**	**ព្រះមហាកប្បិនត្ថេរ**
៦៤	គាថាទី **៨០**	**បណ្ឌិតសាមណេរ**
៦៥	គាថាទី **៨១**	**ព្រះលកុណ្ឌកភទ្ទិយត្ថេរ**
៦៦	គាថាទី **៨២**	**មាតានាងកាណា**
៦៧	គាថាទី **៨៣**	**បញ្ចសតភិក្ខុ** (ភិក្ខុ ៥០០ អង្គ)
៦៨	គាថាទី **៨៤**	**ព្រះធម្មិកត្ថេរ**
៦៩	គាថាទី **៨៥, ៨៦**	**ធម្មស្សវនៈ**

៧០	គាថាទី **៨៧, ៨៨, ៨៩**	**អាគន្តុកភិក្ខុ**
វគ្គទី ៧ : **អរហន្តវគ្គ**, មាន ១០ គាថា = ១០ រឿង,		
៧១	គាថាទី **៩០**	**ពេទ្យជីវក**
៧២	គាថាទី **៩១**	**ព្រះមហាកស្សបត្ថេរ**
៧៣	គាថាទី **៩២**	**ព្រះពេឡដ្ឋសីសត្ថេរ**
៧៤	គាថាទី **៩៣**	**ព្រះអនុរុទ្ធត្ថេរ**
៧៥	គាថាទី **៩៤**	**ព្រះមហាកច្ចាយនត្ថេរ**
៧៦	គាថាទី **៩៥**	**ព្រះសារីបុត្តត្ថេរ**
៧៧	គាថាទី **៩៦**	**ព្រះកោសម្ពីវាសីតិស្ស**
៧៨	គាថាទី **៩៧**	**ព្រះសារីបុត្តត្ថេរ**
៧៩	គាថាទី **៩៨**	**ព្រះខទិរវនិយរេវតត្ថេរ**
៨០	គាថាទី **៩៩**	**អញ្ញតរិត្ថី** (ប្រារព្ធស្ត្រីម្នាក់)
វគ្គទី ៨ : **សហស្សវគ្គ**, មាន ១៦ គាថា = ១៤ រឿង,		
៨១	គាថាទី **១០០**	**តម្ពទាឋិកចោរឃាតកៈ**
៨២	គាថាទី **១០១**	**ព្រះពាហិយទារុចីរិយត្ថេរ**
៨៣	គាថាទី **១០២, ១០៣**	**នាងកុណ្ឌលកេសីថេរី**
៨៤	គាថាទី **១០៤, ១០៥**	**អនត្ថបុច្ឆកព្រាហ្មណ៍**
៨៥	គាថាទី **១០៦**	**សារីបុត្តមាតុលព្រាហ្មណ៍**
៨៦	គាថាទី **១០៧**	**សារីបុត្តភាគិនេយ្យព្រាហ្មណ៍**

៨៧	គាថាទី **១០៨**	**សារីបុត្តសហាយព្រាហ្មណ៍**
៨៨	គាថាទី **១០៩**	**អាយុវឌ្ឍនកុមារ**
៨៩	គាថាទី **១១០**	**សង្កិច្ចសាមណេរ**
៩០	គាថាទី **១១១**	**ព្រះខាណុកោណ្ឌញ្ញត្ថេរ**
៩១	គាថាទី **១១២**	**ព្រះសប្បទាសត្ថេរ**
៩២	គាថាទី **១១៣**	**ព្រះនាងបដាចារាថេរី**
៩៣	គាថាទី **១១៤**	**នាងកិសាគោតមី**
៩៤	គាថាទី **១១៥**	**នាងពហុបុត្តិកាថេរី**
វគ្គទី ៩ : **បាបវគ្គ**, មាន ១៣ គាថា = ១២ រឿង,		
៩៥	គាថាទី **១១៦**	**ចូឡេកសាដកព្រាហ្មណ៍**
៩៦	គាថាទី **១១៧**	**សេយ្យកភិក្ខុ**
៩៧	គាថាទី **១១៨**	**នាងលាជទេវធីតា**
៩៨	គាថាទី **១១៩,១២០**	**អនាថបិណ្ឌិកសេដ្ឋី**
៩៩	គាថាទី **១២១**	**អសញ្ញតបរិក្ខារភិក្ខុ**
១០០	គាថាទី **១២២**	**ពិឡាលបទកសេដ្ឋី**
១០១	គាថាទី **១២៣**	**មហាធនពាណិជ**
១០២	គាថាទី **១២៤**	**នាយព្រានកុក្កុដមិត្ត**
១០៣	គាថាទី **១២៥**	**នាយកោកសុនខលុទ្ទកៈ**
១០៤	គាថាទី **១២៦**	**ព្រះមណីការកុលុបកតិស្សត្ថេរ**

១០៥	គាថាទី **១២៧**	ជន ៣ នាក់
១០៦	គាថាទី **១២៨**	សុប្បពុទ្ធសក្កៈ
វគ្គទី ១០ : **ទណ្ឌវគ្គ**, មាន ១៧ គាថា = ១១ រឿង,		
១០៧	គាថាទី **១២៩**	ឆព្វគ្គិយភិក្ខុ
១០៨	គាថាទី **១៣០**	ឆព្វគ្គិយភិក្ខុ
១០៩	គាថាទី **១៣១,១៣២**	សម្ពហុលកុមារ (ក្មេងច្រើននាក់)
១១០	គាថាទី **១៣៣,១៣៤**	ព្រះកោណ្ឌធានត្ថេរ
១១១	គាថាទី **១៣៥**	ឧបោសថកម្ម
១១២	គាថាទី **១៣៦**	អជគរប្រេត
១១៣	គាថាទី **១៣៧, ១៣៨, ១៣៩, ១៤០**	ព្រះមហាមោគ្គល្លានត្ថេរ
១១៤	គាថាទី **១៤១**	ពហុភណ្ឌិកភិក្ខុ
១១៥	គាថាទី **១៤២**	សន្តតិមហាមាត្យ
១១៦	គាថាទី **១៤៣, ១៤៤**	ព្រះបិលោតិកត្ថេរ
១១៧	គាថាទី **១៤៥**	សុខសាមណេរ
វគ្គទី ១១ : **ជរាវគ្គ**, មាន ១១ គាថា = ៩ រឿង,		
១១៨	គាថាទី **១៤៦**	វិសាខាសហាយិកា
១១៩	គាថាទី **១៤៧**	នាងសិរិមា
១២០	គាថាទី **១៤៨**	ព្រះនាងឧត្តរាថេរី
១២១	គាថាទី **១៤៩**	អធិមានិកភិក្ខុ

១២២	គាថាទី **១៥០**	**នាងរូបនន្ទាថេរី**
១២៣	គាថាទី **១៥១**	**នាងមល្លិកាទេវី**
១២៤	គាថាទី **១៥២**	**ព្រះលោឡុទាយិត្ថេរ**
១២៥	គាថាទី **១៥៣, ១៥៤**	**ព្រះពុទ្ធបឋមឧទាន**
១២៦	គាថាទី **១៥៥, ១៥៦**	**មហាធនសេដ្ឋីបុត្រ**
វគ្គទី ១២ : **អត្តវគ្គ**, មាន ១០ គាថា = ១០ រឿង,		
១២៧	គាថាទី **១៥៧**	**ពោធិរាជកុមារ**
១២៨	គាថាទី **១៥៨**	**ព្រះឧបនន្ទសក្យបុត្រ**
១២៩	គាថាទី **១៥៩**	**ព្រះបធានិកតិស្សត្ថេរ**
១៣០	គាថាទី **១៦០**	**មាតាព្រះកុមារកស្សបត្ថេរ**
១៣១	គាថាទី **១៦១**	**មហាកាលឧបាសក**
១៣២	គាថាទី **១៦២**	**ទេវទត្តភិក្ខុ**
១៣៣	គាថាទី **១៦៣**	**ការព្យាយាមបំបែកសង្ឃនៃភិក្ខុទេវទត្ត**
១៣៤	គាថាទី **១៦៤**	**ព្រះកាលត្ថេរ**
១៣៥	គាថាទី **១៦៥**	**ចូឡកាលឧបាសក**
១៣៦	គាថាទី **១៦៦**	**ព្រះអត្តទត្ថត្ថេរ**
វគ្គទី ១៣ : **លោកវគ្គ**, មាន ១២ គាថា = ១១ រឿង,		
១៣៧	គាថាទី **១៦៧**	**ទហរភិក្ខុ** (ភិក្ខុកម្លោះ)
១៣៨	គាថាទី **១៦៨, ១៦៩**	**ព្រះបាទសុទ្ធោទនៈ**

១៣៩	គាថាទី **១៧០**	**ពិបស្សកភិក្ខុ**
១៤០	គាថាទី **១៧១**	**អភយរាជកុមារ**
១៤១	គាថាទី **១៧២**	**ព្រះសម្មជ្ជនត្ថេរ**
១៤២	គាថាទី **១៧៣**	**ព្រះអង្គុលិមាលត្ថេរ**
១៤៣	គាថាទី **១៧៤**	**ធីតា**កូនស្រីជាងតម្បាញ
១៤៤	គាថាទី **១៧៥**	**ភិក្ខុ** ៣០ **អង្គ**
១៤៥	គាថាទី **១៧៦**	**នាងចិញ្ចាមាណវិកា**
១៤៦	គាថាទី **១៧៧**	**ជុំណ្ណអាមាត្យ អសទិសទាន**
១៤៧	គាថាទី **១៧៨**	**នាយកាឡៈ**កូនអនាថបិណ្ឌិកសេដ្ឋី
វគ្គទី ១៤ : **ពុទ្ធវគ្គ**, មាន ១៨ គាថា = ៩ រឿង,		
១៤៨	គាថាទី **១៧៩, ១៨០**	**មារធីតា**
១៤៩	គាថាទី **១៨១**	**យមកបាដិហារ្យ**
១៥០	គាថាទី **១៨២**	**ឯរកបត្តនាគរាជ**
១៥១	គាថាទី **១៨៣, ១៨៤, ១៨៥**	**អានន្ទត្ថេរបុច្ឆា**
១៥២	គាថាទី **១៨៦, ១៨៧**	**អនភិរតភិក្ខុ**
១៥៣	គាថាទី **១៨៨, ១៨៩, ១៩០, ១៩១, ១៩២**	**អគ្គិទត្តបុរោហិត**
១៥៤	គាថាទី **១៩៣**	**អានន្ទត្ថេរបុច្ឆា**
១៥៥	គាថាទី **១៩៤**	**សម្ពហុលភិក្ខុ**
១៥៦	គាថាទី **១៩៥, ១៩៦**	**កស្សបទសពលសុវណ្ណចេតិយ**

វគ្គទី ១៥ : សុខវគ្គ, មាន ១២ គាថា = ៨ រឿង,		
១៥៧	គាថាទី **១៩៧, ១៩៨, ១៩៩**	ការហាមព្រះញាតិក្នុងរឿងវិវាទដណ្តើមការកាន់កាប់ទឹកស្ទឹងរោហិណី រវាងពួកអ្នកដែនសាក្យៈ និង ពួកកោលិយៈ
១៥៨	គាថាទី **២០០**	**មារប្រែញ្ញា**
១៥៩	គាថាទី **២០១**	**កោសលរាជបរាជ័យ**
១៦០	គាថាទី **២០២**	**ប្រារព្ធគូស្វាមី-ភរិយាមួយគូ**
១៦១	គាថាទី **២០៣**	**ទុគ្គតបុរសគង្វាលគោ**
១៦២	គាថាទី **២០៤**	**ព្រះបាទបសេនទិកោសល**
១៦៣	គាថាទី **២០៥**	**ព្រះតិស្សត្ថេរ**
១៦៤	គាថាទី **២០៦, ២០៧, ២០៨**	**សក្កទេវរាជ**
វគ្គទី ១៦ : បិយវគ្គ, មាន ១២ គាថា = ៩ រឿង,		
១៦៥	គាថាទី **២០៩ , ២១០, ២១១**	**តយោបព្វជិត** (បព្វជិត ៣ រូប)
១៦៦	គាថាទី **២១២**	**អញ្ញតរកុដុម្ពី**
១៦៧	គាថាទី **២១៣**	**នាងវិសាខាឧបាសិកា**
១៦៨	គាថាទី **២១៤**	**ពួកក្សត្រលិច្ឆវី**
១៦៩	គាថាទី **២១៥**	**អនិត្ថិគន្ធកុមារ**
១៧០	គាថាទី **២១៦**	**អញ្ញតរព្រាហ្មណ៍**
១៧១	គាថាទី **២១៧**	**បញ្ចសតកុមារ** (កុមារ ៥០០ នាក់)

១៧២	គាថាទី **២១៨**	ព្រះអនាគាមិត្ថេរ
១៧៣	គាថាទី **២១៩, ២២០**	នន្ទិយកុលបុត្រ
វគ្គទី ១៧ : **កោធវគ្គ**, មាន ១៤ គាថា = ៨ រឿង,		
១៧៤	គាថាទី **២២១**	ព្រះនាងរោហិណីខត្តិយកញ្ញា
១៧៥	គាថាទី **២២២**	អញ្ញតរភិក្ខុ
១៧៦	គាថាទី **២២៣**	នាងឧត្តរាឧបាសិកា
១៧៧	គាថាទី **២២៤**	ព្រះមោគ្គល្លានត្ថេរប្បញ្ហា
១៧៨	គាថាទី **២២៥**	ភិក្ខុទូលសួរបញ្ហា
១៧៩	គាថាទី **២២៦**	នាងបុណ្ណាទាសី
១៨០	គាថាទី **២២៧, ២២៨, ២២៩, ២៣០**	អតុលឧបាសក
១៨១	គាថាទី **២៣១, ២៣២, ២៣៣, ២៣៤**	ឆព្វគ្គិយភិក្ខុ
វគ្គទី ១៨ : **មលវគ្គ**, មាន ២១ គាថា = ១២ រឿង,		
១៨២	គាថាទី **២៣៥, ២៣៦, ២៣៧, ២៣៨**	បុត្តនាយគោឃាតកៈ
១៨៣	គាថាទី **២៣៩**	អញ្ញតរព្រាហ្មណ៍
១៨៤	គាថាទី **២៤០**	ព្រះតិស្សត្ថេរ
១៨៥	គាថាទី **២៤១**	ព្រះលោឡុទាយិត្ថេរ
១៨៦	គាថាទី **២៤២, ២៤៣**	អញ្ញតរកុលបុត្រ
១៨៧	គាថាទី **២៤៤, ២៤៥**	ចូឡសារីភិក្ខុ
១៨៨	គាថាទី **២៤៦, ២៤៧, ២៤៨**	បញ្ចឧបាសក

១៨៩	គាថាទី **២៤៩, ២៥០**	ភិក្ខុកម្លោះឈ្មោះតិស្សៈ
១៩០	គាថាទី **២៥១**	បញ្ចឧបាសក
១៩១	គាថាទី **២៥២**	មេណ្ឌកសេដ្ឋី
១៩២	គាថាទី **២៥៣**	ព្រះឧជ្ឈានសញ្ញីត្ថេរ
១៩៣	គាថាទី **២៥៤, ២៥៥**	សុភទ្ទបរិព្វាជកបច្ឆិមសក្ខិស្សាវក
វគ្គទី ១៩ : **ធម្មដ្ឋវគ្គ**, មាន ១៧ គាថា = ១០ រឿង,		
១៩៤	គាថាទី **២៥៦, ២៥៧**	មហាមាត្យអ្នកវិនិច្ឆ័យ
១៩៥	គាថាទី **២៥៨**	ឆព្វគ្គិយភិក្ខុ
១៩៦	គាថាទី **២៥៩**	ឯកុទានត្ថេរ
១៩៧	គាថាទី **២៦០, ២៦១**	លកុណ្ឌកភទ្ទិយភិក្ខុត្ថេរ
១៩៨	គាថាទី **២៦២, ២៦៣**	សម្ពហុលភិក្ខុ
១៩៩	គាថាទី **២៦៤, ២៦៥**	ហត្ថកភិក្ខុ
២០០	គាថាទី **២៦៦, ២៦៧**	អញ្ញត្រព្រាហ្មណ៍
២០១	គាថាទី **២៦៨, ២៦៩**	រឿងពួកតិរ្ថិយ
២០២	គាថាទី **២៧០**	ព្រានសន្ទូចឈ្មោះអរិយៈ
២០៣	គាថាទី **២៧១, ២៧២**	សម្ពហុលភិក្ខុ
វគ្គទី ២០ : **មគ្គវគ្គ**, មាន ១៧ គាថា = ១០ រឿង,		
២០៤	គាថាទី **២៧៣, ២៧៤, ២៧៥, ២៧៦**	បញ្ចសតភិក្ខុ (ភិក្ខុ ៥០០)
២០៥	គាថាទី **២៧៧, ២៧៨, ២៧៩**	អបរបញ្ចសតភិក្ខុ (ភិក្ខុ៥០០ផ្សេង)

២០៦	គាថាទី **២៨០**	**ព្រះបធានកម្មិកតិស្សត្ថេរ**
២០៧	គាថាទី **២៨១**	**សូករប្រេត**
២០៨	គាថាទី **២៨២**	**ព្រះពោឋិលត្ថេរ**
២០៩	គាថាទី **២៨៣, ២៨៤**	**ព្រះមហល្លកត្ថេរ** (ភិក្ខុចាស់ច្រើនរូប)
២១០	គាថាទី **២៨៥**	**សទ្ធិវិហារិកព្រះសារីបុត្រ**
២១១	គាថាទី **២៨៦**	**មហាធនពាណិជ**
២១២	គាថាទី **២៨៧**	**នាងកិសាគោតមី**
២១៣	គាថាទី **២៨៨, ២៨៩**	**នាងបដាចារា**
វគ្គទី ២១ : **បកិណ្ណកវគ្គ**, មាន ១៦ គាថា = ៩ រឿង,		
២១៤	គាថាទី **២៩០**	**បុព្វកម្មរបស់ព្រះពុទ្ធអង្គ**
២១៥	គាថាទី **២៩១**	**កុក្កុដណ្ឌខាទិកា** (កុមារិកាបរិភោគស៊ុតមាន់)
២១៦	គាថាទី **២៩២, ២៩៣**	**ភទ្ទិយភិក្ខុ** (ភិក្ខុអ្នកនគរភទ្ទិយៈ)
២១៧	គាថាទី **២៩៤, ២៩៥**	**ព្រះលកុណ្ឌកភទ្ទិយត្ថេរ**
២១៨	គាថាទី ២៩៦, ២៩៧, ២៩៨, ២៩៩, ៣០០, ៣០១	**បុត្តនាយទារុសាកដិកៈ**
២១៩	គាថាទី ៣០២	**ភិក្ខុវជ្ជីបុត្រ**
២២០	គាថាទី ៣០៣	**ចិត្តគហបតី**
២២១	គាថាទី ៣០៤	**នាងចូឡសុភទ្ទា**
២២២	គាថាទី ៣០៥	**ព្រះឯកវិហារីត្ថេរ**

វគ្គទី ២២ : **និរយវគ្គ**, មាន ១៤ គាថា = ៩ រឿង,		
២២៣	គាថាទី ៣០៦	**នាងបរិព្វាជិកាសុន្ទរី**
២២៤	គាថាទី ៣០៧	**សត្វត្រូវទុក្ខបៀតបៀន**
២២៥	គាថាទី ៣០៨	**វគ្គុមុទាតីរិយភិក្ខុ**
២២៦	គាថាទី ៣០៩, ៣១០	**ខេមកសេដ្ឋីបុត្រ** ក្មួយរបស់អនាថបិណ្ឌិកសេដ្ឋី
២២៧	គាថាទី ៣១១, ៣១២, ៣១៣	**ទុព្វចភិក្ខុ** (ភិក្ខុលំបាកទូន្មានប្រដៅ)
២២៨	គាថាទី ៣១៤	**ស្ត្រីអ្នកមានសេចក្តីប្រចណ្ឌ**
២២៩	គាថាទី ៣១៥	**អាគន្តុកភិក្ខុ**
២៣០	គាថាទី ៣១៦, ៣១៧	**ពួកនិគ្រន្ថ**
២៣១	គាថាទី ៣១៨, ៣១៩	**តិរ្ថិយសាវ័ក**
វគ្គទី ២៣ : **នាគវគ្គ**, មាន ១៤ គាថា = ៨ រឿង,		
២៣២	គាថាទី ៣២០, ៣២១, ៣២២	**រឿងរបស់ព្រះពុទ្ធអង្គ**
២៣៣	គាថាទី ៣២៣	**ហត្ថាចារិយបុព្វកភិក្ខុ**
២៣៤	គាថាទី ៣២៤	**បុត្ររបស់ព្រាហ្មណ៍ចាស់ជរាម្នាក់**
២៣៥	គាថាទី ៣២៥	**ព្រះបាទបសេនទិកោសល**
២៣៦	គាថាទី ៣២៦	**សានុសាមណេរ**
២៣៧	គាថាទី ៣២៧	ដំរីបាវេរកៈរបស់ព្រះបាទកោសល
២៣៨	គាថាទី ៣២៨, ៣២៩, ៣៣០	**សម្ពហុលភិក្ខុ** (ភិក្ខុច្រើនរូប)
២៣៩	គាថាទី ៣៣១, ៣៣២, ៣៣៣	**ទ្រង់ប្រារព្ធមារ**

វគ្គទី ២៤ : **តណ្ហាវគ្គ**, មាន ២៦ គាថា = ១២ រឿង,		
២៤០	គាថាទី ៣៣៤, ៣៣៥, ៣៣៦, ៣៣៧	ត្រីឈ្មោះកបិលៈ
២៤១	គាថាទី ៣៣៨, ៣៣៩, ៣៤០, ៣៤១, ៣៤២, ៣៤៣	ប្រារព្ធរឿងកូនជ្រូកញីមួយ កំពុងស៊ីលាមក
២៤២	គាថាទី ៣៤៤	វិព្ភន្តកភិក្ខុ
២៤៣	គាថាទី ៣៤៥, ៣៤៦	អំពីពន្ធនាគារ
២៤៤	គាថាទី ៣៤៧	ព្រះនាងខេមា
២៤៥	គាថាទី ៣៤៨	ឧគ្គសេនសេដ្ឋីបុត្រ
២៤៦	គាថាទី ៣៤៩, ៣៥០	ចូឡធនុគ្គហបណ្ឌិត
២៤៧	គាថាទី ៣៥១, ៣៥២	ទ្រង់ប្រារព្ធរឿងមារ
២៤៨	គាថាទី ៣៥៣	ឧបកាជីវក
២៤៩	គាថាទី ៣៥៤	សក្កទេវរាជ
២៥០	គាថាទី ៣៥៥	អបុត្តកសេដ្ឋី
២៥១	គាថាទី ៣៥៦, ៣៥៧, ៣៥៨, ៣៥៩	អង្កុរទេវបុត្រ និង ឥន្ទកទេវបុត្រ
វគ្គទី ២៥ : **ភិក្ខុវគ្គ**, មាន ២៣ គាថា = ១២ រឿង,		
២៥២	គាថាទី ៣៦០, ៣៦១	ភិក្ខុ ៥ អង្គ
២៥៣	គាថាទី ៣៦២	ភិក្ខុសម្លាប់ហង្ស
២៥៤	គាថាទី ៣៦៣	កោកាលិកភិក្ខុ
២៥៥	គាថាទី ៣៦៤	ព្រះធម្មារាមត្ថេរ

២៥៦	គាថាទី ៣៦៥, ៣៦៦	អញ្ញត្រវិបក្ខកភិក្ខុ
២៥៧	គាថាទី ៣៦៧	បញ្ចគ្គទាយកព្រាហ្មណ៍
២៥៨	គាថាទី ៣៦៨, ៣៦៩, ៣៧០, ៣៧១, ៣៧២, ៣៧៣, ៣៧៤, ៣៧៥, ៣៧៦	សម្ពហុលភិក្ខុ
២៥៩	គាថាទី ៣៧៧	ភិក្ខុប្រមាណ ៥០០ អង្គ
២៦០	គាថាទី ៣៧៨	ព្រះសន្តកាយត្ថេរ
២៦១	គាថាទី ៣៧៩, ៣៨០	ព្រះនង្គលកូដត្ថេរ
២៦២	គាថាទី ៣៨១	ព្រះវក្កលិត្ថេរ
២៦៣	គាថាទី ៣៨២	សុមនសាមណេរ
វគ្គទី ២៦ : **ព្រាហ្មណវគ្គ**, មាន ៤១ គាថា = ៣៩ រឿង,		
២៦៤	គាថាទី ៣៨៣	បសាទពហុលព្រាហ្មណ៍
២៦៥	គាថាទី ៣៨៤	សម្ពហុលភិក្ខុ
២៦៦	គាថាទី ៣៨៥	ព្រារព្ធរឿងមារ
២៦៧	គាថាទី ៣៨៦	អញ្ញត្រព្រាហ្មណ៍
២៦៨	គាថាទី ៣៨៧	ព្រះអានន្ទត្ថេរ
២៦៩	គាថាទី ៣៨៨	អញ្ញត្របព្វជិត
២៧០	គាថាទី ៣៨៩, ៣៩០	ព្រះសារីបុត្រត្ថេរ
២៧១	គាថាទី ៣៩១	ព្រះនាងមហាបជាបតិគោតមី
២៧២	គាថាទី ៣៩២	ព្រះសារីបុត្រត្ថេរ

២៧៣	គាថាទី ៣៩៣	ជដិលព្រាហ្មណ៍
២៧៤	គាថាទី ៣៩៤	ព្រាហ្មណ៍កុហក
២៧៥	គាថាទី ៣៩៥	នាងកិសាគោតមី
២៧៦	គាថាទី ៣៩៦	រឿងព្រាហ្មណ៍ម្នាក់
២៧៧	គាថាទី ៣៩៧	ឧគ្គសេន
២៧៨	គាថាទី ៣៩៨	ព្រាហ្មណ៍ពីរនាក់
២៧៩	គាថាទី ៣៩៩	អក្កោសកភារទ្វាជព្រាហ្មណ៍
២៨០	គាថាទី ៤០០	ព្រះសារីបុត្រត្ថេរ
២៨១	គាថាទី ៤០១	នាងឧប្បលវណ្ណាថេរី
២៨២	គាថាទី ៤០២	អញ្ញត្រព្រាហ្មណ៍
២៨៣	គាថាទី ៤០៣	នាងខេមាភិក្ខុនី
២៨៤	គាថាទី ៤០៤	ព្រះបព្ភារវាសីតិស្សត្ថេរ
២៨៥	គាថាទី ៤០៥	អញ្ញត្រភិក្ខុ
២៨៦	គាថាទី ៤០៦	សាមណេរ៤អង្គ
២៨៧	គាថាទី ៤០៧	ព្រះមហាបន្ថកត្ថេរ
២៨៨	គាថាទី ៤០៨	ព្រះបិលិន្ទវច្ឆត្ថេរ
២៨៩	គាថាទី ៤០៩	អញ្ញត្រភិក្ខុ
២៩០	គាថាទី ៤១០	ព្រះសារីបុត្រត្ថេរ
២៩១	គាថាទី ៤១១	ព្រះមហាមោគ្គល្លានត្ថេរ

២៩២	គាថាទី ៤១២	ព្រះរេវតត្ថេរ
២៩៣	គាថាទី ៤១៣	ព្រះចន្ទាភត្ថេរ
២៩៤	គាថាទី ៤១៤	ព្រះសីវលី
២៩៥	គាថាទី ៤១៥	ព្រះសុន្ទរសមុទ្ទត្ថេរ
២៩៦	គាថាទី ៤១៦	ព្រះជោតិកត្ថេរ
២៩៧	គាថាទី ៤១៧	ព្រះបឋមនដបុព្វកត្ថេរ
២៩៨	គាថាទី ៤១៨	ព្រះទុតិយនដបុព្វកត្ថេរ
២៩៩	គាថាទី ៤១៩, ៤២០	ព្រះវង្គីសត្ថេរ
៣០០	គាថាទី ៤២១	ព្រះនាងធម្មទិន្នាថេរី
៣០១	គាថាទី ៤២២	ព្រះអង្គុលិមាលត្ថេរ
៣០២	គាថាទី ៤២៣	បញ្ហាទេវហិតព្រាហ្មណ៍





នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការ ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ !

Homage to Him, the Blessed One, the Perfected One, The Supremely Enlightened One!

ជំពូកទី ១

យមកវគ្គ

(Yamaka Vagga)

The Twin Verses

(Versets Conjugués)

(មាន ២០ គាថា)

(ពី គាថា ទី ១ ➩ ដល់ គាថា ទី ២០)

១.. **មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា**
មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា
តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ ។

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត (មានចិត្តជាធំ) សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តត្រូវ **ទោស**[១] ប្រទូស្តហើយ ពោលក្តី ធ្វើក្តី (នូវទុច្ចរិត) ព្រោះទុច្ចរិតទាំងនោះ **ទុក្ខ** រមែងជាប់តាមបុគ្គលនោះទៅ ដូចកង់រទេះវិលតាមដានជើងគោ ដែលកំពុងអូសទៅ ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែងនៅក្រុងសាវត្ថី ប្រារព្ធ **ព្រះចក្ខុបាលត្ថេរ**)

☞ ក្នុងកាលចប់ព្រះគាថា ភិក្ខុ ៣.០០០ អង្គ បានសម្រេចព្រះអរហត្ត ព្រមដោយដោយបដិសម្ភិទាទាំងឡាយ ។

២.. **មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា**
មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា
តតោ នំ សុខមន្វេតិ ឆាយាវ អនុបាយិនី ។

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត សម្រេចអំពីចិត្ត បើបុគ្គលមានចិត្ត**ជ្រះថ្លា**[២] ហើយ ពោលក្តី ធ្វើក្តី (នូវសុចរិត) ព្រោះសុចរិតទាំងនោះ **សុខ** រមែងជាប់តាមបុគ្គលនោះ ទៅដូចស្រមោលអន្ទោលតាមប្រាណ ។

---

(១) ធម៌ជាទោស ឬជាឧបក្កិលេសនៃចិត្ត មានអភិជ្ឈាជាដើម ដែលចូលមកធ្វើចិត្តឱ្យរីករវ ។
(២) ជ្រះថ្លាដោយគុណ មាន **អនភិជ្ឈា** ជាដើម ។ **អដ្ឋកថា** ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងប្រារព្ធ មដ្ឋកុណ្ឌលី
កូនប្រុសរបស់ព្រាហ្មណ៍ម្នាក់ឈ្មោះ អទិន្នបុព្វកៈ នៅក្រុងសាវត្ថី)

☞ ក្នុងកាលចប់ព្រះគាថា ការត្រាស់ដឹងធម៌ បានមានហើយដល់ពួកសត្វ ៨៤.០០០, មដ្ឋកុណ្ឌលីទេវបុត្រតាំងនៅក្នុងសោតាបត្តិផល, អទិន្នបុព្វកព្រាហ្មណ៍ ក៏ដូចគ្នាដែរ ។

៣.. អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ
យេ ច តំ ឧបនយ្ហន្តិ វេរំ តេសំ ន សម្មតិ ។

៤.. អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ
យេ ច តំ នូបនយ្ហន្តិ វេរំ តេសូបសម្មតិ ។

អ្នកឯណោះ បានជេរអញ, អ្នកឯណោះ បានវាយអញ, អ្នកឯណោះ បានផ្ចាញ់អញ, អ្នកឯណោះ បានលួចយកទ្រព្យរបស់អញទៅហើយ បើអ្នកណា ចងសេចក្តីក្រោធបែបនោះទុក (ដូច្នេះ) ពៀររបស់អ្នកនោះមិនរម្ងាប់ឡើយ ។

អ្នកឯណោះ បានជេរអញ, អ្នកឯណោះ បានវាយអញ, អ្នកឯណោះ បានផ្ចាញ់អញ, អ្នកឯណោះ បានលួចយកទ្រព្យរបស់អញទៅហើយ បើអ្នកណា មិនចងសេចក្តីក្រោធបែបនោះទុក (ដូច្នេះ) ពៀររបស់អ្នកនោះទើបរម្ងាប់បាន ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន ប្រារព្ធ ព្រះតិស្សត្ថេរៈ)

☞ ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុ ១០០.០០០ អង្គ, បានសម្រេចអរិយផល មានសោតាបត្តិផលជាដើម ។

៥.. ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ
អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ ។

ពិតមែន តាំងពីកាលណាមក ក្នុងលោកនេះ ពៀរទាំងឡាយ មិនរម្ងាប់ដោយការចងពៀរឡើយ ពៀរទាំងឡាយតែងស្ងប់រម្ងាប់ ដោយការមិនចងពៀរ នេះជាបវេណីធម៌ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្ដែងនៅវត្តជេតពន ប្រារព្ធចំពោះនាងកាឡីយក្ខនី ជាស្ត្រីដល់ហើយនូវភាវៈជាអ្នកថ្កើងដោយលាភ និង បរិវារ) ។

៦.. បរេ ច ន វិជានន្តិ មយមេត្ថ យមាម្ហសេ
យេ ច តត្ថ វិជានន្តិ តតោ សម្មន្តិ មេធគា ។

ជនទាំងឡាយដទៃ (ក្រៅអំពីបណ្ឌិត) តែងមិនដឹងខ្លួនថា យើងទាំងឡាយនឹងវិនាសក្នុងកណ្ដាលនៃពួកនេះ ដូច្នេះឡើយ, ចំណែកជនទាំងឡាយណា ក្នុងពួកនេះ ដឹងខ្លួនថា យើងទាំងឡាយ នឹងវិនាសក្នុងកណ្ដាលនៃពួកនេះ ដូច្នេះ ការឈ្លោះប្រកែកទាំងឡាយ រមែងរម្ងាប់អំពីជនទាំងឡាយនោះ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្ដែងនៅវត្តជេតពន ប្រារព្ធពួកភិក្ខុក្រុងកោសម្ពី ដែលឈ្លោះប្រទូស្តទាស់ទែងគ្នា) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុដែលមានបញ្ហាវិវាទនឹងគ្នានោះ ក៏បានតាំងនៅក្នុងអរិយមគ្គ-ផល មានសោតាបត្តិផលជាដើម ។

៧.. សុភានុបស្សឹ វិហរន្តំ ឥន្ទ្រិយេសុ អសំវុតំ

ភោជនម្ហិ អមត្តញ្ញុំ កុសីតំ ហីនវីរិយំ
តំ វេ បសហតី មារោ វាតោ រុក្ខំវ ទុព្វលំ ។

៨.. អសុភានុបស្សឹ វិហរន្តំ ឥន្ទ្រិយេសុ សុសំវុតំ
ភោជនម្ហិ ច មត្តញ្ញុំ សទ្ធំ អារទ្ធវីរិយំ
តំ វេ នប្បសហតី មារោ វាតោ សេលំវ បព្វតំ ។

☞ បុគ្គល ដែលយល់ឃើញនូវអារម្មណ៍ថាល្អ មិនសង្រួមក្នុងឥន្ទ្រិយទាំងឡាយ មិនដឹងប្រមាណក្នុងភោជន ខ្ជិលច្រអូស មានព្យាយាមធូរថយ កិលេសមារ រមែងគ្របសង្កត់បុគ្គលនោះឯង ដូចខ្យល់ ដែលគ្របសង្កត់ដើមឈើទុព្វលដូច្នោះ ។

☞ ឯបុគ្គល ដែលយល់ឃើញនូវអារម្មណ៍ថាមិនល្អ សង្រួមប្រពៃក្នុងឥន្ទ្រិយទាំងឡាយ ដឹងប្រមាណក្នុងភោជន មានសទ្ធា ប្រារព្ធព្យាយាម កិលេសមារ តែងគ្របសង្កត់បុគ្គលនោះមិនបាន ដូចខ្យល់ គ្របសង្កត់ថ្មភ្នំតាន់ មិនបានដូច្នោះ ។

☸ [**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែងនៅក្នុងព្រៃធ្មង់ នាសេតព្យនគរ ប្រារព្ធ **ចុល្លកាល** (ត្ថេរ) និង **មហាកាល** (ត្ថេរ)]

☞ ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុដែលមកប្រជុំគ្នា ក៏បានតាំងនៅក្នុងអរិយផល មានសោតាបត្តិផលជាដើម ។

៩.. អនិក្កសាវោ កាសាវំ យោ វត្ថំ បរិទហេស្សតិ
អបេតោ ទមសច្ចេន ន សោ កាសាវមរហតិ ។

១០.. យោ ច វន្តកសាវស្ស សីលេសុ សុសមាហិតោ
ឧបេតោ ទមសច្ចេន ស វេ កាសាវមរហតិ ។

អ្នកណា នៅមានទឹកចត់ គឺរាគាទិក្កិលេស (ក្នុងសន្តាន) ជាអ្នកបោះបង់ការទូន្មាននូវឥន្ទ្រិយ និង សច្ចៈ ហើយស្លៀកដណ្តប់សំពត់កាសាវៈ អ្នកនោះ មិនគួរនឹងស្លៀកដណ្តប់សំពត់កាសាវៈឡើយ ។

លុះតែអ្នកណា មានទឹកចត់ គឺរាគាទិក្កិលេសខ្ជាក់ចោលអស់ហើយ ជាអ្នកមានចិត្តតម្កល់មាំ ក្នុងចតុប្បារិសុទ្ធិសីល ប្រកបដោយការទូន្មាននូវឥន្ទ្រិយ និង សច្ចៈ អ្នកនោះឯង ទើបគួរនឹងស្លៀកដណ្តប់សំពត់កាសាវៈបាន ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន ប្រារព្ធភិក្ខុ **ទេវទត្ត**)

☞ ក្នុងកាលចប់ព្រះធម្មទេសនា **អរិយផល** (ក៏បានប្រាកដ ដល់ពួកភិក្ខុទាំងឡាយ ដែលនិមន្តមកអំពីគ្រប់ទិសទីនានា) មាន **សោតាបត្តិផល** ជាដើម ។

១១.. អសារេ សារមតិនោ សារេ ចាសារទស្សិនោ [១]
តេ សារំ នាធិគច្ឆន្តិ មិច្ឆាសង្កប្បគោចរា ។

១២.. សារញ្ច សារតោ ញត្វា អសារញ្ច អសារតោ
តេ សារំ អធិគច្ឆន្តិ សម្មាសង្កប្បគោចរា ។

[១] សារេ ចាសារទស្សិនោ < សារេ ច អសារទស្សិនោ ។

ជនទាំងឡាយ ដែលយល់ឃើញក្នុងធម៌មិនមានខ្លឹម (**អសារធម្ម**) ថាជាធម៌មានខ្លឹម, ក្នុងធម៌មានខ្លឹម ថាជាធម៌មិនមានខ្លឹមផង ជាអ្នកមានតម្រិះខុសជាអារម្មណ៍ រមែងមិនបាននូវធម៌ដែលមានខ្លឹមឡើយ ។

ជនទាំងឡាយ ដែលយល់ឃើញ នូវធម៌មានខ្លឹម ថាជាធម៌មានខ្លឹមផង, យល់ឃើញ នូវធម៌គ្មានខ្លឹម ថាជាធម៌គ្មានខ្លឹមផង ជាអ្នកមានតម្រិះត្រូវជាអារម្មណ៍ រមែងបាននូវធម៌ដែលមានខ្លឹម (**ធម្មសារ**) ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែងកាលប្រថាប់គង់នៅវេឡុវនារាម ក្រុងរាជគ្រឹះ ប្រារព្ធចំពោះការមិនមក នៃ **សញ្ជ័យបរិព្វាជក**)

☞ ក្នុងកាលចប់ព្រះធម្មទេសនា **អរិយផល** ក៏បានប្រាកដ ដល់ជនានុជនទាំងឡាយដ៏ច្រើន មាន **សោតាបត្តិផល** ជាដើម ។

១៣.. **យថា អគារំ ទុច្ឆន្នំ វុដ្ឋី សមតិវិជ្ឈតិ**
ឯវំ អភាវិតំ ចិត្តំ រាគោ សមតិវិជ្ឈតិ ។

ផ្ទះដែលប្រក់ខ្ជីខ្ជាហើយ ដំណក់ទឹកភ្លៀងរមែងលេចរហូតយ៉ាងណាមិញ ចិត្តដែលបុគ្គលមិនបានអប់រំទុកហើយ **រាគៈ** រមែងចាក់ដោតយ៉ាងនោះឯង ។

១៤.. **យថា អគារំ សុឆន្នំ វុដ្ឋី ន សមតិវិជ្ឈតិ**
ឯវំ សុភាវិតំ ចិត្តំ រាគោ ន សមតិវិជ្ឈតិ ។

ផ្ទះដែលប្រក់ល្អហើយ ដំណក់ទឹកភ្លៀង រមែងមិនលេចរហូត យ៉ាងណាមិញ ចិត្តដែលបុគ្គលបានអប់រំទុកល្អហើយ **រាគៈ** រមែងមិនចាក់ដោតបាន យ៉ាងនោះឯង ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែងនៅ**វេឡុវនារាម** ក្រុងសាវត្ថី ប្រារព្ធចំពោះ **ព្រះនន្ទត្ថេរ**)

☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចធ្លាប់ **អរិយផល** ទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

១៥.. ឥធ សោចតិ បេច្ច សោចតិ   បាបការី ឧភយត្ថ សោចតិ
សោ សោចតិ សោ វិហញ្ញតិ   ទិស្វា កម្មកិលិដ្ឋមត្តនោ ។

បុគ្គលអ្នកធ្វើបាប តែងសោកស្តាយក្នុងលោកទាំងពីរ គឺសោកស្តាយក្នុងលោកនេះ១ ក្នុងលោកខាងមុខ១ បុគ្គលនោះ រមែងសោកស្តាយ ក្តៅក្រហាយ ព្រោះឃើញអំពើសៅហ្មងរបស់ខ្លួន ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែងនៅ**វេឡុវនារាម** ក្រុងរាជគ្រឹះ ប្រារព្ធបុរស ឈ្មោះ **ចុន្ទសូករិក**)

☞ ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុជាច្រើនអង្គបានសម្រេចជា**ព្រះអរិយបុគ្គល** មាន **សោតាបន្ន** ជាដើម ។

១៦.. ឥធ មោទតិ បេច្ច មោទតិ   កតបុញ្ញោ ឧភយត្ថ មោទតិ
សោ មោទតិ សោ បមោទតិ   ទិស្វា កម្មវិសុទ្ធិមត្តនោ ។

បុគ្គលអ្នកធ្វើបុណ្យទុក រមែងរីករាយ ក្នុងលោកទាំងពីរ គឺរីករាយក្នុងលោកនេះ១ រីករាយក្នុងលោកខាងមុខ១ បុគ្គលនោះ រមែងរីករាយស្រស់ស្រាយ ព្រោះឃើញអំពើបរិសុទ្ធរបស់ខ្លួន ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្ត ជេតពន ក្រុងសាវត្ថី ប្រារព្ធ ធម្មិកឧបាសក)

☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចជាព្រះអរិយបុគ្គល មាន សោតាបន្ន ជាដើម ។

១៧.. ឥធ តប្បតិ បេច្ច តប្បតិ បាបការី ឧភយត្ថ តប្បតិ
បាបំ មេ កតន្តិ តប្បតិ ភិយ្យោ តប្បតិ ទុគ្គតឹ គតោ ។

បុគ្គលអ្នកធ្វើអំពើបាប តែងក្តៅក្រហាយ ក្នុងលោកទាំងពីរ គឺក្តៅក្រហាយក្នុងលោកនេះ១ ក្តៅក្រហាយក្នុងលោកខាងមុខ១ បុគ្គលនោះរមែងក្តៅក្រហាយ ដោយគិតឃើញថា បាបអញបានធ្វើហើយ លុះធ្វើមរណកាល ទៅកាន់ទុគ្គតិ ក៏រឹងរឹតតែក្តៅក្រហាយ ដ៏ក្រៃលែង ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្ត ជេតពន ក្រុងសាវត្ថី ទ្រង់ប្រារព្ធបុព្វកម្ម នៃភិក្ខុ ទេវទត្ត)

☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចជាអរិយបុគ្គលភាព មាន សោតាបន្ន ជាដើម ។

១៨.. ឥធ នន្ទតិ បេច្ច នន្ទតិ កតបុញ្ញោ ឧភយត្ថ នន្ទតិ
បុញ្ញំ មេ កតន្តិ នន្ទតិ ភិយ្យោ នន្ទតិ សុគតឹ គតោ ។

បុគ្គលអ្នកធ្វើបុណ្យទុក រមែងត្រេកអរ ក្នុងលោកទាំងពីរ គឺត្រេកអរក្នុងលោកនេះ១ ត្រេកអរក្នុងលោកខាងមុខ១ បុគ្គលនោះ រមែងត្រេកអរដោយគិតឃើញថា បុណ្យអញបានធ្វើហើយ លុះធ្វើមរណកាល ទៅកាន់សុគតិ ក៏រឹងរឹតតែត្រេកអរដ៏ក្រៃលែង ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែងនៅវត្ត **ជេតពន** ក្រុងសាវត្ថី ប្រារព្ធនាង **សុមនាទេវី** កូនស្រី **អនាថបិណ្ឌិកសេដ្ឋី**) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចជា**អរិយបុគ្គលភាព** មាន **សោតាបន្ន** ជាដើម ។

១៩.. **ពហុម្បិ ចេ សហិតំ ភាសមានោ**
ន តក្ករោ ហោតិ នរោ បមត្តោ
គោបោវ គាវោ គណយំ បរេសំ
ន ភាគវា សាមញ្ញស្ស ហោតិ ។

២០.. **អប្បម្បិ ចេ សហិតំ ភាសមានោ**
ធម្មស្ស ហោតិ អនុធម្មចារី
រាគញ្ច ទោសញ្ច បហាយ មោហំ
សម្មប្បជានោ សុវិមុត្តចិត្តោ
អនុបាទិយានោ ឥធ វា ហុរំ វា
ស ភាគវា សាមញ្ញស្ស ហោតិ ។

បើនរជន ពោលពាក្យប្រកបដោយប្រយោជន៍ សូម្បីច្រើន តែជាអ្នកប្រមាទ មិនធ្វើតាមពាក្យនោះ រមែងជាអ្នកមិនមានចំណែកសាមញ្ញផលឡើយ ដូចអ្នករក្សាគោ កាលរាប់គោប្រគល់ឱ្យអ្នកដទៃហើយ (ជាអ្នកមិនបានបរិភោគនូវបញ្ចគោរស) ដូច្នោះឯង ។

បើនរជន ពោលពាក្យប្រកបដោយប្រយោជន៍ សូម្បីបន្តិចបន្តួច តែជាអ្នកប្រព្រឹត្តនូវធម៌ សមគួរដល់ធម៌ បានលះបង់រាគៈ ទោសៈ និងមោហៈ ជាអ្នកដឹងនូវធម៌ ដែលគួរកំណត់តាមហេតុ មានចិត្តដកផុតអំពីសេចក្តីសៅហ្មង មិនមានសេចក្តីប្រកាន់មាំ ក្នុងលោកនេះ និង លោកខាងមុខ នរជននោះ រមែងជាអ្នកបានចំណែកសាមញ្ញផល ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែងនៅវត្ត **ជេតពន** ក្រុងសាវត្ថី ប្រារព្ធនូវ ភិក្ខុពីរអង្គជាសម្លាញ់នឹងគ្នា) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា មនុស្សជាច្រើនបានសម្រេចជា**អរិយបុគ្គលភាព** មាន **សោតាបន្ន** ជាដើម ។

(ចប់ **យមកវគ្គ** ទី១ = មាន ២០ គាថា)

ជំពូកទី ២

អប្បមាទវគ្គ

(Appamāda Vagga)

Heedfulness

(Versets sur la Vigilance)

(មាន ១២ គាថា)

(ពី គាថា ទី ២១ ➪ ដល់ គាថា ទី ៣២)

២១.. អប្បមាទោ អមតំបទំ បមាទោ មច្ចុនោ បទំ
អប្បមត្តា ន មីយន្តិ យេ បមត្តា យថា មតា ។
២២.. ឯតំ វិសេសតោ ញត្វា អប្បមាទម្ហិ បណ្ឌិតា
អប្បមាទេ បមោទន្តិ អរិយានំ គោចរេ រតា ។
២៣.. តេ ឈាយិនោ សាតតិកា និច្ចំ ទឡ្ហបរក្កមា
ផុសន្តិ ធីរា និព្វានំ យោគក្ខេមំ អនុត្តរំ ។

សេចក្ដីមិនប្រមាទ[១] ជាផ្លូវនៃសេចក្ដីមិនស្លាប់[២] សេចក្ដីប្រមាទ ជាផ្លូវនៃសេចក្ដីស្លាប់, ជនទាំងឡាយ ដែលមិនប្រមាទហើយ ឈ្មោះថា មិនស្លាប់ ជនទាំងឡាយ ដែលប្រមាទហើយ[៣] ទុកដូចជាមនុស្សស្លាប់ទៅហើយ ។ ពួកបណ្ឌិត បានជ្រាបនូវដំណើរនេះ ដោយប្លែកគ្នា (ទើបឋិតនៅ) ក្នុងសេចក្ដីមិនប្រមាទ រីករាយក្នុងសេចក្ដីមិនប្រមាទ បណ្ឌិតទាំងនោះ ជាអ្នកត្រេកអរក្នុងធម៌ ជាគោចរ[៤] នៃអរិយបុគ្គលទាំងឡាយ មានការពិនិត្យជាប្រក្រតី មានព្យាយាមជាប់តគ្នា មានសេចក្ដីប្រឹងប្រែងមាំមួនជានិច្ច ជាអ្នកមានប្រាជ្ញា តែងប៉ះពាល់នូវ **ព្រះនិព្វាន** ជាទីក្សេមក្សាន្តចាកយោគៈ ជាគុណជាតដ៏ប្រសើរបំផុត ។

---

(១) បានដល់ការប្រុងប្រយ័ត្ន ពាក្យនេះជាឈ្មោះស្មារតី ដែលបានតាំងប្រុងជានិច្ច ។
(២) ពាក្យថាមិនស្លាប់នេះ ជាឈ្មោះព្រះនិព្វាន ព្រោះព្រះនិព្វាន មិនមានចាស់ មិនមានស្លាប់ ។
(៣) បានដល់ការមិនប្រុងប្រយ័ត្ន ពាក្យនេះជាឈ្មោះនៃការលះបង់ស្មារតី ។
(៤) **ពោធិបក្ខិយធម៌** ៣៧ និង **លោកុត្តរធម៌** ៩ ហៅថា គោចរនៃអរិយៈ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅឃោសិតារាម-ក្រុងកោសម្ពី ប្រារព្ធចំពោះ ព្រះនាងសាមាវតី) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា មនុស្សជាច្រើនបានសម្រេចជាអរិយបុគ្គលភាព មាន សោតាបន្ន ជាដើម ។

២៤.. **ឧដ្ឋានវតោ សតីមតោ សុចិកម្មស្ស និសម្មការិនោ**
សញ្ញតស្ស ច ធម្មជីវិនោ អប្បមត្តស្ស យសោភិវឌ្ឍតិ ។

យស[១] តែងចម្រើនកុះករ ដល់បុគ្គល អ្នកមានសេចក្តីប្រឹងប្រែង មានស្មារតី មានការងារស្អាត (ឥតទោស) ជាអ្នកពិចារណា រួចហើយទើបធ្វើ ជាអ្នកសង្រួម រស់នៅដោយធម៌ មិនមានសេចក្តីប្រមាទ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តវេឡុវ័ន ប្រារព្ធ កុម្ភឃោសកសេដ្ឋី) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនាកុម្ភឃោសកៈ បានតាំងនៅក្នុងសោតាបត្តិផល ជនដទៃជាច្រើន ក៏បានសម្រេចនូវ អរិយផល មាន សោតាបត្តិផល ជាដើម ។

២៥.. **ឧដ្ឋានេនប្បមាទេន សញ្ញមេន ទមេន ច**
ទីបំ កយិរាថ មេធាវី យំ ឱឃោ នាភិកីរតិ ។

អ្នកប្រាជ្ញ គប្បីសាងកោះ គឺអរហត្តផល ជាកោះដែលជំនន់ គឺ កិលេសជន់ពន្លិចមិនបាន ដោយសេចក្តីប្រឹងប្រែងផង ដោយសេចក្តីមិនប្រមាទផង ដោយការសង្រួមក្នុងចតុប្បារិសុទ្ធសីលផង ដោយការទូន្មានឥន្ទ្រិយផង ។

---

[១] ភាពជាធំ ភោគសម្បត្តិ សេចក្តីរាប់អាន កិត្តិស័ព្ទដ៏ពីរោះ ☞ គុណទាំងនេះ រួមហៅថា **យស** ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្ដែងនៅវត្តវេឡុវ័ន ប្រារព្ធ ព្រះចូឡបន្ថកត្ថេរៈ) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចជា អរិយបុគ្គលភាព មាន សោតាបន្ន ជាដើម ។

២៦.. បមាទមនុយុញ្ជន្តិ ពាលា ទុម្មេធិនោ ជនា
អប្បមាទញ្ច មេធាវី ធនំ សេដ្ឋំវ រក្ខតិ ។
២៧.. មា បមាទមនុយុញ្ជេថ មា កាមរតិសន្ថវំ
អប្បមត្តោ ហិ ឈាយន្តោ បប្បោតិ វិបុលំ សុខំ ។

ពួកជនពាលអប្បឥតប្រាជ្ញា តែងប្រកបរឿយ ៗ នូវសេចក្ដីប្រមាទ ចំណែក **អ្នកប្រាជ្ញ** រមែងរក្សាទុកនូវសេចក្ដីមិនប្រមាទ ដូចទ្រព្យយ៉ាងប្រសើរ ។

អ្នកទាំងឡាយ ចូរកុំប្រកបរឿយៗ នូវសេចក្ដីប្រមាទ ចូរកុំប្រកបរឿយ ៗ នូវសេចក្ដីរីករាយ ត្រេកអរក្នុងកាមឡើយ ដ្បិតបុគ្គលអ្នកមិនប្រមាទ ខំសង្កេតពិនិត្យ រមែងបានសេចក្ដីសុខដ៏ទូលាយ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្ដែងនៅវត្តជេតពន "ជេតវនារាម" ក្រុងសាវត្ថី ទ្រង់ប្រារព្ធ ពាលនក្ខត្តឃុដ្ឋ របស់ជនពាល) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចជា អរិយបុគ្គលភាព មាន សោតាបន្ន ជាដើម ។

២៨.. បមាទំ អប្បមាទេន យទា នុទតិ បណ្ឌិតោ
បញ្ញាបាសាទមារុយ្ហ អសោកោ សោកិនឹ បជំ
បព្វតដ្ឋោវ ភុម្មដ្ឋេ ធីរោ ពាលេ អវេក្ខតិ ។

កាលណា **បណ្ឌិត** បន្ទោបង់នូវសេចក្ដីប្រមាទ ដោយសេចក្ដីមិនប្រមាទ កាលណោះ លោកនឹងឡើងកាន់ប្រាសាទ គឺបញ្ញា ជាបុគ្គលមិនសោក រមែងឃើញពួកសត្វដែលមានសោក, ធីរជនតែងឃើញពួកជនពាល ដូចបុគ្គលដែលឈរលើកំពូលភ្នំ ហើយក្រឡេកមើលពួកជនដែលឋិតនៅលើផែនដី ដូច្នោះឯង ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្ដែងនៅ**វត្តជេតពន** ក្រុងសាវត្ថី ប្រារព្ធ **ព្រះមហាកស្សបត្ថេរ**) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានធ្វើឱ្យជាក់ច្បាស់នូវ **អរិយផល** ទាំងឡាយ មាន**សោតាបត្តិផល** ជាដើម ។

២៩.. **អប្បមត្តោ បមត្តេសុ សុត្តេសុ ពហុជាគរោ**
អពលស្សំវ សីឃស្សោ ហិត្វា យាតិ សុមេធសោ ។

បណ្ឌិត មានប្រាជ្ញាមោះមុត កាលពួកបុគ្គលកំពុងប្រមាទ លោកមិនប្រមាទ កាលពួកបុគ្គលកំពុងដេកលក់ លោកភ្ញាក់រឮកច្រើន លោករមែងលះបង់ចោលនូវបុគ្គលបែបនោះ ដូចសេះលឿន ដែលទៅចោលសេះមានកម្លាំងទន់ទាប ដូច្នោះឯង ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្ដែងនៅ**វត្តជេតពន** ក្រុងសាវត្ថី ទ្រង់ប្រារព្ធភិក្ខុពីរអង្គជាសម្លាញ់នឹងគ្នា) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចនូវ **អរិយផល** ទាំងឡាយ មាន**សោតាបត្តិផល** ជាដើម ។

៣០.. **អប្បមាទេន មឃវា ទេវានំ សេដ្ឋតំ គតោ**
អប្បមាទំ បសំសន្តិ បមាទោ គរហិតោ សទា ។

មឃមាណព ដល់នូវភាពជាបុគ្គលប្រសើរបំផុតជាងទេវតាទាំងឡាយ ព្រោះតែសេចក្តីមិនប្រមាទ អ្នកប្រាជ្ញទាំងឡាយ តែងសរសើរនូវសេចក្តីមិនប្រមាទ តិះតិះដៀលនូវសេចក្តីប្រមាទ សព្វ ៗ កាល ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែងនៅ**កូដាគារសាលា** ក្រុងវេសាលី ទ្រង់ប្រារព្ធ **សក្កទេវរាជ**) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ស្តេចលិច្ឆវី មាននាមថា **មហាលិ** ទ្រង់តាំងក្នុង **សោតាបត្តិផល**, សូម្បីបរិស័ទជាច្រើន ដែលមកជួបប្រជុំគ្នានោះ ក៏បានសម្រេចនូវអរិយបុគ្គលភាព មាន**សោតាបន្ន** ជាដើមផងដែរ ។

៣១.. **អប្បមាទរតោ ភិក្ខុ បមាទេ ភយទស្សិ វា**
សញ្ញោជនំ អណុំ ថូលំ ឌហំ អគ្គីវ គច្ឆតិ ។

ភិក្ខុអ្នកត្រេកអរ ក្នុងសេចក្តីមិនប្រមាទ ឬ ឃើញភ័យក្នុងសេចក្តីប្រមាទ តែងដុតចោលសំយោជនៈ ទាំងតូច ទាំងធំ ដូចភ្លើងឆេះ (រាលនូវកំទេចទាំងតូច ទាំងធំ) ដូច្នោះឯង ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែងនៅ**វត្តជេតពន** ក្រុងសាវត្ថី ទ្រង់ប្រារព្ធ **ភិក្ខុ**មួយរូប) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុអង្គនោះក៏បានសម្រេចនូវ**ព្រះអរហត្ត** ព្រមទាំង**បដិសម្ភិទា** ទាំងឡាយ ។

៣២.. អប្បមាទរតោ ភិក្ខុ បមាទេ ភយទស្សិ វា
អភព្វោ បរិហានាយ និព្វានស្សេវ សន្តិកេ ។

ភិក្ខុអ្នកត្រេកអរ ក្នុងសេចក្តីមិនប្រមាទ ឬ ឃើញភ័យក្នុងសេចក្តីប្រមាទ ជាអ្នកមិនគួរនឹងសាបសូន្យចាកគុណធម៌ ឈ្មោះថាឋិតនៅក្នុងទីជិតនៃព្រះនិព្វាន ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន ក្រុងសាវត្ថី ទ្រង់ប្រារព្ធ ព្រះនិគមវាសីតិស្សត្ថេរ) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ព្រះនិគមវាសីតិស្សត្ថេរ ក៏បានសម្រេចនូវ ព្រះអរហត្ត មួយអន្លើដោយ បដិសម្ភិទា ទាំងឡាយ ។
ជនដទៃដ៏ច្រើន ក៏បានសម្រេចជាអរិយបុគ្គល មានសោតាបន្ន ជាដើម ។

(ចប់ អប្បមាទវគ្គ ទី ២ = មាន ១២ គាថា)

ជំពូកទី ៣

ចិត្តវគ្គ

(Citta Vagga)

Mind

(Versets sur la Psyché)

(មាន ១១ គាថា)

(ពី គាថា ទី ៣៣ ➪ ដល់ គាថា ទី ៤៣)

៣៣.. **ផន្ទនំ ចបលំ ចិត្តំ ទុរក្ខំ ទុន្និវារយំ**
ឧជុំ ករោតិ មេធាវី ឧសុការោវ តេជនំ ។

អ្នកប្រាជ្ញ តែងធ្វើចិត្តដែលញាប់ញ័រ ឃ្លេងឃ្លោង រក្សាបានដោយកម្រ ហាមឃាត់បានដោយលំបាក ឱ្យជាចិត្តត្រង់បាន ដូចអ្នកធ្វើព្រួញ ពត់ព្រួញឱ្យត្រង់ ។

៣៤.. **វារិជោវ ថលេ ខិត្តោ ឱកមោកតឧព្ភតោ**
បរិផន្ទតិទំ ចិត្តំ មារធេយ្យំ បហាតវេ ។

ចិត្តនេះ ដែលបុគ្គលលើកឡើងចាកអាល័យ គឺកាមគុណ ៥ បោះទៅក្នុងវិបស្សនាកម្មដ្ឋាន ដើម្បីលះបង់នូវវដ្តៈជាទីនៅនៃមារ រមែងញាប់ញ័រដូចត្រី ដែលគេលើកឡើងចាកទីនៅ គឺទឹក បោះទៅលើគោកដូច្នោះឯង ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែង នៅទៀបភ្នំ **ចាលិកា** ប្រារព្ធ **ព្រះមេឃិយត្ថេរ**) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា**ព្រះមេឃិយត្ថេរ** បានតាំងនៅក្នុង **សោតាបត្តិផល** ជនដទៃក្រៅពីនេះជាច្រើន ក៏បានសម្រេចជា**អរិយបុគ្គលភាព** មាន **សោតាបន្ន** ជាដើមផងដែរ ។

៣៥.. **ទុន្និគ្គហស្ស លហុនោ យត្ថ កាមនិបាតិនោ**
ចិត្តស្ស ទមថោ សាធុ ចិត្តំ ទន្តំ សុខាវហំ ។

ការទូន្មានចិត្ត ដែលសង្កត់សង្កិនបានដោយលំបាក ជាធម្មជាតរហ័ស មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ

រមែងជាគុណ ញុាំងប្រយោជន៍ឱ្យសម្រេច (ព្រោះថា) **ចិត្តដែលឃ្លឹកឃ្លើន បានហើយ រមែងនាំមកនូវសេចក្តីសុខ ។**

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែង នៅវត្ត **ជេតពន** ប្រារព្ធ **ព្រះភិក្ខុ** មួយអង្គ) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា បរិស័ទដែលមកប្រជុំគ្នាជាច្រើននោះ ក៏បានសម្រេចជា**អរិយបុគ្គលភាព** មាន **សោតាបន្ន** ជាដើម ។

៣៦.. **សុទុទ្ទសំ សុនិបុណំ យត្ថ កាមនិបាតិនំ**
ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ ។

អ្នកមានប្រាជ្ញា គួររក្សាចិត្តដែលឃើញដោយកម្រក្រៃពេក ដែលល្អិតពេកណាស់ មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ (ព្រោះថា) **ចិត្តដែលគេរក្សាបានហើយ រមែងនាំមកនូវសេចក្តីសុខ ។**

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែង នៅក្រុង **សាវត្ថី** ប្រារព្ធ **ឧក្កណ្ឋិតភិក្ខុ** - ភិក្ខុអផ្សុកមួយអង្គ) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុអង្គនេះក៏បានសម្រេច **សោតាបត្តិផល** ជនដទៃជាច្រេនក៏បានសម្រេចជា**អរិយបុគ្គលភាព** មាន **សោតាបន្ន** ជាដើម ។

៣៧.. **ទូរង្គមំ ឯកចរំ អសរីរំ គុហាសយំ**
យេ ចិត្តំ សញ្ញមេស្សន្តិ មោក្ខន្តិ មារពន្ធនា ។

អ្នកទាំងឡាយណា នឹងសង្រួមចិត្តដែលទៅឆ្ងាយ ជាចិត្តត្រាច់ទៅតែឯង មិនមានសរីរៈ មានគុហា គឺមហាភូតរូប ៤ ជាទីអាស្រ័យនៅ អ្នកទាំងនោះឯង រមែងរួចចាកចំណងនៃមារ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែង នៅវត្តជេតពន ក្រុងសាវត្ថី
ប្រារព្ធ ព្រះភាគិនេយ្យសង្ឃរក្ខិតត្ថេរ) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ព្រះភាគិនេយ្យសង្ឃរក្ខិតត្ថេរៈ បានសម្រេច សោតាបត្តិផល, ជនដទៃជាច្រើនក៏បានសម្រេចជា**អរិយបុគ្គលភាព** មាន **សោតាបន្ន** ជាដើមផងដែរ ។

៣៨.. អនវដ្ឋិតចិត្តស្ស សទ្ធម្មំ អវិជានតោ
បរិប្លវប្បសាទស្ស បញ្ញា ន បរិបូរតិ ។
៣៩.. អនវស្សុតចិត្តស្ស អនន្វាហតចេតសោ
បុញ្ញបាបប្បហីនស្ស នត្ថិ ជាគរតោ ភយំ ។

ប្រាជ្ញា រមែងមិនបរិបូណ៌ដល់បុគ្គល ដែលមានចិត្តមិនខ្ជាប់ខ្ជួន មិនដឹងច្បាស់នូវព្រះសទ្ធម្ម មានសេចក្តីជ្រះថ្លាអណ្តែតទៅ ។ ភ័យរមែងមិនមាន ដល់បុគ្គលអ្នកមានចិត្តមិនទទឹកដោយរាគៈ មានចិត្តដែលទោសខ្ទាំងខ្ទប់មិនបាន មានបុណ្យនិង បាបលះចោលហើយ ភ្ញាក់រឭកជានិច្ច ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែង នៅវត្តជេតពន ក្រុងសាវត្ថី
ប្រារព្ធ ព្រះភិក្ខុចិត្តហត្ថត្ថេរ) ។

ព្រះភិក្ខុចិត្តហត្ថត្ថេរ បានសម្រេច **ព្រះអរហត្ត** មួយអន្លើដោយ **បដិសម្ភិទា**។

៤០.. កុម្ភូបមំ កាយមិមំ វិទិត្វា
នគរូបមំ ចិត្តមិទំ ឋបេត្វា
យោធេថ មារំ បញ្ញាវុធេន
ជិតញ្ច រក្ខេ អនិវេសនោ សិយា ។

បុគ្គលគប្បីដឹងច្បាស់នូវកាយនេះថា ដូចជាថ្នាំង គប្បីបិទនូវចិត្តនេះឱ្យដូចជាបិទទ្វារនគរ គប្បីច្បាំងនូវមារដោយអាវុធ គឺបញ្ញា គប្បីរក្សាទុកនូវធម៌ ដែលខ្លួនឈ្នះហើយ មិនគប្បីជាអ្នកជំអក់នៅ (ក្នុងធម៌នោះ)ឡើយ ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែង នៅក្រុងសាវត្ថី ប្រារព្ធភិក្ខុអ្នកប្រារព្ធវិបស្សនា ៥០០ អង្គ) ។ ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុទាំង៥០០អង្គ បានសម្រេច **ព្រះអរហត្ត** មួយអន្លើដោយ **បដិសម្ភិទា**។

៤១.. **អចិរំ វតយំ កាយោ បឋវឹ អធិសេស្សតិ**
ឆុឌ្ធោ អបេតវិញ្ញាណោ និរត្ថំវ កលិង្គរំ ។

ឱហ្ន៎ មិនយូរប៉ុន្មានទេតើ កាយនេះ មានវិញ្ញាណទៅប្រាស គេយកទៅចោលផុតហើយ មុខជានឹងដេកស្តូកស្តឹងលើផែនដី ដូចជាអង្កត់ឧសរកប្រយោជន៍គ្មាន ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែង នៅ**វត្តជេតពន** ក្រុងសាវត្ថី ប្រារព្ធ **ព្រះបូតិគត្តតិស្សត្ថេរ**) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ព្រះបូតិគត្តតិស្សត្ថេរៈ បានសម្រេច **ព្រះអរហត្ត** មួយអន្លើដោយ **បដិសម្ភិទា**។

ជនដទៃជាច្រើនក៏បានសម្រេចជា**អរិយបុគ្គលភាព** មាន **សោតាបន្ន** ជាដើមផងដែរ ។

៤២.. **ទិសោ ទិសំ យន្តំ កយិរា វេរី វា បន វេរិនំ**
មិច្ឆាបណិហិតំ ចិត្តំ បាបិយោ នំ តតោ ករេ ។

ចោរក្រឡេកឃើញចោរផងគ្នា ឬក៏បុគ្គលមានពៀរ ក្រឡេកឃើញបុគ្គលមានពៀរផងគ្នា គប្បីធ្វើនូវសេចក្តីវិនាសណាមួយដល់គ្នា ចិត្តដែល

បុគ្គលតាំងទុកខុសហើយ រមែងធ្វើបុគ្គលនោះ ឱ្យអាក្រក់ក្រៃលែង ជាងសេចក្តីវិនាសនោះ ទៅទៀត ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅ កោសលជនបទ ប្រារព្ធនាយគោបាល ឈ្មោះ នន្ទៈ) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនក៏បានសម្រេច **អរិយផល** ទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៤៣.. ន តំ មាតា បិតា កយិរា អញ្ញេ វាបិច ញាតកា
សម្មាបណិហិតំ ចិត្តំ សេយ្យសោ នំ តតោ ករេ ។

មាតាបិតា មិនគប្បីធ្វើនូវហេតុនោះបាន ឬជនទាំងឡាយដទៃជាញាតិ មិនគប្បីធ្វើនូវហេតុនោះបាន ចំណែកខាងចិត្ត ដែលបុគ្គលតាំងទុកត្រូវហើយ រមែងធ្វើបុគ្គលនោះ ឱ្យប្រសើរជាងហេតុនោះបាន ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅ សោរេយ្យនគរ ប្រារព្ធ ព្រះសោរេយ្យត្ថេរៈ) ។ ព្រះសោរេយ្យត្ថេរៈ បានសម្រេច **ព្រះអរហត្ត** មួយអន្លើដោយ **បដិសម្ភិទា**។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនក៏បានសម្រេច **អរិយផល** ទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

(ចប់ **ចិត្តវគ្គ** ទី ៣ = មាន **១១** គាថា)

ជំពូកទី ៤

បុប្ផវគ្គ

(Puppha Vagga)

Flowers

(Versets sur les Fleurs)

(មាន ១៦ គាថា)

(ពី គាថា ទី ៤៤ ➯ ដល់ គាថា ទី ៥៩)

៤៤.. កោ ឥមំ បឋវឹ វិជេស្សតិ យមលោកញ្ច ឥមំ សទេវកំ
កោ ធម្មបទំ សុទេសិតំ កុសលោ បុប្ផមិវ បចេស្សតិ។
៤៥.. សេក្ខោ បឋវឹ វិជេស្សតិ យមលោកញ្ច ឥមំ សទេវកំ
សេក្ខោ ធម្មបទំ សុទេសិតំ កុសលោ បុប្ផមិវ បចេស្សតិ។

អ្នកណានឹងដឹងច្បាស់នូវផែនដី គឺអត្តភាពនេះ និង យមលោក គឺ អបាយភូមិ ៤ និង មនុស្សលោកនេះ ព្រមទាំងទេវលោកបាន អ្នកណានឹងជ្រើសរើសនូវចំណែកនៃធម៌ ដែល**ព្រះតថាគត** សម្ដែងប្រពៃហើយ ដូចមាលាការដែលឈ្លាសវៃ ជ្រើសរើសនូវផ្កា ដូច្នោះឯង ។

ព្រះសេក្ខបុគ្គល នឹងដឹងច្បាស់នូវផែនដីគឺអត្តភាពនេះ និង យម-លោក គឺ អបាយភូមិ ៤ និង មនុស្សលោកនេះ ព្រមទាំងទេវលោកបាន ព្រះសេក្ខបុគ្គលនឹងជ្រើសរើសនូវចំណែកនៃធម៌ ដែលព្រះតថាគតសម្ដែងប្រពៃហើយ ដូចមាលាការដែលឈ្លាសវៃ ជ្រើសរើសនូវផ្កាដូច្នោះ ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្ដែងនៅក្រុងសាវត្ថី ប្រារព្ធភិក្ខុ ៥០០ រូប ដែលជាអ្នកខ្វល់ខ្វាយក្នុងបឋវីកថា) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុទាំង ៥០០ រូប ក៏បានសម្រេច **ព្រះអរហត្ត** ព្រមទាំង **បដិសម្ភិទា** ទាំងឡាយ ។

៤៦.. ផេណូបមំ កាយមិមំ វិទិត្វា
មរីចិធម្មំ អភិសម្ពុធានោ
ឆេត្វាន មារស្ស បបុប្ផកានិ
អទស្សនំ មច្ចុរាជស្ស គច្ឆេ ។

ភិក្ខុ កាលដឹងច្បាស់នូវកាយនេះថា ដូចជាដុំពពុះទឹក ដឹងច្បាស់នូវកាយនេះថា មានសភាពដូចព្រេញថ្ងៃ គប្បីកាត់នូវផ្កាជាប្រធាននៃមារ គឺវដ្តៈ ៣ ទៅកាន់ស្ថានជាទីមិនឃើញនៃមច្ចុរាជ ។

☸ (<u>**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្ដែងនៅក្រុងសាវត្ថី ប្រារព្ធភិក្ខុ ១ រូប ដែលចម្រើន **មរីចិកម្មដ្ឋាន** គឺ កម្មដ្ឋានដែល ពិចារណានូវថ្ងៃបណ្ដើរកូនជាអារម្មណ៍</u>) ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ព្រះថេរៈអង្គនេះក៏បានសម្រេច **ព្រះអរហត្ត** ព្រមទាំង **បដិសម្ភិទា** ទាំងឡាយ ។

៤៧.. បុប្ផានិ ហេវ បចិនន្តំ ព្យាសត្តមនសំ នរំ
សុត្តំ គាមំ មហោឃោវ មច្ចុ អាទាយ គច្ឆតិ ។

មច្ចុ គឺសេចក្ដីស្លាប់ តែងកៀរយកទៅនូវនរជន អ្នកមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេង ៗ កំពុងជ្រើសរើសនូវផ្កា គឺកាមគុណ ៥ នុ៎ះឯង ដូចទឹកជំនន់ធំ ដែលកួចយកអ្នកស្រុកកំពុងដេកលក់ទៅ ដូច្នោះឯង ។

☸ (<u>**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្ដែងនៅក្រុងសាវត្ថី ប្រារព្ធ **ព្រះបាទវិឌូឌភៈ** ព្រមទាំងបរិស័ទ ដែលត្រូវទឹកជំនន់កួចពន្លិចឱ្យសោយទិវង្គត</u>)។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេច **អរិយផល** ទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៤៨.. បុប្ផានិ ហេវ បចិនន្តំ ព្យាសត្តមនសំ នរំ
អតិត្តំយេវ កាមេសុ អន្តកោ កុរុតេ វសំ ។

អ្នកធ្វើទីបំផុត គឺមរណៈ តែងក្រុងសត្វ ដែលមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេង ៗ កំពុងជ្រើសរើសនូវផ្កា គឺកាមគុណ ៥ មិនឆ្អែតឆ្អន់ក្នុងកាមទាំងឡាយនុ៎ះឯង ឱ្យនៅក្នុងអំណាចរបស់ខ្លួន ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្ដែងនៅក្រុងសាវត្ថីប្រារព្ធស្ត្រីឈ្មោះ **បតិបូជិកា**)
☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេច **អរិយផល**
ទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៤៩.. **យថាបិ ភមរោ បុប្ផំ វណ្ណគន្ធំ អហេឋយំ**
បលេតិ រសមាទាយ ឯវំ គាមេ មុនី ចរេ ។

ភមរជាតិ មិនធ្វើផ្កាឈើដែលមានពណ៌ និង ក្លិន ឱ្យវិនាសទេ ក្រេបយកតែរស ហើរទៅយ៉ាងណាមិញ អ្នកប្រាជ្ញ គប្បីត្រាច់ទៅក្នុងស្រុក ក៏យ៉ាងនោះឯង ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្ដែងនៅក្រុងសាវត្ថី
ប្រារព្ធសេដ្ឋីឈ្មោះ **មច្ឆរិយកោសិយសេដ្ឋី** អ្នកមានសេចក្ដីកំណាញ់) ។
☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេច **អរិយផល**
ទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៥០.. **ន បរេសំ វិលោមានិ ន បរេសំ កតាកតំ**
អត្តនោ វ អវេក្ខេយ្យ កតានិ អកតានិ ច ។

ពាក្យចាក់ដោតទាំងឡាយរបស់ជនដទៃ បុគ្គលមិនគួរធ្វើទុកក្នុងចិត្តទេ កិច្ចដែលធ្វើហើយ និង មិនទាន់ធ្វើហើយរបស់ជនដទៃ (ដែលមិនមែនជាមុខការរបស់ខ្លួន) បុគ្គលមិនគួរពិនិត្យមើលទេ បុគ្គលគួរពិនិត្យពិចារណាតែកិច្ចការទាំងឡាយ ដែលធ្វើហើយ និង មិនទាន់ធ្វើហើយ របស់ខ្លួនតែម្យ៉ាង ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្ដែងនៅក្រុងសាវត្ថី ប្រារព្ធ **ឆត្តបាណិឧបាសក**) ។
☞ ក្នុងកាលចប់ព្រះធម្មទេសនា ឧបាសិកាស្ត្រីមេផ្ទះម្នាក់តាំងនៅក្នុង **សោតាបត្តិផល** ។

៥១.. **យថាបិ រុចិរំ បុប្ផំ វណ្ណវន្តំ អគន្ធកំ**
ឯវំ សុភាសិតា វាចា អផលា ហោតិ អកុព្វតោ ។
៥២.. **យថាបិ រុចិរំ បុប្ផំ វណ្ណវន្តំ សគន្ធកំ**
ឯវំ សុភាសិតា វាចា សផលា ហោតិ សុកុព្វតោ ។

ផ្កាឈើមានទ្រង់ទ្រាយល្អ មានពណ៌ (ល្អ) តែគ្មានក្លិន (ក្រអូប) (រមែងមិនក្រអូបដល់អ្នកដែលទ្រទ្រង់) ដូចម្ដេចមិញ វាចាជាសុភាសិត រមែងគ្មានផលដល់អ្នកដែលមិនធ្វើតាមដូច្នោះ, ផ្កាឈើដែលមានទ្រង់ទ្រាយល្អ មានពណ៌ មានក្លិន (រមែងក្រអូបដល់អ្នកដែលទ្រទ្រង់) ដូចម្ដេចមិញ វាចាជាសុភាសិត រមែងមានផលដល់អ្នកដែលធ្វើតាមដោយគោរព ដូច្នោះឯង ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្ដែងនៅក្រុងសាវត្ថី ប្រារព្ធសេដ្ឋីឈ្មោះ **ឆត្តបាណិឧបាសក**) ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ពពួកជនជាច្រើន បានសម្រេចនូវ **អរិយផល**ទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៥៣.. **យថាបិ បុប្ផរាសិម្ហា កយិរា មាលាគុណេ ពហូ**
ឯវំ ជាតេន មច្ចេន កត្តព្វំ កុសលំ ពហុំ ។

មាលាការ ចេះធ្វើសំណុំនៃកម្រងផ្កា អំពីគំនរនៃផ្កា(ផ្សេង ៗ គ្នា) ឱ្យច្រើនបាន យ៉ាងណាមិញ **កុសល** ដែលសត្វកើតមកហើយ គួរធ្វើឱ្យច្រើន យ៉ាងនោះ ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្ដែងនៅ **វត្តបុព្វារាម**-ក្រុងសាវត្ថី ប្រារព្ធ ឧបាសិកា ឈ្មោះ **វិសាខាមិគារមាតា**) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេច **អរិយផល** ទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៥៤.. **ន បុប្ផគន្ធោ បដិវាតមេតិ**
ន ចន្ទនំ តគរមល្លិកា វា
សតញ្ច គន្ធោ បដិវាតមេតិ
សព្វា ទិសា សប្បុរិសោ បវាយតិ ។

៥៥.. **ចន្ទនំ តគរំ វាបិ ឧប្បលំ អថ វស្សិកី**
ឯតេសំ គន្ធជាតានំ សីលគន្ធោ អនុត្តរោ ។

ក្លិនផ្កាឈើ ផ្សាយទៅច្រាសខ្យល់មិនបាន ក្លិនខ្លឹមចន្ទន៍ក្ដី ក្លិនខ្លឹមក្រស្នាក្ដី ក្លិនផ្កាម្លិះរួតក្ដី ក៏ផ្សាយទៅច្រាសខ្យល់មិនបាន, ចំណែកក្លិនរបស់សប្បុរសទាំងឡាយ រមែងផ្សាយទៅច្រាសខ្យល់បាន ព្រោះសប្បុរសរមែងផ្សាយទៅបានគ្រប់ទិស ។ ក្លិននៃសីល ជាគុណជាតប្រសើរបំផុតជាងគន្ធជាតទាំងនេះ គឺ ខ្លឹមចន្ទន៍ ខ្លឹមក្រស្នា ផ្កាឧប្បល ផ្កាម្លិះលា ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្ដែងនៅក្រុងសាវត្ថី ប្រារព្ធ បញ្ហារបស់ **ព្រះអានន្ទត្ថេរ**) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេច **អរិយផល** ទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៥៦.. អប្បមត្តោ អយំ គន្ធោ យ្វាយំ តគរចន្ទនី
យោ ច សីលវតំ គន្ធោ វាតិ ទេវេសុ ឧត្តមោ ។

ក្លិនក្រស្នា និង ក្លិនចន្ទន៍ណា ក្លិននេះ ក្រអូបមានប្រមាណតិចទេ ចំណែកក្លិននៃបុគ្គលមានសីលទាំងឡាយណា ក្លិននោះ ទើបក្រអូបលើសលប់ ផ្សាយទៅក្នុងទេវលោក និង មនុស្សលោកបាន ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តវេឡុវ័ន "វេឡុវនារាម" ប្រារព្ធ ការប្រគេនបិណ្ឌបាតដល់ ព្រះមហាកស្សបត្ថេរ) ។
☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេច អរិយផល ទាំងឡាយ មាន សោតាបត្តិផល ជាដើម ។

៥៧.. តេសំ សម្បន្នសីលានំ អប្បមាទវិហារិនំ
សម្មទញ្ញា វិមុត្តានំ មារោ មគ្គំ ន វិន្ទតិ ។

មារាធិរាជ (ទុកជាខំស្វែងរក) ក៏មិនជួបនូវផ្លូវរបស់លោក អ្នកមានសីលបរិបូណ៌ អ្នកនៅដោយសេចក្តីមិនប្រមាទ អ្នករួចស្រឡះ (ចាកធម៌ជាគ្រឿងសៅហ្មង) ព្រោះដឹងច្បាស់តាមហេតុ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តវេឡុវ័ន "វេឡុវនារាម" ប្រារព្ធ ការបរិនិព្វានរបស់ ព្រះគោធិកត្ថេរ) ។
☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេច អរិយផល ទាំងឡាយ មាន សោតាបត្តិផល ជាដើម ។

៥៨.. យថា សង្ការធានស្មឹ ឧជ្ឈិតស្មឹ មហាបថេ
បទុមំ តត្ថ ជាយេថ សុចិគន្ធំ មនោរមំ ។
៥៩.. ឯវំ សង្ការភូតេសុ អន្ធភូតេ បុថុជ្ជនេ
អតិរោចតិ បញ្ញាយ សម្មាសម្ពុទ្ធសាវកោ ។

ផ្កាឈូក ទុកជាកើតក្នុងគំនរសម្រាម ដែលគេចាក់ចោលក្បែរផ្លូវធំនោះ ក៏គង់មានក្លិនក្រអូប ជាទីរីករាយនៃចិត្តបាន ដូចម្តេចមិញ បណ្តាជនដែលដូចជាគំនរសម្រាម សាវ័ករបស់ព្រះសម្មាសម្ពុទ្ធ រមែងរុងរឿង កន្លងផុតបុថុជ្ជនទាំងឡាយ ដែលល្ងិតល្ងង់ ដោយប្រាជ្ញា (របស់ខ្លួន) ដូច្នោះឯង ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "**ជេតវនារាម**"
ប្រារព្ធសាវ័ករបស់និគ្រន្ថ ឈ្មោះ **គរហទិន្ន**) ។
☞ គរហទិន្ន និង សិរីគុត្ត បានសម្រេចសោតាបត្តិផល
☞ ក្នុងកាលចប់ព្រះធម្មទេសនា ការត្រាស់ដឹងធម៌ បានកើតមានដល់សត្វ ៨៤.០០០ ។

(ចប់ **បុប្ផវគ្គ** ទី ៤ = មាន **១៦** គាថា)

ជំពូកទី ៥

ពាលវគ្គ

(Bāla Vagga)

Fools

(Versets sur les Fous)

(មាន ១៦ គាថា)

(ពី គាថា ទី ៦០ ↳ ដល់ គាថា ទី ៧៥)

៦០.. ទីឃា ជាគរតោ រត្តិ ទីឃំ សន្តស្ស យោជនំ
ទីឃោ ពាលាន សំសារោ សទ្ធម្មំ អវិជានតំ ។

រាត្រីវែង ចំពោះតែអ្នកភ្ញាក់រឭក (អ្នកដេកមិនលក់), យោជន៍វែង ចំពោះតែអ្នកនឿយហត់, សង្សារវដ្តវែង ចំពោះតែបុគ្គលពាល មិនដឹងច្បាស់នូវព្រះសទ្ធម្ម ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធព្រះបាទ បសេនទិកោសល និង ទុគ្គតបុរស) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ទុគ្គតបុរស ក៏បានសម្រេចសោតាបត្តិផល សូម្បីជនដទៃជាច្រើន ក៏បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

៦១.. ចរញ្ចេ នាធិគច្ឆេយ្យ សេយ្យំ សទិសមត្តនោ
ឯកចរិយំ ទឡ្ហំ កយិរា នត្ថិ ពាលេ សហាយតា ។

បុគ្គលកាលស្វះស្វែងរកកល្យាណមិត្ត បើមិនបានមិត្តដ៏ប្រសើរជាងខ្លួន ឬមិត្តដែលស្មើនឹងខ្លួនទេ គប្បីប្រព្រឹត្តនៅតែម្នាក់ឯង ឱ្យខ្ជាប់ខ្ជួនវិញ ព្រោះថា **សហាយតាគុណ**[៙] មិនមានក្នុងបុគ្គលពាលឡើយ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅក្រុងសាវត្ថី ទ្រង់ប្រារព្ធ សទ្ធិវិហារិក របស់ ព្រះមហាកស្សបត្ថេរ) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា អាគន្តុកភិក្ខុ ក៏បានសម្រេចសោតាបត្តិផល សូម្បីជនដទៃជាច្រើន ក៏បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

[៙] ចូឡសីល, មជ្ឈិមសីល, មហាសីល, កថាវត្ថុ ១០, ធុតង្គគុណ ១៣, វិបស្សនាគុណ, មគ្គ ៤, ផល ៤, វិជ្ជា ៣, អភិញ្ញា ៦ ហៅថា **សហាយតាគុណ** ។

៦២.. **បុត្តា មត្ថិ ធនមត្ថិ ឥតិ ពាលោ វិហញ្ញតិ**
អត្តា ហិ អត្តនោ នត្ថិ កុតោ បុត្តា កុតោ ធនំ ។

ជនពាលតែងព្រួយលំបាក ដោយសេចក្ដីសំគាល់ថា កូនទាំងឡាយរបស់អញមាន ទ្រព្យរបស់អញមាន តាមដែលពិត សូម្បីខ្លួនរបស់ខ្លួនក៏មិនមាន[១] ចំណង់បើកូនទាំងឡាយ នឹងរាប់ថាមានអំពីណាបាន ទ្រព្យនឹងរាប់ថា មានអំពីណាបាន ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្ដែងនៅក្រុងសាវត្ថីប្រារព្ធ **អានន្ទសេដ្ឋី**)។
☞ ក្នុងកាលចប់ព្រះធម្មទេសនា ការត្រាស់ដឹងធម៌ បានកើតមានដល់សត្វ ៨៤.០០០ ។

៦៣.. **យោ ពាលោ មញ្ញតី ពាល្យំ បណ្ឌិតោ វាបិ តេន សោ**
ពាលោ ច បណ្ឌិតមានី ស វេ ពាលោតិ វុច្ចតិ ។

អ្នកណាជាមនុស្សពាល ហើយដឹងនូវភាពនៃខ្លួន ថាជាពាល អ្នកនោះនឹងទៅជាបណ្ឌិតបានខ្លះ ដោយហេតុដែលដឹងខ្លួន ថាជាពាលនោះ, ម្យ៉ាងទៀត អ្នកណាជាមនុស្សពាល មានសេចក្ដីប្រកាន់ថាខ្លួនជាបណ្ឌិត អ្នកនោះ ឈ្មោះថាជាមនុស្សពាល ដោយពិត ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្ដែងនៅវត្តជេតពន "**ជេតវនារាម**" ទ្រង់ប្រារព្ធចោរអ្នកទម្លាយនូវបង្វិចទ្រព្យ) ។
☞ ក្នុងកាលចប់ព្រះធម្មទេសនា មហាជន ព្រមទាំងញាតិទាំងឡាយរបស់ចោរ ដែលបានសម្រេចជាសោតាបន្ននោះ ក៏បានសម្រេចសោតាបត្តិផលផងដែរ ។

---

[១] ព្រោះមិនអាចនឹងការពារទុក្ខបាន ។ **អដ្ឋកថា** ។

៦៤.. យាវជីវម្បិ ចេ ពាលោ បណ្ឌិតំ បយិរុបាសតិ
ន សោ ធម្មំ វិជានាតិ ទព្វី សូបរសំ យថា ។

មនុស្សពាល បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីអស់មួយជីវិត ក៏ឥតមានដឹងរសធម៌អ្វី ឱ្យច្បាស់លាស់ឡើយ ដូចវែក ដែលមិនដឹងរសសម្ល ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធ ព្រះឧទាយិត្ថេរ) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ចិត្តរបស់ពួកអាគន្តុកភិក្ខុ ក៏រួចផុតស្រឡះចាកអាសវៈ។

៦៥.. មុហុត្តមបិ ចេ វិញ្ញូ បណ្ឌិតំ បយិរុបាសតិ
ខិប្បំ ធម្មំ វិជានាតិ ជិវ្ហា សូបរសំ យថា ។

វិញ្ញូជន បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីតែមួយរំពេច រមែងយល់រសធម៌ ដោយឆាប់រហ័ស ដូចអណ្តាត ដឹងនូវរសសម្ល ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធ ពួកភិក្ខុអ្នកក្រុងបាវា ប្រមាណ ៣០ រូប) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុជាច្រើន បានសម្រេចព្រះអរហត្ត ។

៦៦.. ចរន្តិ ពាលា ទុម្មេធា អមិត្តេនេវ អត្តនា
ករោន្តា បាបកំ កម្មំ យំ ហោតិ កដុកប្ផលំ ។

ពួកជនពាល មិនមានប្រាជ្ញា មានខ្លួនដូចជាសត្រូវ តែងធ្វើកម្មលាមក ដែលជាអំពើមានផលក្តៅក្រហាយ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តវេឡុវ័ន "វេឡុវនារាម" ប្រារព្ធបុរសកើតឃ្លង់ម្នាក់ ឈ្មោះ សុប្បពុទ្ធកុដ្ឋិ) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

៦៧.. ន តំ កម្មំ កតំ សាធុ យំ កត្វា អនុតប្បតិ
យស្ស អស្សុមុខោ រោទំ វិបាកំ បដិសេវតិ ។

បុគ្គលធ្វើកម្មណាហើយ រមែងក្តៅក្រហាយ ឬមានមុខប្រឡាក់ដោយទឹកភ្នែក ស្រែកយំ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះ ឈ្មោះថាជាកម្មមិនល្អឡើយ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធ បុរសអ្នកភ្ជួរស្រែម្នាក់) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ឧបាសកអ្នកភ្ជួរស្រែ បានសម្រេចសោតាបត្តិផល ។ សូម្បីភិក្ខុដែលមកប្រជុំគ្នាជាច្រើនក្នុងទីនោះ ក៏បានសម្រេចនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

៦៨.. តញ្ច កម្មំ កតំ សាធុ យំ កត្វា នានុតប្បតិ
យស្ស បតីតោ សុមនោ វិបាកំ បដិសេវតិ ។

បុគ្គលធ្វើកម្មណាហើយ រមែងមិនក្តៅក្រហាយ ឬ ដល់នូវសេចក្តីពេញចិត្ត មានចិត្តល្អ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះឯង ឈ្មោះថាជាកម្មល្អ ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្ដែងនៅវត្តវេឡុវ័ន "**វេឡុវនារាម**"
ប្រារព្ធ **នាយមាលាការ** ឈ្មោះ **សុមនៈ**) ។
☞ ក្នុងកាលចប់ព្រះធម្មទេសនា **ធម្មាភិសម័យ** (ការត្រាស់ដឹងធម៌)
បានកើតមានដល់សត្វ ៨៤.០០០ ។

៦៩.. **មធុវា មញ្ញតី ពាលោ យាវ បាបំ ន បច្ចតិ**
យទា ច បច្ចតី បាបំ អថ (ពាលោ) ទុក្ខំ និគច្ឆតិ ។

បាបមិនទាន់ឱ្យផលត្រឹមណា ជនពាល តែងសំគាល់នូវបាបនោះ ថាដូចទឹកឃ្មុំ លុះតែកាលណាបាបឱ្យផល ជនពាលទើបប្រទះនូវសេចក្ដីទុក្ខ ក្នុងកាលណោះ ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្ដែងនៅវត្តជេតពន "**ជេតវនារាម**"
ប្រារព្ធព្រះថេរី **ឧប្បលវណ្ណា**) ។
☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចនូវអរិយផលទាំងឡាយ
មានសោតាបត្តិផលជាដើម ។

៧០.. **មាសេ មាសេ កុសគ្គេន ពាលោ ភុញ្ជេថ ភោជនំ**
ន សោ សង្ខាតធម្មានំ កលំ អគ្ឃតិ សោឡសឹ ។

ជនពាល ទុកជាបរិភោគភោជនដោយចុង[៩]ស្បូវ រាល់ ៧ ខែ ជនពាលនោះ ក៏មិនដល់មួយចំណិតនៃចំណែកទី ១៦ ៗ លើក របស់បុគ្គលទាំងឡាយ ដែលមានធម៌បានដឹង ឬបានពិចារណាហើយឡើយ ។

[៩] បានសេចក្ដីថា យកចុងស្បូវទៅចាក់ភោជន ហើយយកមកគេះនឹងចុងអណ្ដាត, ចំពោះគាថានេះ ព្រះសម្ពុទ្ធទ្រង់សម្ដែងប្រារព្ធនឹងជម្ពុកាជីវក ដែលជាអ្នកប្រព្រឹត្តបរិភោគបែបនោះជាវត្ត ក្នុងពេលដែលមហាជន នាំភោជនមកបូជា ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តវេឡុវ័ន "វេឡុវនារាម" ប្រារព្ធ ជម្ពុកាជីវក) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា **ធម្មាភិសម័យ** បានកើតមានដល់សត្វ ៨៤.០០០ ។

៧១.. **ន ហិ បាបំ កតំ កម្មំ សជ្ជុខីរំវ មុច្ចតិ**
ឌហន្តំ ពាលមន្វេតិ ភស្មាច្ឆន្នោវ បាវកោ ។

កម្មលាមក ដែលជនពាលធ្វើហើយ មិនទាន់ឱ្យផលនោះក៏មាន ដូចទឹកដោះស្រស់ ដែលមិនទាន់ប្រែក្លាយ (ក្នុងមួយរំពេច) ដូច្នោះ បាបកម្មនោះតាមដុតបុគ្គលពាល ដូចរងើកភ្លើងដែលបិទបាំងទុកដោយផេះ ដូច្នោះ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តវេឡុវ័ន "វេឡុវនារាម" ប្រារព្ធប្រេត ដែលមានអត្តភាពដូចជាពស់ "អហិប្រេត") ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

៧២.. **យាវទេវ អនត្ថាយ ញត្តំ ពាលស្ស ជាយតិ**
ហន្តិ ពាលស្ស សុក្កំសំ មុទ្ធំ អស្ស វិបាតយំ ។

ការចេះដឹង កើតឡើងដល់បុគ្គលពាល គ្រាន់តែដើម្បីសេចក្តីវិនាសប៉ុណ្ណោះ រមែងញុំាំងបញ្ញាឱ្យធ្លាក់ចុះ បំផ្លិចបំផ្លាញចំណែកធម៌ស គឺកុសលរបស់បុគ្គលពាលនោះ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តវេឡុវ័ន "វេឡុវនារាម" ប្រារព្ធ "សដ្ឋិកូដប្រេត" ប្រេតដែលត្រូវញញួរ ៦ម៉ឺន សំពងក្បាលរាល់ថ្ងៃ) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

៧៣.. អសន្តំ ភាវមិច្ឆេយ្យ បុរេក្ខារញ្ច ភិក្ខុសុ
អាវាសេសុ ច ឥស្សរិយំ បូជា បរកុលេសុ ច ។

៧៤.. មមេវ កត មញ្ញន្តុ គិហិបព្វជិតា ឧភោ
មមេវ អតិវសា អស្សុ កិច្ចាកិច្ចេសុ កិស្មិចិ
ឥតិ ពាលស្ស សង្កប្បោ ឥច្ឆា មានោ ច វឌ្ឍតិ ។

ភិក្ខុពាល រមែងប្រាថ្នានូវសេចក្តីសរសើរ ដែលមិនមាន(ក្នុងខ្លួន)ផង នូវការធ្វើ ក្នុងខាងមុខ គឺជាប្រមុខ ក្នុងពួកភិក្ខុផង នូវភាពជាឥស្សរៈ ក្នុងអាវាសទាំងឡាយផង នូវការបូជាទាំងឡាយ ក្នុងត្រកូលនៃជនទាំងឡាយដទៃផង ។

ភិក្ខុពាល តែងមានសេចក្តីត្រិះរិះថា គ្រហស្ថ និង បព្វជិត ទាំង ២ពួក ចូរសំគាល់នូវកិច្ចដែលមនុស្សដទៃធ្វើហើយ ជាកិច្ចរបស់អញវិញ អំណាចដ៏ក្រៃលែងរបស់អញ ចូរមានក្នុងកិច្ចតូច ធំ ណា ៗ មួយ (កាលបើយ៉ាងនេះ) ឫស្យា និង មានះ រមែងចម្រើន ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធ "ព្រះសុធម្មត្ថេរ") ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ តាំងនៅក្នុងឱវាទដែលព្រះសាស្តាប្រទានហើយ អស់កាល ២_៣ ថ្ងៃប៉ុណ្ណោះ ព្រះសុធម្មត្ថេរ ក៏បានសម្រេចព្រះអរហត្ត មួយអន្លើដោយបដិសម្ភិទា ។

៧៥.. អញ្ញា ហិ លាភូបនិសា អញ្ញា និព្វានគាមិនី
ឯវមេតំ អភិញ្ញាយ ភិក្ខុ ពុទ្ធស្ស សាវកោ

សក្ការំ នាភិនន្ទេយ្យ វិវេកមនុព្រូហយេ ។

បដិបទា អាស្រ័យនូវលាភផ្សេង, **បដិបទា** ជាដំណើរទៅកាន់ព្រះនិព្វានផ្សេង ភិក្ខុជាសាវ័ករបស់ព្រះពុទ្ធ ដឹងច្បាស់នូវហេតុនុ៎ះយ៉ាងនេះហើយ មិនគួរត្រេកអរចំពោះសក្ការៈឡើយ គប្បីញុំាងវិវេកឱ្យចម្រើនដោយលំដាប់ ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្ដែងនៅវត្តជេតពន "**ជេតវនារាម**" ប្រារព្ធ "**ព្រះវនវាសីតិស្សត្ថេរ**" អ្នកមានប្រក្រតីនៅក្នុងព្រៃ) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

(ចប់ **ពាលវគ្គ** ទី ៥ = មាន **១៦** គាថា)

ជំពូកទី ៦

បណ្ឌិតវគ្គ

(Paṇḍita Vagga)

The Wise

(Versets sur le Sage)

(មាន ១៤ គាថា)

(ពី គាថា ទី ៧៦ ➩ ដល់ គាថា ទី ៨៩)

៧៦.. និធីនំវ បវត្តារំ យំ បស្សេ វជ្ជទស្សិនំ
និគ្គយ្ហវាទឹ មេធាវឹ តាទិសំ បណ្ឌិតំ ភជេ
តាទិសំ ភជមានស្ស សេយ្យោ ហោតិ ន បាបិយោ ។

បុគ្គលគួរឃើញនូវអ្នកប្រាជ្ញណា ដែលជាអ្នកពោលសង្កត់សង្កិនចង្អុលប្រាប់ទោស ថាដូចជាបុគ្គលអ្នកប្រាប់កំណប់ទ្រព្យឱ្យដូច្នោះ គួរគប់អ្នកប្រាជ្ញបែបនោះ (ព្រោះថា) កាលបុគ្គល គប់អ្នកប្រាជ្ញបែបនោះហើយ រមែងមានសេចក្តីគាប់ប្រសើរ ឥតមានទោសដ៏លាមកឡើយ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធ "ព្រះរាធត្ថេរ") ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

៧៧.. ឱវទេយ្យា នុសាសេយ្យ អសព្ភា ច និវារយេ
សតំ ហិ សោ បិយោ ហោតិ អសតំ ហោតិ អប្បិយោ ។

បណ្ឌិតគួរទូន្មានប្រៀនប្រដៅ គួរហាមឃាត់នូវជនទាំងឡាយចាកអំពើអសប្បុរស បណ្ឌិតនោះ រមែងជាទីស្រឡាញ់របស់សប្បុរសតែម្យ៉ាង មិនជាទីស្រឡាញ់នៃអសប្បុរសឡើយ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធភិក្ខុ "អស្សជិ និង បុនព្វសុកៈ") ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

៧៨.. ន ភជេ បាបកេ មិត្តេ ន ភជេ បុរិសាធមេ
ភជេថ មិត្តេ កល្យាណេ ភជេថ បុរិសុត្តមេ ។

បុគ្គល មិនគួរគប់មិត្តអាក្រក់ មិនគួរគប់បុរសថោកទាប គួរគប់តែមិត្តដែលល្អ គួរគប់តែបុរសជាន់ខ្ពស់ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្ដែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធព្រះថេរៈឈ្មោះ "ឆន្នៈ") ។ ☞ ព្រះឆន្នត្ថេរ បំពេញវត្តដោយប្រពៃ អស់កាលមិនយូរ ក៏បានសម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ ។

៧៩.. ធម្មប្បីតិ សុខំ សេតិ វិប្បសន្នេន ចេតសា
អរិយប្បវេទិតេ ធម្មេ សទា រមតិ បណ្ឌិតោ ។

បណ្ឌិត ដែលមានសេចក្ដីឆ្អែតក្នុងធម៌ មានចិត្តជ្រះថ្លាហើយ រមែងដេកជាសុខ រមែងត្រេកអរ ក្នុងធម៌ដែលព្រះអរិយៈ ប្រកាសទុកហើយគ្រប់ពេល ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្ដែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធ "ព្រះមហាកប្បិនត្ថេរ") ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចនូវអរិយបុគ្គលភាព មានសោតាបត្តិផលជាដើម ។

៨០.. ឧទកញ្ហិ នយន្តិ នេត្តិកា
ឧសុការា នមយន្តិ តេជនំ
ទារុំ នមយន្តិ តច្ឆកា
អត្តានំ ទមយន្តិ បណ្ឌិតា ។

ធម្មតាអ្នកបង្ហូរទឹក តែងបង្ហូរទឹកទៅ, អ្នកធ្វើព្រួញ តែងពត់ព្រួញ (ឱ្យត្រង់), អ្នកចាំងឈើ តែងចាំងឈើ, ឯបណ្ឌិតទាំងឡាយ តែងទូន្មានខ្លួន (ដូច្នោះដែរ) ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្ដែងនៅវត្តជេតពន "**ជេតវនារាម**" ប្រារព្ធ "**បណ្ឌិតសាមណេរ**") ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

៨១.. សេលោ យថា ឯកឃនោ វាតេន ន សមីរតិ
ឯវំ និន្ទាបសំសាសុ ន សមិញ្ជន្តិ បណ្ឌិតា ។

ភ្នំថ្មតាន់មិនរំភើបព្រោះខ្យល់ ដូចម្ដេចមិញ បណ្ឌិតទាំងឡាយ ក៏មិនរំភើប ព្រោះពាក្យតិះដៀល និង ពាក្យសរសើរ (ជាដើម) ដូច្នោះឯង ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្ដែងនៅវត្តជេតពន "**ជេតវនារាម**" ប្រារព្ធ "**ព្រះលកុណ្ឌកភទ្ទិយត្ថេរ**") ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចនូវអរិយបុគ្គលភាព មានសោតាបត្តិផលជាដើម ។

៨២.. យថាបិ រហទោ គម្ភីរោ វិប្បសន្នោ អនាវិលោ
ឯវំ ធម្មានិ សុត្វាន វិប្បសីទន្តិ បណ្ឌិតា ។

អន្លង់ទឹកដែលជ្រៅ រមែងថ្លាមិនល្អក់យ៉ាងណា បណ្ឌិតទាំងឡាយ បើបានស្ដាប់ធម៌ទេសនាហើយ រមែងជ្រះថ្លាស៊ប់ស្ងួន យ៉ាងនោះ ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្ដែងនៅវត្តជេតពន "**ជេតវនារាម**" ប្រារព្ធ "**មាតា របស់នាង កាណា**") ។ ព្រះសាស្ដា បានត្រាស់អនុបុព្វីកថាដល់នាង

នាងកាណា បានសម្រេចសោតាបត្តិផល ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចនូវអរិយបុគ្គលភាព មានសោតាបត្តិផលជាដើម ។

៨៣.. **សព្វត្ថ វេ សប្បុរិសា វជន្តិ**
ន កាមកាមា លបយន្តិ សន្តោ
សុខេន ផុដ្ឋា អថ វា ទុខេន
ន ឧច្ចាវចំ បណ្ឌិតា ទស្សយន្តិ ។

ពួកសប្បុរស តែងលះ (ឆន្ទរាគៈ) ក្នុងធម៌ទាំងពួង ពួកលោកអ្នកស្ងប់ រមែងមិនរអែរអូរ ព្រោះសេចក្តីប្រាថ្នាក្នុងកាម ពួកបណ្ឌិត បើសេចក្តីសុខ ឬ ទុក្ខ ពាល់ត្រូវហើយ រមែងមិនសម្តែងអាការឡើងចុះឡើយ ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "**ជេតវនារាម**" ប្រារព្ធ "**ភិក្ខុ ៥០០ រូប**") ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

៨៤.. **ន អត្តហេតុ ន បរស្ស ហេតុ**
ន បុត្តមិច្ឆេ ន ធនំ ន រដ្ឋំ
ន ឥច្ឆេយ្យ អធម្មេន សមិទ្ធិមត្តនោ
ស សីលវា បញ្ញវា ធម្មិកោ សិយា ។

បណ្ឌិតមិនគួរធ្វើអាក្រក់ ព្រោះហេតុនៃខ្លួន មិនគួរធ្វើអាក្រក់ ព្រោះហេតុនៃអ្នកដទៃ មិនគួរប្រាថ្នាកូន មិនគួរប្រាថ្នាទ្រព្យ មិនគួរប្រាថ្នារដ្ឋ មិនគួរប្រាថ្នាសិទ្ធិដើម្បីខ្លួន ដោយហេតុមិនមែនជាធម៌ឡើយ លោកគួរជាអ្នកមានសីល មានប្រាជ្ញាប្រកបដោយធម៌ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធ "ព្រះធម្មិកត្ថេរ") ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

៨៥.. **អប្បកា តេ មនុស្សេសុ យេ ជនា បារគាមិនោ**
អថាយំ ឥតរា បជា តីរមេវានុធាវតិ ។
៨៦.. **យេ ច ខោ សម្មទក្ខាតេ ធម្មេ ធម្មានុវត្តិនោ**
តេ ជនា បារមេស្សន្តិ មច្ចុធេយ្យំ សុទុត្តរំ ។

បណ្ដាមនុស្សទាំងឡាយ ពួកជនណា ដែលឆ្លងដល់ត្រើយ គឺ **ព្រះនិព្វាន** ពួកជននោះ មានប្រមាណតិច ចំណែកពួកសត្វក្រៅនេះ រមែងស្ទុះទៅកាន់ត្រើយ (គឺ **សក្កាយទិដ្ឋិ**)។

ជនទាំងឡាយណា ប្រព្រឹត្តតាមធម៌ក្នុងធម៌ ដែល**ព្រះតថាគត**ទ្រង់ត្រាស់សម្តែងទុកហើយដោយប្រពៃ ជនទាំងនោះនឹងឆ្លងនូវលំនៅនៃមច្ចុ ដែលមិនងាយឆ្លងបាន ហើយដល់នូវ **ព្រះនិព្វាន** ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធ "ការស្តាប់ធម៌") ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

៨៧.. **កណ្ហំ ធម្មំ វិប្បហាយ សុក្កំ ភាវេថ បណ្ឌិតោ**
ឱកា អនោកមាគម្ម វិវេកេ យត្ថ ទូរមំ ។
៨៨.. **តត្រាភិរតិមិច្ឆេយ្យ ហិត្វា កាមេ អកិញ្ចនោ**
បរិយោទបេយ្យ អត្តានំ ចិត្តក្លេសេហិ បណ្ឌិតោ ។

៨៩.. **យេសំ សម្ពោធិយង្គេសុ　　សម្មា ចិត្តំ សុភាវិតំ**
អាទានប្បដិនិស្សគ្គេ　　អនុបាទាយ យេ រតា
ខីណាសវា ជុតិមន្តោ　　តេ លោកេ បរិនិព្វុតា ។

បណ្ឌិត គួរលះបង់ធម៌ខ្មៅ[១] ចេញ ញុំាំងធម៌ស[២] ឱ្យចម្រើនឡើង (ដោយវិធី)ចេញចាកអាល័យ គឺកាមគុណ ហើយឈមទៅរកព្រះនិព្វាន ជាធម្មជាតមិនមានអាល័យ, គប្បីលះបង់កាមទាំងឡាយចេញ ជាអ្នកមិនមានកង្វល់ ប្រាថ្នានូវសេចក្ដីត្រេកអរ ក្នុងវិវេក ដែលពួកសត្វត្រេកអរបាន ដោយក្រនោះ, បណ្ឌិតគួរញុំាំងខ្លួនឱ្យផូរផង់ ចាកគ្រឿងសៅហ្មងចិត្ត ។

ចិត្តដែលបណ្ឌិតទាំងឡាយណា បានអប់រំល្អហើយ ក្នុងអង្គនៃធម៌ជាគ្រឿងត្រាស់ដឹងទាំងឡាយ ឬ បណ្ឌិតទាំងឡាយណា មិនប្រកាន់មាំ ត្រេកអរតែក្នុងការលះនូវសេចក្ដីប្រកាន់មាំ បណ្ឌិតទាំងឡាយនោះ ៗ រមែងជាអ្នកអស់អាសវៈ មានសេចក្ដីរុងរឿង បរិនិព្វាន ក្នុងលោក ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្ដែងនៅវត្តជេតពន "**ជេតវនារាម**" ប្រារព្ធ "**ភិក្ខុអាគន្តុកៈ ៥០០ រូប**") ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

(ចប់ **បណ្ឌិតវគ្គ** ទី ៦ = មាន **១៤** គាថា)

---

[១] អកុសលធម៌ មានកាយទុច្ចរិតជាដើម ។
[២] កុសលធម៌ មានកាយសុចរិតជាដើម ។ **អដ្ឋកថា** ។

ជំពូកទី ៧

អរហន្តវគ្គ

(Arahanta Vagga)

The Worthy

(Versets sur l'Arahant)

(មាន ១០ គាថា)

(ពី គាថា ទី ៩០ ➩ ដល់ គាថា ទី ៩៩)

៩០.. **គតទ្ធិនោ វិសោកស្ស វិប្បមុត្តស្ស សព្វធិ**
សព្វគន្ថប្បហីនស្ស បរិឡាហោ ន វិជ្ជតិ ។

សេចក្ដីក្ដៅក្រហាយ[១] រមែងមិនមានដល់លោកអ្នក មានផ្លូវឆ្ងាយដើរដល់[២]ហើយ មិនមានសេចក្ដីសោក រួចស្រឡះចាកធម៌ទាំងពួង (មានខន្ធជាដើម) មានកិលេសជាគ្រឿងចាក់ស្រេះទាំងពួងលះបង់ហើយ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្ដែងនៅវត្តជេតពន "**ជេតវនារាម**" ប្រារព្ធ "**ពេទ្យជីវក**") ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

៩១.. **ឧយ្យុញ្ជន្តិ សតីមន្តោ ន និកេតេ រមន្តិ តេ**
ហំសាវ បល្លលំ ហិត្វា ឱកមោកំ ជហន្តិ តេ ។

ព្រះខីណាស្រពទាំងឡាយ មានស្មារតី រមែងខ្វល់ខ្វាយ[១] រមែងត្រេកអរ ក្នុងទីនៅអាស្រ័យ លោកលះបង់ចោលស្រឡះ នូវអាល័យទាំងអស់ ដូចហង្សលះបង់ភក់ ហើរទៅ ដូច្នោះ ។

---

[១] សេចក្ដីក្ដៅក្រហាយ មាន ២ យ៉ាង គឺក្ដៅក្រហាយកាយ១ ក្ដៅក្រហាយចិត្ត១, ព្រះខីណាស្រព នៅមានសេចក្ដីក្ដៅក្រហាយកាយ ព្រោះអំណាចកំដៅថ្ងៃ ឬ ត្រជាក់ជាដើម តែក្ដៅក្រហាយក្នុងចិត្ត មិនមាន ។ ក្នុងទីនេះសំដៅសេចក្ដីក្ដៅក្រហាយក្នុងចិត្ត ។

[២] ផ្លូវឆ្ងាយក្នុងទីនេះ សំដៅយកវដ្ដៈ ដែលហៅថា **វដ្ដទុក្ខ** ។ ពួកសត្វដែលជាប់ក្នុងវដ្ដៈ នៅក្នុងវដ្ដៈដរាបណា ឈ្មោះថាជាអ្នកដើរផ្លូវឆ្ងាយដរាបនោះ, ព្រះសោតាបន្នបុគ្គលជា-ដើម ក៏ហៅថាអ្នកដើរផ្លូវឆ្ងាយដែរ ព្រោះមិនទាន់អស់វដ្ដៈ តែព្រះខីណាស្រព លោកធ្វើវដ្ដៈឱ្យអស់ហើយ ឱ្យឈ្មោះថា ជាអ្នកដ៏មានផ្លូវឆ្ងាយដើរដល់ហើយ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្ដែងនៅវត្តវេឡុវ័ន "វេឡុវនារាម" ប្រារព្ធ "ព្រះមហាកស្សបត្ថេរ") ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

៩២.. យេសំ សន្និចយោ នត្ថិ យេ បរិញ្ញាតភោជនា
សុញ្ញតោ អនិមិត្តោ ច វិមោក្ខោ យេស គោចរោ
អាកាសេវ សកុន្តានំ គតិ តេសំ ទុរន្នយា ។

ពួកជនណា មិនមានសេចក្ដីសន្សំ, ពួកជនណា កំណត់ដឹងភោជនហើយ, ជនណា មាន **សុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ** និង **អប្បណិហិ--តវិមោក្ខ** ជាគោចរ **គតិ** គឺដំណើររបស់ពួកជននោះ ⁽⁹⁾ គេកម្រដឹងបាន ដូចដំណើរនៃពួកសត្វស្លាបឰដ៏អាកាស ដូច្នោះ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្ដែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធ "ពេឡដ្ឋសីសត្ថេរ") ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

៩៣.. យស្សាសវា បរិក្ខីណា អាហារេ ច អនិស្សិតោ
សុញ្ញតោ អនិមិត្តោ ច វិមោក្ខោ យស្ស គោចរោ
អាកាសេវ សកុន្តានំ បទន្តស្ស ទុរន្នយំ ។

---

[9] ខ្វល់ខ្វាយក្នុងគុណដែលខ្លួនបានហើយ ឬក្នុងឈាន និង វិបស្សនា ដោយកិច្ច គឺរំពឹង ចូល ចេញ អធិដ្ឋាន ឬ ពិចារណាមិនមានសម្រាក ។ **អដ្ឋកថា** ។ (ក្នុងទំព័រ ៦០) ។

ជនណា អស់អាសវៈហើយ ទាំងមិនអាស្រ័យ (តណ្ហា និង ទិដ្ឋិ) ក្នុងអាហារ, ជនណា មានសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ និង អប្បណិហិត-វិមោក្ខ ជាគោចរ ដំណើររបស់ជននោះ គេកម្រដឹងបាន ដូចដំណើរនៃពួកសត្វស្លាបឰដ៏អាកាស ដូច្នោះ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តវេឡុវ័ន "វេឡុវនារាម" ប្រារព្ធ "ព្រះអនុរុទ្ធត្ថេរ") ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

៩៤.. **យស្សិន្ទ្រិយានិ សមថង្គតានិ**
អស្សា យថា សារថិនា សុទន្តា
បហីនមានស្ស អនាសវស្ស
ទេវាបិ តស្ស បិហយន្តិ តាទិនោ ។

ឥន្ទ្រិយទាំងឡាយ របស់អ្នកណា ដល់នូវការស្ងប់រម្ងាប់ ដូចសេះដែលនាយសារថី ហ្វឹកហ្វឺនរាបហើយ សូម្បីទេវតា និង មនុស្សទាំងឡាយក៏ស្រឡាញ់អ្នកនោះឯង ដែលមាន មានះ លះបង់ហើយ មិនមានអាសវៈ ជាបុគ្គលមានចិត្តនឹងធឹង មិនញាប់ញ័រ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅ "វត្តបុព្វារាម" ប្រារព្ធ "ព្រះមហាកច្ចាយនត្ថេរ") ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើនដែលមកប្រជុំគ្នាក្នុងទីនោះ បានសម្រេចនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

៩៥.. **បឋវីសមោ នោ វិរុជ្ឈតិ**

ឥន្ទខីលូបមោ តាទិ សុព្វតោ

រហទោវ អបេតកទ្ទមោ

សំសារា ន ភវន្តិ តាទិនោ ។

ភិក្ខុមានចិត្តដូចផែនដី មិនក្រោធ មានវត្តល្អ មានចិត្តនឹងធឹងដូចសសរគោល មានចិត្តថ្លា ដូចអន្លង់ប្រាសចាកភក់ សង្សារទាំងឡាយរបស់ភិក្ខុបែបនោះ រមែងមិនមាន ។

☸ (<u>**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែងនៅ "**វត្តជេតពន**"</u>
<u>ប្រារព្ធ "**ព្រះសារីបុត្តត្ថេរ**"</u>) ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុ ៩.០០០
រូប បានសម្រេច**ព្រះអរហត្ត** មួយអន្លើដោយ **បដិសម្ភិទា** ទាំងឡាយ ។

៩៦.. **សន្តំ តស្ស មនំ ហោតិ**

សន្តា វាចា ច កម្ម ច

សម្មទញ្ញា វិមុត្តស្ស

ឧបសន្តស្ស តាទិនោ ។

ចិត្តស្ងប់ វាចាស្ងប់ និង កាយកម្មស្ងប់ រមែងមាន ដល់លោកដែលដឹងដោយប្រពៃ ផុតស្រឡះ (ចាករាគាទិក្កិលេស) ជាអ្នកស្ងប់រម្ងាប់ ដូច្នោះ ។

☸ (<u>**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែងនៅ "**វត្តជេតពន**"</u>
<u>ប្រារព្ធ **សាមណេរ** របស់ **ព្រះតិស្សត្ថេរ**</u>) ។
☞ ក្នុងកាលចប់ព្រះធម្មទេសនា **ព្រះតិស្សៈ** អ្នកក្រុងកោសម្ពី
បានសម្រេច**ព្រះអរហត្ត** មួយអន្លើដោយ **បដិសម្ភិទា** ទាំងឡាយ ។

៩៧.. អស្សទ្ធោ អកតញ្ញូ ច

សន្ធិច្ឆេទោ ច យោ នរោ

ហតាវកាសោ វន្តាសោ

ស វេ ឧត្តមបោរិសោ ។

នរជនណា មិនជឿអ្នកដទៃផង ស្គាល់ព្រះនិព្វានផង កាត់នូវគ្រឿងត គឺ វដ្តៈ ផង មានឱកាសកំចាត់បង់ហើយផង មានសេចក្តីប្រាថ្នាខ្ជាក់ចោលហើយផង នរជននោះជា **ឧត្តមបុរស** ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅ "វត្តជេតពន" ប្រារព្ធ "ព្រះសារីបុត្តត្ថេរ") ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុប្រមាណ ៣០ រូប ដែលនៅព្រៃ ជាវត្តនោះ បានសម្រេច **ព្រះអរហត្ត** មួយអន្លើដោយ **បដិសម្ភិទា** ទាំងឡាយ ។

៩៨.. គាមេ វា យទិ វារញ្ញេ

និន្នេ វា យទិ វា ថលេ

យត្ថ អរហន្តោ វិហរន្តិ

តំ ភូមិរាមណេយ្យកំ ។

ព្រះអរហន្តទាំងឡាយ នៅក្នុងទីណា ទោះជាស្រុកក្តី ព្រៃក្តី ទីទាបក្តី ទីទួលក្តី ទីនោះឯង ជាភូមិ គួរត្រេកអរ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅ "វត្តជេតពន" ប្រារព្ធ "ព្រះខទិរវនិយរេវតត្ថេរ") ។

☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

៩៩.. រមណីយានិ អរញ្ញានិ

យត្ថ ន រមតី ជនោ

វីតរាគា រមេស្សន្តិ

ន តេ កាមគវេសិនោ ។

ជន (អ្នកស្វែងរកកាម) រមែងមិនត្រេកអរក្នុងព្រៃដែលគួររីករាយទេ ព្រះខីណាស្រពដែលមានរាគៈទៅប្រាសហើយ ទើបត្រេកអរក្នុងព្រៃនោះ ព្រោះលោកជាអ្នក មិនស្វែងរកកាម ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្ដែងនៅ "**វត្តជេតពន**" ប្រារព្ធ **ស្ត្រីម្នាក់**)

☞ ក្នុងវេលាចប់ព្រះធម្មទេសនា ភិក្ខុអ្នកមានប្រក្រតីត្រាច់ទៅ ដើម្បីបិណ្ឌបាតជាវត្តមួយរូប រៀនកម្មដ្ឋានក្នុងសំណាក់របស់ព្រះសាស្ដា បានសម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ ។

(ចប់ **អរហន្តវគ្គ** ទី ៧ = មាន ១០ គាថា)

ជំពូកទី ៨

សហស្សវគ្គ

(Sahassa Vagga)

Thousands

(Versets sur les Milliers)

(មាន ១៦ គាថា)

(ពី គាថា ទី ១០០ ↳ ដល់ គាថា ទី ១១៥)

១០០.. សហស្សមបិ ចេ វាចា អនត្ថបទសញ្ហិតា
ឯកំ អត្ថបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។

បើវាចា សូម្បីមួយពាន់ម៉ាត់ ជាវាចាប្រកបដោយបទឥតប្រយោជន៍ វាចានោះ ពុំប្រសើរឡើយ, អ្នកណា ស្តាប់បទមានប្រយោជន៍ណាហើយ រមែងស្ងប់រម្ងាប់បាន បទមានប្រយោជន៍នោះ សូម្បីតែមួយបទ ក៏ឈ្មោះថា ប្រសើរជាង ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តវេឡុវ័ន "វេឡុវនារាម" ប្រារព្ធបុរសអ្នកសម្លាប់ចោរឈ្មោះ "តម្ពទាឋិក") ។
☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

១០១.. សហស្សមបិ ចេ គាថា អនត្ថបទសញ្ហិតា
ឯកំ គាថាបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។

បើគាថា សូម្បីមួយពាន់ ជាគាថា ប្រកបដោយបទឥតប្រយោជន៍ គាថានោះ ពុំប្រសើរឡើយ, អ្នកណា ស្តាប់បទនៃគាថាណាហើយ រមែងស្ងប់រម្ងាប់បាន បទនៃគាថានោះ សូម្បីតែមួយបទ ក៏ឈ្មោះថា ប្រសើរជាង ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធ "ព្រះពាហិយទារុចីរិយត្ថេរ") ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ទារុចីរិយៈ បានសម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទា ៤ ទាំងដែលខ្លួននៅជាគ្រហស្ថ ឯតទគ្គផ្នែកខាងត្រាស់ដឹងឆាប់រហ័ស "ខិប្បាភិញ្ញា"។

១០២.. យោ ច គាថា សតំ ភាសេ អនត្ថបទសញ្ហិតា
ឯកំ ធម្មបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។
១០៣.. យោ សហស្សំ សហស្សេន សង្គាមេ មានុសេ ជិនេ
ឯកញ្ច ជេយ្យមត្តានំ ស វេ សង្គាមជុត្តមោ ។

អ្នកណា គប្បីពោលគាថាមួយរយ ជាគាថា ប្រកបដោយបទឥតប្រយោជន៍ គាថាដែលអ្នកនោះពោលហើយនោះពុំប្រសើរឡើយ អ្នកណាស្តាប់បទនៃធម៌ហើយ រមែងស្ងប់រម្ងាប់បាន បទនៃធម៌នោះ សូម្បីតែមួយបទក៏ឈ្មោះថាប្រសើរជាង ។

អ្នកណាគប្បីឈ្នះពួកមនុស្សក្នុងសង្គ្រាម អស់មួយពាន់ ៧ ដង គឺមួយលាន ចំណែកអ្នកណា ឈ្នះខ្លួនឯងម្នាក់ឯងបាន អ្នកនោះឈ្មោះថា ជាមនុស្សខ្ពង់ខ្ពស់ ជាងអ្នកដែលឈ្នះ ក្នុងសង្គ្រាមនោះ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធ "ព្រះកុណ្ឌលកេសីថេរី") ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

១០៤.. អត្តា ហវេ ជិតំ សេយ្យោ យា ចាយំ ឥតរា បជា
អត្តទន្តស្ស បោសស្ស និច្ចំ សញ្ញតចារិនោ ។
១០៥.. នេវ ទេវោ ន គន្ធព្វោ ន មារោ សហ ព្រហ្មុនា
ជិតំ អបជិតំ កយិរា តថារូបស្ស ជន្តុនោ ។

ខ្លួនឯងដែលឈ្នះហើយ ប្រសើរជាង ចំណែកពួកសត្វក្រៅពីនេះ ដែលគេឈ្នះហើយ មិនប្រសើរឡើយ, កាលបើបុរសមានខ្លួនទូន្មានហើយ ជាអ្នកប្រព្រឹត្តសង្រួមជានិច្ច ទេវតា គន្ធព្វ មារ ព្រមទាំងព្រហ្ម មិនគប្បីធ្វើនូវជំនះ របស់សត្វមានសភាពដូច្នោះ ឱ្យត្រឡប់ចាញ់វិញបានឡើយ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធ "អនត្ថបុច្ឆកព្រាហ្មណ៍") ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

១០៦.. **មាសេ មាសេ សហស្សេន យោ យជេថ សតំ សមំ**
ឯកញ្ច ភាវិតត្តានំ មុហុត្តមបិ បូជយេ
សាយេវ បូជនា សេយ្យោ យញ្ចេ វស្សសតំ ហុតំ ។

អ្នកណាបូជា (**លោកិយមហាជន**) ដោយទ្រព្យមួយពាន់ រាល់ ១ ខែ អស់មួយរយឆ្នាំគត់, ចំណែកអ្នកណា គប្បីបូជាចំពោះបុគ្គល ដែលមានខ្លួនអប់រំហើយ តែ ១ នាក់ សូម្បីតែមួយរំពេច ការបូជានោះឯង ប្រសើរជាងការបូជារបស់អ្នកដែលបូជាអស់ ១រយឆ្នាំនោះ ការបូជាអស់១០០ឆ្នាំ មិនប្រសើរឡើយ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធ "សារីបុត្តមាតុលព្រាហ្មណ៍" ព្រាហ្មណ៍ជាឪពុកមារ របស់ព្រះសារីបុត្ត) ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ព្រាហ្មណ៍នោះ បានសម្រេចសោតាបត្តិផល, ជនជាច្រើនបានសម្រេចនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមផងដែរ ។

១០៧.. យោ ច វស្សសតំ ជន្តុ អគ្គឹ បរិចរេ វនេ
ឯកញ្ច ភាវិតត្តានំ មុហុត្តមបិ បូជយេ
សាយេវ បូជនា សេយ្យោ យញ្ចេ វស្សសតំ ហុតំ ។

ជនណា បម្រើភ្លើងក្នុងព្រៃអស់ ១០០ ឆ្នាំ, ចំណែកអ្នកណាបូជាលោកដែលមានខ្លួនអប់រំហើយ តែ ១ នាក់ សូម្បីមួយរំពេច ការបូជានោះឯង ប្រសើរជាងការបូជារបស់ជននោះ ការបូជាអស់ ១០០ ឆ្នាំ មិនប្រសើរឡើយ ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្ដែងនៅវត្តវេឡុវ័ន "**វេឡុវនារាម**" ប្រារព្ធ **ព្រាហ្មណ៍**ជាក្មួយ របស់**ព្រះសារីបុត្តត្ថេរ**) ។

☞ ក្នុងវេលាចប់ព្រះធម្មទេសនា ព្រាហ្មណ៍នោះ បានសម្រេចសោតាបត្តិផល, ជនជាច្រើនបានសម្រេចនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមផងដែរ ។

១០៨.. យង្កិញ្ចិ យិដ្ឋំ វ ហុតំ វ លោកេ [១]
សំវច្ឆរំ យជេថ បុញ្ញបេក្ខោ
សព្វំបិ តំ ន ចតុភាគមេតិ
អភិវាទនា ឧជ្ជុគតេសុ សេយ្យោ ។

បុគ្គលអ្នកប្រាថ្នាបុណ្យ គប្បីបូជាគ្រឿងសក្ការបូជាធំតូចណាមួយក្នុងលោក អស់មួយឆ្នាំ ការបូជាទាំងអស់នោះឯង រមែងមិនដល់នូវចំណែកទី ៤ នៃការអភិវាទន៍ ចំពោះលោកទាំងឡាយ ដែលប្រព្រឹត្តត្រង់ហើយ ប្រសើរជាង ។

---

[១] ក្នុង អដ្ឋកថា លោកសរសេរយ៉ាងនេះ យំ កិញ្ចិ យិដ្ឋញ្ច ហុតញ្ច លោកេ ... សព្វម្បិ តំ ន ចតុភាគមេតិ ....

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែងនៅ "**វត្តទេវឡូវ័ន**"
ប្រារព្ធ **ព្រាហ្មណ៍** ជាសម្លាញ់របស់ **ព្រះសារីបុត្តត្ថេរ**) ។
☞ ក្នុងវេលាចប់ព្រះធម្មទេសនា ព្រាហ្មណ៍នោះ បានសម្រេចសោតាបត្តិផល, ជនជាច្រើនបានសម្រេចនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមផងដែរ ។

១០៩.. អភិវាទនសីលិស្ស   និច្ចំ វុឌ្ឍាបចាយិនោ
ចត្តារោ ធម្មា វឌ្ឍន្តិ   អាយុ វណ្ណោ សុខំ ពលំ ។

ធម៌ ៤ ប្រការ គឺ អាយុ១ វណ្ណៈ១ សុខៈ១ ពលៈ១ រមែងចម្រើនដល់អ្នកដែលមានសេចក្តីឱនកាយថ្វាយបង្គំ ជាប្រក្រតី មានសេចក្តីកោតក្រែងដល់បុគ្គលដែលចម្រើនជាងខ្លួន អស់កាលជានិច្ច ។

☸ (**ព្រះពុទ្ធគាថា**នេះទ្រង់ត្រាស់សម្តែងកាលទ្រង់គង់អាស្រ័យនៅទីឃលម្ពិកនគរ
ប្រារព្ធ **អាយុវឌ្ឍនកុមារ**) ។
☞ ក្នុងវេលាចប់ព្រះធម្មទេសនា អាយុវឌ្ឍនកុមារ តាំងនៅក្នុងសោតាបត្តិផល មួយអន្លើដោយឧបាសក ៥០០ រូប ។ ជនដទៃជាច្រើនទៀត ក៏បានសម្រេចនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ផងដែរ ។

១១០.. យោ ច វស្សសតំ ជីវេ   ទុស្សីលោ អសមាហិតោ
ឯកាហំ ជីវិតំ សេយ្យោ   សីលវន្តស្ស ឈាយិនោ ។

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សទ្រុស្តសីល មានចិត្តមិនបានតម្កល់ខ្ជាប់, ការរស់នៅតែមួយថ្ងៃ របស់លោកដែលមានសីល មានការពិនិត្យពិចារណា ជាប្រក្រតី ប្រសើរជាង ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធ សង្កិច្ចសាមណេរ) ។

☞ ក្នុងវេលាចប់ព្រះធម្មទេសនា ភិក្ខុ ៥០០ រូប បានសម្រេច អរហត្ត ព្រមទាំង បដិសម្ភិទា ទាំងឡាយ ។

១១១.. យោ ច វស្សសតំ ជីវេ ទុប្បញ្ញោ អសមាហិតោ
ឯកាហំ ជីវិតំ សេយ្យោ បញ្ញវន្តស្ស ឈាយិនោ ។

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សមិនមានប្រាជ្ញា មានចិត្តមិនបានតម្កល់ខ្ជាប់, ការរស់នៅតែមួយថ្ងៃ របស់លោកដែលមានប្រាជ្ញា មានការពិនិត្យពិចារណា ជាប្រក្រតី ប្រសើរជាង ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធ ខាណុកោណ្ឌញ្ញត្ថេរ) ។

☞ ក្នុងវេលាចប់ព្រះធម្មទេសនា ភិក្ខុ ៥០០ រូប បានសម្រេច អរហត្ត ព្រមទាំង បដិសម្ភិទា ទាំងឡាយ ។

១១២.. យោ ច វស្សសតំ ជីវេ កុសីតោ ហីនវីរិយោ
ឯកាហំ ជីវិតំ សេយ្យោ វីរិយំ អារភតោ ទឡ្ហំ ។

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សមានចិត្តងុលងប់ ក្នុងអកុសលវិតក្កៈ មានព្យាយាមថោកថយ, ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោក ដែលប្រារព្ធសេចក្តីព្យាយាមមាំមួន ប្រសើរជាង ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធ ព្រះសប្បទាសត្ថេរ) ។

☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេច **អរិយផល** ទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

១១៣.. យោ ច វស្សសតំ ជីវេ អបស្សំ ឧទយព្វយំ
ឯកាហំ ជីវិតំ សេយ្យោ បស្សតោ ឧទយព្វយំ ។

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនឃើញការកើតឡើង និង ការវិនាសទៅ, ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកដែលឃើញការកើតឡើង និង ការវិនាសទៅ ប្រសើរជាង ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធ ព្រះនាងបដាចារាថេរី) ។

☞ ក្នុងវេលាចប់ព្រះធម្មទេសនា **នាងបដាចារា** បានសម្រេច **ព្រះអរហត្ត** ព្រមទាំង **បដិសម្ភិទា** ទាំងឡាយ ។

១១៤.. យោ ច វស្សសតំ ជីវេ អបស្សំ អមតំ បទំ
ឯកាហំ ជីវិតំ សេយ្យោ បស្សតោ អមតំ បទំ ។

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនឃើញផ្លូវព្រះនិព្វាន, ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកអ្នកឃើញផ្លូវព្រះនិព្វាន ប្រសើរជាង ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "**ជេតវនារាម**" ប្រារព្ធ **នាងកិសាគោតមី**) ។
☞ ក្នុងវេលាចប់ព្រះធម្មទេសនា **នាងកិសាគោតមី** បានតាំងនៅក្នុង **ព្រះអរហត្ត** ព្រមទាំង **បដិសម្ភិទា** ទាំងឡាយ ។

១១៥.. **យោ ច វស្សសតំ ជីវេ អបស្សំ ធម្មមុត្តមំ**
ឯកាហំ ជីវិតំ សេយ្យោ បស្សតោ ធម្មមុត្តមំ ។

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនឃើញធម៌ដ៏ខ្ពង់ខ្ពស់, ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកអ្នកឃើញធម៌ដ៏ខ្ពង់ខ្ពស់ ប្រសើរជាង ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "**ជេតវនារាម**" ប្រារព្ធ **នាងពហុបុត្តិកាថេរី**) ។
☞ ក្នុងវេលាចប់ព្រះធម្មទេសនា **ពហុបុត្តិកាថេរី** បានតាំងនៅក្នុង **ព្រះអរហត្ត** ព្រមទាំង **បដិសម្ភិទា** ទាំងឡាយ ។

(ចប់ **សហស្សវគ្គ** ទី ៨ = មាន **១៦** គាថា)

ជំពូកទី ៩

បាបវគ្គ

(Pāpa Vagga)

Evil

(Versets sur le Mal)

(មាន ១៣ គាថា)

(ពី គាថា ទី ១១៦ ➪ ដល់ គាថា ទី ១២៨)

១១៦.. អភិត្ថរេថ កល្យាណេ បាបា ចិត្តំ និវារយេ
ទន្ធំ ហិ ករតោ បុញ្ញំ បាបស្មឹ រមតី មនោ ។

បុគ្គលគួរប្រញាប់ធ្វើអំពើល្អ គួរឃាត់ចិត្តចាកបាប ព្រោះថា កាលបើបុគ្គលធ្វើបុណ្យយឺតយូរ ចិត្តរមែងត្រេកអរក្នុងបាប ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធ ចូឡេកសាដកព្រាហ្មណ៍) ។
☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេច អរិយផល ទាំងឡាយ មាន សោតាបត្តិផល ជាដើម ។

១១៧.. បាបញ្ចេ បុរិសោ កយិរា ន នំ កយិរា បុនប្បុនំ
ន តម្ហិ ឆន្ទំ កយិរាថ ទុក្ខោ បាបស្ស ឧច្ចយោ ។

បើបុរសធ្វើបាប កុំធ្វើបាបនោះរឿយ ៗ ឡើយ កុំគប្បីធ្វើសេចក្តីពេញចិត្ត ក្នុងបាបនោះ (ព្រោះថា) ការសន្សំបាប តែងនាំសេចក្តីទុក្ខ មកឱ្យ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធ ព្រះសេយ្យសកត្ថេរៈ) ។
☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេច អរិយផល ទាំងឡាយ មាន សោតាបត្តិផល ជាដើម ។

១១៨.. បុញ្ញញ្ចេ បុរិសោ កយិរា កយិរាថេនំ បុនប្បុនំ
តម្ហិ ឆន្ទំ កយិរាថ សុខោ បុញ្ញស្ស ឧច្ចយោ ។

បើបុរសធ្វើបុណ្យ គួរធ្វើបុណ្យនោះឱ្យរឿយ ៗ គួរធ្វើសេចក្ដីពេញចិត្ត ក្នុងបុណ្យនោះ (ព្រោះថា) ការសន្សំបុណ្យ តែងនាំសេចក្ដីសុខមកឱ្យ ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្ដែងនៅវត្តជេតពន "**ជេតវនារាម**" ប្រារព្ធ **នាងលាជទេវធីតា**) ។

☞ ក្នុងវេលាចប់ព្រះធម្មទេសនា **នាងលាជទេវធីតា** បានសម្រេច **សោតាបត្តិផល** ។

១១៩.. បាបោបិ បស្សតី ភទ្រំ យាវ បាបំ ន បច្ចតិ
យទា ច បច្ចតី បាបំ អថ (បាបោ) បាបានិ បស្សតិ ។
១២០.. ភទ្រោបិ បស្សតី បាបំ យាវ ភទ្រំ ន បច្ចតិ
យទា ច បច្ចតី ភទ្រំ អថ (ភទ្រោ) ភទ្រានិ បស្សតិ។

បាបមិនទាន់ឱ្យផលត្រឹមណា មនុស្សបាប ក៏នៅឃើញតែសេចក្ដីចម្រើនត្រឹមណោះ លុះកាលណា បាបឱ្យផល មនុស្សបាប ទើបឃើញបាប ក្នុងកាលនោះ ។

អំពើល្អ (បុណ្យ) មិនទាន់ឱ្យផលត្រឹមណា មនុស្សល្អ នៅឃើញតែបាបត្រឹមណោះ លុះកាលណា អំពើល្អឱ្យផល មនុស្សល្អ ទើបឃើញល្អក្នុងកាលនោះ ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្ដែងនៅវត្តជេតពន "**ជេតវនារាម**" ប្រារព្ធ **អនាថបិណ្ឌិកសេដ្ឋី**) ។

☞ ក្នុងវេលាចប់ព្រះធម្មទេសនា **ទេវតា** មួយអង្គ បានតាំងនៅក្នុង **សោតាបត្តិផល** ព្រមទាំងបានជាប្រយោជន៍ ដល់ជនច្រើន ដែលមកប្រជុំគ្នានៅទីនោះផង ។

១២១.. មាវមញ្ញេថ បាបស្ស ន មត្តំ អាគមិស្សតិ
ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ
អាបូរតិ ពាលោ បាបស្ស ថោកំ ថោកំបិ អាចិនំ ។

បុគ្គល មិនគួរមើលងាយបាបថា មានប្រមាណតិច នឹងមិនឱ្យផល ដូច្នេះឡើយ ប្រៀបដូចក្អមទឹក រមែងពេញបានដោយដំណក់ទឹក ដែលធ្លាក់ចុះយ៉ាងណា បុគ្គលពាល កាលសន្សំបាប សូម្បីបន្តិចម្តង ៗ គង់ពេញបានដោយងាយ យ៉ាងនោះដែរ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធ ភិក្ខុមិនចេះទុកដាក់បរិក្ខារ) ។

☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេច អរិយផល ទាំងឡាយ មាន សោតាបត្តិផល ជាដើម ។

១២២.. មាវមញ្ញេថ បុញ្ញស្ស ន មត្តំ អាគមិស្សតិ
ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ
អាបូរតិ ធីរោ បុញ្ញស្ស ថោកំ ថោកំបិ អាចិនំ ។

បុគ្គល មិនគួរមើលងាយបុណ្យថា មានប្រមាណតិច នឹងមិនឱ្យផល ដូច្នេះឡើយ ប្រៀបដូចក្អមទឹក រមែងពេញបានដោយដំណក់ទឹក ដែលធ្លាក់ចុះយ៉ាងណា អ្នកមានប្រាជ្ញា កាលសន្សំបុណ្យបន្តិចម្តង ៗ គង់ពេញបានដោយបុណ្យ យ៉ាងនោះ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធសេដ្ឋីឈ្មោះ ពិឡាលបទកៈ) ។

☞ ក្នុងវេលាចប់ព្រះធម្មទេសនា សេដ្ឋីនោះ បានសម្រេច **សោតាបត្តិផល** ព្រះធម្មទេសនា ជាកថាមានប្រយោជន៍ដល់បរិស័ទ ដែលមកប្រជុំគ្នានៅទីនោះឯង ។

១២៣.. វាណិជោវ ភយំ មគ្គំ អប្បសត្ថោ មហទ្ធនោ
វិសំ ជីវិតុកាមោវ បាបានិ បរិវជ្ជយេ ។

បុគ្គល គួរចៀសវាងបាបទាំងឡាយ ឱ្យដូចពាណិជ ដែលមានទ្រព្យច្រើន តែមានគ្នាតិច ចៀសវាងផ្លូវគួរខ្លាច ឬ ដូចជាបុរសប្រាថ្នារស់នៅ ចៀសវាងថ្នាំពិសដូច្នោះដែរ ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "**ជេតវនារាម**" ប្រារព្ធ **មហាធនពាណិជ** ពាណិជអ្នកមានទ្រព្យច្រើន) ។

☞ ក្នុងវេលាចប់ព្រះធម្មទេសនា ភិក្ខុ **៥០០** អង្គ បានសម្រេច **ព្រះអរហត្ត** ព្រមដោយ **បដិសម្ភិទា** ទាំងឡាយ ។

១២៤.. បាណិម្ហិ ចេ វណោ នាស្ស ហរេយ្យ បាណិនា វិសំ
នាព្វណំ វិសមន្វេតិ នត្ថិ បាបំ អកុព្វតោ ។

បើដំបៅមិនមានក្នុងបាតដៃទេ បុគ្គលគប្បីនាំយកថ្នាំពិសដោយបាតដៃ ថ្នាំពិស តែងមិនជ្រាបចូលទៅកាន់បាតដៃដែលគ្មានដំបៅ យ៉ាងណា បាប រមែងមិនមានដល់បុគ្គលអ្នកមិនធ្វើ យ៉ាងនោះដែរ ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "**ជេតវនារាម**" ប្រារព្ធនាយព្រាន **កុក្កុដមិត្ត** ពាណិជអ្នកមានទ្រព្យច្រើន) ។

☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេច **អរិយផល** ទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

១២៥.. យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ
សុទ្ធស្ស បោសស្ស អនង្គណស្ស
តមេវ ពាលំ បច្ចេតិ បាបំ
សុខុមោ រជោ បដិវាតំវ ខិត្តោ ។

បុគ្គលណា ប្រទូស្តចំពោះអ្នកមិនប្រទូស្តតប ជាសត្វស្អាត មិនមានកិលេសដូចជាទីទូល បាប រមែងត្រឡប់មករកបុគ្គលពាលនោះវិញ ដូចធូលីល្អិត ដែលបុគ្គលបាចសាចទៅកាន់ទីច្រាសខ្យល់ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅ "វត្តជេតពន" ប្រារព្ធនាយព្រានសុនខ ឈ្មោះ កោកៈ) ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ព្រះថេរៈ មួយអង្គ តាំងនៅក្នុង ព្រះអរហត្តផល ។
ព្រះធម្មទេសនា បានជាកថាមានប្រយោជន៍ ដល់បរិស័ទ ដែលមកប្រជុំគ្នានៅទីនោះ ។

១២៦.. គព្ភមេកេ ឧប្បជ្ជន្តិ និរយំ បាបកម្មិនោ
សគ្គំ សុគតិនោ យន្តិ បរិនិព្វន្តិ អនាសវា ។

ជនពួកខ្លះ កើតក្នុងគភ៌មនុស្ស, ពួកអ្នកមានអំពើអាក្រក់ ទៅកាន់នរក, ពួកអ្នកមានគតិល្អ ទៅកាន់ឋានសួគ៌, ពួកអ្នកមិនមានអាសវៈ បរិនិព្វាន ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធ ព្រះតិស្សត្ថេរ ចូលទៅកាន់ត្រកូលជាងកែវមណី) ។
☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេច អរិយផល ទាំងឡាយ មាន សោតាបត្តិផល ជាដើម ។

១២៧.. ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ
ន បព្វតានំ វិវរំ បវិសំ
ន វិជ្ជតី សោ ជគតិប្បទេសោ
យត្រដ្ឋិតោ មុច្ចេយ្យ បាបកម្មា ។

បុគ្គលអ្នកធ្វើបាបកម្មហើយ ទោះបីចូលទៅឰដ៏អាកាស ក្នុងកណ្តាលសមុទ្រ កាន់ចន្លោះភ្នំទាំងឡាយ ក៏មិនគប្បីរួចចាកបាបកម្ម ព្រោះប្រទេសលើផែនដី ដែលបុគ្គលឋិតនៅហើយ គប្បីរួចចាកបាបកម្មបាននោះ មិនដែលមានឡើយ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅ "វត្តជេតពន" ប្រារព្ធជន ៣ នាក់) ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ភិក្ខុ ៧ រូប បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។
ព្រះធម្មទេសនា បានជាកថាមានប្រយោជន៍ ដល់បរិស័ទ ដែលមកប្រជុំគ្នានៅទីនោះ ។

១២៨.. ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ
ន បព្វតានំ វិវរំ បវិស្ស
ន វិជ្ជតី សោ ជគតិប្បទេសោ
យត្រដ្ឋិតំ នប្បសហេយ្យ មច្ចុ ។

បុគ្គលទៅឰដ៏អាកាស ក្នុងកណ្តាលសមុទ្រ កាន់ចន្លោះនៃភ្នំទាំងឡាយ ក៏មិនរួចចាកសេចក្តីស្លាប់បាន ព្រោះប្រទេសលើផែនដី ដែលបុគ្គលឋិតនៅហើយ សេចក្តីស្លាប់គ្របសង្កត់មិនបាននោះ មិនដែលមានឡើយ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្ដែងនៅ "វត្តនិគ្រោធារាម" ប្រារព្ធ ព្រះបាទសុប្បពុទ្ធ) ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេច អរិយផល ទាំងឡាយ មាន សោតាបត្តិផល ជាដើម ។

(ចប់ បាបវគ្គ ទី ៩ = មាន ១៣ គាថា)

ជំពូកទី ១០

ទណ្ឌវគ្គ

(Daṇḍa Vagga)

The Rod or Punishment

(Versets sur le Châtiment)

(មាន ១៧ គាថា)

(ពី គាថា ទី ១២៩ ➯ ដល់ គាថា ទី ១៤៥)

១២៩.. សព្វេ តសន្តិ ទណ្ឌស្ស   សព្វេ ភាយន្តិ មច្ចុនោ
អត្តានំ ឧបមំ កត្វា   ន ហនេយ្យ ន ឃាតយេ ។

សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា សត្វទាំងឡាយ តែងខ្លាចចំពោះសេចក្តីស្លាប់គ្រប់ ៗ រូប បុគ្គលគួរធ្វើខ្លួនឱ្យជាឧបមា ហើយមិនគួរប្រហារ ដោយខ្លួនឯង មិនគួរប្រើគេឱ្យប្រហារឡើយ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធ **ឆព្វគ្គិយភិក្ខុ**) ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេច **អរិយផល** ទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

១៣០.. សព្វេ តសន្តិ ទណ្ឌស្ស   សព្វេសំ ជីវិតំ បិយំ
អត្តានំ ឧបមំ កត្វា   ន ហនេយ្យ ន ឃាតយេ ។

សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា (ព្រោះថា)ជីវិត ជាទីស្រឡាញ់របស់សត្វទាំងពួង បុគ្គលគួរធ្វើខ្លួនឱ្យជាឧបមា ហើយមិនគួរប្រហារ ដោយខ្លួនឯង មិនគួរប្រើគេឱ្យប្រហារឡើយ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធ **ឆព្វគ្គិយភិក្ខុ**) ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេច **អរិយផល** ទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

១៣១.. សុខកាមានិ ភូតានិ   យោ ទណ្ឌេន វិហឹសតិ
អត្តនោ សុខមេសានោ   បេច្ច សោ ន លភតេ សុខំ ។
១៣២.. សុខកាមានិ ភូតានិ   យោ ទណ្ឌេន ន ហឹសតិ
អត្តនោ សុខមេសានោ   បេច្ច សោ លភតេ សុខំ ។

ជនណាស្វែងរកសេចក្តីសុខដើម្បីខ្លួន តែបៀតបៀនសត្វទាំងឡាយដែលប្រាថ្នាសេចក្តីសុខ ដោយអាជ្ញា ជននោះ លះលោកនេះទៅហើយនឹងមិនបានសេចក្តីសុខឡើយ ។

ជនណា ស្វែងរកសេចក្តីសុខដើម្បីខ្លួន តែមិនបៀតបៀនសត្វទាំងឡាយ អ្នកដែលប្រាថ្នាសេចក្តីសុខ ដោយអាជ្ញា ជននោះ លះលោកនេះទៅហើយ រមែងបានសេចក្តីសុខ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធ ក្មេងច្រើននាក់) ។

☞ ក្នុងវេលាចប់ព្រះធម្មទេសនា ក្មេង ៥០០ នាក់ តាំងនៅក្នុង សោតាបត្តិផល។

១៣៣.. មាវោច ផរុសំ កញ្ចិ វុត្តា បដិវទេយ្យុ តំ
ទុក្ខា ហិ សារម្ភកថា បដិទណ្ឌា ផុសេយ្យុ តំ ។
១៣៤.. សចេ នេរេសិ អត្តានំ កំសោ ឧបហតោ យថា
ឯស បត្តោសិ និព្វានំ សារម្ភោ តេ ន វិជ្ជតិ ។

អ្នកកុំនិយាយពាក្យអាក្រក់នឹងអ្នកណាមួយឡើយ ជនទាំងឡាយដែលអ្នកស្តីថាឱ្យហើយ គេគប្បីស្តីថាតបមកអ្នកវិញ ព្រោះថា ការពោលពាក្យប្រណាំងប្រជែង ជាហេតុនាំឱ្យកើតទុក្ខ ការតស៊ូទាំងឡាយ គប្បីប៉ះពាល់នូវអ្នក ។ បើអ្នកធ្វើខ្លួនមិនឱ្យញាប់ញ័រ ដូចរគាំងដែលចៀរមាត់ចេញហើយ(រមែងមិនលាន់ឮសូរ) ដូច្នោះ អ្នកនុ៎ះជាបុគ្គលដល់នូវព្រះនិព្វានការប្រណាំងប្រជែង មិនមានដល់អ្នក ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធ ព្រះកោណ្ឌធានត្ថេរ) ។

☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេច **អរិយផល** ទាំងឡាយ មាន **សោតាបត្តិផល** ជាដើម, ចំណែកព្រះកោណ្ឌធានត្ថេរ តាំងនៅក្នុងឱវាទ ដែលព្រះសាស្តាប្រទានឱ្យហើយ ក៏បានសម្រេច **ព្រះអរហត្តផល**។

១៣៥.. **យថា ទណ្ឌេន គោបាលោ   គាវោ បាជេតិ គោចរំ**
ឯវំ ជរា ច មច្ចុ ច   អាយុំ បាជេន្តិ បាណិនំ ។

គង្វាលគោ រមែងកៀងគោ ទៅកាន់ទីគោចរដោយអាជ្ញា ដូចម្តេចមិញ **ជរា** និង **មច្ចុ** តែងកៀងអាយុរបស់សត្វទាំងឡាយ ដូច្នោះឯង ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅ "បុព្វារាម" ប្រារព្ធ ឧបោសថកម្ម របស់ឧបាសិកាទាំងឡាយ មាននាងវិសាខាជាដើម) ។

☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើននាក់ បានសម្រេច **អរិយផល** ទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

១៣៦.. **អថ បាបានិ កម្មានិ   ករំ ពាលោ ន ពុជ្ឈតិ**
សេហិ កម្មេហិ ទុម្មេធោ   អគ្គិទឌ្ឍោវ តប្បតិ ។

បុគ្គលមិនមានប្រាជ្ញា កាលធ្វើអំពើអាក្រក់ រមែងមិនភ្ញាក់ខ្លួន លុះកាលជាខាងក្រោយ ទើបក្តៅក្រហាយ ដោយសារកម្មរបស់ខ្លួន ដូចត្រូវភ្លើងឆេះ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅ "វេឡុវនារាម" ប្រារព្ធ អជគរប្រេត) ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើននាក់ បានសម្រេច អរិយផល ទាំងឡាយ មាន សោតាបត្តិផល ជាដើម ។

១៣៧.. យោ ទណ្ឌេន អទណ្ឌេសុ   អប្បទុដ្ឋេសុ ទុស្សតិ
ទសន្នមញ្ញតរំ ឋានំ   ខិប្បមេវ និគច្ឆតិ
១៣៨.. វេទនំ ផរុសំ ជានឹ   សរីរស្ស វ ភេទនំ
គរុកំ វាបិ អាពាធំ   ចិត្តក្ខេបំ វ បាបុណេ
១៣៩.. រាជតោ វា ឧបស្សគ្គំ   អព្ភក្ខានំ វ ទារុណំ
បរិក្ខយំ វ ញាតីនំ   ភោគានំ វ បភង្គុណំ
១៤០.. អថ វាស្ស អគារានិ   អគ្គិ ឌហតិ បាវកោ
កាយស្ស ភេទា ទុប្បញ្ញោ   និរយំ សោ ឧបបជ្ជតិ ។

បុគ្គលណា ប្រទូស្តដោយអាជ្ញា ចំពោះបុគ្គលទាំងឡាយ ដែលមិនមានអាជ្ញា-មិនប្រទូស្តបុគ្គលនោះ រមែងដល់នូវហេតុនៃសេចក្តីទុក្ខណាមួយ ក្នុងហេតុ ១០ យ៉ាង ដោយទាន់ហន់ *គឺ គប្បីដល់នូវវេទនាដ៏អាក្រក់, សេចក្តីវិនាសទ្រព្យ, បែកធ្លាយសរីរៈ, អាពាធជាទម្ងន់, ក្រឡុកចិត្ត* (ឆ្កួត), *រឹបជាន់អំពីស្តេច, ពោលពាក្យបង្កាច់ដ៏អាក្រក់, អស់ពួកញាតិវលីង, ពុកផុយភោគសម្បត្តិទាំងឡាយ, ទាំងភ្លើងនឹងឆេះបំផ្លាញនូវផ្ទះរបស់បុគ្គលនោះ,* បុគ្គលមិនមានប្រាជ្ញានោះ លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងនរក ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្ដែងនៅ "វត្តវេឡុវ័ន" ប្រារព្ធ ព្រះមហាមោគ្គល្លានត្ថេរ) ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើននាក់បានសម្រេច អរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ។

១៤១.. ន នគ្គចរិយា ន ជដា ន បង្កា
នានាសកា ថណ្ឌិលសាយិកា វា
រជោជល្លំ ឧក្កុដិកប្បធានំ
សោធេន្តិ មច្ចំ អវិតិណ្ណកង្ខំ ។

ការប្រព្រឹត្តអាក្រាតកាយ ទុកសក់ ដេកលើភក់ មិនបរិភោគបាយ ដេកលើផែនដី ប្រឡាក់ខ្លួនដោយធូលី ព្យាយាមអង្គុយច្រហោង មិនជម្រះសត្វ (មិនអាចញុាំងសត្វ) ដែលមិនទាន់ឆ្លងផុតសេចក្ដីសង្ស័យ (ឱ្យស្អាតល្អ) បានទេ[១] ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្ដែងនៅ "វត្តជេតពន" ប្រារព្ធភិក្ខុអ្នកមានភណ្ឌៈច្រើន) ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើននាក់បានសម្រេច អរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ។

១៤២.. អលង្កតោ ចេបិ សមំ ចរេយ្យ
សន្តោ ទន្តោ និយតោ ព្រហ្មចារី
សព្វេសុ ភូតេសុ និធាយ ទណ្ឌំ
សោ ព្រាហ្មណោ សោ សមណោ ស ភិក្ខុ ។

---

[១] យកន័យសេចក្ដីតាមក្នុង អដ្ឋកថា ។ ក្នុងព្រះត្រៃបិដក មានត្រឹមតែ ... បានទេ ។

បើបុគ្គលណា មានខ្លួនប្រដាប់ស្អិតស្អាងហើយ (ដោយគ្រឿងអម្ពរ) តែគប្បីប្រព្រឹត្តស្មើ អ្នកស្ងប់រម្ងាប់ ទូន្មាន (ឥន្ទ្រិយ) ជាបុគ្គលទៀង (ចំពោះ-មគ្គផល) អ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ទម្លាក់ចោលនូវអាជ្ញា ក្នុងសត្វទាំងពួងចេញហើយ បុគ្គលនោះ ហៅថា **ព្រាហ្មណ៍** ក៏បាន, ថា **សមណៈ** ក៏បាន, ថា **ភិក្ខុ** ក៏បាន ។

☸ (<u>**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្ដែងនៅ "**វត្តជេតពន**"</u>
<u>ប្រារព្ធ **សន្តតិមហាមាត្យ**</u>) ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា
ជនជាច្រើននាក់បានសម្រេច **អរិយផល**ទាំងឡាយ មាន **សោតាបត្តិផល**ជាដើម ។

១៤៣.. ហិរីនិសេធោ បុរិសោ កោចិ លោកស្មិ វិជ្ជតិ
យោ និន្ទំ អបពោធេតិ អស្សោ ភទ្រោ កសាមិវ ។

១៤៤.. អស្សោ យថា ភទ្រោ កសានិវិដ្ឋោ
អាតាបិនោ សំវេគិនោ ភវាថ
សទ្ធាយ សីលេន ច វីរិយេន ច
សមាធិនា ធម្មវិនិច្ឆយេន ច
សម្បន្នវិជ្ជាចរណា បតិស្សតា
បហស្សថ ទុក្ខមិទំ អនប្បកំ ។

បុគ្គលអ្នកកំចាត់បង់នូវអកុសលវិតក្កៈ ដោយសេចក្តីខ្មាសបាប មានតិចក្នុងលោក បុគ្គលណាបន្ទោបង់នូវការដេកលក់ ដូចសេះល្អ ខ្លាចព្រោះរំពាត់ បុរសនោះ រកបានដោយក្រ ក្នុងលោក ។

សេះល្អ ដែលនាយសារថីទូន្មាន ដោយរំពាត់ តក់ស្លុតយ៉ាងណា អ្នកទាំងឡាយ ចូរជាបុគ្គលមានព្យាយាម មានសេចក្ដីតក់ស្លុតយ៉ាងនោះឯង, បើអ្នកទាំងឡាយ ប្រកបដោយសទ្ធាផង សីលផង ព្យាយាមផង សមាធិផង ធម្មវិនិច្ឆ័យផង ជាអ្នកមានវិជ្ជា និង ចរណៈដ៏បរិបូណ៌ មានស្មារតីតម្កល់មាំ រមែងលះបង់ទុក្ខ មានប្រមាណច្រើននេះ មិនខាន ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្ដែងនៅ "ជេតវនារាម" ប្រារព្ធ បិលោតិកត្ថេរ) ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើននាក់ បានសម្រេច **អរិយផល** ទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

១៤៥.. **ឧទកំ ហិ នយន្តិ នេត្តិកា ឧសុការា នមយន្តិ តេជនំ**
ទារុំ នមយន្តិ តច្ឆកា អត្តានំ ទមយន្តិ សុព្វតា ។

ធម្មតា អ្នកបង្ហូរ តែងបង្ហូរទឹក អ្នកធ្វើព្រួញ តែងពត់ព្រួញ (ឱ្យត្រង់) អ្នកចាំង តែងចាំងឈើ, អ្នកមានវត្តល្អ តែងទូន្មានខ្លួន ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្ដែងនៅ "ជេតវនារាម" ប្រារព្ធ សុខសាមណេរ) ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើននាក់ បានសម្រេច **អរិយផល** ទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

(ចប់ **ទណ្ឌវគ្គ** ទី ១០ = មាន **១៧** គាថា)

ជំពូកទី ១១

ជរាវគ្គ

(Jarā Vagga)

The Old Age

(Versets sur la Vieillesse)

(មាន ១១ គាថា)

(ពី គាថា ទី ១៤៦ ➪ ដល់ គាថា ទី ១៥៦)

១៤៦.. កោ នុ ហាសោ កិមានន្ទោ និច្ចំ បជ្ជលិតេ សតិ
អន្ធការេន ឱនទ្ធា បទីបំ ន គវេសថ ។

កាលបើលោកសន្និវាស ត្រូវភ្លើង មានរាគៈ ជាដើម ឆេះទ្រលោម ជានិច្ច ម្តេចក៏សើច ម្តេចក៏ត្រេកត្រអាល អ្នកទាំងឡាយត្រូវងងឹត គឺអវិជ្ជារួបរឹតហើយ (ម្តេចឡើយ) ក៏មិនស្វែងរកប្រទីប គឺ ប្រាជ្ញា ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធ ពួកស្ត្រី ជាសម្លាញ់របស់នាងវិសាខា) ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ពួកស្ត្រីទាំង ៥០០ នាក់នោះ តាំងនៅក្នុង សោតាបត្តិផល ។

១៤៧.. បស្ស ចិត្តកតំ ពិម្ពំ អរុកាយំ សមុស្សិតំ
អាតុរំ ពហុសង្កប្បំ យស្ស នត្ថិ ធុវំ ឋិតិ ។

អត្តភាពណា មិនទៀងទាត់ឋិតថេរ អ្នកចូរមើលអត្តភាព (នោះ) ដែលកុសលាកុសលកម្ម (កុសល+អកុសលកម្ម) ធ្វើវិចិត្រហើយ ជាកាយពាសពេញដោយដំបៅ ដែលឆ្អឹង ៣០០ កំណាត់ ផ្គុំគ្នាហើយ ជាអត្តភាពក្តៅក្រហាយជានិច្ច ជាទីរំពឹងត្រិះរិះរបស់ជនច្រើនគ្នា ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅវត្តវេឡុវ័ន "វេឡុវនារាម" ប្រារព្ធ នាងសិរិមា) ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ធម្មាភិសម័យ (ការត្រាស់ដឹងធម៌) បានមានដល់សត្វ ៨៤.០០០ នាក់, ភិក្ខុអង្គមួយ ក៏បានតាំងនៅក្នុង សោតាបត្តិផល ។

១៤៨.. **បរិជិណ្ណមិទំ រូបំ　　　រោគនិឌ្ឍំ បភង្គុណំ**
ភិជ្ជតិ បូតិ សន្ទេហោ　　　មរណន្តំ ហិ ជីវិតំ ។

រូបនេះគ្រាំគ្រាអស់ហើយ ជាទីសំណាក់នៃរោគ ជារបស់ពុកផុយ រាងកាយជារបស់ស្អុយ (នេះ) តែងបែកធ្លាយទៅវិញ ព្រោះថាជីវិត មានសេចក្តីស្លាប់ ជាទីបំផុត ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន **"ជេតវនារាម"** ប្រារព្ធ **ព្រះនាងឧត្តរាថេរី**) ។
☞ ក្នុងវេលាចប់ព្រះធម្មទេសនា ព្រះថេរី បានសម្រេច **សោតាបត្តិផល** ។

១៤៩.. **យានិមានិ អបត្ថានិ　　　អលាពូនេវ សារទេ**
កាបោតកានិ អដ្ឋីនិ　　　តានិ ទិស្វាន កា រតិ ។

ឆ្អឹងទាំងឡាយណា មានសម្បុរដូចសត្វព្រាប ដែលគេចោលហើយ ដូចផ្លែឃ្លោកក្នុងសរទកាល សេចក្តីត្រេកអរអ្វីហ្ន៎ (របស់អ្នកទាំងឡាយ) ព្រោះតែឃើញឆ្អឹងទាំងឡាយនោះ ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន **"ជេតវនារាម"** ប្រារព្ធ **ព្រះអធិមានិកភិក្ខុ**) ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ភិក្ខុទាំងឡាយ (៥០០ រូប) ដែលកំពុងគង់ឈរស្តាប់ក្នុងទីនោះ ក៏បានសម្រេចនូវ **អរហត្តផល** ។

១៥០.. **អដ្ឋីនំ នគរំ កតំ　　　មំសលោហិតលេបនំ**
យត្ថ ជរា ច មច្ចុ ច　　　មានោ មក្ខោ ច ឱហិតោ ។

សេចក្ដីគ្រាំគ្រា សេចក្ដីស្លាប់ សេចក្ដីប្រកាន់ខ្លួន និង សេចក្ដីលុបគុណ ប្រជុំចុះក្នុងសរីរៈណា (សរីរៈនោះ) ដែលកុសលាកុសលកម្ម (កុសល+អកុសលកម្ម) ធ្វើហើយ ឱ្យជានគររបស់ឆ្អឹងទាំងឡាយ ជាគ្រឿងប្រឡាក់ដោយសាច់ និង ឈាម ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្ដែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធ រូបនន្ទាថេរី) ។

☞ ក្នុងវេលាចប់ព្រះធម៌ទេសនា **ព្រះនាងរូបនន្ទាថេរី** បានសម្រេច **អរហត្តផល**។

១៥១.. ជីរន្តិ វេ រាជរថា សុចិត្តា
អថោ សរីរម្បិ ជរំ ឧបេតិ
សតញ្ច ធម្មោ ន ជរំ ឧបេតិ
សន្តោ ហវេ សព្ភិ បវេទយន្តិ ។

រាជរថទាំងឡាយ ដ៏វិចិត្រល្អ រមែងគ្រាំគ្រា សូម្បីសរីរៈ ក៏ដល់នូវសេចក្ដីគ្រាំគ្រាដូចគ្នា ចំណែកធម៌[១] របស់សប្បុរសទាំងឡាយ រមែងមិនដល់នូវសេចក្ដីគ្រាំគ្រា (ដូច្នោះ) ទេ សប្បុរសទាំងឡាយ តែងនិយាយឱ្យពួកសប្បុរសផងគ្នា ដឹងបាន ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្ដែងនៅវត្តជេតពន "ជេតវនារាម" ប្រារព្ធ ព្រះនាងមល្លិកាទេវី) ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើននាក់ បានសម្រេច **អរិយផល**ទាំងឡាយ មាន **សោតាបត្តិផល**ជាដើម ។

---

[១] យកន័យសេចក្ដីតាមក្នុង **អដ្ឋកថា** ។

១៥២.. អប្បស្សុតាយំ បុរិសោ ពលិពទ្ទោវ ជីរតិ
មំសានិ តស្ស វឌ្ឍន្តិ បញ្ញា តស្ស ន វឌ្ឍតិ ។

បុរស អ្នកមិនមានការចេះដឹងនេះ តែងចាស់ (ឥតអំពើ) ដូចគោបំរើ សាច់របស់វា តែងចម្រើនឡើង តែប្រាជ្ញារបស់វាមិនចម្រើនឡើយ ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែងនៅវត្តជេតពន "**ជេតវនារាម**" ប្រារព្ធ **ព្រះលោឡុទាយិត្ថេរ**) ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើននាក់ បានសម្រេច **អរិយផល**ទាំងឡាយ មាន **សោតាបត្តិផល**ជាដើម ។

១៥៣.. អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ
គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ ។

១៥៤.. គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ
សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ
វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា ។

កាល **តថាគត** មិនទាន់បានជួបប្រទះ (**ពោធិញ្ញាណ**) រវល់តែស្វះស្វែង រក **ជាងផ្ទះ** គឺ **តណ្ហា**, អ្នកធ្វើ **ផ្ទះ** គឺ **អត្តភាព** ក៏អន្ទោលទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន សេចក្តីកើតជាទុក្ខរឿយៗ ។

នៃជាងផ្ទះ អ្នកឯងធ្វើផ្ទះ គឺអត្តភាព **តថាគត**ឃើញហើយ អ្នកនឹងធ្វើផ្ទះ (របស់**តថាគត**) ទៀត មិនបានឡើយ, ឆ្អឹងជំនីរ គឺកិលេស របស់អ្នកទាំងអស់ **តថាគត** កាច់បំបាក់អស់ហើយ, ដម្បូលផ្ទះ គឺអវិជ្ជា **តថាគត**កំចាត់ចោលហើយ ចិត្តរបស់ **តថាគត** ដល់ **ព្រះនិព្វាន** ដែលមានសង្ខារប្រាសហើយ **តថាគត** បានដល់ធម៌ ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ។

☸ (ព្រះពុទ្ធគាថានេះ កាលព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្បែរគល់ពោធិព្រឹក្ស ទ្រង់បន្លឺនូវឧទានវាចា ជា ព្រះបឋមឧទាន ដោយព្រះហឫទ័យសោមនស្ស ។ ក្នុងសម័យក្រោយមក ព្រះអានន្ទទូលសួរ ទើបទ្រង់ត្រាស់ព្រះធម្មទេសនានេះ ។

១៥៥.. **អចរិត្វា ព្រហ្មចរិយំ អលទ្ធា យោព្វនេ ធនំ**
ជិណ្ណកោញ្ចាវ ឈាយន្តិ ខីណមច្ឆេវ បល្លលេ ។
១៥៦.. **អចរិត្វា ព្រហ្មចរិយំ អលទ្ធា យោព្វនេ ធនំ**
សេន្តិ ចាបាតិខីណាវ បុរាណានិ អនុត្ថុនំ ។

ជនពាលទាំងឡាយ មិនប្រព្រឹត្ត **ព្រហ្មចរិយធម៌** មិនបានទ្រព្យ ក្នុងកាលខ្លួននៅជាកំឡោះក្រមុំ រមែងសញ្ជប់សញ្ជឹង ដូចសត្វក្រៀលចាស់សំកុកនៅក្នុងភក់ ដែលអស់ត្រីហើយ ។

ជនពាលទាំងឡាយ មិនប្រព្រឹត្ត **ព្រហ្មចរិយធម៌** មិនបានទ្រព្យ ក្នុងកាលខ្លួននៅជាកំឡោះក្រមុំ រមែងដេកថ្ងូរ សោកស្តាយទ្រព្យចាស់ទាំងឡាយ ដូចព្រួញដែលផុតចាកខ្សែបន្ទោះដូច្នោះ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅក្នុងព្រៃ "ឥសិបតនមិគទាយវ័ន" ប្រារព្ធ **បុត្រសេដ្ឋី** អ្នកមានទ្រព្យច្រើន) ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេច **អរិយផល**ទាំងឡាយ មាន **សោតាបត្តិផល**ជាដើម ។

(ចប់ **ជរាវគ្គ** ទី ១១ = មាន **១១** គាថា)

វគ្គទី ១២

អត្តវគ្គ

(Atta Vagga)

The Self (Ego)

(Versets sur le Moi)

(មាន ១០ គាថា)

(ពី គាថា ទី ១៥៧ ➩ ដល់ គាថា ទី ១៦៦)

១៥៧.. អត្តានញ្ចេ បិយំ ជញ្ញា   រក្ខេយ្យ នំ សុរក្ខិតំ
តិណ្ណំ អញ្ញតរំ យាមំ   បដិជគ្គេយ្យ បណ្ឌិតោ ។

បើបណ្ឌិតដឹងថា ខ្លួនជាទីស្រឡាញ់ គួររក្សាខ្លួននោះឱ្យល្អ គួរស្ងួនគ្រងខ្លួនទុកក្នុងវ័យទាំង ៣ វ័យណាមួយ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅ "ភេសកឡាវ័ន" ប្រារព្ធ ពោធិរាជកុមារ) ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ពោធិរាជកុមារ បានតាំងនៅក្នុង សោតាបត្តិផល ។

១៥៨.. អត្តានមេវ បឋមំ   បដិរូបេ និវេសយេ
អថញ្ញមនុសាសេយ្យ   ន កិលិស្សេយ្យ បណ្ឌិតោ ។

បណ្ឌិត គួរតម្កល់ខ្លួនទុក ក្នុងគុណដ៏សមគួរជាមុនសិន ហើយសឹមប្រៀនប្រដៅអ្នកដទៃ ជាខាងក្រោយ (ធ្វើយ៉ាងនេះ) នឹងមិនលំបាកឡើយ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅ "វត្តជេតពន" ប្រារព្ធ ព្រះឧបនន្ទសក្យបុត្រ) ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ភិក្ខុពីររូប បានតាំងនៅក្នុង សោតាបត្តិផល ។

១៥៩.. អត្តានញ្ចេ តថា កយិរា   យថញ្ញមនុសាសតិ
សុទន្តោ វត ទមេថ   អត្តា ហិ កិរ ទុទ្ទមោ ។

បុគ្គលប្រៀនប្រដៅអ្នកដទៃយ៉ាងណា ត្រូវធ្វើខ្លួនឱ្យបានយ៉ាងនោះដែរ អ្នកដែលទូន្មានខ្លួនល្អហើយ ទើបគួរទូន្មានអ្នកដទៃបាន ព្រោះថាខ្លួនកម្រទូន្មានបានពេកណាស់ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅ "វត្តជេតពន" ប្រារព្ធ ព្រះបធានិកតិស្សត្ថេរ) ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ភិក្ខុប្រមាណ ៥០០ រូប បានសម្រេច ព្រះអរហត្តផល ។

១៦០.. អត្តា ហិ អត្តនោ នាថោ កោ ហិ នាថោ បរោ សិយា
អត្តនា ហិ សុទន្តេន នាថំ លភតិ ទុល្លភំ ។

ខ្លួនជាទីពឹងរបស់ខ្លួន អ្នកដទៃជាទីពឹងដូចម្តេចបាន ព្រោះបុគ្គលអ្នកមានខ្លួនហ្វឹកហ្វឺនល្អហើយ រមែងបាននូវទីពឹង ដែលគេបានដោយកម្រ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅ "វត្តជេតពន" ប្រារព្ធ មាតារបស់ព្រះកុមារកស្សបត្ថេរ) ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេច អរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ។

១៦១.. អត្តនា វ កតំ បាបំ អត្តជំ អត្តសម្ភវំ
អភិមត្ថតិ ទុម្មេធំ វជិរំវម្ហមយំ មណឹ ។

បាប កើតអំពីខ្លួន មានខ្លួនជាដែនកើត ដែលខ្លួនធ្វើហើយ តែងញាំញីមនុស្សឥតប្រាជ្ញា ដូចពេជ្រសម្រាប់កាត់កែវមណី ដែលកើតអំពីថ្ម ដូច្នោះឯង ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅ "វត្តជេតពន" ប្រារព្ធ ឧបាសក ជាព្រះសោតាបន្នម្នាក់ឈ្មោះ មហាកាល) ។
☞ ក្នុងវេលាចប់ព្រះធម្មទេសនា ភិក្ខុដែលមកប្រជុំគ្នា បានសម្រេច អរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ។

១៦២.. **យស្ស អច្ចន្តទុស្សីល្យំ មាលុវា សាលមិវោត្ថតំ**
ករោតិ សោ តថត្តានំ យថា នំ ឥច្ឆតី ទិសោ ។

ភាពជាអ្នកទ្រុស្តសីលហួសហេតុ[១] គ្របសង្កត់ (នូវអត្តភាព) របស់បុគ្គលណា ដូចវល្លិ៍ដែលរួបរឹតដើមឈើ បុគ្គលនោះឈ្មោះថា ធ្វើខ្លួនឯងឱ្យវិនាស ដូចជាចោរ អ្នកប្រាថ្នាធ្វើបុគ្គលនោះ ឱ្យវិនាសដូច្នោះ ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែងនៅ "**វត្តវេឡុវ័ន**" ប្រារព្ធ **ភិក្ខុទេវទត្ត**) ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេច **អរិយផល**ទាំងឡាយ មាន **សោតាបត្តិផល**ជាដើម ។

១៦៣.. **សុករានិ អសាធូនិ អត្តនោ អហិតានិ ច**
យំ វេ ហិតញ្ច សាធុញ្ច តំ វេ បរមទុក្ករំ ។

កម្មទាំងឡាយណា មិនល្អផង មិនជាប្រយោជន៍ដល់ខ្លួនផង កម្មទាំងនោះ ដែលជនពាលធ្វើបានដោយងាយ, កម្មណាជាប្រយោជន៍ផងល្អផង កម្មនុ៎ះឯង ដែលជនពាលធ្វើបាន ដោយលំបាក ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែងនៅ "**វេឡុវ័ន**" ប្រារព្ធការព្យាយាមដើម្បីនឹងបំបែកសង្ឃនៃ **ភិក្ខុទេវទត្ត**) ។
☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេច **លោកុត្តរផល** មាន **សោតាបត្តិផល**ជាដើម ។

---

[១] បើគ្រហស្ថ ចាប់តាំងអំពីកើតមក ធ្វើតែអកុសលកម្មបថទាំង ១០, បើបព្វជិត គិតអំពីថ្ងៃដែលបានឧបសម្បទមក ត្រូវគរុកាបត្តិ យ៉ាងនេះឈ្មោះថា ភាពជាអ្នកទ្រុស្តសីលហួសហេតុ ។

១៦៤.. យោ សាសនំ អរហតំ អរិយានំ ធម្មជីវិនំ
បដិក្កោសតិ ទុម្មេធោ ទិដ្ឋឹ និស្សាយ បាបិកំ
ផលានិ កណ្ដកស្សេវ អត្តឃញ្ញាយ ផល្លតិ ។

បុគ្គលណាអប្បប្រាជ្ញា អាស្រ័យទិដ្ឋិដ៏លាមក ហាមឃាត់សាសនារបស់ព្រះអរហន្តទាំងឡាយដ៏ប្រសើរ_រស់នៅដោយធម៌ ការហាមឃាត់របស់បុគ្គលនោះ រមែងចេញផល ដើម្បីសម្លាប់ខ្លួន ដូចផ្លៃឫស្សីដូច្នោះ ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្ដែងនៅ "**វត្តជេតពន**" ប្រារព្ធ **ព្រះកាឡត្ថេរ**) ។
☞ ក្នុងវេលាចប់ព្រះធម្មទេសនា ឧបាសិកាម្នាក់តាំងនៅក្នុងសោតាបត្តិផល ។

១៦៥.. អត្តនា ច កតំ បាបំ អត្តនា សង្កិលិស្សតិ
អត្តនា អកតំ បាបំ អត្តនា ច វិសុជ្ឈតិ
សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ ។

អ្នកធ្វើបាបខ្លួនឯង នឹងសៅហ្មងខ្លួនឯង, អ្នកមិនធ្វើបាបខ្លួនឯង តែងបរិសុទ្ធស្អាតខ្លួនឯង, សេចក្ដីបរិសុទ្ធ និង មិនបរិសុទ្ធ មានចំពោះខ្លួន អ្នកដទៃនឹងធ្វើអ្នកដទៃ ឱ្យបរិសុទ្ធពុំបានទេ ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្ដែងនៅ "**វត្តជេតពន**" ប្រារព្ធឧបាសកឈ្មោះចុល្លកាល) ។
☞ ក្នុងវេលាចប់ព្រះធម្មទេសនា **ឧបាសកចុល្លកាល** បានសម្រេចសោតាបត្តិផល ។

១៦៦.. អត្តទត្ថំ បរត្ថេន ពហុនាបិ ន ហាបយេ
អត្តទត្ថមភិញ្ញាយ សទត្ថបសុតោ សិយា ។

បុគ្គល កុំគប្បីធ្វើប្រយោជន៍ខ្លួនឱ្យវិនាស ព្រោះប្រយោជន៍របស់អ្នកដទៃ សូម្បីច្រើន បើដឹងច្បាស់នូវប្រយោជន៍របស់ខ្លួនហើយ គប្បីខ្វល់ខ្វាយក្នុងប្រយោជន៍របស់ខ្លួន (នោះ) ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅ "វត្តជេតពន" ប្រារព្ធ ព្រះអត្តទត្ថត្ថេរ) ។

☞ ក្នុងវេលាចប់ព្រះធម្មទេសនា ព្រះថេរៈ បានតាំងនៅក្នុង អរហត្តផល ។

(ចប់ **អត្តវគ្គ** ទី ១២ = មាន ១០ គាថា)

វគ្គទី ១៣

លោកវគ្គ

(Loka Vagga)

The World

(Versets sur le Monde)

(មាន ១២ គាថា)

(ពី គាថា ទី ១៦៧ ↳ ដល់ គាថា ទី ១៧៨)

១៦៧.. ហីនំ ធម្មំ ន សេវេយ្យ   បមាទេន ន សំវសេ
មិច្ឆាទិដ្ឋឹ ន សេវេយ្យ   ន សិយា លោកវឌ្ឍនោ ។

បុគ្គលមិនគួរសេពធម៌ថោកទាប[១] មិនគួរនៅដោយសេចក្ដីប្រមាទ មិនគួរសេពមិច្ឆាទិដ្ឋិ មិនគួរជាមនុស្សចង្អៀតលោក ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្ដែងនៅ "វត្តជេតពន" ប្រារព្ធ ភិក្ខុកំឡោះ១រូប)។
☞ ក្នុងវេលាចប់ព្រះធម្មទេសនា ភិក្ខុកំឡោះរូបនោះបានសម្រេច **សោតាបត្តិផល** ។

១៦៨.. ឧត្តិដ្ឋេ នប្បមជ្ជេយ្យ   ធម្មំ សុចរិតំ ចរេ
ធម្មចារី សុខំ សេតិ   អស្មឹ លោកេ បរម្ហិ ច ។

បុគ្គលមិនគួរប្រមាទក្នុងដុំបាយ ដែលខ្លួនគប្បីក្រោកឡើងទទួល គប្បីប្រព្រឹត្តធម៌[២] ឱ្យសុចរិត បុគ្គលអ្នកប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

១៦៩.. ធម្មំ ចរេ សុចរិតំ   ន តំ ទុច្ចរិតំ ចរេ
ធម្មចារី សុខំ សេតិ   អស្មឹ លោកេ បរម្ហិ ច ។

---

[១] **កាមគុណ ៥** ឈ្មោះថាធម៌ថោកទាប ព្រោះជាធម៌សម្រាប់ជនថោកទាប រាប់តាំងអំពីឱដ្ឋ និង គោជាដើមគប្បីសេព ទាំងជាធម៌ នាំសត្វទៅកើតក្នុងទីទាប មាននរកជាដើម ។

[២] សំដៅយក**ភិក្ខាចរិយធម៌** ការលះបង់អនេសនៈ ដើរទៅបិណ្ឌបាត តាមលំដាប់ច្រកល្ហក ឈ្មោះថា **ភិក្ខាចរិយធម៌** ។

បុគ្គលគួរប្រព្រឹត្តធម៌ឱ្យសុចរិត មិនគួរប្រព្រឹត្តធម៌នោះឱ្យទុច្ចរិតឡើយ បុគ្គលគប្បីប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅនា "និគ្រោធារាម" ប្រារព្ធ ព្រះសុទ្ធោទនៈ)។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ព្រះបាទសុទ្ធោទនៈ តាំងនៅក្នុង សោតាបត្តិផល ។

១៧០.. យថា បុព្វុឡកំ បស្សេ យថា បស្សេ មរីចិកំ
ឯវំ លោកំ អវេក្ខន្តំ មច្ចុរាជា ន បស្សតិ ។

បុគ្គលឃើញពពុះទឹកយ៉ាងណា ឃើញព្រេញថ្ងៃយ៉ាងណា ស្តេចមច្ចុ (មច្ចុរាជ) មិនឃើញអ្នកពិចារណាខន្ធលោកជាដើម យ៉ាងនោះទេ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅ "វត្តជេតពន" ប្រារព្ធ ភិក្ខុអ្នកចម្រើនវិបស្សនា ប្រមាណ ៥០០ រូប) ។

☞ ក្នុងវេលាចប់ព្រះធម្មទេសនា ភិក្ខុទាំងនោះបានសម្រេច ព្រះអរហត្ត ។

១៧១.. ឯថ បស្សថិមំ លោកំ ចិត្តំ រាជរថូបមំ
យត្ថ ពាលា វិសីទន្តិ នត្ថិ សង្គោ វិជានតំ ។

អ្នកទាំងឡាយ ចូរមកមើលលោកនេះដ៏ត្រកាល ដូចរាជរថ ជនពាលទាំងឡាយ រមែងលិចលង់ក្នុងលោកណា សេចក្តីជាប់ជំពាក់ ក្នុងលោកនេះ រមែងមិនមាន ដល់ជនជាបណ្ឌិតទាំងឡាយ ដែលដឹងច្បាស់ទេ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅ "វត្តវេឡុវ័ន" ប្រារព្ធ អភយរាជកុមារ)។

☞ ក្នុងវេលាចប់ព្រះធម្មទេសនា ព្រះរាជកុមារ តាំងនៅក្នុងសោតាបត្តិផល ។

១៧២.. **យោ ច បុព្វេ បមជ្ជិត្វា   បច្ឆា សោ នប្បមជ្ជតិ**
សោមំ លោកំ បភាសេតិ   អព្ភា មុត្តោវ ចន្ទិមា ។

បុគ្គលណាមួយ កាលពីមុនប្រមាទហើយ លុះកាលជាខាងក្រោយ គេមិនប្រមាទវិញ បុគ្គលនោះ ឈ្មោះថា ញុំាំងខន្ធាទិលោកនេះឱ្យភ្លឺច្បាស់ ដូចព្រះចន្ទ្រវះផុតចាកពពក ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែងនៅ "**វត្តវេឡុវ័ន**" ប្រារព្ធ **ព្រះសម្មជ្ជនត្ថេរ**)។
☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេច **អរិយផល** មាន **សោតាបត្តិផល**ជាដើម ។

១៧៣.. **យស្ស បាបំ កតំ កម្មំ   កុសលេន បិធីយតិ**
សោមំ លោកំ បភាសេតិ   អព្ភា មុត្តោវ ចន្ទិមា ។

បុគ្គលណា ធ្វើអំពើបាបហើយ បិទខ្ទប់អំពើបាបនោះដោយកុសល គឺ អរហត្តមគ្គបាន បុគ្គលនោះ ឈ្មោះថា ញុំាំងខន្ធាទិលោកនេះឱ្យភ្លឺច្បាស់ ដូចព្រះចន្ទ្រវះផុតចាកពពក ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែងនៅ "**វត្តជេតពន**" ប្រារព្ធ **ព្រះអង្គុលិមាលត្ថេរ**) ។
☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេច **លោកុត្តរផល** មាន **សោតាបត្តិផល**ជាដើម ។

១៧៤.. **អន្ធភូតោ អយំ លោកោ   តនុកេត្ថ វិបស្សតិ**
សកុន្តោ (សកុណោ) **ជាលមុត្តោវ   អប្បោ សគ្គាយ គច្ឆតិ ។**

លោកិយមហាជននេះ ជាមនុស្សងងឹត **បណ្ឌិតជនទាំងនេះ** ជនតិចគ្នា ដែលឃើញច្បាស់ (**នូវខន្ធាទិលោកនេះ ដោយអំណាចអនិច្ចលក្ខណៈជាដើម**) ជនតិចគ្នា ដែលទៅកាន់ឋានសួគ៌ ដូចសត្វស្លាប (**ដែលជាប់សំណាញ់របស់ព្រានហើយ**) តិចណាស់ ដែលរួចអំពីសំណាញ់ ដូច្នោះ ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែងនៅនា "**អគ្គាឡវចេតិយ**" ប្រារព្ធនាង**ធីតា**កូនស្រីជាងតម្បាញម្នាក់) ។

☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេច **លោកុត្តរផល** មាន **សោតាបត្តិផល**ជាដើម ។

១៧៥.. **ហំសាទិច្ចបថេ**[១] **យន្តិ** **អាកាសេ យន្តិ ឥទ្ធិយា**
នីយន្តិ ធីរា លោកម្ហា **ជេត្វា មារំ សវាហនំ** ។

ពួកហង្ស តែងហើរទៅក្នុងគន្លងផ្លូវព្រះអាទិត្យ, អ្នកមានឫទ្ធិ តែងហោះទៅក្នុងអាកាស ដោយឫទ្ធិ, អ្នកប្រាជ្ញ ផ្ចាញ់កិលេសមារ ព្រមទាំងវាហនៈ គឺ តណ្ហាបានហើយ រមែងរលាស់ខ្លួន ចេញចាកលោកបាន ។

☸ (**ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែងនៅ "**វត្តជេតពន**" ប្រារព្ធ ភិក្ខុ ៣០ រូប) ។

☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេច **អរិយផល** ទាំងឡាយ មាន **សោតាបត្តិផល**ជាដើម ។

១៧៦.. **ឯកំ ធម្មំ អតីតស្ស** **មុសាវាទិស្ស ជន្តុនោ**
វិតិណ្ណបរលោកស្ស **នត្ថិ បាបំ អការិយំ** ។

---

[១] ក្នុង **អដ្ឋកថា** គឺយ៉ាងនេះ : **ហំសា អាទិច្ចបថេ យន្តិ** ...

បុគ្គលប្រព្រឹត្តកន្លង (ពាក្យសច្ចៈ) ដែលជាធម៌ឯក និយាយតែពាក្យកុហក មានបរលោក លះចោលហើយ ឈ្មោះថា មិនធ្វើអំពើបាប មិនមែនឡើយ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្ដែងនៅ "វត្តជេតពន" ប្រារព្ធ នាងចិញ្ចមាណវិកា)។

☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេច អរិយផល ទាំងឡាយ មាន សោតាបត្តិផលជាដើម ។

១៧៧.. ន វេ កទរិយា ទេវលោកំ វជន្តិ
ពាលា ហវេ នប្បសំសន្តិ ទានំ
ធីរោ ច ទានំ អនុមោទមានោ
តេនេវ សោ ហោតិ សុខី បរត្ថ ។

បុគ្គលកំណាញ់ស្វិតស្វាញ មិនបានទៅកាន់ទេវលោកទេ ជនពាលទាំងឡាយ មិនសរសើរទានឡើយ, ចំណែកអ្នកប្រាជ្ញ តែងអនុមោទនាទាន ព្រោះហេតុនោះ លោកតែងបានសេចក្ដីសុខ ក្នុងលោកខាងមុខ ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្ដែងនៅ "វត្តជេតពន" ប្រារព្ធ អសទិសទាន)។

☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជុណ្ហអាមាត្យ តាំងនៅក្នុងសោតាបត្តិផល ។

១៧៨.. បថព្យា ឯករជ្ជេន សគ្គស្ស គមនេន វា
សព្វលោកាធិបច្ចេន សោតាបត្តិផលំ វរំ ។

សោតាបត្តិផល ជាគុណជាតដ៏ប្រសើរជាងភាពនៃឯករាជ្យលើផែនដីផង ជាងដំណើរទៅកាន់ឋានសួគ៌ផង ជាងភាពជាធំក្នុងលោកទាំងមូលផង ។

☸ (ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែងនៅ "វត្តជេតពន" ប្រារព្ធ នាយកាឡៈ បុត្ររបស់អនាថបិណ្ឌិកសេដ្ឋី)។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេច **អរិយផល** ទាំងឡាយ មាន **សោតាបត្តិផល**ជាដើម ។

(ចប់ លោកវគ្គ ទី ១៣ = មាន ១២ គាថា)



ជំពូកទី ១៤

ពុទ្ធវគ្គ

(Buddha Vagga)

The Buddha

(Versets sur le Bouddha)

(មាន ១៨ គាថា)

(ពី គាថា ទី ១៧៩ ➩ ដល់ គាថា ទី ១៩៦)

១៧៩.. យស្ស ជិតំ នាវជីយតិ
ជិតមស្ស នោយាតិ កោចិ លោកេ
តំ ពុទ្ធំ អនន្តគោចរំ
អបទំ កេន បទេន នេស្សថ ។

១៨០.. យស្ស ជាលិនី វិសត្តិកា
តណ្ហា នត្ថិ កុហិញ្ចិ នេតវេ
តំ ពុទ្ធំ អនន្តគោចរំ
អបទំ កេន បទេន នេស្សថ ។

ជ័យជំនះរបស់ព្រះពុទ្ធអង្គណា មិនត្រឡប់ចាញ់វិញ កិលេសណាមួយក្នុងលោក រមែងមិនជាប់តាមជ័យជំនះ របស់ព្រះពុទ្ធអង្គនោះ នាងទាំងឡាយនឹងប្រលោមព្រះពុទ្ធអង្គនោះ ដែលមានគោចរ រកទីបំផុតគ្មាន មិនមានកិលេសដូចស្នាមជើង ដោយកិលេសដូចស្នាមជើង ម្ដេចកើត ។

តណ្ហាដែលមានបណ្ដាញផ្សាយទៅ ក្នុងអារម្មណ៍ផ្សេង ៗ មិនមានដល់ព្រះពុទ្ធអង្គណា ដើម្បីនឹងនាំទៅក្នុងភពណាមួយ នាងទាំងឡាយនឹងប្រលោមព្រះពុទ្ធអង្គនោះ ដែលមានគោចរ រកទីបំផុតគ្មាន មិនមានកិលេសដូចស្នាមជើង ដោយកិលេសដូចស្នាមជើង ម្ដេចកើត ។

☸ ព្រះពុទ្ធគាថានេះ កាលព្រះសាស្ដាទ្រង់គង់នៅនា ពោធិមណ្ឌលស្ថាន ទ្រង់ប្រារព្ធមារធីតាទាំង ៣ រូប ។

១៨១.. យេ ឈានប្បសុតា ធីរា   នេក្ខម្មូបសមេ រតា
      ទេវាបិ តេសំ បិហយន្តិ   សម្ពុទ្ធានំ សតីមតំ   ។

អ្នកប្រាជ្ញទាំងឡាយណា ជាអ្នកខ្វល់ខ្វាយក្នុងឈាន ត្រេកអរក្នុងនេក្ខម្មៈ ជាឋានស្ងប់រម្ងាប់កិលេស សូម្បីទេវតា និង មនុស្សទាំងឡាយ តែងរាប់រកចំពោះអ្នកប្រាជ្ញទាំងឡាយនោះ ដែលជាអ្នកត្រាស់ដឹងខ្លួនឯង ទាំងមានស្មារតី ។

☸ **ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែង ប្រារព្ធ ទេវតា និង ពួកមនុស្សជាច្រើន នៅទៀបទ្វារនគរ **សង្កស្ស** : "**យមកប្បាដិហារ្យ**" ។
☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេច **ធម្មាភិសម័យ** បានមានដល់សត្វ ប្រមាណ ៣០ កោដិ ។ ភិក្ខុ ៥០០ រូប ដែលជាសទ្ធិវិហារិក របស់ព្រះសារីបុត្រ តាំងនៅក្នុង**ព្រះអរហត្ត** ។

១៨២.. កិច្ឆោ មនុស្សបដិលាភោ   កិច្ឆំ មច្ចាន ជីវិតំ
      កិច្ឆំ សទ្ធម្មស្សវនំ   កិច្ឆោ ពុទ្ធានមុប្បាទោ   ។

ការត្រឡប់បានអត្តភាពជាមនុស្ស បានដោយកម្រ, ការរស់របស់សត្វទាំងឡាយ បានដោយកម្រ, ការស្តាប់ធម៌របស់សប្បុរស បានដោយកម្រ ការកើតឡើងនៃ **ព្រះពុទ្ធ** ទាំងឡាយ បានដោយកម្រ ។

☸ **ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែងនៅទៀបគល់នៃដើមច្រេសក្នុងនគរពារាណសី ប្រារព្ធ ឯរកបត្តនាគរាជ ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ពួកសត្វ ៨៤.០០០ បានត្រាស់ដឹងធម៌ ។ ចំណែក ឯរកបត្តនាគរាជ គួរនឹងបានសម្រេច សោតាបត្តិផល ក្នុងថ្ងៃនោះ ប៉ុន្តែមិនបានសម្រេច ព្រោះខ្លួនជាសត្វតិរច្ឆាន ។

១៨៣.. សព្វបាបស្ស អករណំ កុសលស្សូបសម្បទា
សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំ ។

១៨៤.. ខន្តិ បរមំ តបោ តីតិក្ខា
និព្វានំ បរមំ វទន្តិ ពុទ្ធា
ន ហិ បព្វជិតោ បរូបឃាតី
សមណោ ហោតិ បរំ វិហេឋយន្តោ ។

១៨៥.. អនូបវាទោ អនូបឃាតោ បាតិមោក្ខេ ច សំវរោ
មត្តញ្ញុតា ច ភត្តស្មឹ បន្តញ្ច សយនាសនំ
អធិចិត្តេ ច អាយោគោ ឯតំ ពុទ្ធាន សាសនំ ។

ការមិនធ្វើបាបទាំងពួង ការញុំាងកុសលឱ្យកើតឡើង ការធ្វើចិត្តរបស់ខ្លួនឱ្យផូរផង់ នេះជាពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធទាំងឡាយ ។

ខន្តី គឺសេចក្ដីអត់ធន់ ជាតបធម៌ [9] ដ៏ឧត្ដម ព្រះពុទ្ធទាំងឡាយតែងពោលថា **ព្រះនិព្វាន** ជាធម្មជាតដ៏ឧត្ដម បុគ្គលដែលសម្លាប់សត្វដទៃ មិនឈ្មោះថា **បព្វជិត** ទេ, បុគ្គលដែលបៀតបៀនសត្វដទៃ ក៏មិនឈ្មោះថា **សមណៈ** ឡើយ ។

ការមិនតិះដៀល, ការមិនបៀតបៀន, ការសង្រួមក្នុងបាតិមោក្ខ, ភាពជាអ្នកដឹងប្រមាណក្នុងភត្ត, ការដេក និង អង្គុយក្នុងទីស្ងាត់, ការព្យាយាមក្នុងអធិចិត្ត, នុ៎ះជាពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធទាំងឡាយ ។

---

[9] ធម្មជាតដុតកិលេសឱ្យក្ដៅ ។

☸ ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែង កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ បញ្ហារបស់ ព្រះអានន្ទត្ថេរ ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផល ជាដើម ។

១៨៦.. ន កហាបណវស្សេន តិត្តិ កាមេសុ វិជ្ជតិ
អប្បស្សាទា ទុក្ខា កាមា ឥតិ វិញ្ញាយ បណ្ឌិតោ ។
១៨៧.. អបិ ទិព្វេសុ កាមេសុ រតឹ សោ នាធិគច្ឆតិ
តណ្ហក្ខយរតោ ហោតិ សម្មាសម្ពុទ្ធសាវកោ ។

ការស្កប់ស្កល់ ក្នុងកាមទាំងឡាយ រមែងមិនមាន ព្រោះកហាបនៈ (ដែលធ្លាក់ចុះ) ដូចទឹកភ្លៀងទេ, **កាមទាំងឡាយ មានសុខតិច មានទុក្ខច្រើន អ្នកប្រាជ្ញ** ដឹងច្បាស់យ៉ាងនេះហើយ លោកមិនបានត្រេកអរក្នុងកាមទាំងឡាយ សូម្បីជាទិព្វឡើយ **សាវ័ករបស់ព្រះសម្មាសម្ពុទ្ធ រមែងជាអ្នកត្រេកអរក្នុងធម៌** ជាគ្រឿងអស់តណ្ហា ។

☸ ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែង កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ ភិក្ខុអ្នកមិនត្រេកអរក្នុងព្រហ្មចារ្យ មួយរូប ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ភិក្ខុនោះតាំងនៅក្នុង សោតាបត្តិផល ។

១៨៨.. ពហុំ វេ សរណំ យន្តិ បព្វតានិ វនានិ ច
អារាមរុក្ខចេត្យានិ មនុស្សា ភយតជ្ជិតា ។
១៨៩.. នេតំ ខោ សរណំ ខេមំ នេតំ សរណមុត្តមំ
នេតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ ។

១៩០.. យោ ច ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ
ចត្តារិ អរិយសច្ចានិ សម្មប្បញ្ញាយ បស្សតិ ។
១៩១.. ទុក្ខំ ទុក្ខសមុប្បាទំ ទុក្ខស្ស ច អតិក្កមំ
អរិយញ្ចដ្ឋង្គិកំ មគ្គំ ទុក្ខូបសមគាមិនំ ។
១៩២.. ឯតំ ខោ សរណំ ខេមំ ឯតំ សរណមុត្តមំ
ឯតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ ។

មនុស្សទាំងឡាយច្រើននាក់ ត្រូវភ័យគម្រាមហើយ តែងយកភ្នំ អារាម និង រុក្ខចេតិយ ជាទីពឹង, **ទីពឹងបែបនេះ** មិនមែនជាទីពឹងដ៏ក្សេមទេ ទីពឹងបែបនេះ មិនមែនជាទីពឹងដ៏ឧត្តមទេ បុគ្គលអាស្រ័យនូវទីពឹងនេះ ហើយ រមែងមិនរួចស្រឡះចាកទុក្ខទាំងពួងឡើយ ។

លុះតែបុគ្គលណា យក **ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ** ជាទីពឹង ឃើញច្បាស់នូវ **អរិយសច្ច** ទាំង ៤ គឺ **ទុក្ខសច្ច, ទុក្ខសមុទយសច្ច, និរោធសច្ច** កន្លងទុក្ខ, **អរិយមគ្គ** ប្រកបដោយអង្គ **៨** ជាដំណើរទៅកាន់ **ព្រះ-និព្វាន** ដែលជាទីរម្ងាប់ទុក្ខ, ដោយប្រាជ្ញាដ៏ប្រពៃ **នេះឯង ជាទីពឹងដ៏ក្សេម នេះឯងជាទីពឹងដ៏ឧត្តម** បុគ្គលអាស្រ័យទីពឹងនេះ រមែងរួចស្រឡះចាកទុក្ខទាំងពួងបាន ។

☸ **ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្តែង កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ **បុរោហិត** ឈ្មោះ **អគ្គិទត្ត** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា **ឥសី**ទាំងអស់នោះ បានសម្រេច**ព្រះអរហត្ត** មួយអន្លើដោយ**បដិសម្ភិទា** ទាំងឡាយ ។

១៩៣.. ទុល្លភោ បុរិសាជញ្ញោ ន សោ សព្វត្ថ ជាយតិ
យត្ថ សោ ជាយតី ធីរោ តំ កុលំ សុខមេធតិ ។

បុរសអាជានេយ្យ រកបានដោយកម្រ លោកមិនកើតក្នុងសព្វឋានឡើយ លោកជាអ្នកមានប្រាជ្ញា កើតក្នុងត្រកូលណា ត្រកូលនោះ តែងដល់នូវសេចក្ដីសុខ ។

☸ ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្ដែង កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ បញ្ហារបស់ ព្រះអានន្ទត្ថេរ ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផល ជាដើម ។

១៩៤.. សុខោ ពុទ្ធានមុប្បាទោ សុខា សទ្ធម្មទេសនា
សុខា សង្ឃស្ស សាមគ្គី សមគ្គានំ តបោ សុខោ ។

ការកើតឡើងនៃព្រះពុទ្ធ ជាសុខ, ការសម្ដែងព្រះសទ្ធម្ម ជាសុខ សេចក្ដីព្រមព្រៀងគ្នានៃពួក ជាសុខ, តបធម៌ របស់បុគ្គលអ្នកព្រមព្រៀងគ្នាទាំងឡាយ ជាសុខ ។

☸ ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្ដែង កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ ការសន្ទនារបស់ភិក្ខុច្រើនរូប ។ ☞ ក្នុងវេលាចប់ព្រះធម្មទេសនា ភិក្ខុជាច្រើនបានសម្រេច អរហត្តផល។

១៩៥.. បូជារហេ បូជយតោ ពុទ្ធេ យទិ ច សាវកេ
បបញ្ចសមតិក្កន្តេ តិណ្ណសោកបរិទ្ទវេ ។

១៩៦.. តេ តាទិសេ បូជយតោ និព្វុតេ អកុតោភយេ
ន សក្កា បុញ្ញំ សង្ខាតុំ ឥមេត្តមបិ កេនចិ ។

កាលបុគ្គលបូជា ដល់ **បូជារហបុគ្គល** គឺ **ព្រះពុទ្ធ** ឬ សាវ័ករបស់ **ព្រះពុទ្ធ** ដែលកន្លងផុត **បបញ្ចធម៌** ដែលកន្លងផុតសេចក្ដីសោក និង ខ្សឹកខ្សួល ឬ កាលបូជាដល់ **បូជារហបុគ្គល** ទាំងនោះ ដែលប្រកបដោយ **គាទិគុណ** លោកមិនមានភ័យអំពីទីណា សូម្បីនិព្វានទៅហើយ បុគ្គលណាមួយ មិនអាចរាប់បុណ្យថា បុណ្យនេះ មានប្រមាណប៉ុណ្ណេះ បានឡើយ ។

☸ **ព្រះពុទ្ធគាថា**នេះ ទ្រង់ត្រាស់សម្ដែង កាលព្រះដ៏មានព្រះភាគ ទ្រង់ត្រាច់ទៅកាន់ទីចារិក ទ្រង់ប្រារព្ធព្រះចេតិយមាស របស់ **ព្រះកស្សបទសពល**។ ☞ ក្នុងវេលាចប់ ព្រះធម្មទេសនា **ធម្មាភិសម័យ** (ការត្រាស់ដឹងធម៌) បានកើតមានដល់មហាជន ៨៤.០០០ ។

(ចប់ **ពុទ្ធវគ្គ** ទី ១៤ = មាន **១៨** គាថា)



ជំពូកទី ១៥

សុខវគ្គ

(Sukha Vagga)

Happiness

(Versets sur le Bonheur)

(មាន ១២ គាថា)

(ពី គាថា ទី ១៩៧ ➪ ដល់ គាថា ទី ២០៨)

១៩៧.. សុសុខំ វត ជីវាម ‌ វេរិនេសុ អវេរិនោ
វេរិនេសុ មនុស្សេសុ ‌ វិហរាម អវេរិនោ ។
១៩៨.. សុសុខំ វត ជីវាម ‌ អាតុរេសុ អនាតុរា
អាតុរេសុ មនុស្សេសុ ‌ វិហរាម អនាតុរា ។
១៩៩.. សុសុខំ វត ជីវាម ‌ ឧស្សុកេសុ អនុស្សុកា
ឧស្សុកេសុ មនុស្សេសុ ‌ វិហរាម អនុស្សុកា ។

យើងជាអ្នកមិនមានពៀរ **រស់នៅជាសុខពិត** ក្នុងពួកមនុស្សមានពៀរ កាលពួកមនុស្សមានពៀរ យើងជាអ្នកមិនមានពៀរ ។

យើងជាអ្នកមិនមានសេចក្ដីក្ដៅក្រហាយ (ដោយកិលេស) **រស់នៅជាសុខពិត** ក្នុងពួកមនុស្សមានសេចក្ដីក្ដៅក្រហាយ កាលពួកមនុស្សមានសេចក្ដីក្ដៅក្រហាយ យើងជាអ្នកមិនមានសេចក្ដីក្ដៅក្រហាយ ។

យើងជាអ្នកមិនមានសេចក្ដីខ្វល់ខ្វាយ ក្នុងការស្វែងរក **រស់នៅជាសុខពិត** ក្នុងពួកមនុស្សមានសេចក្ដីខ្វល់ខ្វាយ កាលពួកមនុស្សមានសេចក្ដីខ្វល់ខ្វាយ យើងជាអ្នកមិនមានសេចក្ដីខ្វល់ខ្វាយ ។

☸ **ព្រះពុទ្ធគាថា**នេះ *ទ្រង់ត្រាស់សម្ដែង កាលព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងដែនរបស់អ្នកស្រុកសក្កៈ ទ្រង់ប្រារព្ធពួកព្រះញាតិ ដើម្បីរម្ងាប់នូវជម្លោះវិវាទ ដណ្ដើមទឹកស្ទឹងរោហិណី ក្នុងចន្លោះនគរកបិលពស្តុ និង នគរកោលិយៈ រវាង ពួកសាក្យៈ និង ពួកកោលិយៈ* ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម។

២០០.. សុសុខំ វត ជីវាម យេសន្នោ នត្ថិ កិញ្ចនំ
បីតិភក្ខា ភវិស្សាម ទេវា អាភស្សរា យថា ។

យើងមិនមានកង្វល់ តែងរស់នៅជាសុខពិត (ព្រោះ) យើងមានបីតិ ជាអាហារ ដូចពួកទេវតាជាន់ អាភស្សរៈ ។

☸ ព្រះពុទ្ធគាថានេះ *ទ្រង់ត្រាស់សម្តែង កាលព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងស្រុកព្រាហ្មណ៍ ឈ្មោះបញ្ចសាលា ទ្រង់ប្រារព្ធមារ ។*

☞ ក្នុងកាលចប់ព្រះធម្មទេសនា កុមារិកា ៥០០ នាក់ បានតាំងនៅក្នុងសោតាបត្តិផល ។

២០១.. ជយំ វេរំ បសវតិ ទុក្ខំ សេតិ បរាជិតោ
ឧបសន្តោ សុខំ សេតិ ហិត្វា ជយបរាជយំ ។

បុគ្គលអ្នកឈ្នះ តែងរងនូវពៀរ បុគ្គលអ្នកចាញ់ តែងដេកជាទុក្ខ ចំណែកបុគ្គល លះបង់ការឈ្នះ និង ការចាញ់ចេញហើយ ជាអ្នកស្ងប់រម្ងាប់ ទើបដេកជាសុខ ។

☸ ព្រះពុទ្ធគាថានេះ *ទ្រង់ត្រាស់សម្តែង កាលព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ ការបរាជ័យក្នុងសង្គ្រាមរបស់ព្រះបាទកោសល ។*

☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផល ជាដើម ។

២០២.. នត្ថិ រាគសមោ អគ្គិ នត្ថិ ទោសសមោ កលិ
នត្ថិ ខន្ធសមា ទុក្ខា នត្ថិ សន្តិបរំ សុខំ ។

ភ្លើងស្មើដោយរាគៈ មិនមាន, ទោសកំហុសស្មើដោយទោសៈ មិនមាន ទុក្ខទាំងឡាយស្មើដោយខន្ធ មិនមាន សុខក្រៅពីសេចក្តីស្ងប់ មិនមាន ។

☸ ព្រះពុទ្ធគាថានេះ *ទ្រង់ត្រាស់សម្តែង កាលព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ គូស្វាមី-ភរិយាមួយគូ ក្នុងពេលអាវាហមង្គល ។*

☞ ក្នុងកាលចប់ព្រះធម្មទេសនា គូស្វាមី-ភរិយានេះ បានតាំងនៅក្នុងសោតាបត្តិផល ។

២០៣.. ជិឃច្ឆា បរមា រោគា សង្ខារា បរមា ទុក្ខា
ឯតំ ញត្វា យថាភូតំ និព្វានំ បរមំ សុខំ ។

សេចក្តីស្រេកឃ្លាន ជារោគយ៉ាងក្រៃលែង, សង្ខារទាំងឡាយ ជាទុក្ខយ៉ាងក្រៃលែង **(អ្នកប្រាជ្ញ)** ដឹងច្បាស់សេចក្តីនុ៎ះ តាមពិតហើយ **(រមែងធ្វើឱ្យច្បាស់)**នូវព្រះនិព្វាន ជាសុខយ៉ាងក្រៃលែង ។

☸ ព្រះពុទ្ធគាថានេះ *ទ្រង់ត្រាស់សម្តែង កាលព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងក្រុងអាឡវី ទ្រង់ប្រារព្ធ បុរសទុគ្គតគង្វាលគោមួយរូប ។*

☞ ក្នុងកាលចប់ព្រះធម្មទេសនា បុរសទុគ្គតរូបនេះ បានតាំងនៅក្នុងសោតាបត្តិផល ។

២០៤.. អារោគ្យបរមា លាភា សន្តុដ្ឋីបរមំ ធនំ
វិស្សាសបរមា ញាតី និព្វានំ បរមំ សុខំ ។

លាភ មានការមិនរោគ ជាយ៉ាងក្រៃលែង, ទ្រព្យមានសេចក្តីសន្តោស ជាយ៉ាងក្រៃលែង **ញាតិមានសេចក្តីស្និទ្ធស្នាល ជាយ៉ាងក្រៃលែង ព្រះនិព្វាន** ជាសុខយ៉ាងក្រៃលែង ។

☸ ព្រះពុទ្ធគាថានេះ *ទ្រង់ត្រាស់សម្តែង កាលព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ ព្រះបាទបសេនទិកោសល ។*

☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផល ជាដើម ។

២០៥.. បវិវេករសំ បិត្វា រសំ ឧបសមស្ស ច
និទ្ទរោ ហោតិ និប្បាបោ ធម្មបីតិរសំ បិវំ ។

ភិក្ខុផឹករស[១]វិវេកផង រសព្រះនិព្វាន ជាទីរម្ងាប់កិលេសផង ផឹករសបីតិដែលកើតអំពីធម៌ផង ទើបជាអ្នកមិនមានសេចក្តីក្រវល់ក្រវាយ មិនមានសេចក្តីសៅហ្មងឡើយ ។

☸ <u>ព្រះពុទ្ធគាថា</u>នេះ *ទ្រង់ត្រាស់សម្តែង កាលព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងក្រុង **វេសាលី** ទ្រង់ប្រារព្ធ **ព្រះតិស្សត្ថេរ** ។*

☞ ក្នុងកាលចប់ព្រះធម្មទេសនា ព្រះតិស្សត្ថេរ បានសម្រេច ព្រះអរហត្ត ។

២០៦.. សាធុ ទស្សនមរិយានំ សន្និវាសោ សទា សុខោ
អទស្សនេន ពាលានំ និច្ចមេវ សុខី សិយា ។
២០៧.. ពាលសង្គតចារី ហិ ទីឃមទ្ធាន សោចតិ
ទុក្ខោ ពាលេហិ សំវាសោ អមិត្តេនេវ សព្វទា
ធីរោ ច សុខសំវាសោ ញាតីនំវ សមាគមោ ។
២០៨.. តស្មា ហិ
ធីរញ្ច បញ្ញញ្ច ពហុស្សុតញ្ច
ធោរយ្ហសីលំ វតវន្តមរិយំ
តំ តាទិសំ សប្បុរិសំ សុមេធំ
ភជេថ នក្ខត្តបថំវ ចន្ទិមា ។

[១] **រស** ក្នុងទីនេះ សំដៅយកសេចក្តីសុខដ៏ប្រសើរ ។

ការជួបប្រទះព្រះអរិយបុគ្គលទាំងឡាយ ជាការល្អ ការនៅរួមជាមួយព្រះអរិយបុគ្គលទាំងឡាយ ជាហេតុឱ្យកើតសេចក្តីសុខសព្វកាល បុគ្គលគប្បីមានសេចក្តីសុខអស់កាលជានិច្ចបាន ព្រោះមិនជួបប្រទះបុគ្គលពាលទាំងឡាយ ។

បុគ្គល អ្នកប្រព្រឹត្តសមគប់ដោយជនពាល រមែងសោកស្តាយអស់កាលយូរអង្វែង ការនៅរួមជាមួយនឹងជនពាល រមែងជាទុក្ខសព្វកាល ដូចការនៅរួមជាមួយនឹងសត្រូវ, ចំណែកខាងការនៅរួមនឹងធីរជន រមែងជាសុខ ដូចការជួបជុំនៃញាតិទាំងឡាយ ។

☞ *ព្រោះហេតុនោះឯង,*

បុគ្គលគួរសេពគប់សប្បុរស ជាអ្នកមាំមួនផង មានបញ្ញាផង មានសេចក្តីចេះដឹងច្រើនផង មានកិរិយានាំទៅនូវធុរៈជាប្រក្រតីផង មានសីលវត្តនិង ធុតង្គវត្តផង ជាអ្នកឆ្ងាយចាកកិលេសផង មានបញ្ញាល្អផង ប្រាកដដូច្នោះៗ ឱ្យដូចព្រះចន្ទគប់នូវផ្លូវនក្ខត្តឫក្ស ។

☸ <u>ព្រះពុទ្ធគាថា</u>នេះ *ទ្រង់ត្រាស់សម្តែង កាលព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុង* ***វេឡុវគ្រាម*** *ទ្រង់ប្រារព្ធ* ***សក្កទេវរាជ*** ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផល ជាដើម ។

(ចប់ **សុខវគ្គ** ទី ១៥ = មាន **១២** គាថា)

ជំពូកទី ១៦

បិយវគ្គ

(Piya Vagga)

Affection

(*Versets sur les Affections*)

(មាន ១២ គាថា)

(ពី គាថា ទី ២០៩ ➪ ដល់ គាថា ទី ២២០)

២០៩.. អយោគេ យុញ្ជមត្តានំ យោគស្មិញ្ច អយោជយំ
អត្ថំ ហិត្វា បិយគ្គាហី បិហេតត្តានុយោគិនំ ។
២១០.. មា បិយេហិ សមាគញ្ឆិ អប្បិយេហិ កុទាចនំ
បិយានំ អទស្សនំ ទុក្ខំ អប្បិយានញ្ច ទស្សនំ ។
២១១.. តស្មា បិយំ ន កយិរាថ បិយាបាយោ ហិ បាបកោ
គន្ថា តេសំ ន វិជ្ជន្តិ យេសំ នត្ថិ បិយាប្បិយំ ។

បុគ្គលកាលប្រកបខ្លួន ទុកក្នុងអំពើដែលមិនគួរប្រកប មិនប្រកបខ្លួនក្នុងអំពើដែលគួរប្រកប លះបង់ប្រយោជន៍ចេញហើយ កាន់យកតាមគាប់ចិត្ត រមែងស្រឡាញ់ បុគ្គលអ្នកប្រកបតាមខ្លួន ។

កុំគប់រកសត្វ និង សង្ខារទាំងឡាយ ដែលជាទីស្រឡាញ់ និង មិនជាទីស្រឡាញ់ ក្នុងកាលណា ៗ ឡើយ ព្រោះថា ការមិនជួបប្រសព្វសត្វ និង សង្ខារជាទីស្រឡាញ់ក្តី ការជួបប្រសព្វសត្វ និង សង្ខារមិនជាទីស្រឡាញ់ក្តី ជាហេតុនាំមកនូវទុក្ខ ។

ព្រោះហេតុនោះ បុគ្គលមិនគួរធ្វើសត្វ និង សង្ខារ ឱ្យជាទីស្រឡាញ់ (ឡើយ) ព្រោះការព្រាត់ប្រាសចាកសត្វ និង សង្ខារជាទីស្រឡាញ់ ជាសភាពអាក្រក់, ការស្រឡាញ់ និង ការស្អប់ មិនមានដល់ពួកជនណា កិលេស គ្រឿងចាក់ស្រែះទាំងឡាយ តែងមិនមានដល់ពួកជននោះ ។

☸ <u>ព្រះពុទ្ធគាថា</u>នេះ *ទ្រង់ត្រាស់សម្តែង កាលព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ បព្វជិត ៣ រូប ។*

☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផល ជាដើម ។

២១២.. បិយតោ ជាយតី សោកោ បិយតោ ជាយតី ភយំ
បិយតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។

សេចក្តីសោក កើតអំពីសេចក្តីស្រឡាញ់, ភ័យកើតអំពីសេចក្តីស្រឡាញ់ កាលបើរួចស្រឡះចាកសេចក្តីស្រឡាញ់ហើយ សេចក្តីសោក ក៏លែងមាន ភ័យនឹងមានមកពីណា ។

☸ ព្រះពុទ្ធគាថានេះ *ទ្រង់ត្រាស់សម្តែង កាលព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ កុដុម្ពិកម្នាក់ ។*

☞ ក្នុងកាលចប់ព្រះធម្មទេសនា កុដុម្ពិករូបនោះ បានសម្រេចនូវសោតាបត្តិផល ។

២១៣.. បេមតោ ជាយតី សោកោ បេមតោ ជាយតី ភយំ
បេមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។

សេចក្តីសោក កើតអំពីសេចក្តីស្រឡាញ់, ភ័យកើតអំពីសេចក្តីស្រឡាញ់ កាលបើរួចស្រឡះចាកសេចក្តីស្រឡាញ់ហើយ សេចក្តីសោក ក៏លែងមាន ភ័យនឹងមានមកពីណា ។

☸ ព្រះពុទ្ធគាថានេះ *ទ្រង់ត្រាស់សម្តែង កាល ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ នាងវិសាខាឧបាសិកា ។*

២១៤.. រតិយា ជាយតី សោកោ រតិយា ជាយតី ភយំ
រតិយា វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។

សេចក្តីសោក កើតអំពីតម្រេក, ភ័យកើតអំពីតម្រេក កាលបើរួចស្រឡះចាកតម្រេកហើយ សេចក្តីសោកក៏លែងមាន ភ័យនឹងមានមកពីណា ។

☸ ព្រះពុទ្ធគាថានេះ *ទ្រង់ត្រាស់សម្តែង កាលព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារសាលា ក្រុងវេសាលី ទ្រង់ប្រារព្ធ ពួកស្តេចលិច្ឆវី ។*

☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផល ជាដើម ។

២១៥.. កាមតោ ជាយតី សោកោ កាមតោ ជាយតី ភយំ
កាមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។

សេចក្តីសោក កើតអំពីកាម, ភ័យកើតអំពីកាម កាលបើរួចស្រឡះចាកកាមហើយ សេចក្តីសោកក៏លែងមាន ភ័យនឹងមានមកពីណា ។

☸ ព្រះពុទ្ធគាថានេះ *ទ្រង់ត្រាស់សម្តែង កាលព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ* ***អនិត្ថិគន្ធកុមារ*** *។*

☞ ក្នុងកាលចប់ព្រះធម្មទេសនា **អនិត្ថិគន្ធកុមារ** បានសម្រេចសោតាបត្តិផល ។

២១៦.. តណ្ហាយ ជាយតី សោកោ តណ្ហាយ ជាយតី ភយំ
តណ្ហាយ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។

សេចក្តីសោក កើតអំពីតណ្ហា, ភ័យកើតអំពីតណ្ហា កាលបើរួចស្រឡះចាកតណ្ហាហើយ សេចក្តីសោកក៏លែងមាន ភ័យនឹងមានមកពីណា ។

☸ ព្រះពុទ្ធគាថានេះ *ទ្រង់ត្រាស់សម្តែង កាលព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ* ***ព្រាហ្មណ៍ម្នាក់*** *។*

☞ ក្នុងកាលចប់ព្រះធម្មទេសនា **ព្រាហ្មណ៍**នោះ បានសម្រេចសោតាបត្តិផល ។

២១៧.. សីលទស្សនសម្បន្នំ ធម្មដ្ឋំ សច្ចវាទិនំ
អត្តនោ កម្មកុព្វានំ តញ្ជនោ កុរុតេ បិយំ ។

ជនតែងធ្វើបុគ្គលដែលបរិបូណ៌ ដោយសីល និង ការឃើញត្រូវ ឋិតនៅក្នុងធម៌ ពោលសច្ចធម៌[១] ជាប្រក្រតី ធ្វើកម្ម[២] ជារបស់ខ្លួននោះ ឱ្យជាទីស្រឡាញ់ ។

☸ ព្រះពុទ្ធគាថានេះ *ទ្រង់ត្រាស់សម្ដែង កាល **ព្រះដ៏មានព្រះភាគ** ទ្រង់គង់នៅក្នុង **វត្តវេឡុវ័ន** ទ្រង់ប្រារព្ធ **កុមារ** ៥០០ នាក់ នៅតាមចន្លោះផ្លូវ ។*

☞ ក្នុងកាលចប់ព្រះធម្មទេសនា **កុមារ**ទាំងអស់នោះ បានសម្រេចសោតាបត្តិផល ។

២១៨.. ឆន្ទជាតោ អនក្ខាតេ មនសា ច ផុដោ សិយា
កាមេ ច អប្បដិពទ្ធចិត្តោ ឧទ្ធំសោតោតិ វុច្ចតិ ។

បុគ្គល អ្នកមានសេចក្ដីប្រាថ្នា ចំពោះព្រះនិព្វាន ដែលគេនិយាយប្រាប់គ្នាមិនបានផង ជាអ្នកមានមគ្គចិត្ត និង ផលចិត្ត (ខាងក្រោម) ប៉ះពាល់ហើយផង មានចិត្តមិនប្រតិព័ទ្ធក្នុងកាមផង **តថាគត** ហៅថា ជាអ្នកមានខ្សែមគ្គប្រព្រឹត្តទៅ ក្នុងខាងលើ ។

☸ ព្រះពុទ្ធគាថានេះ *ទ្រង់ត្រាស់សម្ដែង កាល **ព្រះដ៏មានព្រះភាគ** ទ្រង់គង់នៅក្នុង **វត្តជេតពន** ទ្រង់ប្រារព្ធ **ព្រះអនាគាមិត្ថេរ** មួយអង្គ ។*

☞ ក្នុងកាលចប់ព្រះធម្មទេសនា ពួក**ភិក្ខុ**ជា**សទ្ធិវិហារិក** បានសម្រេចអរហត្តផល ។

២១៩.. ចិរប្បវាសឹ បុរិសំ ទូរតោ សោត្ថិមាគតំ
ញាតី មិត្តា សុហជ្ជា ច អភិនន្ទន្តិ អាគតំ ។

---

[១] សំដៅយក **អរិយសច្ច ៤** ។
[២] បានដល់ **ត្រៃសិក្ខា** ។ **អដ្ឋកថា** ។

២២០.. តថេវ កតបុញ្ញម្បិ អស្មា លោកា បរំ គតំ
បុញ្ញានិ បដិគណ្ហន្តិ បិយំ ញាតីវ អាគតំ ។

ពួកញាតិក្តី មិត្រក្តី សម្លាញ់ក្តី រមែងត្រេកអរនឹងបុរស ដែលឃ្លាតគ្នាអស់កាលយូរ មកអំពីចម្ងាយដោយសួស្តី មកដល់ហើយ យ៉ាងណាមិញ បុណ្យទាំងឡាយ តែងទទួលបុគ្គល ដែលបានធ្វើបុណ្យ ច្យុតអំពីមនុស្សលោកនេះ ទៅកាន់លោកខាងមុខ ដូចញាតិទាំងឡាយ ទទួលបុរសជាទីស្រឡាញ់ ទើបមកដល់ ដូច្នោះឯង ។

☸ ព្រះពុទ្ធគាថានេះ *ទ្រង់ត្រាស់សម្តែង កាលព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងព្រៃឥសិបតនៈ ទ្រង់ប្រារព្ធ* ***នន្ទិយកុលបុត្រ*** *។*

☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផល ជាដើម ។

(ចប់ **បិយវគ្គ** ទី ១៦ = មាន **១២** គាថា)

ជំពូកទី ១៧

កោធវគ្គ

(Kodha Vagga)

Anger

(Versets sur la Colère)

(មាន ១៤ គាថា)

(ពី គាថា ទី ២២១ ➩ ដល់ គាថា ទី ២៣៤)

២២១.. កោធំ ជហេ វិប្បជហេយ្យ មានំ
សញ្ញោជនំ សព្វមតិក្កមេយ្យ
តន្នាមរូបស្មិ មសជ្ជមានំ
អកិញ្ចនំ នានុបតន្តិ ទុក្ខា ។

បុគ្គលគួរលះបង់សេចក្តីក្រោធចេញ គួរលះបង់មានះចេញ គួរកន្លងសញ្ញោជនធម៌ទាំងអស់ចោលចេញ ទុក្ខទាំងឡាយ តែងមិនជាប់តាមបុគ្គល ដែលមិនជំពាក់ក្នុងនាម និង រូប មិនមានកិលេស គ្រឿងកង្វល់នោះឡើយ ។

☸ **ព្រះពុទ្ធគាថា**នេះ *ទ្រង់ត្រាស់សម្តែង កាល **ព្រះដ៏មានព្រះភាគ** ទ្រង់គង់នៅក្នុង **និគ្រោធារាម** ទ្រង់ប្រារព្ធ **ខត្តិយកញ្ញា** ឈ្មោះ **រោហិណី** ។*

☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផល ជាដើម ។ **ព្រះនាងរោហិណី** ក៏បានសម្រេចនូវសោតាបត្តិផលដែរ ។

២២២.. យោ វេ ឧប្បតិតំ កោធំ រថំ ភន្តំវ ធារយេ
តមហំ សារថឹ ព្រូមិ រស្មិគ្គាហោ ឥតរោ ជនោ ។

បុគ្គលណា ឃាត់សេចក្តីក្រោធ ដែលកើតឡើងហើយ ដូចសារថីទប់រថដែលកំពុងលឿនបាន **តថាគត** ហៅបុគ្គលនោះថា ជាសារថីជនក្រៅពីនេះ គ្រាន់តែជាអ្នកកាន់ខ្សែបរ (មិនមែនសារថីឡើយ) ។

☸ **ព្រះពុទ្ធគាថា**នេះ *ទ្រង់ត្រាស់សម្តែង កាល **ព្រះដ៏មានព្រះភាគ** ទ្រង់គង់នៅក្បែរ **អគ្គាឡវចេតិយ** ទ្រង់ប្រារព្ធ **ភិក្ខុមួយរូប** ។*

☞ ក្នុងកាលចប់ព្រះធម្មទេសនា ទេវតាមួយអង្គ បានតាំងនៅក្នុងសោតាបត្តិផល ។

២២៣.. អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ
ជិនេ កទរិយំ ទានេន សច្ចេនាលិកវាទិនំ ។

បុគ្គលគប្បីផ្ចាញ់មនុស្សក្រោធ ដោយសេចក្ដីមិនក្រោធ, គប្បីផ្ចាញ់មនុស្សអសប្បុរស ដោយសប្បុរស, គប្បីផ្ចាញ់មនុស្សកំណាញ់ ដោយការឱ្យ, គប្បីផ្ចាញ់មនុស្សនិយាយពាក្យមិនពិត ដោយពាក្យពិត ។

☸ ព្រះពុទ្ធគាថានេះ *ទ្រង់ត្រាស់សម្ដែង កាល* ***ព្រះដ៏មានព្រះភាគ*** *ទ្រង់គង់នៅក្នុង* ***វត្តវេឡុវ័ន*** *ទ្រង់ប្រារព្ធ* ***នាងឧត្តរាឧបាសិកា*** *។*

☞ ក្នុងកាលចប់ព្រះធម្មទេសនា**នាងសិរិមា** មួយអន្លើដោយបរិវារទាំង ៥០០ របស់នាងឧត្តរាឧបាសិកា បានតាំងនៅក្នុង **សោតាបត្តិផល** ។

២២៤.. សច្ចំ ភណេ ន កុជ្ឈេយ្យ ទជ្ជា អប្បស្មិ យាចិតោ
ឯតេហិ តីហិ ឋានេហិ គច្ឆេ ទេវាន សន្តិកេ ។

បុគ្គលគួរពោលពាក្យពិត, មិនគួរក្រោធ, កាលគេសូមវត្ថុសូម្បីមានតិច ក៏គួរឱ្យ (តាមតិច), បុគ្គលគប្បីទៅកើត ក្នុងសំណាក់ទេវតាទាំងឡាយបាន ដោយហេតុទាំង ៣ នេះឯង ។

☸ ព្រះពុទ្ធគាថានេះ *ទ្រង់ត្រាស់សម្ដែង កាល* ***ព្រះដ៏មានព្រះភាគ*** *ទ្រង់គង់នៅក្នុង* ***វត្តជេតពន*** *ទ្រង់ប្រារព្ធ* ***បញ្ហារបស់ព្រះមហាមោគ្គល្លានត្ថេរ*** *។*

☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

២២៥.. អហឹសកា យេ មុនយោ និច្ចំ កាយេន សំវុតា
តេ យន្តិ អច្ចុតំ ឋានំ យត្ថ គន្ត្វា ន សោចរេ ។

ជនទាំងឡាយណា ជាអ្នកប្រាជ្ញ[១] មិនបៀតបៀនសត្វដទៃ សង្រួមហើយដោយកាយទ្វារ (ជាដើម) ជានិច្ច ជនទាំងឡាយនោះ រមែងទៅកាន់ស្ថានដ៏មិនប្រែប្រួល ជាស្ថានដែលគេទៅដល់ហើយ តែងមិនសោកស្តាយ ។

☸ __ព្រះពុទ្ធគាថានេះ__ *ទ្រង់ត្រាស់សម្តែង កាល* ***ព្រះដ៏មានព្រះភាគ*** *ទ្រង់គង់នៅក្នុងព្រៃ* ***អញ្ជនវ័ន*** *ក្រុងសាកេត ទ្រង់ប្រារព្ធ* ***បញ្ហាដែលភិក្ខុទាំងឡាយ*** *ទូលសួរ ។*

☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយមាន **សោតាបត្តិផល** ជាដើម ។

២២៦.. សទា ជាគរមានានំ អហោរត្តានុសិក្ខិនំ
និព្វានំ អធិមុត្តានំ អត្ថំ គច្ឆន្តិ អាសវា ។

អាសវៈទាំងឡាយរបស់បុគ្គល អ្នកភ្ញាក់រឭកសព្វកាល ជាអ្នកសិក្សាត្រៃសិក្ខា ទាំងថ្ងៃទាំងយប់ មានចិត្តចុះស៊ប់កាន់ព្រះនិព្វាន តែងដល់នូវការតាំងនៅមិនបានឡើយ ។

☸ __ព្រះពុទ្ធគាថានេះ__ *ទ្រង់ត្រាស់សម្តែង កាល* ***ព្រះដ៏មានព្រះភាគ*** *ទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ទ្រង់ប្រារព្ធ ទាសីរបស់សេដ្ឋីក្រុងរាជគ្រឹះឈ្មោះ* ***នាងបុណ្ណា*** *។*

☞ ក្នុងកាលចប់ព្រះធម្មទេសនា **នាងបុណ្ណា** បានសម្រេច **សោតាបត្តិផល** ។

២២៧.. បោរាណមេតំ អតុល នេតំ អជ្ជតនាមិវ
និន្ទន្តិ តុណ្ហិមាសីនំ និន្ទន្តិ ពហុភាណិនំ
មិតភាណិម្បិ និន្ទន្តិ នត្ថិ លោកេ អនិន្ទិតោ ។

---

[១] សំដៅយក **អសេក្ខមុនី** ដែលសម្រេចមគ្គផល ដោយមោនេយ្យប្បដិបទា ។ អដ្ឋកថា ។

២២៨.. ន ចាហុ ន ច ភវិស្សតិ ន ចេតរហិ វិជ្ជតិ
ឯកន្តំ និន្ទិតោ បោសោ ឯកន្តំ វា បសំសិតោ ។
២២៩.. យញ្ចេ វិញ្ញូ បសំសន្តិ អនុវិច្ច សុវេ សុវេ
អច្ឆិទ្ទវុត្តឹ មេធាវឹ បញ្ញាសីលសមាហិតំ ។
២៣០.. នេក្ខំ ជម្ពោនទស្សេវ កោ តំ និន្ទិតុមរហតិ
ទេវាបិ នំ បសំសន្តិ ព្រហ្មុនាបិ បសំសិតោ ។

ម្នាលអតុល: ការតិះដៀល និង ការសរសើរនេះ ជារបស់បូរាណ ការតិះដៀល និង ការសរសើរនេះ មិនមែនទើបនឹងកើតឡើងក្នុងថ្ងៃនេះទេ (ព្រោះថា) ជនទាំងឡាយ តែងនិន្ទាបុគ្គលអ្នកអង្គុយស្ងៀម ក៏មាន និន្ទាបុគ្គលអ្នកនិយាយច្រើនក៏មាន និន្ទាបុគ្គលអ្នកនិយាយល្មមប្រមាណក៏មាន, (អ្នកណា ៗ ក៏ដោយ) ក្នុងលោក ដែលមិនត្រូវគេនិន្ទា គ្មានឡើយ, បុគ្គលដែលត្រូវគេនិន្ទាតែម្យ៉ាង ឬ ត្រូវគេសរសើរតែម្យ៉ាង មិនមែនមានមកហើយ តែក្នុងអតីតទេ នឹងមានទៅក្នុងអនាគតក៏ទេ មានតែក្នុងបច្ចុប្បន្ននេះក៏ទេ ។

បើអ្នកប្រាជ្ញទាំងឡាយ សង្កេតមើលរាល់ ៗ ថ្ងៃ ហើយសរសើរបុគ្គលណា ដែលជាអ្នកប្រព្រឹត្តមិនដាច់ មានប្រាជ្ញា មានចិត្តតម្កល់ខ្ជាប់ក្នុងបញ្ញា និង សីល អ្នកណាគួរនឹងនិន្ទាបុគ្គល ដែលដូចជាឆ្កោរនៃមាសជម្ពូនទនោះបាន សូម្បីទេវតា និង មនុស្សទាំងឡាយ ក៏សរសើរបុគ្គលនោះ ទាំងព្រហ្មក៏សរសើរ (ដូចគ្នា) ។

☸ <u>**ព្រះពុទ្ធគាថា**នេះ</u> *ទ្រង់ត្រាស់សម្តែង កាល **ព្រះដ៏មានព្រះភាគ** ទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ **អតុលឧបាសក** និង បរិវារ ៥០០ នាក់ ។* ☞ ក្នុងកាលចប់ព្រះធម្មទេសនា **ពួកឧបាសក** ទាំង ៥០០ នាក់ បានសម្រេច **សោតាបត្តិផល** ។

២៣១.. កាយប្បកោបំ រក្ខេយ្យ	កាយេន សំវុតោ សិយា
កាយទុច្ចរិតំ ហិត្វា	កាយេន សុចរិតំ ចរេ ។

២៣២.. *វចីបកោបំ រក្ខេយ្យ	វាចាយ សំវុតោ សិយា*
*វចីទុច្ចរិតំ ហិត្វា	វាចាយ សុចរិតំ ចរេ* ។

២៣៣.. មនោបកោបំ រក្ខេយ្យ	មនសា សំវុតោ សិយា
មនោទុច្ចរិតំ ហិត្វា	មនសា សុចរិតំ ចរេ ។

២៣៤.. កាយេន សំវុតា ធីរា	អថោ វាចាយ សំវុតា
មនសា សំវុតា ធីរា	តេ វេ សុបរិសំវុតា ។

បុគ្គលគប្បីរក្សានូវការកម្រើកកាយ គប្បីសង្រួមកាយ គប្បីលះបង់កាយទុច្ចរិត គប្បីប្រព្រឹត្តកាយសុចរិត, **គប្បីរក្សានូវការកម្រើកវាចា គប្បីសង្រួមវាចា គប្បីលះបង់វចីទុច្ចរិត គប្បីប្រព្រឹត្តវចីសុចរិត**, គប្បីរក្សានូវការកម្រើកចិត្ត គប្បីសង្រួមចិត្ត គប្បីលះបង់មនោទុច្ចរិត គប្បីប្រព្រឹត្តមនោសុចរិត ។

☞ *អ្នកប្រាជ្ញទាំងឡាយ បានសង្រួមកាយ សង្រួមវាចា អ្នកប្រាជ្ញទាំងឡាយ បានសង្រួមចិត្តហើយ លោកទាំងនោះឯង ឈ្មោះថាសង្រួមហើយដោយប្រពៃ ។*

☸ **ព្រះពុទ្ធគាថា**នេះ *ទ្រង់ត្រាស់សម្តែង កាល* ***ព្រះដ៏មានព្រះភាគ*** *ទ្រង់គង់នៅវត្ត* ***វេឡុវ័ន*** *ទ្រង់ប្រារព្ធ* ***ឆព្វគ្គិយភិក្ខុ*** *។* ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

(ចប់ កោធវគ្គ ទី ១៧ = មាន ១៤ គាថា)

ជំពូកទី ១៨

មលវគ្គ

(Mala Vagga)

Impurities

or Taints

(*Versets sur les Impuretés*)

(មាន ២១ គាថា)

(ពី គាថា ទី ២៣៥ ↳ ដល់ គាថា ទី ២៥៥)

២៣៥.. បណ្ឌុបលាសោវទានិសិ
យមបុរិសាបិ ច តេ ឧបដ្ឋិតា
ឧយ្យោគមុខេ ច តិដ្ឋសិ
បាថេយ្យម្បិ ច តេ ន វិជ្ជតិ ។

២៣៦.. សោ ករោហិ ទីបមត្តនោ
ខិប្បំ វាយាម បណ្ឌិតោ ភវ
និទ្ធន្តមលោ អនង្គណោ
ទិព្វំ អរិយភូមិមេហិសិ ។

ឥឡូវនេះ ខ្លួនអ្នកដូចស្លឹកឈើទុំហើយ ទាំងពួកបុរសរបស់យមរាជ[១] ប្រាកដដល់អ្នកហើយ ខ្លួនអ្នកតាំងនៅក្នុងមាត់សេចក្តីវិនាស សូម្បីស្បៀង គឺ កុសលរបស់អ្នក ក៏មិនទាន់មានឡើយ ។

អ្នកចូរធ្វើកុសលជាទីពឹងសម្រាប់ខ្លួនទៅ ចូរព្យាយាមឱ្យឆាប់ទៅ ចូរជាអ្នកប្រាជ្ញទៅ បើអ្នក (ធ្វើយ៉ាងនេះហើយ) នឹងទៅជាអ្នកកំចាត់បង់មន្ទិលបាន មិនមានទីទួល គឺកិលេស នឹងដល់នូវភូមិរបស់ព្រះអរិយៈ ដូចជាទិព្វបាន ។

ព្រះសាស្តា កាលនឹងទ្រង់ធ្វើអនុមោទនា បានត្រាស់ពីរព្រះគាថាបន្តទៀតថា :

---

[១] អ្នកបម្រើស្តេច **យមៈ** តែពាក្យនេះ សំដៅយកសេចក្តីស្លាប់ ។ **អដ្ឋកថា** ។

២៣៧.. ឧបនីតវយោ វទានិសិ
សម្បយាតោសិ យមស្ស សន្តិកំ
វាសោបិ ច តេ នត្ថិ អន្តរា
បាថេយ្យម្បិ ច តេ ន វិជ្ជតិ ។

២៣៨.. សោ ករោហិ ទីបមត្តនោ
ខិប្បំ វាយាម បណ្ឌិតោ ភវ
និទ្ធន្តមលោ អនង្គណោ
ន បុន ជាតិជរំ ឧបេហិសិ ។

ឥឡូវនេះ ខ្លួនអ្នកត្រូវជរាចូលមកដល់ហើយ ជាអ្នករៀបចំដំណើរទៅកាន់សេចក្តីស្លាប់, មួយទៀត ទីសំចតក្នុងចន្លោះ មិនមានដល់អ្នកទេ ស្បៀង ក៏មិនមានដល់អ្នក ។

អ្នកចូរធ្វើទីពឹងសម្រាប់ខ្លួនទៅ ចូរព្យាយាមឱ្យឆាប់ទៅ ចូរជាអ្នកប្រាជ្ញទៅ បើអ្នក (ធ្វើយ៉ាងនេះហើយ) នឹងទៅជាអ្នកកំចាត់បង់មន្ទិលបាន មិនមានទីទួល គឺកិលេស នឹងមិនត្រូវចូលទៅកាន់ជាតិ ជរា ព្យាធិ មរណៈទៀតឡើយ ។

☸ <u>ព្រះពុទ្ធគាថា</u>នេះ *ទ្រង់ត្រាស់សម្តែង កាល **ព្រះដ៏មានព្រះភាគ** ទ្រង់គង់នៅក្នុង **វត្តជេតពន** ទ្រង់ប្រារព្ធ **បុត្តនាយគោឃាតកៈ** បុត្តរបស់បុរសអ្នកសម្លាប់គោម្នាក់ ។*

☞ ក្នុងកាលសម្តែងអនុមោទនាគាថា ២ គាថា ដំបូង **បុត្តគោឃាតកៈ** បានសម្រេចសោតាបត្តិផល, ក្នុងវេលាចប់អនុមោទនាកថា ២ គាថាក្រោយ សម្រេចអនាគាមិផល ។

២៣៩.. អនុបុព្វេន មេធាវី ថោកំ ថោកំ ខណេ ខណេ
កម្មារោ រជតស្សេវ និទ្ធមេ មលមត្តនោ ។

អ្នកមានប្រាជ្ញា គួរកំចាត់បង់មន្ទិលរបស់ខ្លួនបន្តិចម្តង ៗ រាល់ ៗ ខណៈ ដោយលំដាប់ ដូចជាងមាស ជម្រះស្នឹម ឬច្រែះរបស់មាសដូច្នោះ ។

☸ ព្រះពុទ្ធគាថានេះ *ទ្រង់ត្រាស់សម្តែង កាល **ព្រះដ៏មានព្រះភាគ** ទ្រង់គង់នៅ វត្ត **ជេតពន** ទ្រង់ប្រារព្ធ **ព្រាហ្មណ៍**ម្នាក់ ។*

☞ ក្នុងកាលចប់ព្រះធម្មទេសនា **ព្រាហ្មណ៍**នោះ បានសម្រេច **សោតាបត្តិផល** ។

២៤០.. អយសា វ មលំ សមុដ្ឋិតំ
តទុដ្ឋាយ តមេវ ខាទតិ
ឯវំ អតិធោនចារិនំ
សានិ កម្មានិ នយន្តិ ទុគ្គតឹ ។

ច្រែះកើតអំពីដែក លុះកើតអំពីដែកនោះហើយ តែងស៊ីដែកនោះវិញ យ៉ាងណាមិញ កម្មទាំងឡាយរបស់ខ្លួន តែងនាំបុគ្គលអ្នកប្រព្រឹត្តកន្លងបញ្ញាជាគ្រឿងជម្រះចិត្ត ឱ្យទៅកាន់ទុគ្គតិ ក៏យ៉ាងនោះឯង ។

☸ ព្រះពុទ្ធគាថានេះ *ទ្រង់ត្រាស់សម្តែង កាល **ព្រះដ៏មានព្រះភាគ** ទ្រង់គង់នៅក្នុង **វត្តជេតពន** ទ្រង់ប្រារព្ធ **ព្រះតិស្សត្ថេរ** ។* ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

២៤១.. អសជ្ឈាយមលា មន្តា អនុដ្ឋានមលា ឃរា
មលំ វណ្ណស្ស កោសជ្ជំ បមាទោ រក្ខតោ មលំ ។

មន្តទាំងឡាយ មានការមិនស្វាធ្យាយន៍ ជាមន្ទិល, ផ្ទះទាំងឡាយ មានការមិនថែទាំ ជាមន្ទិល, សេចក្តីខ្ជិល ជាមន្ទិលរបស់ពណ៌សម្បុរ សេចក្តីប្រមាទ ជាមន្ទិលរបស់បុគ្គលអ្នករក្សា ។

☸ ព្រះពុទ្ធគាថានេះ *ទ្រង់ត្រាស់សម្តែង កាល **ព្រះដ៏មានព្រះភាគ** ទ្រង់គង់នៅវត្ត ជេតពន ទ្រង់ប្រារព្ធ **ព្រះលោឡុទាយិត្ថេរ** ។* ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

២៤២.. មលិត្ថិយា ទុច្ចរិតំ មច្ឆេរំ ទទតោ មលំ
មលា វេ បាបកា ធម្មា អស្មឹ លោកេ បរម្ហិ ច ។

២៤៣.. តតោ មលា មលតរំ អវិជ្ជា បរមំ មលំ
ឯតំ មលំ បហន្ត្វាន និម្មលា ហោថ ភិក្ខវោ ។

ការប្រព្រឹត្តអាក្រក់[១] ជាមន្ទិលរបស់ស្ត្រី, សេចក្តីកំណាញ់ ជាមន្ទិលរបស់អ្នកឱ្យ, ធម៌អាក្រក់ទាំងឡាយ ជាមន្ទិលក្នុងលោកនេះ និង លោកខាងមុខ, ធម្មជាត ជាមន្ទិលដ៏លើសលុប ជាងមន្ទិលទាំងនោះ គឺអវិជ្ជា ជាមន្ទិលដ៏ក្រៃលែង, ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះមន្ទិលទាំងនេះចេញ ចូរកុំជាអ្នកមានមន្ទិលឡើយ ។

[១] សំដៅយកការប្រព្រឹត្តកន្លងចិត្តប្តី ។ **អដ្ឋកថា** ។

☸ ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែង កាល ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅ វត្ត ជេតពន ទ្រង់ប្រារព្ធ ភិក្ខុចុឡសារី ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផល ជាដើម ។

២៤៤.. សុជីវំ អហិរិកេន កាកសូរេន ធំសិនា
បក្ខន្ទិនា បគព្ភេន សង្កិលិដ្ឋេន ជីវិតំ ។
២៤៥.. ហិរីមតា ច ទុជ្ជីវំ និច្ចំ សុចិគវេសិនា
អលីនេនាបគព្ភេន សុទ្ធាជីវេន បស្សតា ។

បុគ្គលអ្នកមិនមានសេចក្តីអៀនខ្មាស ក្លៀវក្លាដូចសត្វក្អែក កំចាត់បង់គុណរបស់អ្នកដទៃ ជាអ្នកឈ្លានពាន (យកមុខ) ជាអ្នកឃ្មើសឃ្មង ជាមនុស្សសៅហ្មង រស់នៅដោយងាយ ។

ចំណែកបុគ្គល អ្នកមានសេចក្តីអៀនខ្មាស ស្វែងរកអំពើស្អាតជានិច្ច មិនខ្ជិលច្រអូស មិនឃ្មើសឃ្មង រស់នៅដោយកម្មដ៏បរិសុទ្ធ អ្នកឃើញត្រូវ រស់នៅដោយលំបាក ។

☸ ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្តែង កាល ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅ វត្ត ជេតពន ទ្រង់ប្រារព្ធ សទ្ធិវិហារិករបស់ព្រះសារីបុត្តម្នាក់ឈ្មោះ ចូឡសារី ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផល ជាដើម ។

២៤៦.. យោ បាណមតិបាតេតិ មុសាវាទញ្ច ភាសតិ
លោកេ អទិន្នំ អាទិយតិ បរទារញ្ច គច្ឆតិ ។

២៤៧.. សុរាមេរយបានញ្ច   យោ នរោ អនុយុញ្ជតិ
ឥធេវមេសោ លោកស្មឹ   មូលំ ខណតិ អត្តនោ ។

២៤៨.. ឯវំ ភោ បុរិស ជានាហិ   បាបធម្មា អសញ្ញតា
មា តំ លោភោ អធម្មោ ច   ចិរំ ទុក្ខាយ រន្ធយុំ ។

ជនណា សម្លាប់សត្វផង និយាយពាក្យកុហកផង កាន់យកវត្ថុដែលគេមិនបានឱ្យក្នុងលោកផង សេពប្រពន្ធរបស់អ្នកដទៃផង ជនណាផឹកទឹកសុរា និង មេរ័យផង ជននោះឯងឈ្មោះថា គាស់រំលើងឫសគល់របស់ខ្លួន ក្នុងលោកនេះ ដោយពិត ។

ម្នាលបុរសដ៏ចម្រើន អ្នកចូរដឹងយ៉ាងនេះថា ជនទាំងឡាយមានធម៌ដ៏លាមក រមែងមិនជាអ្នកសង្រួមដូច្នេះ លោភៈ និង សភាពមិនមែនធម៌គឺទោសៈ ចូរកុំបៀតបៀនអ្នក ឱ្យបានសេចក្ដីទុក្ខអស់កាលយូរឡើយ ។

☸ <u>ព្រះពុទ្ធគាថានេះ</u> *ទ្រង់ត្រាស់សម្ដែង កាល ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅ វត្ត ជេតពន ទ្រង់ប្រារព្ធ ឧបាសក ៥ នាក់ ។* ☞ ក្នុងកាលចប់ព្រះធម្មទេសនា ឧបាសក ទាំង៥ នាក់នោះ បានសម្រេច សោតាបត្តិផល ។

២៤៩.. ទទាតិ វេ យថាសទ្ធំ   យថាបសាទនំ ជនោ
តត្ថ យោ មង្កុតោ ហោតិ   បរេសំ បានភោជនេ
ន សោ ទិវា វា រត្តឹ វា   សមាធឹ អធិគច្ឆតិ ។

២៥០.. យស្ស ចេតំ សមុច្ឆិន្នំ   មូលឃច្ចំ សមូហតំ
ស វេ ទិវា វា រត្តឹ វា   សមាធឹ អធិគច្ឆតិ ។

ជន រមែងឱ្យតាមសទ្ធា តាមសេចក្ដីជ្រះថ្លា បុគ្គលណា ជាអ្នកអៀនខ្មាសក្នុងទឹក និង ភោជន របស់ជនទាំងឡាយដទៃ ជននោះ រមែងមិនបានសមាធិចិត្ត ក្នុងវេលាថ្ងៃ ឬ ក្នុងវេលាយប់ឡើយ ។ លុះតែសេចក្ដីអៀនខ្មាសនោះ បុគ្គលណា បានផ្ដាច់ផ្ដិលដកឡើង ធ្វើឱ្យមានឫសគល់ដាច់ហើយ បុគ្គលនោះឯង ទើបបានសមាធិចិត្ត ក្នុងវេលាថ្ងៃ ឬ ក្នុងវេលាយប់ ។

☸ **ព្រះពុទ្ធគាថា**នេះ *ទ្រង់ត្រាស់សម្ដែង កាល **ព្រះដ៏មានព្រះភាគ** ទ្រង់គង់នៅវត្ត **ជេតពន** ទ្រង់ប្រារព្ធភិក្ខុកំលោះឈ្មោះ **តិស្សៈ*** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

២៥១.. **នត្ថិ រាគសមោ អគ្គិ នត្ថិ ទោសសមោ គហោ**
នត្ថិ មោហសមំ ជាលំ នត្ថិ តណ្ហាសមា នទី ។

ភ្លើង ស្មើដោយរាគៈ មិនមាន, ការចាប់ ស្មើដោយទោសៈ មិនមាន, បណ្ដាញ ស្មើដោយមោហៈ មិនមាន, ស្ទឹង ស្មើដោយតណ្ហា មិនមាន ។

☞ *<u>បទថា</u> **មោហសមំ ជាលំ** សេចក្ដីថា ឈ្មោះថាបណ្ដាញ (សំណាញ់) ស្មើដោយមោហៈ រមែងមិនមាន, <u>ដោយអត្ថថា</u> **រួបរឹត និង រួបរឹតដោយជុំវិញ*** ។

☸ **ព្រះពុទ្ធគាថា**នេះ *ទ្រង់ត្រាស់សម្ដែង កាល **ព្រះដ៏មានព្រះភាគ** ទ្រង់គង់នៅវត្ត **ជេតពន** ទ្រង់ប្រារព្ធ **ឧបាសក ៥ នាក់*** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា **ឧបាសក**ម្នាក់ (ក្នុងចំណោម ទាំង ៥ នាក់) ដែលស្ដាប់ធម៌ដោយគោរពនោះ ក៏បានសម្រេចនូវ **សោតាបត្តិផល** ។

២៥២.. សុទស្សំ វជ្ជមញ្ញេសំ អត្តនោ បន ទុទ្ទសំ
បរេសំ ហិ សោ វជ្ជានិ ឱបុនាតិ យថាភុសំ
អត្តនោ បន ឆាទេតិ កលឹវ កិតវា សឋោ ។

ទោសរបស់ពួកជនដទៃ ឃើញបានដោយងាយ ចំណែកទោសរបស់ខ្លួន ឃើញបានដោយលំបាក ព្រោះថា បុគ្គលនោះ រោយទោសទាំងឡាយចំពោះពួកជនដទៃ ដូចបុគ្គលរោយអង្កាមដូច្នោះ តែថា រមែងបិទបាំងទោសរបស់ខ្លួនទុក ដូចព្រានបក្សី បិទបាំងអត្តភាព ដោយវត្ថុសម្រាប់បិទបាំង (មានមែកឈើជាដើម) ដូច្នោះ ។

☸ <u>ព្រះពុទ្ធគាថា</u>នេះ *ទ្រង់ត្រាស់សម្តែង កាល* ***ព្រះដ៏មានព្រះភាគ*** *ទ្រង់គង់អាស្រ័យនៅក្នុងព្រៃធ្នង់ នា* ***ភទ្ទិយនគរ*** *ទ្រង់ប្រារព្ធ* ***មេណ្ឌកសេដ្ឋី*** ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

២៥៣.. បរវជ្ជានុបស្សិស្ស និច្ចំ ឧជ្ឈានសញ្ញិនោ
អាសវា តស្ស វឌ្ឍន្តិ អារា សោ អាសវក្ខយា ។

កាលបុគ្គលគយឃ្លាំមើលទោស របស់បុគ្គលដទៃ ជាប្រក្រតី មានការសំគាល់ហេតុក្នុងការពោលទោស (អ្នកដទៃ) ជានិច្ច ជាប្រក្រតី អាសវៈទាំងឡាយ របស់បុគ្គលនោះ តែងចម្រើន បុគ្គលនោះ ឈ្មោះថា ឋិតនៅឆ្ងាយអំពីធម៌ជាគ្រឿងអស់អាសវៈ ។

☸ ព្រះពុទ្ធគាថានេះ *ទ្រង់ត្រាស់សម្តែង កាល* ***ព្រះដ៏មានព្រះភាគ*** *ទ្រង់គង់នៅក្នុង* ***វត្តជេតពន*** *ទ្រង់ប្រារព្ធ ព្រះថេរៈមួយរូប ឈ្មោះ* ***ខុជ្ជានសញ្ញី*** ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

២៥៤.. អាកាសេវ បទំ នត្ថិ សមណោ នត្ថិ ពាហិរេ
បបញ្ចាភិរតា បជា និប្បបញ្ចា តថាគតា ។

២៥៥.. អាកាសេវ បទំ នត្ថិ សមណោ នត្ថិ ពាហិរេ
សង្ខារា សស្សតា នត្ថិ នត្ថិ ពុទ្ធានមិញ្ជិតំ ។

ស្នាមជើងក្នុងអាកាស មិនមាន, សមណៈខាងក្រៅ មិនមាន, ពួកសត្វត្រេកអរហើយ ក្នុងធម៌ជាគ្រឿងយឺតយូរ **ព្រះតថាគត** ទាំងឡាយ មិនមានធម៌ជាគ្រឿងយឺតយូរឡើយ ។

ស្នាមជើងក្នុងអាកាស មិនមាន, សមណៈខាងក្រៅ មិនមាន, សង្ខារទាំងឡាយជារបស់ទៀង មិនមាន, **ព្រះពុទ្ធ** ទាំងឡាយ មិនមានកិលេសជាគ្រឿងញាប់ញ័រទេ ។

☸ ព្រះពុទ្ធគាថានេះ *ទ្រង់ត្រាស់សម្តែង កាល* ***ព្រះដ៏មានព្រះភាគ*** *ទ្រង់ផ្ទំលើសយនដ្ឋាន ជាទីបរិនិព្វានក្នុងសាលវ័ន របស់មល្លក្សត្រ ជិតនគរកុសិនារា ទ្រង់ប្រារព្ធបរិព្វាជកឈ្មោះ* ***សុភទ្ទ*** ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា **សុភទ្ទបរិព្វាជក** តាំងនៅក្នុង **អនាគាមិផល** ។

(ចប់ **មលវគ្គ** ទី ១៨ = មាន **២១** គាថា)

ជំពូកទី ១៩

ធម្មដ្ឋវគ្គ

(DHAMAṬṬHA VAGGA)

The Just or The Righteous

(Versets sur le Juste)

(មាន ១៧ គាថា)

(ពី គាថា ទី ២៥៦ ➩ ដល់ គាថា ទី ២៧២)

២៥៦.. ន តេន ហោតិ ធម្មដ្ឋោ យេនត្ថំ សហសា នយេ
យោ ច អត្ថំ អនត្ថញ្ច ឧភោ និច្ឆេយ្យ បណ្ឌិតោ ។
២៥៧.. អសាហសេន ធម្មេន សមេន នយតី បរេ
ធម្មស្ស គុត្តោ មេធាវី ធម្មដ្ឋោតិ បវុច្ចតិ ។

បុគ្គលកាត់សេចក្តីដោយអាក្រក់ ដោយសារហេតុណា ឈ្មោះថាជាអ្នកតាំងនៅក្នុងធម៌ ដោយហេតុនោះ មិនទាន់បានទេ លុះត្រាតែបុគ្គលណា ជាបណ្ឌិតកាត់សេចក្តីទាំងពីរ គឺសេចក្តីពិត និង សេចក្តីមិនពិត ណែនាំជនទាំងឡាយដទៃ ដោយមិនអាក្រក់ ដោយសារធម៌ តាមសមគួរ (ដល់ទោស) បុគ្គលនោះ ឈ្មោះថា ជាអ្នកមានប្រាជ្ញា រក្សាធម៌ អ្នកតាំងនៅក្នុងធម៌ ។

☸ ព្រះពុទ្ធគាថានេះ *ទ្រង់ត្រាស់សម្តែង កាល **ព្រះដ៏មានព្រះភាគ** ទ្រង់គង់នៅក្នុង **វត្តជេតពន** ទ្រង់ប្រារព្ធ **មហាមាត្យអ្នកវិនិច្ឆ័យ*** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

២៥៨.. ន តេន បណ្ឌិតោ ហោតិ យាវតា ពហុ ភាសតិ
ខេមី អវេរី អភយោ បណ្ឌិតោតិ បវុច្ចតិ ។

បុគ្គលនិយាយច្រើន ដោយហេតុមានប្រមាណប៉ុណ្ណា ឈ្មោះថាជា **បណ្ឌិត** ដោយហេតុមានប្រមាណប៉ុណ្ណោះ មិនទាន់បានទេ លុះត្រាតែបុគ្គលដែលមានសេចក្តីក្សេម មិនមានពៀរ មិនមានភ័យ ទើបហៅថាបណ្ឌិតបាន។

☸ ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្ដែង កាល ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធ ឯកុទានត្ថេរ ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផល ជាដើម ។

២៥៩.. ន តាវតា ធម្មធរោ យាវតា ពហុ ភាសតិ
យោ ច អប្បម្បិ សុត្វាន ធម្មំ កាយេន បស្សតិ
ស វេ ធម្មធរោ ហោតិ យោ ធម្មំ នប្បមជ្ជតិ ។

បុគ្គលនិយាយច្រើន ដោយហេតុមានប្រមាណប៉ុណ្ណា ឈ្មោះថាជាអ្នកទ្រទ្រង់ធម៌ ដោយហេតុមានប្រមាណប៉ុណ្ណោះ មិនទាន់បានទេ លុះត្រាតែបុគ្គលណាស្ដាប់ពុទ្ធវចនៈ សូម្បីមានប្រមាណតិច ហើយឃើញធម៌ដោយនាមកាយ គឺចិត្តបាន បុគ្គលនោះទើបឈ្មោះថា ជាអ្នកទ្រទ្រង់ធម៌ បុគ្គលណាមិនមើលងាយធម៌ បុគ្គលនោះឯងឈ្មោះថាជាអ្នកទ្រទ្រង់ធម៌។

☸ ព្រះពុទ្ធគាថានេះ ទ្រង់ត្រាស់សម្ដែង កាល ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធ ព្រះខីណាស្រពឯកុទានត្ថេរ ។
☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផល ជាដើម ។

២៦០.. ន តេន ថេរោ ហោតិ យេនស្ស បលិតំ សិរោ
បរិបក្កោ វយោ តស្ស មោឃជិណ្ណោតិ វុច្ចតិ ។
២៦១.. យម្ហិ សច្ចញ្ច ធម្មោ ច អហឹសា សញ្ញមោ ទមោ
ស វេ វន្តមលោ ធីរោ សោ ថេរោតិ បវុច្ចតិ ។

បុគ្គលមានក្បាលស្កូវហើយ ដោយហេតុណា ឈ្មោះថា ជា **ថេរៈ** ដោយហេតុនោះ មិនទាន់បានទេ វ័យរបស់បុគ្គលនោះ ចាស់ជ្រុលហើយ ហៅថា **ចាស់ជាមោឃៈ** ។ លុះត្រាតែ សច្ចៈផង ធម៌ផង ការមិនបៀតបៀនផង ការសង្រួមផង ការទូន្មានផង មានក្នុងបុគ្គលណា បុគ្គលនោះឯងជាអ្នកមានមន្ទិលខ្ជាក់ចោលហើយ ជាអ្នកមានប្រាជ្ញា ទើបហៅថា**ថេរៈ** ។

☸ *__ព្រះពុទ្ធគាថា__នេះ ទ្រង់ត្រាស់សម្ដែង កាល **ព្រះដ៏មានព្រះភាគ** ទ្រង់គង់នៅក្នុង **វត្តជេតពន** ទ្រង់ប្រារព្ធ **ព្រះលកុណ្ឌកភទ្ទិយត្ថេរ** ។* ☞ ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុប្រមាណ ៣០ រូប បានតាំងនៅក្នុង **ព្រះអរហត្ត** ។

២៦២.. ន វាក្ករណមត្តេន វណ្ណបោក្ខរតាយ វា
សាធុរូបោ នរោ ហោតិ ឥស្សុកី មច្ឆរី សឋោ ។
២៦៣.. យស្ស ចេតំ សមុច្ឆិន្នំ មូលឃច្ចំ សមូហតំ
ស វន្តទោសោ មេធាវី សាធុរូបោតិ វុច្ចតិ ។

បុគ្គលមានសេចក្ដីឫស្យា មានសេចក្ដីកំណាញ់ ជាអ្នកអួតអាង ឈ្មោះថាជា **មនុស្សល្អ** ដោយហេតុត្រឹមតែធ្វើការនិយាយពាក្យ (ល្អ) ឬដោយភាពជាអ្នកមានសម្បុរជាទីគាប់ចិត្ត ក៏មិនទាន់បានទេ ។

លុះត្រាតែ **ទោសជាតិ** មានឫស្យាជាដើមនេះ បុគ្គលណាបានផ្ដាច់ផ្ដិលដកឡើង ធ្វើឱ្យមានឫសគល់ដាច់ហើយ បុគ្គលនោះ ជាអ្នកមាន **ទោស**ខ្ជាក់ចោលហើយ ជាអ្នកមានប្រាជ្ញា ទើបហៅថាជា **មនុស្សល្អ** បាន ។

☸ *__ព្រះពុទ្ធគាថា__នេះ ទ្រង់ត្រាស់សម្ដែង កាល **ព្រះដ៏មានព្រះភាគ** ទ្រង់គង់នៅក្នុង **វត្តជេតពន** ទ្រង់ប្រារព្ធចំពោះ **ភិក្ខុច្រើនរូប** ។*

☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

២៦៤.. ន មុណ្ឌកេន សមណោ អព្វតោ អលិកំ ភណំ
ឥច្ឆាលោភសមាបន្នោ សមណោ កឹ ភវិស្សតិ ។
២៦៥.. យោ ច សមេតិ បាបានិ អណុំថូលានិ សព្វសោ
សមិតត្តា ហិ បាបានំ សមណោតិ បវុច្ចតិ ។

បុគ្គលមិនបានឈ្មោះថា ជា**សមណៈ** ដោយភាពជាអ្នកមានក្បាលត្រងោលទេ បុគ្គលអ្នកមិនមានសីលវត្ត និង ធុតង្គវត្ត ពោលតែពាក្យឡេះឡោះ ប្រកបដោយសេចក្ដីប្រាថ្នា និង លោភៈ ឈ្មោះថាជា **សមណៈ** ដូចម្ដេចបាន ។ លុះត្រាតែបុគ្គលណា រម្ងាប់បាបទាំងឡាយ ទាំងតូច ទាំងធំ ដោយប្រការទាំងពួងបាន ទើបហៅថា **សមណៈ** ព្រោះបាបទាំងឡាយ ដែលបុគ្គលនោះរម្ងាប់បានហើយ ។

☸ <u>**ព្រះពុទ្ធគាថា**នេះ</u> *ទ្រង់ត្រាស់សម្ដែង កាល **ព្រះដ៏មានព្រះភាគ** ទ្រង់គង់នៅក្រុង **សាវត្ថី** ទ្រង់ប្រារព្ធចំពោះ **ភិក្ខុហត្ថកៈ*** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

២៦៦.. ន តេន ភិក្ខុ សោ ហោតិ យាវតា ភិក្ខតេ បរេ
វិសំ ធម្មំ សមាទាយ ភិក្ខុ ហោតិ ន តាវតា ។
២៦៧.. យោធ បុញ្ញញ្ច បាបញ្ច ពាហេត្វា ព្រហ្មចរិយវា
សង្ខាយ លោកេ ចរតិ ស វេ ភិក្ខូតិ បវុច្ចតិ ។

បុគ្គលណា ដើរសូមជនទាំងឡាយដទៃ ដោយហេតុត្រឹមណា បុគ្គលនោះ មិនបានឈ្មោះថាជា **ភិក្ខុ** ដោយហេតុត្រឹមណោះទេ បុគ្គលសមា-
-ទានធម៌ជាពិស ឈ្មោះថាជា**ភិក្ខុ** ដោយហេតុត្រឹមតែការដើរសូមប៉ុណ្ណោះមិនទាន់បានទេ ។ លុះត្រាតែបុគ្គលណា ក្នុងលោកនេះ បន្សាត់បុណ្យ និងបាបចេញហើយ ជាអ្នកមានការប្រព្រឹត្តដ៏ប្រសើរ ត្រាច់ទៅក្នុងលោកដោយសេចក្តីចេះដឹង បុគ្គលនោះឯង ទើបហៅថាជា **ភិក្ខុ** ។

☸ **ព្រះពុទ្ធគាថា**នេះ *ទ្រង់ត្រាស់សម្តែង កាល **ព្រះដ៏មានព្រះភាគ** ទ្រង់គង់នៅវត្តជេតពន ទ្រង់ប្រារព្ធ **ព្រាហ្មណ៍**ម្នាក់ ។* ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

២៦៨.. ន មោនេន មុនិ ហោតិ មូឡ្ហរូបោ អវិទ្ទសុ
យោ ច តុលំវ បគ្គយ្ហ វរមាទាយ បណ្ឌិតោ ។
២៦៩.. បាបានិ បរិវជ្ជេតិ ស មុនិ តេន សោ មុនិ
យោ មុនាតិ ឧភោ លោកេ មុនិ តេន បវុច្ចតិ ។

បុគ្គលមានសេចក្តីវង្វេង ជាធម្មតា មិនមានការចេះដឹង មិនបានឈ្មោះថាជា **មុនី** ដោយភាពជាអ្នកស្ងៀមទេ លុះត្រាតែបុគ្គលណា ជាបណ្ឌិតកាន់យកធម៌ដ៏ប្រសើរ វៀរចាកបាបទាំងឡាយ ដូចបុគ្គលកាន់ជញ្ជីងហើយថ្លឹងដូច្នោះ បុគ្គលនោះទើបឈ្មោះថាជា **មុនី** ដោយភាពជាអ្នកស្ងៀមនោះបាន បុគ្គលណា ដឹងប្រយោជន៍ទាំងពីរ ក្នុងលោក បុគ្គលនោះហៅថា **មុនី** ដោយហេតុនោះ ។

☸ ព្រះពុទ្ធគាថានេះ *ទ្រង់ត្រាស់សម្តែង កាល* ***ព្រះដ៏មានព្រះភាគ*** *ទ្រង់គង់នៅវត្ត* ***ជេតពន*** *ទ្រង់ប្រារព្ធពួក* ***ភិក្ខុ*** *។* ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

២៧០.. ន តេន អរិយោ ហោតិ យេន បាណានិ ហឹសតិ
អហឹសា សព្វបាណានំ អរិយោតិ បវុច្ចតិ ។

បុគ្គលបៀតបៀនសត្វទាំងឡាយ ដោយហេតុណា មិនបានឈ្មោះថាជា **អរិយៈ** ដោយហេតុនោះទេ បុគ្គលដែល**តថាគត**ហៅថា **អរិយៈ** ព្រោះមិនបៀតបៀនសត្វទាំងពួង ។

☸ ព្រះពុទ្ធគាថានេះ *ទ្រង់ត្រាស់សម្តែង កាល* ***ព្រះដ៏មានព្រះភាគ*** *ទ្រង់គង់នៅវត្ត* ***ជេតពន*** *ទ្រង់ប្រារព្ធព្រានសន្ទូចឈ្មោះ* ***អរិយៈ*** *។*
☞ ក្នុងកាលចប់ព្រះធម្មទេសនា ព្រានសន្ទូចនោះ តាំងនៅក្នុង **សោតាបត្តិផល** ។

២៧១.. ន សីលព្វតមត្តេន ពាហុសច្ចេន វា បន
អថ វា សមាធិលាភេន វិវិត្តសយនេន វា ។
២៧២.. ផុសាមិ នេក្ខម្មសុខំ អបុថុជ្ជនសេវិតំ
ភិក្ខុ វិស្សាសមាបាទិ អប្បត្តោ អាសវក្ខយំ ។

ម្នាលភិក្ខុ បើភិក្ខុមិនទាន់ដល់នូវការអស់អាសវៈទេ កុំអាលទុកចិត្តដោយគុណត្រឹមតែសីល និង វត្ត ឬដោយភាពជាអ្នកចេះដឹងច្រើនឡើយ មួយទៀត ដោយការបានសមាធិ ឬដោយការដេកក្នុងទីស្ងាត់ ឬក៏ដោយគុណមានប្រមាណប៉ុណ្ណេះថា អាត្មាអញ ពាល់ត្រូវនេក្ខម្មសុខដែលបុថុជ្ជនមិនដែលជួបប្រសព្វ ដូច្នេះឡើយ ។

☸ ព្រះពុទ្ធគាថានេះ *ទ្រង់ត្រាស់សម្ដែង កាល* ***ព្រះដ៏មានព្រះភាគ*** *ទ្រង់គង់នៅវត្ត* ***ជេតពន*** *ទ្រង់ប្រារព្ធ* ***ភិក្ខុច្រើនរូប*** *។*

☞ ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុទាំងនោះ តាំងនៅក្នុង **ព្រះអរហត្ត** ។

(ចប់ **ធម្មដ្ឋវគ្គ** ទី ១៩ = មាន **១៧** គាថា)



វគ្គទី ២០

មគ្គវគ្គ

(Magga Vagga)

The Way or The Path

(Versets sur le Sentier)

(មាន ១៧ គាថា)

(ពី គាថា ទី ២៧៣ ➩ ដល់ គាថា ទី ២៨៩)

២៧៣.. មគ្គានដ្ឋង្គិកោ សេដ្ឋោ   សច្ចានំ ចតុរោ បទា
វិរាគោ សេដ្ឋោ ធម្មានំ   ទិបទានញ្ច ចក្ខុមា ។
២៧៤.. ឯសេវ មគ្គោ នត្ថញ្ញោ   ទស្សនស្ស វិសុទ្ធិយា
ឯតញ្ហិ តុម្ហេ បដិបជ្ជថ   មារស្សេតំ បមោហនំ ។
២៧៥.. ឯតញ្ហិ តុម្ហេ បដិបន្នា   ទុក្ខស្សន្តំ ករិស្សថ
អក្ខាតោ វោ មយា មគ្គោ   អញ្ញាយ សល្លសត្ថនំ ។
២៧៦.. តុម្ហេហិ កិច្ចំ អាតប្បំ   អក្ខាតារោ តថាគតា
បដិបន្នា បមោក្ខន្តិ   ឈាយិនោ មារពន្ធនា ។

ផ្លូវមានអង្គ ៨ ប្រសើរជាងផ្លូវទាំងឡាយ, បទ ៤ គឺអរិយសច្ចប្រសើរជាងសច្ចៈទាំងឡាយ, វិរាគធម៌ប្រសើរជាងធម៌ទាំងឡាយ មួយទៀត **ព្រះតថាគត** មានចក្ខុ ប្រសើរជាងសត្វទ្វេបាទទាំងឡាយ ផ្លូវនេះឯងប្រព្រឹត្តទៅ ដើម្បីសេចក្តីបរិសុទ្ធនៃទស្សនៈ ផ្លូវដទៃមិនមានទេ ។ ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរដើរទៅកាន់ផ្លូវនោះ ផ្លូវនេះជាផ្លូវញាំងមារឱ្យវង្វេង អ្នកទាំងឡាយដើរទៅកាន់ផ្លូវនេះហើយ អាចនឹងធ្វើឱ្យផុតទុក្ខបាន ។ ផ្លូវនេះហើយ ដែល **តថាគត** ដឹងថា ជាផ្លូវកំចាត់បង់កូនសរ ប្រាប់ដល់អ្នកទាំងឡាយ សេចក្តីព្យាយាម ញាំងកិលេសឱ្យក្តៅសព្វ **អ្នកទាំងឡាយគប្បីធ្វើ** **ព្រះតថាគត**ទាំងឡាយ គ្រាន់តែជាអ្នកប្រាប់ ជនទាំងឡាយមានការពិនិត្យ បើបានដើរទៅហើយ នឹងរួចចាកចំណងរបស់មារបាន ។

☸ __ព្រះពុទ្ធគាថា__នេះ *ទ្រង់ត្រាស់សម្តែង កាល **ព្រះដ៏មានព្រះភាគ** ទ្រង់គង់នៅវត្តជេតពន ទ្រង់ប្រារព្ធ **ភិក្ខុ ៥០០ រូប** ។*

☞ ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុទាំងនោះ តាំងនៅក្នុង **ព្រះអរហត្តផល** ។

២៧៧.. សព្វេ សង្ខារា អនិច្ចាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។

២៧៨.. សព្វេ សង្ខារា ទុក្ខាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។

២៧៩.. សព្វេ ធម្មា អនត្តាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។

កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា **សង្ខារទាំងពួងមិនទៀង** ដូច្នេះ កាលណោះ រមែងនឿយណាយក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធ ។

កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា **សង្ខារទាំងពួងនាំមកនូវសេចក្តីទុក្ខ** ដូច្នេះ កាលណោះ រមែងនឿយណាយក្នុងសេចក្តីទុក្ខ នេះជា ផ្លូវនៃសេចក្តីបរិសុទ្ធ ។

កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា **សង្ខារ (ធម្ម)ទាំងពួងមិនមែនជារបស់ខ្លួន**ដូច្នេះ កាលណោះ រមែងនឿយណាយក្នុងសេចក្តីទុក្ខ នេះជា ផ្លូវនៃសេចក្តីបរិសុទ្ធ ។

☸ ព្រះពុទ្ធគាថានេះ *ទ្រង់ត្រាស់សម្តែង កាល **ព្រះដ៏មានព្រះភាគ** ទ្រង់គង់នៅវត្ត **ជេតពន** ទ្រង់ប្រារព្ធ **ភិក្ខុ ៥០០ រូប** ។*

☞ ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុទាំងនោះ តាំងនៅក្នុង **ព្រះអរហត្តផល** ។

២៨០.. ឧដ្ឋានកាលម្ហិ អនុដ្ឋហានោ

យុវា ពលី អាលសិយំ ឧបេតោ

សំសន្នសង្កប្បមនោ កុសីតោ

បញ្ញាយ មគ្គំ អលសោ ន វិន្ទតិ ។

បុគ្គលនៅកំឡោះ មានកម្លាំង ទាស់តែប្រកបដោយសេចក្តីខ្ជិលច្រអូស មិនប្រឹងប្រែង ក្នុងកាលដែលគួរប្រឹងប្រែង មានសេចក្តីត្រិះរិះក្នុងចិត្ត លិចចុះក្នុងអកុសលវិតក្កៈ ជាមនុស្សខ្ជិល បុគ្គលខ្ជិល(នោះ) រមែងមិនបានផ្លូវបញ្ញាឡើយ ។

☸ ព្រះពុទ្ធគាថានេះ កាលព្រះសាស្តាទ្រង់គង់នៅវត្ត ជេតពន ទ្រង់ប្រារព្ធ ព្រះបធានកម្មិកតិស្សត្ថេរ ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផល ជាដើម ។

២៨១.. វាចានុរក្ខី មនសា សុសំវុតោ

កាយេន ច អកុសលំ ន កយិរា

ឯតេ តយោ កម្មបថេ វិសោធយេ

អារាធយេ មគ្គមិសិប្បវេទិតំ ។

បុគ្គលគប្បីជាអ្នករក្សាវាចា សង្រួមឱ្យល្អ ដោយចិត្ត ទាំងមិនគប្បីធ្វើអកុសលដោយកាយ បុគ្គលគប្បីជម្រះកម្មបថទាំង ៣ នេះ និង គប្បីត្រេក-
-អរចំពោះមគ្គ ដែលលោកអ្នកស្វែងរកគុណដ៏ល្អ សម្តែងទុកហើយ ។

☸ **ព្រះពុទ្ធគាថា**នេះ កាល**ព្រះសាស្តា**ទ្រង់គង់នៅវត្ត **ជេតពន** ទ្រង់ប្រារព្ធ **សូករប្រេត** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

២៨២.. យោគា វេ ជាយតី ភូរិ អយោគា ភូរិសង្ខយោ
ឯតំ ទ្វេធា បថំ ញត្វា ភវាយ វិភវាយ ច
តថត្តានំ និវេសេយ្យ យថា ភូរិ បវឌ្ឍតិ ។

ប្រាជ្ញា រមែងកើតអំពីការប្រកប សេចក្តីវិនាសប្រាជ្ញា រមែងកើតអំពីការមិនប្រកប, អ្នកមានប្រាជ្ញា ដឹងការប្រកប និង ការមិនប្រកបទាំងពីរនេះថា ជាគន្លងនៃសេចក្តីចម្រើន និង សេចក្តីវិនាសហើយ ប្រាជ្ញាចម្រើនឡើងដោយប្រការណា គួរតម្កល់ខ្លួនទុក ដោយប្រការនោះ ។

☸ **ព្រះពុទ្ធគាថា**នេះ កាល**ព្រះសាស្តា**ទ្រង់គង់នៅវត្ត **ជេតពន** ទ្រង់ប្រារព្ធ **ព្រះពោឋិលត្ថេរ** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា **ព្រះពោឋិលៈ** បានតាំងនៅក្នុង**ព្រះអរហត្តផល** ។

២៨៣.. វនំ ឆិន្ទថ មា រុក្ខំ វនតោ ជាយតី ភយំ
ឆេត្វា វនំ វនថញ្ច និព្វនា ហោថ ភិក្ខវោ ។

២៨៤.. យាវញ្ហិ វនថោ ន ឆិជ្ជតិ
អណុមត្តោបិ នរស្ស នារិសុ
បដិពទ្ធមនោ វ តាវ សោ
វច្ឆោ ខីរបកោវ មាតរិ ។

អ្នកទាំងឡាយ ចូរកាត់កិលេសដូចជាព្រៃចេញ ចូរកុំកាត់ដើមឈើ (ព្រោះ) ភ័យកើតអំពីកិលេសដូចជាព្រៃ, ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរកាត់កិលេស ដូចជាព្រៃផង កិលេសដូចជាដើមឈើ ដុះក្នុងព្រៃផង ហើយចូរជាអ្នក កុំមានកិលេស ដូចជាព្រៃឡើយ ព្រោះថាកិលេសដូច ដើមឈើ ដុះក្នុងព្រៃរបស់នរជន សូម្បីមានប្រមាណតិចក៏ដោយ បើកាត់ មិនដាច់ក្នុងពួកនារីដរាបណា នរជននោះឯង តែងមានចិត្តជាប់ចំពោះក្នុងពួកនារី ដូចកូនគោនៅកំពុងបៅដោះ ដែលមានចិត្តជាប់នៅនឹងមេ ដរាបនោះ ។

☸ **ព្រះពុទ្ធគាថា**នេះ កាល**ព្រះសាស្ដា**ទ្រង់គង់នៅវត្ត **ជេតពន** ទ្រង់ប្រារព្ធ **ភិក្ខុចាស់ច្រើនរូប** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ព្រះថេរៈចាស់ទាំងនោះ តាំងនៅក្នុង **សោតាបត្តិផល** ។

២៨៥.. **ឧច្ឆិន្ទ សិនេហមត្តនោ**
កុមុទំ សារទិកំវ បាណិនា
សន្តិមគ្គមេវ ព្រូហយ
និព្វានំ សុគតេន ទេសិតំ ។

អ្នកចូរដក សេចក្ដីស្រឡាញ់របស់ខ្លួនចេញ ដូចបុគ្គល ដកផ្កាកុមុទ ដែលកើតក្នុងសរទកាលដោយដៃ អ្នកចូរបណ្ដុះនូវផ្លូវសន្តិភាពតែម្យ៉ាង **ព្រះនិព្វាន ព្រះសុគត** សម្ដែងទុកហើយ ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្ដាទ្រង់គង់នៅវត្ត **ជេតពន** ទ្រង់ប្រារព្ធ **សទ្ធិវិហារិករបស់ព្រះសារីបុត្រ** ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុនោះ តាំងនៅក្នុង **អរហត្ត** ។

២៨៦.. ឥធ វស្សំ វសិស្សាមិ ឥធ ហេមន្តគិម្ហិសុ
ឥតិ ពាលោ វិចិន្តេតិ អន្តរាយំ ន ពុជ្ឈតិ ។

អញនឹងនៅក្នុងទីនេះអស់វស្សានរដូវ អញនឹងនៅក្នុងទីនេះក្នុងហេមន្តរដូវ និង គិម្ហរដូវ ជនពាល រមែងគិតខុសដូច្នេះ តែងមិនដឹងច្បាស់សេចក្តីអន្តរាយឡើយ ។

☸ ព្រះពុទ្ធគាថានេះ កាលព្រះសាស្តាទ្រង់គង់នៅវត្ត ជេតពន ទ្រង់ប្រារព្ធ មហាធនពាណិជ ឈ្មួញដែលមានទ្រព្យច្រើន ។
☞ ក្នុងកាលចប់ព្រះធម្មទេសនា ឈ្មួញនោះ តាំងនៅក្នុង សោតាបត្តិផល ។

២៨៧.. តំ បុត្តបសុសម្មត្តំ ព្យាសត្តមនសំ នរំ
សុត្តំ គាមំ មហោឃោវ មច្ចុ អាទាយ គច្ឆតិ ។

មច្ចុ គឺសេចក្តីស្លាប់ តែងនាំយកនរជន អ្នកស្រវឹងជ្រប់ ក្នុងកូន និងសត្វចិញ្ចឹម មានចិត្តជាប់ជំពាក់ ក្នុងអារម្មណ៍ផ្សេង ៗ នោះ ដូចជំនន់ទឹកធំនាំយកអ្នកស្រុកកំពុងដេកលក់ ។

☸ ព្រះពុទ្ធគាថានេះ កាលព្រះសាស្តាទ្រង់គង់នៅវត្ត ជេតពន ទ្រង់ប្រារព្ធ នាងកិសាគោតមី ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា នាងកិសាគោតមី តាំងនៅក្នុង សោតាបត្តិផល ។

២៨៨.. ន សន្តិ បុត្តា តាណាយ ន បិតា នបិ ពន្ធវា
អន្តកេនាធិបន្នស្ស នត្ថិ ញាតីសុ តាណតា ។

២៨៩.. **ឯតមត្ថវសំ ញត្វា　　　　បណ្ឌិតោ សីលសំវុតោ**
និព្វានគមនំ មគ្គំ　　　　ខិប្បមេវ វិសោធយេ ។

កាលបុគ្គល ត្រូវ“**មច្ចុ**”គ្របសង្កត់ហើយ កូនទាំងឡាយ មិនមាន ដើម្បីជាទីពឹង, **បិតា** ក៏មិនមាន ទាំងផៅពង្ស ក៏មិនមាន ដើម្បីជាទីពឹង ឡើយ, សេចក្តីទីពឹងក្នុងញាតិទាំងឡាយ ក៏មិនមាន **បណ្ឌិត**ដឹងអំណាច ប្រយោជន៍នេះហើយ គួរជាអ្នកសង្រួមក្នុងសីល គួរប្រញាប់ប្រញាល់ ជម្រះផ្លូវ ជាទីទៅកាន់ព្រះនិព្វានឱ្យបាន ។

☸ **ព្រះពុទ្ធគាថា**នេះ កាល**ព្រះសាស្តា**ទ្រង់គង់នៅវត្ត **ជេតពន** ទ្រង់ត្រាស់សម្តែងប្រារព្ធ **នាងបដាចារា** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា នាងបដាចារា តាំងនៅក្នុង **សោតាបត្តិផល** ។ ជនជាច្រើន បានសម្រេច អរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

(ចប់ **មគ្គវគ្គ** ទី ២០ = មាន **១៧** គាថា)

ជំពូកទី ២១

បកិណ្ណកវគ្គ

(Pakiṇṇaka Vagga)

Miscellaneous

(Versets Divers)

(មាន ១៦ គាថា)

(ពី គាថា ទី ២៩០ ➡ ដល់ គាថា ទី ៣០៥)

២៩០.. មត្តាសុខបរិច្ចាគា បស្សេ ចេ វិបុលំ សុខំ

ចជេ មត្តាសុខំ ធីរោ សម្បស្សំ វិបុលំ សុខំ ។

បើឃើញសេចក្តីសុខដ៏ធំទូលាយ ព្រោះលះបង់សុខល្មមប្រមាណ **អ្នកមានប្រាជ្ញា** កាលឃើញសុខធំទូលាយ គប្បីលះសុខល្មមប្រមាណចេញ។

☸ <u>**ព្រះពុទ្ធគាថា**នេះ កាល**ព្រះសាស្តា**ទ្រង់គង់នៅវត្ត **វេឡុវ័ន** ទ្រង់ប្រារព្ធ **បុព្វកម្មរបស់ព្រះអង្គ**</u> ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

២៩១.. បរទុក្ខូបធានេន យោ អត្តនោ សុខមិច្ឆតិ

វេរសំសគ្គសំសដ្ឋោ វេរា សោ ន បរិមុច្ចតិ ។

ជនប្រាថ្នាសេចក្តីសុខ ដើម្បីខ្លួន ដោយបង្កទុក្ខឱ្យអ្នកដទៃ ជននោះឈ្មោះថា ច្របូកច្របល់ហើយ ដោយការជាប់ជំពាក់ គឺពៀរ រមែងមិនរួចចាកពៀរទេ ។

☸ <u>**ព្រះពុទ្ធគាថា**នេះ កាល**ព្រះសាស្តា**ទ្រង់គង់នៅវត្ត **ជេតពន** ទ្រង់ប្រារព្ធ **កុមារិកា** អ្នកបរិភោគស៊ុតមាន់ម្នាក់</u> ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា នាងកុមារិកាកុលធីតា តាំងនៅក្នុង **សោតាបត្តិផល** ។

២៩២.. យញ្ហិ កិច្ចំ តទបវិទ្ធំ អកិច្ចំ បន កយីរតិ

ឧន្នលានំ បមត្តានំ តេសំ វឌ្ឍន្តិ អាសវា ។

២៩៣.. យេសញ្ច សុសមារទ្ធា និច្ចំ កាយគតា សតិ

អកិច្ចន្តេ ន សេវន្តិ កិច្ចេ សាតច្ចការិនោ

សតានំ សម្បជានានំ អត្ថំ គច្ឆន្តិ អាសវា ។

របស់ណាដែលខ្លួនគួរធ្វើ របស់នោះ ពួកភិក្ខុណា លះបង់ចោលហើយ, តែរបស់ដែលមិនគួរធ្វើ ត្រឡប់ជាធ្វើវិញ អាសវៈទាំងឡាយ តែងចម្រើនឡើងដល់ពួកភិក្ខុនោះ ជាអ្នកមានសេចក្តីប្រមាទ មានមានះ ដូចជាដើមបបុស លើកឡើងហើយ ។

លុះតែសតិប្រព្រឹត្តទៅក្នុងកាយជានិច្ច (**កាយគតាសតិ**) ដែលពួកភិក្ខុណាបានប្រារព្ធប្រពៃហើយ ភិក្ខុទាំងនោះ រមែងជាអ្នកធ្វើការ ដែលគួរធ្វើរឿយៗ មិនធ្វើការដែលមិនគួរធ្វើ អាសវៈទាំងឡាយ របស់ពួកភិក្ខុនោះ ដែលជាអ្នកមានសតិ មានសម្បជញ្ញៈ រមែងដល់នូវការអស់ទៅ ។

☸ **ព្រះពុទ្ធគាថា**នេះ កាល**ព្រះសាស្តា**ទ្រង់គង់នៅ **ជាតិយាវ័ន** ក្នុងនគរភទ្ទិយៈ ទ្រង់ប្រារព្ធ **ភិក្ខុអ្នកនគរភទ្ទិយៈ** ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុអង្គនោះ តាំងនៅក្នុង **ព្រះអរហត្ត** ។

២៩៤.. មាតរំ បិតរំ ហន្ត្វា រាជានោ ទ្វេ ច ខត្តិយេ
រដ្ឋំ សានុចរំ ហន្ត្វា អនីឃោ យាតិ ព្រាហ្មណោ ។

បុគ្គលសម្លាប់**តណ្ហា** ដូចមាតាផង, សម្លាប់**អស្មិមានះ** ដូចបិតាផង, សម្លាប់ **សស្សតទិដ្ឋិ** និង **ឧច្ឆេទទិដ្ឋិ** ដូចស្តេចជាក្សត្រពីរព្រះអង្គផង, សម្លាប់**អាយតនះ** ដូចជាដែន ប្រព្រឹត្តទៅមួយអន្លើ ដោយបុរសអ្នកដើរតាម គឺ ស្មៀនផង រមែងបានទៅជាខីណាសវព្រាហ្មណ៍ ជាអ្នកមិនមានទុក្ខ ។

២៩៥.. មាតរំ បិតរំ ហន្ត្វា រាជានោ ទ្វេ ច សោត្ថិយេ
វេយគ្ឃបញ្ចមំ ហន្ត្វា អនីឃោ យាតិ ព្រាហ្មណោ ។

បុគ្គលសម្លាប់**តណ្ហា** ដូចមាតាផង, សម្លាប់**អស្មិមានះ** ដូចបិតាផង, សម្លាប់**សស្សតទិដ្ឋិ** និង **ឧច្ឆេទទិដ្ឋិ** ដូចជាស្តេច ជាព្រាហ្មណ៍ទាំងពីរផង, សម្លាប់ វិចិកិច្ឆា ដូចជាខ្លាធំ គម្រប់ ៥ ផង (ដែលនៅស្កាត់ផ្លូវ) បានហើយ រមែងបានទៅជាខីណាសវព្រាហ្មណ៍ ជាអ្នកមិនមានទុក្ខ ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅវត្ត **ជេតពន** ទ្រង់ប្រារព្ធ **ព្រះលកុណ្ឌកភទ្ទិយត្ថេរ** ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុច្រើនរូប តាំងនៅក្នុង **ព្រះអរហត្ត** ។

២៩៦.. សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ ពុទ្ធគតា សតិ ។

២៩៧.. សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ ធម្មគតា សតិ ។

២៩៨.. សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ សង្ឃគតា សតិ ។

២៩៩.. សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ កាយគតា សតិ ។

៣០០.. សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច អហឹសាយ រតោ មនោ ។

៣០១.. សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច ភាវនាយ រតោ មនោ ។

សតិ របស់ជនពួកណា ដែលឋិតនៅ ក្នុង<u>ព្រះពុទ្ធគុណ</u> អស់កាលជានិច្ច ទាំងថ្ងៃទាំងយប់ ជនពួកនោះឈ្មោះថា សាវ័ករបស់**ព្រះគោតម** រមែងភ្ញាក់រឭក ៗ ដោយប្រពៃ សព្វកាល ។

សតិ របស់ជនពួកណា ដែលឋិតនៅ ក្នុង<u>ព្រះធម្មគុណ</u> អស់កាលជានិច្ច ទាំងថ្ងៃទាំងយប់ ជនពួកនោះឈ្មោះថា សាវ័ករបស់**ព្រះគោតម** រមែងភ្ញាក់រឭក ៗ ដោយប្រពៃ សព្វកាល ។

សតិ របស់ជនពួកណា ដែលឋិតនៅ ក្នុង<u>ព្រះសង្ឃគុណ</u> អស់កាលជានិច្ច ទាំងថ្ងៃទាំងយប់ ជនពួកនោះឈ្មោះថា សាវ័ករបស់**ព្រះគោតម** រមែងភ្ញាក់រឭក ៗ ដោយប្រពៃ សព្វកាល ។

សតិ របស់ជនពួកណា ដែលឋិតនៅ ក្នុងកាយ (<u>**កាយគតាសតិ**</u>) អស់កាលជានិច្ច ទាំងថ្ងៃទាំងយប់ ជនពួកនោះឈ្មោះថា សាវ័ករបស់**ព្រះគោតម** រមែងភ្ញាក់រឭក ៗ ដោយប្រពៃ សព្វកាល ។

ចិត្តរបស់ជនពួកណា <u>ត្រេកអរហើយ ក្នុងការមិនបៀតបៀនគេ</u> ទាំងថ្ងៃទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័ករបស់**ព្រះគោតម** រមែងភ្ញាក់រឭក ៗ ដោយប្រពៃ សព្វកាល ។

ចិត្តរបស់ជនពួកណា <u>ត្រេកអរហើយ ក្នុងមេត្តាភាវនា</u> ទាំងថ្ងៃទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័ករបស់**ព្រះគោតម** រមែងភ្ញាក់រឭក ៗ ដោយប្រពៃ សព្វកាល ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្ដាទ្រង់គង់នៅវត្ត **វេឡុវ័ន** ទ្រង់ប្រារព្ធ **បុត្ត** របស់នាយ **ឧគ្គសេនសេដ្ឋី** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា កុមារនោះ ព្រមទាំងមាតាបិតារបស់គេ តាំងនៅក្នុង **សោតាបត្តិផល** ។ ក្រោយមក ជនទាំង ៣ នាក់ នោះបានបួសហើយ បានសម្រេច **ព្រះអរហត្ត** ។

៣០២.. **ទុប្បព្វជ្ជំ ទុរភិរមំ ទុរាវាសា ឃរា ទុខា**
ទុក្ខោសមានសំវាសោ ទុក្ខានុបតិតទ្ធគូ
តស្មា ន ចទ្ធគូ សិយា ន ច ទុក្ខានុបតិតោ សិយា ។

ការចេញបួសបានដោយក្រ, **ការត្រេកអរត្រូវ**បានដោយក្រ, **ផ្ទះទាំងឡាយ**មានការនៅគ្រប់គ្រងដោយលំបាក ជាការក្រ, **ការនៅរួមដោយជនស្មើគ្នា**[9] (ដែលមិនមានសេចក្ដីកោតក្រែង) ជាការក្រ, ជនអ្នកដើរផ្លូវឆ្ងាយ គឺវដ្ដៈ តែងត្រូវសេចក្ដីទុក្ខធ្លាក់ជាប់តាម ព្រោះហេតុនោះ បុគ្គលមិនគប្បីជាអ្នកដើរផ្លូវឆ្ងាយផង មិនគប្បីជាអ្នកត្រូវសេចក្ដីទុក្ខធ្លាក់ជាប់តាមផង ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្ដាទ្រង់គង់នៅក្នុងព្រៃ **មហាវ័ន** ក្រុងវេសាលី ទ្រង់ប្រារព្ធ **ភិក្ខុ** ដែលជាឱរសរបស់ព្រះបាទ **វជ្ជី** មួយរូប ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុនោះ នឿយណាយក្នុងទុក្ខ ទម្លាយចោលនូវសំយោជនៈទាំងអស់ ហើយក៏តាំងនៅក្នុង **ព្រះអរហត្ត** ។

---

[9] អាចារ្យខ្លះប្រែថា ការនៅរួមដោយជនមិនស្មើគ្នា ព្រោះបទថា **ទុក្ខោសមានសំវាសោ** អាចកាត់បទជា **ទុក្ខោ** + **អសមានសំវាសោ** យ៉ាងនេះបាន ។ **អដ្ឋកថា** ក៏មានពន្យល់ដែរ ចំណែកសេចក្ដី បានសេចក្ដីល្អទាំង២យ៉ាង គឺការមិននៅរួមនឹងមនុស្សស្មើគ្នា ក៏ជាការក្រ នៅរួមនឹងមនុស្សមិនស្មើគ្នា ក៏ជាការក្រ ។

៣០៣.. សទ្ធោ សីលេន សម្បន្នោ យសោភោគសមប្បិតោ
យំ យំ បទេសំ ភជតិ តត្ថ តត្ថេវ បូជិតោ ។

បុគ្គលអ្នកមានសទ្ធា បរិបូណ៌ដោយសីល ស្កប់ស្កល់ដោយយស និង ភោគសម្បត្តិ គប់រកប្រទេសណាៗ គេតែងបូជា ក្នុងប្រទេសនោះ ៗ ។

☸ ព្រះពុទ្ធគាថានេះ កាលព្រះសាស្ដាទ្រង់គង់នៅវត្ត ជេតពន ទ្រង់ប្រារព្ធ ចិត្តគហបតី ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផល ទាំងឡាយ មាន សោតាបត្តិផល ជាដើម ។

៣០៤.. ទូរេ សន្តោ បកាសេន្តិ ហិមវន្តោវ បព្វតោ
អសន្តេត្ថ ន ទិស្សន្តិ រត្តឹ ខិត្តា យថា សរា ។

ពួកសប្បុរស រមែងប្រាកដ ក្នុងទីឆ្ងាយ ដូចភ្នំហិមពាន្តដូច្នោះ ពួក អសប្បុរស (ទុកជាឋិតនៅ) ក្នុងទីជិត ក៏រមែងមិនប្រាកដ ដូចព្រួញ ដែល បុគ្គលបាញ់ក្នុងវេលាយប់ ។

☸ ព្រះពុទ្ធគាថានេះ កាលព្រះសាស្ដាទ្រង់គង់នៅវត្ត ជេតពន ទ្រង់ប្រារព្ធ ធីតា របស់ អនាថបិណ្ឌិកសេដ្ឋី ឈ្មោះ ចូឡសុភទ្រា ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផល ជាដើម ។

៣០៥.. ឯកាសនំ ឯកសេយ្យំ ឯកោ ចរមតន្ទិតោ
ឯកោ ទមយមត្តានំ វនន្តេ រមិតោ សិយា ។

បុគ្គល គួរគប់រកទីអង្គុយម្នាក់ឯង ទីដេកម្នាក់ឯង ជាអ្នកត្រាច់ទៅម្នាក់ឯង មិនជាអ្នកខ្ជិលច្រអូស ជាអ្នកម្នាក់ឯងទូន្មានខ្លួន គួរជាអ្នកត្រេកអរ ក្នុងព្រៃស្ងាត់ ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្ដាទ្រង់គង់នៅវត្ត **ជេតពន** ទ្រង់ប្រារព្ធ **ព្រះថេរៈ** មួយអង្គ ឈ្មោះ **ឯកវិហារី** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។ តាំងពីពេលនោះមក មហាជនរមែងប្រាថ្នា ការនៅតែម្នាក់ឯង ប៉ុណ្ណោះ ។

(ចប់ **បកិណ្ណកវគ្គ** ទី ២១ = មាន **១៦** គាថា)

ជំពូកទី ២២

និរយវគ្គ

(Niraya Vagga)

Woeful State

(Versets sur les Etats Malheureux)

(មាន ១៤ គាថា)

(ពី គាថា ទី ៣០៦ ➩ ដល់ គាថា ទី ៣១៩)

៣០៦.. **អភូតវាទី និរយំ ឧបេតិ**

យោ វាបិ កត្វា ន ករោមីតិ ចាហ

ឧភោបិ តេ បេច្ច សមា ភវន្តិ

និហីនកម្មា មនុជា បរត្ថ ។

អ្នកពោលពាក្យមិនពិត ឬបុគ្គលណាធ្វើ (អំពើអាក្រក់) ហើយនិយាយថា អញមិនធ្វើទេ (បុគ្គលនោះ) រមែងទៅកាន់នរក, ជនទាំងពីរនាក់ ដែលមានអំពើទាបថោក (ស្មើគ្នា) នោះ លុះលះលោកនេះទៅហើយ រមែងជាអ្នកស្មើគ្នា (ដោយគតិ) ក្នុងលោកខាងមុខទៀត ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះបរមសាស្តាទ្រង់គង់នៅវត្ត **ជេតពន** ទ្រង់ប្រារព្ធ **នាងបរិព្វាជិកាសុន្ទរី** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៣០៧.. **កាសាវកណ្ឋា ពហវោ បាបធម្មា អសញ្ញតា**

បាបា បាបេហិ កម្មេហិ និរយន្តេ ឧបបជ្ជរេ ។

ពួកជនច្រើននាក់ ដែលមាន **ក** ព័ទ្ធព័ទ្ធដោយសំពត់កាសាវៈ តែ (ប្រព្រឹត្ត) ធម៌ដ៏លាមក មិនបានសង្រួម ពួកជនលាមកទាំងនោះ រមែងទៅកើតក្នុងនរក ដោយសារកម្មទាំងឡាយ ដ៏លាមកនោះ ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅវត្ត **ជេតពន** ទ្រង់ប្រារព្ធ **សត្វ** ទាំងឡាយ ដែលត្រូវអានុភាពនៃផលទុច្ចរិតបៀតបៀន ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៣០៨.៎ សេយ្យោ អយោគុឡោ ភុត្តោ តត្តោ អគ្គិសិខូបមោ
យញ្ចេ ភុញ្ជេយ្យ ទុស្សីលោ រដ្ឋបិណ្ឌំ អសញ្ញតោ ។

បព្វជិតទ្រុស្តសីល សូវបរិភោគដុំដែកដែលកំពុងក្តៅ មានពណ៌ដូចអណ្តាតភ្លើង ប្រសើរជាង, បព្វជិតទ្រុស្តសីល មិនសង្រួម បរិភោគដុំបាយអ្នកដែន នឹងប្រសើរដូចម្តេចបាន ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅក្នុងព្រៃ **មហាវ័ន** ក្រុងវេសាលី ទ្រង់ប្រារព្ធពួក **ភិក្ខុ** ដែលនៅក្បែរឆ្នេរស្ទឹង **វគ្គុមុទា** ។
☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៣០៩.៎ ចត្តារិ ឋានានិ នរោ បមត្តោ
អាបជ្ជតី បរទារូបសេវី
អបុញ្ញលាភំ ន និកាមសេយ្យំ
និន្ទំ តតិយំ និរយំ ចតុត្ថំ ។

៣១០.៎ អបុញ្ញលាភោ ច គតី ច បាបិកា
ភីតស្ស ភីតាយ រតី ច ថោកិកា
រាជា ច ទណ្ឌំ គរុកំ បណេតិ
តស្មា នរោ បរទារំ ន សេវេ ។

នរជន អ្នកប្រមាទហើយ សេពប្រពន្ធរបស់បុគ្គលដទៃ រមែងដល់នូវហេតុនៃសេចក្តីទុក្ខ ៤ យ៉ាង គឺ : ទី១ : បានរបស់មិនមែនជាបុណ្យ, ទី២ : ដេកមិនបានតាមប្រាថ្នា, ទី៣ : ការតិះដៀល, ទី៤ : ការធ្លាក់នរក ។

(**ហេតុនៃសេចក្ដីទុក្ខ ៤ យ៉ាងផ្សេងទៀត**) គឺ : បានរបស់មិនជាបុណ្យ ១, មានគតិអាក្រក់១, តម្រេករបស់បុរសអ្នកខ្លាច ជាមួយនឹងស្ត្រីដែលខ្លាចដែរ មានប្រមាណតិច១ ព្រះរាជានឹងដាក់អាជ្ញាយ៉ាងធ្ងន់១, ព្រោះហេតុនោះ បុរស មិនគួរសេពប្រពន្ធរបស់បុគ្គលដទៃឡើយ ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្ដាទ្រង់គង់នៅវត្ត **ជេតពន** ទ្រង់ប្រារព្ធ បុត្រសេដ្ឋីឈ្មោះ **ខេមកៈ** ជាក្មួយរបស់ **អនាថបិណ្ឌិកសេដ្ឋី** ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា នាយខេមកៈតាំងនៅក្នុង **សោតាបត្តិផល** ។

៣១១.. **កុសោ យថា ទុគ្គហិតោ ហត្ថមេវានុកន្តតិ**
សាមញ្ញំ ទុប្បរាមដ្ឋំ និរយាយុបកឌ្ឍតិ ។
៣១២.. **យំ កិញ្ចិ សិថិលំ កម្មំ សង្កិលិដ្ឋញ្ច យំ វតំ**
សង្កស្សរំ ព្រហ្មចរិយំ ន តំ ហោតិ មហប្ផលំ ។
៣១៣.. **កយិរា ចេ កយិរាថេនំ ទឡ្ហមេនំ បរក្កមេ**
សិថិលោ ហិ បរិព្វាជោ ភិយ្យោ អាកិរតេ រជំ ។

ស្បូវភ្លាំង ដែលបុគ្គលកាន់មិនចំណាប់ រមែងលះដៃ យ៉ាងណាមិញ ភាពជាសមណៈដែលបព្វជិតកាន់មិនស៊ប់សួនហើយ រមែងទាញបព្វជិតនោះ ទៅនរកយ៉ាងនោះឯង ។

កម្មណាមួយ ដែលធូរថយក្ដី វត្តណាមួយដែលសៅហ្មងក្ដី ព្រហ្មចរិយៈ ដែលបុគ្គលរឭកដោយសេចក្ដីរង្កៀសក្ដី កម្មទាំង ៣ នេះ ជារបស់មិនមានផលច្រើនឡើយ ។

បើបុគ្គលធ្វើ គប្បីធ្វើកិច្ចនោះឱ្យមែនទែន គប្បីប្រឹងប្រែងធ្វើកិច្ចនោះឱ្យមាំមួន ព្រោះថា **សមណធម៌**ជាគ្រឿងវៀរចាកកិលេសធូរថយ រមែងរោយធូលី គឺ រាគាទិក្កិលេសដល់បុគ្គល ដោយក្រៃលែង ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅក្នុងវត្ត **ជេតពន** ទ្រង់ប្រារព្ធ **ភិក្ខុ** ប្រដៅក្រមួយរូប ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម, សូម្បីភិក្ខុនោះក៏តាំងនៅក្នុងការសង្រួម ខាងក្រោយមក ចម្រើនវិបស្សនា បានសម្រេចព្រះអរហត្ត ។

៣១៤._ **អកតំ ទុក្កតំ សេយ្យោ បច្ឆា តបតិ ទុក្កតំ**
កតញ្ច សុកតំ សេយ្យោ យំ កត្វា នានុតប្បតិ ។

អំពើអាក្រក់ ដែលបុគ្គលមិនធ្វើ ប្រសើរជាង (ព្រោះថា) អំពើអាក្រក់ រមែងធ្វើឱ្យក្តៅក្រហាយ ក្នុងកាលខាងក្រោយ, បុគ្គលធ្វើអំពើណាហើយ រមែងមិនក្តៅក្រហាយក្រោយ អំពើនោះ ជាអំពើល្អ បើបុគ្គលធ្វើហើយ ឈ្មោះថា បុគ្គលប្រសើរ ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅក្នុងវត្ត **ជេតពន** ទ្រង់ប្រារព្ធ **ស្ត្រី** ដែលត្រូវសេចក្តីប្រចណ្ឌគ្របសង្កត់មួយរូប ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ស្វាមី និង ស្ត្រី ជាភរិយានោះ បានតាំងនៅក្នុង **សោតាបត្តិផល** ។

៣១៥._ **នគរំ យថា បច្ចន្តំ គុត្តំ សន្តរពាហិរំ**
ឯវំ គោបេថ អត្តានំ ខណោ វោ មា ឧបច្ចគា
ខណាតីតា ហិ សោចន្តិ និរយម្ហិ សមប្បិតា ។

នគរនៅទីបំផុតដែន ដែលគេគ្រប់គ្រងហើយ ទាំងខាងក្នុង ទាំងខាងក្រៅយ៉ាងណា អ្នកទាំងឡាយ គួររក្សាខ្លួនយ៉ាងនោះ កុំឱ្យ **ខណៈ**[9] កន្លងអ្នកទាំងឡាយបានឡើយ ព្រោះថាជនទាំងឡាយ ដែលឱ្យខណៈកន្លងហើយ រមែងសោកស្ដាយ ក្នុងនរក មីរដេរដាស ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្ដាទ្រង់គង់នៅក្នុងវត្ត **ជេតពន** ទ្រង់ប្រារព្ធ **ភិក្ខុអាគន្តុក** ច្រើនរូប ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុទាំងនោះ កើតសេចក្ដីសង្វេគ (សេចក្ដីតក់ស្លុត) ក៏បានតាំងនៅក្នុង **ព្រះអរហត្តផល** ។

៣១៦.. **អលជ្ជិតាយេ លជ្ជន្តិ លជ្ជិតាយេ ន លជ្ជរេ**
មិច្ឆាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ ទុគ្គតឹ ។

សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងខ្មាស ក្នុងហេតុដែលគេមិនត្រូវខ្មាស, រមែងមិនខ្មាស ក្នុងហេតុដែលគេត្រូវខ្មាស សត្វទាំងនោះតែងទៅកាន់ទុគ្គតិ ។

៣១៧.. **អភយេ ភយទស្សិនោ ភយេ ច អភយទស្សិនោ**
មិច្ឆាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ ទុគ្គតឹ ។

---

[9] **ខណៈ** ស័ព្ទនេះ ប្រែថា “**ពេលល្អ**” ចែកចេញជា ៤ យ៉ាង គឺៈ **ពុទ្ធុប្បាទក្ខណោ** ពេលដែលព្រះពុទ្ធបានត្រាស់១, **មជ្ឈិមប្បទេសេ ឧបត្តិក្ខណោ** ពេលដែលសត្វកើតឡើងក្នុងមជ្ឈិមប្បទេស១, **សម្មាទិដ្ឋិយា បដិលទ្ធក្ខណោ** ពេលដែលត្រូវបានសម្មាទិដ្ឋិ១, **ឆន្នមា--យតនានំ អវេកល្លក្ខណោ** ពេលដែលមិនវិកលអាយតនៈប្រាំមួយ១ ។ **អដ្ឋកថា** ។

សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងយល់ឃើញ ក្នុងហេតុដែលគេមិនត្រូវខ្លាច ថាជាហេតុដែលគេត្រូវខ្លាចផង, យល់ឃើញក្នុងហេតុដែលគេត្រូវខ្លាច ថាជាហេតុដែលគេមិនត្រូវខ្លាចផង សត្វទាំងនោះ តែងទៅកាន់ទុគ្គតិ ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅក្នុងវត្ត **ជេតពន** ទ្រង់ប្រារព្ធពួក**និគ្រន្ថ**។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ពួកនិគ្រន្ថជាច្រើន មានចិត្តសង្វេគហើយបួស, ធម្មទេសនា បានជា**សាត្ថកថា** ញ៉ាំងការសម្រេចប្រយោជន៍ដល់បុគ្គល អ្នកដែលមកប្រជុំគ្នា បានត្រងត្រាប់ស្តាប់ដោយយោនិសោមនសិការហើយ យ៉ាងនោះ ។

៣១៨.. **អវជ្ជេ វជ្ជមតិនោ វជ្ជេ ច អវជ្ជទស្សិនោ**
មិច្ឆាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ ទុគ្គតឹ ។

សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងយល់ឃើញ ក្នុងហេតុដែលឥតទោស ថាជាហេតុមានទោសផង យល់ឃើញក្នុងហេតុដែលមានទោស ថាជាហេតុឥតទោសផង សត្វទាំងនោះតែងទៅកាន់ទុគ្គតិ ។

៣១៩.. **វជ្ជញ្ច វជ្ជតោ ញត្វា អវជ្ជញ្ច អវជ្ជតោ**
សម្មាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ សុគ្គតឹ ។

សត្វទាំងឡាយ ដែលប្រកាន់សម្មាទិដ្ឋិ ដឹងរបស់មានទោស ថាជារបស់មានទោសផង ដឹងរបស់មិនមានទោស ថាជារបស់មិនមានទោសផង សត្វទាំងនោះ តែងទៅកាន់សុគតិ ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅក្នុងវត្ត **ជេតពន** ទ្រង់ប្រារព្ធសាវ័ករបស់ពួក**តិរ្ថិយ**។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា សាវ័ករបស់ពួក**តិរ្ថិយ**ទាំងនោះ តាំងនៅក្នុងត្រៃសរណៈ ហើយបានស្តាប់ធម៌ ក៏បានតាំងនៅ ក្នុងសោតាបត្តិផល ។

(ចប់ **និរយវគ្គ** ទី ២២ = មាន **១៤** គាថា)

វគ្គទី ២៣

នាគវគ្គ

(Nāga Vagga)

The Elephant

(Versets sur l’Eléphant)

(មាន ១៤ គាថា)

(ពី គាថា ទី ៣២០ ➩ ដល់ គាថា ទី ៣៣៣)

៣២០.. អហំ នាគោវ សង្គាមេ ចាបាតោ បតិតំ សរំ
អតិវាក្យន្តិតិក្ខិស្សំ ទុស្សីលោ ហិ ពហុជ្ជនោ ។
៣២១.. ទន្តំ នយន្តិ សមិតឹ ទន្តំ រាជាភិរូហតិ
ទន្តោ សេដ្ឋោ មនុស្សេសុ យោតិវាក្យន្តិតិក្ខតិ ។
៣២២.. វរមស្សតរា ទន្តា អាជានីយា ច សិន្ធវា
កុញ្ជរា ច មហានាគា អត្តទន្តោ តតោ វរំ ។

តថាគត នឹងអត់ទ្រាំពាក្យល្មើស ដូចដំរីកាលអត់ទ្រាំចំពោះព្រួញ ដែលរបូតចេញអំពីធ្នូ ក្នុងសង្គ្រាមដូច្នោះ ព្រោះថា ជនទ្រុស្តសីលមានច្រើននាក់ ។

ពួកជនតែងនាំវាហនៈ ដែលទូន្មានហើយទៅកាន់ទីប្រជុំ ព្រះរាជាតែងស្ដេចឡើងកាន់វាហនៈ ដែលទូន្មានហើយ, បណ្ដាមនុស្សទាំងឡាយ មនុស្សណា អត់សង្កត់នឹងពាក្យល្មើសបាន មនុស្សនោះ ជាអ្នកមានខ្លួនទូន្មានហើយ ឈ្មោះថា បុគ្គលប្រសើរបំផុត ។

ពួកសេះអស្សតរក្តី សេះអាជានេយ្យក្តី សេះសិន្ធពក្តី ដំរីកុញ្ជរ ដ៏ប្រសើរក្តី ដែលបុគ្គលប្រៀនប្រដៅបានបទហើយ រាប់ថាជាសត្វប្រសើរ **បុគ្គលដែលមានខ្លួនទូន្មានបានបទហើយ** ប្រសើរជាងសត្វទាំងអស់នោះ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្ដាទ្រង់គង់នៅក្រុង**កោសម្ពី** ទ្រង់ប្រារព្ធរឿងរបស់**ព្រះអង្គ** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ពួកជនដែលស៊ីឈ្នួលនាងមាគន្ទិយាឈរជេរបរិភាសដោយអក្កោសវត្ថុ ១០ យ៉ាងតាមផ្លូវថ្នល់ទាំងនោះ ក៏បានសម្រេចសោតាបត្តិផល ។

៣២៣.. ន ហិ ឯតេហិ យានេហិ គច្ឆេយ្យ អគតំ ទិសំ
យថាត្តនា សុទន្តេន ទន្តោ ទន្តេន គច្ឆតិ ។

បុគ្គលទូន្មានខ្លួនបានបទហើយ ទូន្មានខ្លួនល្អហើយ ឈ្មោះថាទូន្មានហើយ ទើបទៅកាន់ទិសដែលខ្លួនមិនធ្លាប់ទៅ គឺព្រះនិព្វានបាន ពុំមែនដូចបុគ្គលទៅកាន់ទិស ដែលខ្លួនមិនធ្លាប់ទៅ ដោយសារយានទាំងឡាយនោះឡើយ ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅក្នុងវត្ត **ជេតពន** ទ្រង់ប្រារព្ធភិក្ខុមួយរូបដែលធ្លាប់ជាហ្មដំរី ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផល ជាដើម ។

៣២៤.. ធនបាលកោ នាម កុញ្ជរោ
កដុកប្បភេទនោ ទុន្និវារយោ
ពទ្ធោ កពឡំ ន ភុញ្ជតិ
សុមរតិ នាគវនស្ស កុញ្ជរោ ។

ដំរីឈ្មោះ **ធនបាល** ជាសត្វចុះប្រេង ក្លៀវក្លា នាយហត្ថាចារ្យឃាត់បានដោយលំបាក បើនាយហត្ថាចារ្យ ចងភ្ជាប់ មិនស៊ីស្មៅទេ ព្រោះរឭកដល់ព្រៃខ្លឹង ដែលដំរីនោះធ្លាប់នៅ ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅក្នុងក្រុង **សាវត្ថី** ទ្រង់ប្រារព្ធ បុត្ររបស់ព្រាហ្មណ៍ចាស់ទុរន់ម្នាក់ (អតីតព្រាហ្មណ៍មហាសាល) ។
☞ ក្នុងកាលចប់ព្រះធម្មទេសនា ព្រាហ្មណ៍នោះ ព្រមទាំងបុត្រ និង កូនប្រសាស្រីទាំងឡាយ តាំងនៅក្នុង **សោតាបត្តិផល** ។

៣២៥.. មិទ្ធី យទា ហោតិ មហគ្ឃសោ ច
និទ្ទាយិតា សម្បរិវត្តសាយី
មហាវរាហោវ និវាបបុដ្ឋោ
បុនប្បុនំ គព្ភមុបេតិ មន្ទោ ។

កាលណា បុគ្គលអ្នកមានសេចក្ដីងោកងុយផង អ្នកបរិភោគភោជនមានប្រមាណច្រើនផង អ្នកដេកលក់ផង អ្នកដេកបម្រះនៀលផង ដូចជ្រូកស្រុក ដែលបុគ្គលចិញ្ចឹម ដោយស្លូករភត្ត កាលនោះបុគ្គលនោះ ជាមនុស្សខ្លៅ រមែងចូលទៅកាន់គភ៌រឿយ ៗ ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្ដាទ្រង់គង់នៅក្នុងវត្ត **ជេតពន** ទ្រង់ប្រារព្ធ **ព្រះបាទបសេនទិកោសល** ។ ☞ មហាជនដែលមកប្រជុំក្នុងទីនោះ បានសម្រេចគុណវិសេសដ៏ធំ ព្រោះអាស្រ័យការអនុមោទនាទាន ។

៣២៦.. ឥទំ បុរេ ចិត្តមចារិ ចារិកំ
យេនិច្ឆកំ យត្ថកាមំ យថាសុខំ
តទជ្ជហំ និគ្គហេស្សាមិ យោនិសោ
ហត្ថិប្បភិន្នំ វិយ អំកុសគ្គហោ ។

ក្នុងកាលមុនអំពីកាលនេះ ចិត្តនេះបានត្រាច់ទៅកាន់ចារិក តាមអាការដែលខ្លួនប្រាថ្នា តាមអារម្មណ៍ដែលខ្លួនប្រាថ្នា តាមសេចក្ដីសប្បាយ, **ក្នុងថ្ងៃនេះ អញនឹងសង្កត់សង្កិនចិត្តនោះ ដោយឧបាយ ដូចឃ្មាំដំរីកាន់កង្វេរសង្កត់សង្កិនដំរីចុះប្រេង ដូច្នោះដែរ ។**

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅក្នុងវត្ត **ជេតពន** ទ្រង់ប្រារព្ធ **សានុសាមណេរ** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា **ធម្មាភិសម័យ** បានកើតមានដល់**ទេវតា**ជាច្រើន ដែលចូលទៅដើម្បីស្តាប់ធម៌ ជាមួយនឹង **សានុសាមណេរ** ។ ចំណែក**សានុសាមណេរ** សិក្សា **ព្រះពុទ្ធវចនៈ** គឺព្រះត្រៃបិដក អំពី **ព្រះសម្មាសម្ពុទ្ធ** ហើយ បានក្លាយជាព្រះធម្មកថិក ដ៏ជំនាញមួយរូប ។ លោកមានអាយុ ១២០ ឆ្នាំ ញ៉ាំងជម្ពូទ្វីបទាំងមូលឱ្យភ្លូកភ្លឹកហើយ បរិនិព្វានដោយបការៈដូច្នេះ ។

៣២៧.. **អប្បមាទរតា ហោថ សចិត្តមនុរក្ខថ**
ទុគ្គា ឧទ្ធរថត្តានំ បង្កេ សន្នោវ កុញ្ជរោ ។

អ្នកទាំងឡាយ ចូរត្រេកអរក្នុងសេចក្តីមិនប្រមាទ ចូររក្សាចិត្តរបស់ខ្លួន ចូររើខ្លួនចេញចាកភក់ គឺកិលេស ដែលឆ្លងបានដោយកម្រ ដូចដំរី ដែលជាប់នៅក្នុងភក់ រើខ្លួនឱ្យរួចបាន ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅក្នុង **វត្តជេតពន** ទ្រង់ប្រារព្ធ ដំរីឈ្មោះ **បាវេរកៈ** របស់ **ព្រះបាទកោសល** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុទាំងឡាយ ដែលគង់ស្តាប់ព្រះធម្មទេសនាដោយគោរព តាំងនៅក្នុងព្រះអរហត្តផល ។

៣២៨.. **សចេ លភេថ និបកំ សហាយំ**
សទ្ធឹ ចរំ សាធុវិហារិ ធីរំ
អភិភុយ្យ សព្វានិ បរិស្សយានិ
ចរេយ្យ តេនត្តមនោ សតីមា ។

៣២៩.. នោ ចេ លភេថ និបកំ សហាយំ
សទ្ធឹ ចរំ សាធុវិហារិ ធីរំ
រាជាវ រដ្ឋំ វិជិតំ បហាយ
ឯកោ ចរេ មាតង្គរញ្ញេវ នាគោ ។

៣៣០.. ឯកស្ស ចរិតំ សេយ្យោ
នត្ថិ ពាលេ សហាយតា
ឯកោ ចរេ ន ច បាបានិ កយិរា
អប្បោស្សុក្កោ មាតង្គរញ្ញេវ នាគោ ។

☞ បើបុគ្គលបានសម្លាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានប្រាជ្ញាចងចាំ មានគុណធម៌ជាគ្រឿងនៅ ញុំាងប្រយោជន៍ឱ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយ គួរជាអ្នកមានចិត្តត្រេកអរ មានស្មារតី គ្របសង្កត់សេចក្តីអន្តរាយទាំងពួង ហើយត្រាច់ទៅជាមួយនឹងសម្លាញ់នោះឯង ។

☞ បើស្វែងរកមិនបានសម្លាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានប្រាជ្ញាចងចាំ មានគុណធម៌ជាគ្រឿងញុំាងប្រយោជន៍ឱ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយទេ គួរត្រាច់ទៅតែឯកឯងវិញ ដូចព្រះរាជាលះបង់រដ្ឋដែលទ្រង់ឈ្នះហើយ ស្តេចទៅតែឯកអង្គ ពុំនោះសោត ដូចដំរីឈ្មោះ **មាតង្គៈ** ដែលលះហ្វូងត្រាច់ទៅ តែឯកឯងក្នុងព្រៃ ដូច្នោះដែរ ។

☞ ការត្រាច់ទៅរបស់បុគ្គលឯកឯង ជាគុណជាតប្រសើរបំផុត (ព្រោះថា) **សហាយតាគុណ** រមែងមិនមាន ក្នុងជនពាលឡើយ បុគ្គលនោះ គប្បីជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ត្រាច់ទៅតែម្នាក់ឯងផង មិនគប្បីធ្វើអំពើបាបទាំងឡាយផង ដូចដំរីឈ្មោះ **មាតង្គៈ** ជាសត្វមិនមានសេចក្តីខ្វល់ខ្វាយ លះបង់ហ្វូង ត្រាច់ទៅតែឯកឯងក្នុងព្រៃ ដូច្នោះដែរ ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅក្នុងដងព្រៃឈ្មោះ **រក្ខិតៈ** ដែលអាស្រ័យព្រៃឈ្មោះ **បាលិលេយ្យកៈ** ទ្រង់ប្រារព្ធ **ភិក្ខុ**ច្រើនរូប ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុទាំង ៥០០ រូប តាំងនៅក្នុងសោតាបត្តិផល ។

៣៣១._ **អត្ថម្ហិ ជាតម្ហិ សុខា សហាយា**
តុដ្ឋី សុខា យា ឥតរីតរេន
បុញ្ញំ សុខំ ជីវិតសង្ខយម្ហិ
សព្វស្ស ទុក្ខស្ស សុខំ បហានំ ។

៣៣២._ **សុខា មត្តេយ្យតា លោកេ អថោ បេត្តេយ្យតា សុខា**
សុខា សាមញ្ញតា លោកេ អថោ ព្រហ្មញ្ញតា សុខា ។
៣៣៣._ **សុខំ យាវ ជរា សីលំ សុខា សទ្ធា បតិដ្ឋិតា**
សុខោ បញ្ញាបដិលាភោ បាបានំ អករណំ សុខំ ។

☞ កាលបើសេចក្តីត្រូវការ កើតឡើងហើយ សម្លាញ់ទាំងឡាយនាំសេចក្តីសុខមកឱ្យ សេចក្តីត្រេកអរដោយបច្ច័យ តាមមានតាមបាន ជាហេតុ

នាំសេចក្តីសុខមកឱ្យ, បុណ្យនាំសេចក្តីសុខមកឱ្យ ក្នុងកាលទៀបក្ស័យជីវិត ការលះបង់ទុក្ខទាំងអស់បាន ជាហេតុនាំសេចក្តីសុខមកឱ្យ ។

☞ **សេចក្តីប្រតិបត្តិល្អក្នុងមាតា** នាំសេចក្តីសុខមកឱ្យក្នុងលោកមួយទៀត **សេចក្តីប្រតិបត្តិល្អក្នុងបិតា** នាំសេចក្តីសុខមកឱ្យ **សេចក្តីប្រតិបត្តិល្អក្នុងសមណៈ** នាំសេចក្តីសុខមកឱ្យក្នុងលោក មួយទៀត **សេចក្តីប្រតិបត្តិល្អក្នុងព្រាហ្មណ៍** នាំសេចក្តីសុខមកឱ្យ, **សីល** នាំសេចក្តីសុខមកឱ្យដរាបដល់ចាស់, **សទ្ធា**ដែលបុគ្គលតម្កល់ស៊ប់ហើយ នាំសេចក្តីសុខមកឱ្យ, **ការបានប្រាជ្ញា** នាំសេចក្តីសុខមកឱ្យ, **ការមិនធ្វើបាបទាំងឡាយ** នាំសេចក្តីសុខមកឱ្យ ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅក្នុងកុដិ ដែលតាំងនៅក្នុងព្រៃ**ហិមពាន្ត** ទ្រង់ប្រារព្ធ **មារ** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា "**ធម្មាភិសម័យ**" បានកើតមានដល់ទេវតាជាច្រើន ។

(ចប់ **នាគវគ្គ** ទី ២៣ = មាន **១៤** គាថា)

វគ្គទី ២៤

តណ្ហាវគ្គ

(Taṇhā Vagga)

The Craving

(Versets sur la Soif)

(មាន ២៦ គាថា)

(ពី គាថា ទី ៣៣៤ ➩ ដល់ គាថា ទី ៣៥៩)

៣៣៤.. មនុជស្ស បមត្តចារិនោ
តណ្ហា វឌ្ឍតិ មាលុវា វិយ
សោ បលវតី ហុរាហុរំ
ផលមិច្ឆំវ វនស្មឹ វានរោ ។

៣៣៥.. យំ ឯសា សហតី ជម្មី តណ្ហា លោកេ វិសត្តិកា
សោកា តស្ស បវឌ្ឍន្តិ អភិវឌ្ឍំវ វីរណំ ។

៣៣៦.. យោ ចេ តំ សហតី ជម្មឹ តណ្ហំ លោកេ ទុរច្ចយំ
សោកា តម្ហា បបតន្តិ ឧទពិន្ទុវ បោក្ខរា ។

៣៣៧.. តំ វោ វទាមិ ភទ្ទំ វោ យាវន្តេត្ថ សមាគតា
តណ្ហាយ មូលំ ខណថ ឧសីរត្ថោវ វីរណំ
មា វោ នឡំ វ សោតោវ មារោ ភញ្ជិ បុនប្បុនំ ។

☞ តណ្ហា តែងចម្រើនដល់មនុស្សអ្នកមានការប្រព្រឹត្ត ដោយសេចក្តីប្រមាទជាប្រក្រតី ដូចវល្លិ៍រួបរឹតដើមឈើហើយ ចម្រើនឡើង បុគ្គលនោះ តែងស្ទុះទៅកាន់ភពតូចភពធំ ដូចស្វា កាលប្រាថ្នាផ្លែឈើលោតទៅក្នុងព្រៃ ដូច្នោះដែរ ។

☞ តណ្ហានុ៎ះ ជាទោសជាតិដ៏លាមក ផ្សាយទៅក្នុងអារម្មណ៍ផ្សេងៗក្នុងលោក គ្របសង្កត់បុគ្គលណា សេចក្តីសោកស្តាយ តែងចម្រើនឡើងដល់បុគ្គលនោះ ដូចស្មៅវរណ្តាស ដែលត្រូវភ្លៀងធ្លាក់ចុះជព្រំហើយ ពន្លកលូតលេចឡើង ដូច្នោះដែរ ។

☞ ចំណែកជនណា គ្របសង្កត់តណ្ហាដ៏លាមក ក្នុងលោក ដែលគេឆ្លងបានដោយកម្រនោះ សេចក្តីសោកស្តាយ តែងធ្លាក់ចេញចាកជននោះឯង ដូចដំណក់ទឹកដែលធ្លាក់ចុះចាកស្លឹកឈូក ដូច្នោះដែរ ។

☞ ព្រោះហេតុនោះ បានជា **តថាគត** ប្រាប់អ្នកទាំងឡាយ អ្នកទាំងឡាយមានប៉ុន្មានរូប ដែលមកប្រជុំក្នុងទីនេះ សេចក្តីចម្រើនចូរមានដល់អ្នកទាំងឡាយ ទាំងប៉ុណ្ណោះចុះ, អ្នកទាំងឡាយ ចូររំលើងឫសតណ្ហាចោលចេញ ដូចបុគ្គលត្រូវការដោយស្បូវភ្លាំង គាស់ស្បូវរណ្តាសចោលចេញ ដូច្នោះ ។ **មារ** កុំរុករានអ្នកទាំងឡាយរឿយ ៗ ដូចខ្សែទឹក កាច់បំបាក់ដើមបបុស ដូច្នោះឡើយ ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធត្រីឈ្មោះ **កបិលៈ** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា បុត្ររបស់អ្នកនេសាទទាំង ៥០០ នាក់នោះ កើតសេចក្តីសង្វេគ ប្រាថ្នានឹងធ្វើនូវទីបំផុតនៃសេចក្តីទុក្ខ ក៏បួសក្នុងសំណាក់ព្រះមានព្រះភាគ ធ្វើនូវទីបំផុតនៃសេចក្តីទុក្ខ អស់កាលមិនយូរ បានជាអ្នកមានការបរិភោគជាមួយគ្នាដោយធម៌ ជាគ្រឿងបរិភោគ គឺ **អានេញ្ជវិហារធម៌** និង **សមាបត្តិធម៌** រួមនឹង **ព្រះ-សម្មាសម្ពុទ្ធ ព្រះបរមសាស្តា** ។

៣៣៨.. **យថាបិ មូលេ អនុបទ្ទវេ ទឡ្ហេ**
ឆិន្នោបិ រុក្ខោ បុនរេវ រូហតិ
ឯវម្បិ តណ្ហានុសយេ អនូហតេ
និព្វត្តតី ទុក្ខមិទំ បុនប្បុនំ ។

☞ កាលបើឫសឈើ មិនមានសេចក្តីអន្តរាយ នៅមាំមួនទេ ដើមឈើទុកជាកាប់ចោលហើយ ក៏តែងដុះឡើងទៀតបាន មានឧបមាដូចម្តេចមិញ កាលបើតណ្ហានុស័យ បុគ្គលកំចាត់មិនទាន់បានហើយ **ទុក្ខ** (មានជាតិទុក្ខ ជាដើម) នេះ ក៏តែងកើតរឿយៗ មានឧបមេយ្យ ដូច្នោះឯង ។

៣៣៩.. **យស្ស ឆត្តឹសតី សោតា មនាបស្សវនា ភុសា**
មហា វហន្តិ ទុទ្ទិដ្ឋី សង្កប្បា រាគនិស្សិតា ។

☞ ខ្សែតណ្ហា ៣៦ ជាធម្មជាតិហូរទៅ ក្នុងអារម្មណ៍ ជាទីគាប់ចិត្ត ជាធម្មជាតិក្លៀវក្លា មានដល់បុគ្គលណា តម្រិះទាំងឡាយដ៏ធំ ដែលអាស្រ័យនូវរាគៈ តែងនាំនូវទិដ្ឋិអាក្រក់ របស់បុគ្គលនោះ ។

៣៤០.. **សវន្តិ សព្វធិ សោតា លតា ឧព្ភិជ្ជ តិដ្ឋតិ**
តញ្ច ទិស្វា លតំ ជាតំ មូលំ បញ្ញាយ ឆិន្ទថ ។

☞ ខ្សែតណ្ហាទាំងឡាយ តែងហូរទៅ ក្នុងអារម្មណ៍ទាំងពួង ដូចជាវល្លិដែលបែកខ្នែងឡើង តាំងនៅដូច្នោះ បើអ្នកទាំងឡាយ ឃើញតណ្ហាដូចជាវល្លិនោះ កើតឡើងហើយ ☞ **ចូរកាត់ឫស (តណ្ហា) ចោលចេញដោយកាំបិត គឺ បញ្ញា** ។

៣៤១.. **សរិតានិ សិនេហិតានិ ច**
សោមនស្សានិ ភវន្តិ ជន្តុនោ

តេ សាតសិតា សុខេសិនោ

តេ វេ ជាតិជរូបគា នរា ។

☞ សោមនស្សទាំងឡាយ ដែលផ្សាយទៅហើយផង ដែលប្រព្រឹត្តទៅ ដោយសេចក្ដីស្រឡាញ់ផង រមែងមានដល់សត្វ ពួកសត្វនោះ ជាអ្នកអាស្រ័យនូវសេចក្ដីរីករាយ អ្នកស្វែងរកសេចក្ដីសុខ នរជនទាំងឡាយនោះឯង តែងឈមទៅរក **ជាតិ** និង **ជរា** ។

៣៤២.. **តសិណាយ បុរក្ខតា បជា**

បរិសប្បន្តិ សសោវ ពាធិតោ

សញ្ញោជនសង្គសត្តា

ទុក្ខមុបេន្តិ បុនប្បុនំ ចិរាយ ។

☞ ពួកសត្វដែលតណ្ហា ជាទីញុាំងសត្វឱ្យតក់ស្លុត ក្រុងទុកហើយ តែងរន្ធត់ដូចទន្សាយ ដែលព្រានទាក់បានហើយដូច្នោះ ពួកសត្វ ដែលជាប់ក្នុង**សំយោជនៈ** និង **សង្គធម៌** (ធម៌ជាគ្រឿងជំពាក់) តែងដល់នូវសេចក្ដីទុក្ខរឿយៗ អស់កាលអង្វែង ។

៣៤៣.. **តសិណាយ បុរក្ខតា បជា**

បរិសប្បន្តិ សសោវ ពាធិតោ

តស្មា តសិណំ វិនោទយេ

ភិក្ខុ អាកង្ខំ វិរាគមត្តនោ ។

☞ ពួកសត្វដែលតណ្ហា ជាទីញុាំងសត្វឱ្យតក់ស្លុត ក្រុងទុកហើយ តែងវន្ធត់ដូចទន្សាយ ដែលនាយព្រានទាក់បានហើយដូច្នោះ ព្រោះហេតុនោះ ភិក្ខុកាលប្រាថ្នាធម៌ ជាគ្រឿងប្រាសចាករាគៈ ដើម្បីខ្លួន គប្បីបន្ទោបង់តណ្ហា ដែលជាគ្រឿងតក់ស្លុត ចោលចេញ ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅក្នុង **វត្តវេឡុវ័ន** ទ្រង់ប្រារព្ធកូនជ្រូកញីកំពុងស៊ីលាមកមួយ ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផល ជាដើម ។

៣៤៤.. **យោ និព្វនថោ វនាធិមុត្តោ**
វនមុត្តោ វនមេវ ធាវតិ
តំ បុគ្គលមេវ បស្សថ
មុត្តោ ពន្ធនមេវ ធាវតិ ។

☞ បុគ្គលណា មិនមានអាល័យក្នុង **គិហិភាព** ដូចដើមឈើតាំងនៅក្នុងព្រៃ មានចិត្តចុះស៊ប់ក្នុងព្រៃ គឺ **តបធម៌** ជាអ្នករួចស្រឡះចាកព្រៃ គឺតណ្ហា ហើយស្ទុះទៅរកព្រៃ គឺតណ្ហាវិញ អ្នកទាំងឡាយ ចូរមើលបុគ្គលនោះឯង បុគ្គលនោះរួចចាកចំណង គឺ **ឃរាវាស** ហើយ ស្ទុះទៅរកចំណង គឺ **ឃរាវាស** វិញ ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅក្នុង **វត្តវេឡុវ័ន** ទ្រង់ប្រារព្ធ **វិព្ភន្តកភិក្ខុ** ភិក្ខុអ្នកសឹកមួយរូប ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុអ្នកសឹករូបនោះលើកចិត្តឡើងកាន់ត្រៃលក្ខណ៍ ពិចារណាសង្ខារទាំងឡាយ បានសម្រេចសោតាបត្តិផល

ហើយ សោយសុខដែលកើតអំពីសមាបត្តិ ហោះឡើងទៅកាន់វេហាស៍ មកកាន់សំណាក់ព្រះមានព្រះភាគតាមអាកាសនោះឯង ថ្វាយបង្គំព្រះមានព្រះភាគហើយបួសបានសម្រេចព្រះអរហត្តនៅកណ្ដាលបរិស័ទ ក្នុងកាលនោះឯង ។

៣៤៥.. ន តំ ទឡ្ហំ ពន្ធនមាហុ ធីរា
យទាយសំ ទារុជំ បព្វជញ្ច
សារត្តរត្តា មណិកុណ្ឌលេសុ
បុត្តេសុ ទារេសុ ច យា អបេក្ខា ។

៣៤៦.. ឯតំ ទឡ្ហំ ពន្ធនមាហុ ធីរា
ឱហារិនំ សិថិលំ ទុប្បមុញ្ចំ
ឯតំបិ ឆេត្វាន បរិព្វជន្តិ
អនបេក្ខិនោ កាមសុខំ បហាយ ។

☞ ចំណងណា ដែលកើតអំពីដែកក្ដី កើតអំពីឈើក្ដី កើតអំពី ស្មៅយាប្លងក្ដី អ្នកប្រាជ្ញមិនហៅចំណងនោះ ថាជាចំណងមាំមួនឡើយ ។

☞ ពួកជនណា ត្រេកអរក្រៃពេក ក្នុងកែវមណី និង កុណ្ឌលទាំងឡាយក្ដី សេចក្ដីអាឡោះអាល័យកូន និង ប្រពន្ធទាំងឡាយក្ដី អ្នកប្រាជ្ញទាំងឡាយ ហៅសេចក្ដីត្រេកអរ និង សេចក្ដីអាឡោះអាល័យនោះ ថាជាចំណងមាំមួន ជាចំណងនាំចុះ (ទាញសត្វទម្លាក់ទៅក្នុងអបាយ) ជាចំណងធូរទេ ប៉ុន្តែសត្វស្រាយបានដោយកម្រ អ្នកប្រាជ្ញទាំងឡាយកាត់ចំណងនោះចេញ ជាអ្នកមិនមានសេចក្ដីអាឡោះអាល័យ លះបង់កាមសុខ ហើយចេញបួស ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅក្នុង **វត្តជេតពន** ទ្រង់ប្រារព្ធអំពីពន្ធនាគារ ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេច អរិយផលទាំងឡាយ មានសោតាបត្តិផល ជាដើម ។

៣៤៧.. **យេ រាគរត្តានុបតន្តិ សោតំ**
សយំ កតំ មក្កដកោវ ជាលំ
ឯតម្បិ ឆេត្វាន វជន្តិ ធីរា
អនបេក្ខិនោ សព្វទុក្ខំ បហាយ ។

☞ ពួកជនណា ត្រេកអរដោយអំណាចរាគៈ ពួកជននោះ តែងធ្លាក់ចុះកាន់ខ្សែតណ្ហា ដូចពីងពាងទម្លាក់ខ្លួនចុះកាន់សំណាញ់ ដែលធ្វើហើយដោយខ្លួនឯង, អ្នកប្រាជ្ញទាំងឡាយ តែងកាត់ខ្សែតណ្ហានោះ ជាអ្នកមិនមានសេចក្តីអាឡោះអាល័យ លះទុក្ខទាំងពួងចេញទៅ ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅក្នុង **វត្តវេឡុវ័ន** ទ្រង់ប្រារព្ធ **ព្រះនាងខេមា** ព្រះអគ្គមហេសីរបស់ព្រះបាទពិម្ពិសារ នគររាជគ្រឹះ ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ព្រះនាងខេមាទ្រង់តាំងនៅក្នុងព្រះអរហត្ត ព្រះនាងបួសហើយ ក៏បានជាសាវិកាដ៏ប្រសើរ “**ឯតទគ្គខាងបញ្ញា**” ។

៣៤៨.. **មុញ្ច បុរេ មុញ្ច បច្ឆតោ**
មជ្ឈេ មុញ្ច ភវស្ស បារគូ
សព្វត្ថ វិមុត្តមានសោ
ន បុន ជាតិជរំ ឧបេហិសិ ។

☞ អ្នកចូរដោះ(សេចក្ដីអាល័យ)ក្នុងកាលមុនចេញ ចូរដោះ(សេចក្ដី-អាល័យ) ក្នុងខាងក្រោយចេញ ចូរដោះ(សេចក្ដីអាល័យ) ក្នុងកាលជាកណ្ដាលចេញ (កាលបើធ្វើយ៉ាងនេះ)អ្នកនឹងដល់ត្រើយនៃភព និង មានចិត្តរួចស្រឡះ ចាកសង្ខតធម៌ទាំងពួង មិនត្រូវទៅកាន់ជាតិ និង ជរាទៀតឡើយ ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្ដាទ្រង់គង់នៅក្នុង **វត្តវេឡុវ័ន** ទ្រង់ប្រារព្ធ **ឧគ្គសេន** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ការត្រាស់ដឹងធម៌ បានមានដល់សត្វ ៨៤.០០០, ចំណែក **ឧគ្គសេន**សេដ្ឋីបុត្រ ក៏បានសម្រេច **ព្រះអរហត្ត** មួយអន្លើដោយ **បដិសម្ភិទា** ។

៣៤៩.. **វិតក្កមថិតស្ស ជន្តុនោ**
តិព្វរាគស្ស សុភានុបស្សិនោ
ភិយ្យោ តណ្ហា បវឌ្ឍតិ
ឯស ខោ ទឡ្ហំ ករោតិ ពន្ធនំ ។

៣៥០.. **វិតក្កូបសមេ ច យោ រតោ**
អសុភំ ភាវយតី សទា សតោ
ឯស ខោ វ្យន្តិកាហតិ
ឯសច្ឆេច្ឆតិ មារពន្ធនំ ។

☞ តណ្ហារមែងចម្រើនក្រៃលែង ដល់ជនដែលវិតក្កៈញាំញី មានតម្រេកក្លៀវក្លា យល់ឃើញអារម្មណ៍ថាល្អ បុគ្គលនោះឯង ឈ្មោះថាធ្វើចំណងឱ្យមាំមួន ។ *លុះតែបុគ្គលណា ត្រេកអរក្នុងអសុភជ្ឈាន ដែលជា*

ហេតុឱ្យស្ងប់រម្ងាប់នូវវិតក្កៈ មានស្មារតីសព្វកាល តែងចម្រើនអសុភជ្ឈាន បុគ្គលនោះឯង នឹងធ្វើតណ្ហាឱ្យអស់ទៅបាន បុគ្គលនោះឯង ទើបឈ្មោះថា កាត់ចំណងមារបាន ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅក្នុង **វត្តជេតពន** ទ្រង់ប្រារព្ធ ភិក្ខុកំលោះមួយរូប (ចូឡធនុគ្គហបណ្ឌិត) ។

☞ ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុរូបនោះ បានតាំងនៅក្នុង **សោតាបត្តិផល** ។

៣៥១.. **និដ្ឋង្គតោ អសន្តាសី វីតតណ្ហោ អនង្គណោ**
អច្ឆិន្ទិ ភវសល្លានិ អន្តិមោយំ សមុស្សយោ ។
៣៥២.. **វីតតណ្ហោ អនាទានោ និរុត្តិបទកោវិទោ**
អក្ខរានំ សន្និបាតំ ជញ្ញា បុព្វាបរានិ ច
ស វេ អន្តិមសារីរោ មហាបញ្ញោ មហាបុរិសោតិ វុច្ចតិ ។

បុគ្គលណា ដល់សេចក្តីសម្រេច គឺ **អរហត្ត** ជាអ្នកមិនតក់ស្លុត មិនមានតណ្ហា មិនមានកិលេសដូចទីទួល បានកាត់កូនសរគឺកិលេស ជាហេតុញុំាងសត្វឱ្យទៅកាន់ភពបានហើយ កាយដែលឆ្អឹង ៣០០ កំណាត់ផ្គុំគ្នាហើយនេះ របស់បុគ្គលនោះ ឈ្មោះថាតាំងនៅក្នុងទីបំផុត ។

បុគ្គលណា មិនមានតណ្ហា មិនមានសេចក្តីប្រកាន់មាំ ជាអ្នកឈ្លាសក្នុង**និរុត្តិ** (វាចាជាគ្រឿងសម្តែងចេញ) និង បទដ៏សេស ដឹងច្បាស់នូវប្រជុំនៃអក្ខរៈទាំងឡាយផង នូវខាងដើម និង ខាងចុង នៃអក្ខរៈទាំងឡាយផង បុគ្គលនោះឯង **តថាគត** ហៅថា អ្នកមានសរីរៈឋិតនៅក្នុងទីបំផុត មាន**បញ្ញា**ច្រើន ជា**មហាបុរស** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅក្នុង **វត្តជេតពន** ទ្រង់ប្រារព្ធ **មារ**។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចនូវ **អរិយផល** ទាំងឡាយ មាន **សោតាបត្តិផល** ជាដើម។

៣៥៣.. សព្វាភិភូ សព្វវិទូហមស្មិ
សព្វេសុ ធម្មេសុ អនូបលិត្តោ
សព្វញ្ជហោ តណ្ហក្ខយេ វិមុត្តោ
សយំ អភិញ្ញាយ កមុទ្ទិសេយ្យំ ។

តថាគត ជាអ្នកគ្របសង្កត់ **តេភូមិកធម៌** ទាំងអស់ ដឹងច្បាស់ **ចតុព្ភូមិកធម៌**ទាំងអស់ មានចិត្តមិនបានជាប់នៅ ក្នុងតេភូមិកធម៌ទាំងអស់ លះបង់តេភូមិកធម៌ទាំងអស់ មានចិត្តរួចស្រឡះ ព្រោះអស់តណ្ហា បើ **តថាគត** ត្រាស់ដឹងធម៌ ដោយខ្លួនឯងហើយ ចាំបាច់យកអ្នកណាជាគ្រូអាចារ្យទៀត ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់ប្រារព្ធ **ឧបកាជីវក** ក្នុងចន្លោះផ្លូវទៅកាន់ **ឥសិបតនមិគទាយវ័ន** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា **ឧបកាជីវក** មិនត្រេកអរ មិនជំទាស់នឹងព្រះតម្រាស់របស់ **ព្រះតថាគត** ឡើយ គ្រាន់តែងក់ក្បាល លៀនអណ្តាត ហើយកាន់យកផ្លូវ ដែលបុគ្គលគប្បីដើរទៅដោយជើង បានទៅកាន់ទីលំនៅនាយព្រានមួយ ។

៣៥៤.. សព្វទានំ ធម្មទានំ ជិនាតិ
សព្វរសំ ធម្មរសោ ជិនាតិ
សព្វរតឹ ធម្មរតិ ជិនាតិ
តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ ។

* **ធម្មទាន** ឈ្នះអាមិសទានទាំងពួង,

* **ធម្មរស** ឈ្នះរសទាំងពួង,

* **សេចក្តីត្រេកអរក្នុងធម៌** ឈ្នះសេចក្តីត្រេកអរទាំងពួង,

* **ការអស់តណ្ហា** ឈ្នះទុក្ខទាំងពួង ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅក្នុង **វត្តជេតពន** ទ្រង់ប្រារព្ធ **សក្កទេវរាជ** ។ ☞ កាលព្រះបរមសាស្តា ទ្រង់ត្រាស់សេចក្តីនៃព្រះគាថានេះ ដោយប្រការដូច្នេះ **ធម្មាភិសម័យ** បានកើតមានដល់សត្វ ៨៤.០០០ ។

៣៥៥.. **ហនន្តិ ភោគា ទុម្មេធំ នោ ច បារគវេសិនោ**
ភោគតណ្ហាយ ទុម្មេធោ ហន្តិ អញ្ញេវ អត្តនំ ។

ភោគៈទាំងឡាយ រមែងសម្លាប់បុគ្គលអប្បប្រាជ្ញា ប៉ុន្តែមិនសម្លាប់បុគ្គលអ្នកស្វែងរកត្រើយ គឺ **ព្រះនិព្វាន** ទេ, ឯបុគ្គលអប្បប្រាជ្ញា រមែងសម្លាប់ខ្លួនឯង ដូចជាសម្លាប់បុគ្គលដទៃ ព្រោះចំណង់ក្នុងភោគៈ ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅក្នុង **វត្តជេតពន** ទ្រង់ប្រារព្ធ **អបុត្តកសេដ្ឋី** (សេដ្ឋីអ្នកមិនមានបុត្រ) ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចនូវ **អរិយផល** ទាំងឡាយមាន **សោតាបត្តិផល** ជាដើម ។

៣៥៦.. **តិណទោសានិ ខេត្តានិ រាគទោសា អយំ បជា**
តស្មា ហិ វីតរាគេសុ ទិន្នំ ហោតិ មហប្ផលំ ។

☞ ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះមាន“**រាគៈ**” ជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឱ្យហើយ ដល់អ្នកមាន“**រាគៈ**” អស់ហើយ រមែងជាទានមានផលច្រើន ។

៣៥៧.. **តិណទោសានិ ខេត្តានិ ទោសទោសា អយំ បជា**
តស្មា ហិ វីតទោសេសុ ទិន្នំ ហោតិ មហប្ផលំ ។

ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះមាន“**ទោសៈ**” ជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឱ្យហើយ ដល់អ្នកមាន“**ទោសៈ**” អស់ហើយ រមែងជាទានមានផលច្រើន ។

៣៥៨.. **តិណទោសានិ ខេត្តានិ មោហទោសា អយំ បជា**
តស្មា ហិ វីតមោហេសុ ទិន្នំ ហោតិ មហប្ផលំ ។

ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះមាន “**មោហៈ**” ជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឱ្យហើយ ដល់អ្នកមាន“**មោហៈ**” អស់ហើយ រមែងជាទានមានផលច្រើន ។

៣៥៩.. **តិណទោសានិ ខេត្តានិ ឥច្ឆាទោសា អយំ បជា**
តស្មា ហិ វិគតិច្ឆេសុ ទិន្នំ ហោតិ មហប្ផលំ ។

ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះមាន “**សេចក្តីប្រាថ្នា**” ជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឱ្យហើយ ដល់អ្នកមាន“**សេចក្តីប្រាថ្នា**” អស់ហើយ រមែងជាទានមានផលច្រើន ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅលើ **សិលា** ដូចជាសំពត់កម្ពលពណ៌លឿង ទ្រង់ប្រារព្ធ **អង្កុរទេវបុត្ត** និង **ឥន្ទកទេវបុត្ត** ។ ☞ ក្នុងកាលចប់ព្រះធម្ម‑ ‑ទេសនា **អង្កុរទេវបុត្ត** និង **ឥន្ទកទេវបុត្ត** តាំងនៅក្នុង **សោតាបត្តិផល** ។

(ចប់ **តណ្ហាវគ្គ** ទី ២៤ = មាន **២៦** គាថា)

វគ្គទី ២៥

ភិក្ខុវគ្គ

(Bhikkhu Vagga)

The Bhikkhu or The Mendicant

(Versets sur le Bhikkhu)

(មាន ២៣ គាថា)

(ពី គាថា ទី ៣៦០ ➩ ដល់ គាថា ទី ៣៨២)

៣៦០.. **ចក្ខុនា សំវរោ សាធុ សាធុ សោតេន សំវរោ**
ឃានេន សំវរោ សាធុ សាធុ ជិវ្ហាយ សំវរោ ។

៣៦១.. **កាយេន សំវរោ សាធុ សាធុ វាចាយ សំវរោ**
មនសា សំវរោ សាធុ សាធុ សព្វត្ថ សំវរោ
សព្វត្ថ សំវុតោ ភិក្ខុ សព្វទុក្ខា បមុច្ចតិ ។

ការសង្រួមភ្នែកប្រពៃ ការសង្រួមត្រចៀកប្រពៃ ការសង្រួមច្រមុះប្រពៃ ការសង្រួមអណ្តាតប្រពៃ ការសង្រួមកាយប្រពៃ ការសង្រួមចិត្តប្រពៃ **ការសង្រួមទាំងអស់ប្រពៃ** ភិក្ខុសង្រួមហើយក្នុងទ្វារទាំងអស់ តែងរួចស្រឡះចាកទុក្ខទាំងពួងបាន ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ**វត្តជេតពន**ទ្រង់ប្រារព្ធ**ភិក្ខុ** ៥រូប ។
☞ ក្នុងកាលចប់ព្រះធម្មទេសនា **ភិក្ខុ** ទាំង ៥ រូបនោះ តាំងនៅក្នុង**សោតាបត្តិផល**។

៣៦២.. **ហត្ថសញ្ញតោ បាទសញ្ញតោ**
វាចាយ សញ្ញតោ សញ្ញតុត្តមោ
អជ្ឈត្តរតោ សមាហិតោ
ឯកោ សន្តុសិតោ តមាហុ ភិក្ខុំ ។

ជនណាសង្រួមដៃ សង្រួមជើង សង្រួមវាចា សង្រួមអត្តភាព ជាអ្នកត្រេកអរក្នុងការចម្រើនកម្មដ្ឋាន ដែលមានក្នុងខ្លួន ជាអ្នកមានចិត្តតម្កល់មាំ ជាអ្នកនៅឯកឯង តែងមានចិត្តត្រេកអរក្នុងធម៌ បណ្ឌិតទាំងឡាយ ហៅជននោះថា **ភិក្ខុ** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ **វត្តជេតពន**ទ្រង់ប្រារព្ធ **ភិក្ខុ**អ្នកសម្លាប់ហង្សមួយរូប ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល**ជាដើម ។

៣៦៣.. យោ មុខសញ្ញតោ ភិក្ខុ មន្តភាណី អនុទ្ធតោ
អត្ថំ ធម្មញ្ច ទីបេតិ មធុរំ តស្ស ភាសិតំ ។

ភិក្ខុណា សង្រួមមាត់ ជាអ្នកពោលដោយបញ្ញា មានចិត្តមិនរាយមាយ សម្តែងអត្ថផង ធម៌ផងបាន ភាសិតរបស់ភិក្ខុនោះ ទើបឈ្មោះថាពីរោះ ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ **វត្តជេតពន** ទ្រង់ប្រារព្ធ **ភិក្ខុ**ឈ្មោះ **កោកាលិកៈ** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៣៦៤.. ធម្មារាមោ ធម្មរតោ ធម្មំ អនុវិចិន្តយំ
ធម្មំ អនុស្សរំ ភិក្ខុ សទ្ធម្មា ន បរិហាយតិ ។

ភិក្ខុ មានធម៌ជាទីត្រេកអរ ត្រេកអរហើយក្នុងធម៌ ពិចារណាធម៌ រឭកធម៌រឿយ ៗ រមែងមិនសាបសូន្យចាកព្រះសទ្ធម្មឡើយ ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ **វត្តជេតពន**ទ្រង់ប្រារព្ធ **ព្រះធម្មា-**
-រាមត្ថេរ ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ព្រះធម្មារាមត្ថេរ តាំងនៅក្នុង **ព្រះអរហត្ត** ។

៣៦៥.. សលាភំ នាតិមញ្ញេយ្យ នាញ្ញេសំ បិហយញ្ចរេ
អញ្ញេសំ បិហយំ ភិក្ខុ សមាធឹ នាធិគច្ឆតិ ។

៣៦៦.. **អប្បលាភោបិ ចេ ភិក្ខុ សលាភំ នាតិមញ្ញតិ**
តំ វេ ទេវា បសំសន្តិ សុទ្ធាជីវមតន្ទិតំ ។

ភិក្ខុ មិនគប្បីមើលងាយលាភរបស់ខ្លួន (ដែលកើតឡើងដោយធម៌) មិនគប្បីប្រព្រឹត្តចង់បានលាភរបស់ភិក្ខុដទៃ បើចង់បានលាភរបស់ភិក្ខុដទៃ រមែងមិនបានសមាធិឡើយ ។

បើភិក្ខុ សូម្បីមានលាភតិច មិនមើលងាយលាភរបស់ខ្លួន ទេវតា និង មនុស្សទាំងឡាយ តែងសរសើរភិក្ខុនោះឯង ដែលជាអ្នកមានព្យាយាម ជាគ្រឿងអាស្រ័យ រស់នៅដោយបរិសុទ្ធ ជាអ្នកមិនខ្ជិលច្រអូស ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្ដាទ្រង់គង់នៅ **វត្តវេឡុវ័ន**ទ្រង់ប្រារព្ធ **ភិក្ខុ** អ្នកសេពគប់ភិក្ខុ ដែលជាបក្ខពួកអ្នកយល់ខុស មួយរូប ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផល មាន **សោតាបត្តិផល** ជាដើម ។

៣៦៧.. **សព្វសោ នាមរូបស្មឹ យស្ស នត្ថិ មមាយិតំ**
អសតា ច ន សោចតិ ស វេ ភិក្ខូតិ វុច្ចតិ ។

បុគ្គលណា មិនមានសេចក្ដីប្រកាន់ក្នុង **នាម** និង **រូប** ថាជារបស់អញ ដោយប្រការទាំងពួង, មួយទៀត **បុគ្គលណា** មិនសោកស្ដាយ ព្រោះ **នាម** និង **រូប** ដែលមិនមាន **បុគ្គលនោះឯង តថាគត** ហៅថា **ភិក្ខុ** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្ដាទ្រង់គង់នៅ **វត្តវេឡុវ័ន**ទ្រង់ប្រារព្ធ **បញ្ចគ្គ-ទាយកព្រាហ្មណ៍** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា **ព្រាហ្មណ៍** និង **ព្រាហ្មណី** ស្វាមី-ភរិយា បានតាំងនៅក្នុង **ព្រះអនាគាមិផល** ។

៣៦៨.. មេត្តាវិហារី យោ ភិក្ខុ បសន្នោ ពុទ្ធសាសនេ
អធិគច្ឆេ បទំ សន្តំ សង្ខារូបសមំ សុខំ ។

ភិក្ខុណា នៅដោយអំណាចមេត្តា ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះ រមែងបានបទដ៏ស្ងប់ ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្តីសុខ ។

៣៦៩.. សិញ្ច ភិក្ខុ ឥមំ នាវំ សិត្តា តេ លហុមេស្សតិ
ឆេត្វា រាគញ្ច ទោសញ្ច តតោ និព្វានមេហិសិ ។

ម្នាលភិក្ខុ ចូរអ្នកស្តារទូក គឺអត្តភាពនេះ ទូកដែលអ្នកស្តារហើយនឹងដល់ត្រើយឆាប់ អ្នកកាត់រាគៈ និង ទោសៈ បានហើយ អំពីនោះនឹងអាចដល់នូវព្រះនិព្វាន ។

៣៧០.. បញ្ច ឆិន្ទេ បញ្ច ជហេ បញ្ច ឧត្តរិ ភាវយេ
បញ្ចសង្គាតិគោ ភិក្ខុ ឱឃតិណ្ណោតិ វុច្ចតិ ។

ភិក្ខុគប្បីកាត់**ឱរម្ភាគិយសំយោជនៈ ៥** ផង គប្បីលះបង់ **ឧទ្ធម្ភា--គិយសំយោជនៈ ៥**ផង គប្បីចម្រើន **ឥន្ទ្រិយ ៥** តទៅ ភិក្ខុអ្នកកន្លងកិលេស ជាគ្រឿងជំពាក់ **៥** **(រាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ)** បានហើយទើប **តថាគត** ហៅថា **អ្នកឆ្លងអន្លង់**បាន ។

៣៧១.. ឈាយ ភិក្ខុ មា ច បមាទោ
មា តេ កាមគុណេ ភមស្សុ ចិត្តំ
មា លោហគុឡំ គិលី បមត្តោ

មា កន្ទិ ទុក្ខមិទន្តិ ឌយ្ហមានោ ។

ម្នាលភិក្ខុ ចូរអ្នកពិនិត្យផង ចូរកុំជាអ្នកប្រមាទផង ចិត្តរបស់អ្នក ចូរកុំវិលទៅរកកាមគុណឡើយ, អ្នកចូរកុំប្រមាទ ទំពាស៊ីនូវដុំលោហៈ កុំឱ្យជាអ្នក កាលភ្លើងឆេះហើយ កន្ទក់កន្ទេញថា នេះ**ទុក្ខ** ដូច្នេះឡើយ ។

៣៧២.. **នត្ថិ ឈានំ អបញ្ញស្ស នត្ថិ បញ្ញា អឈាយិនោ**
យម្ហិ ឈានញ្ច បញ្ញា ច ស វេ និព្វានសន្តិកេ ។

ការពិនិត្យ មិនមានដល់បុគ្គលអ្នកមិនមានប្រាជ្ញា ប្រាជ្ញាមិនមានដល់បុគ្គលអ្នកមិនពិនិត្យ, **ការពិនិត្យ** និង **ប្រាជ្ញា** មានក្នុងបុគ្គលណា បុគ្គលនោះឯង ឈ្មោះថា ឋិតនៅក្នុងទីជិតនៃព្រះនិព្វាន ។

៣៧៣.. **សុញ្ញាគារំ បវិដ្ឋស្ស សន្តចិត្តស្ស ភិក្ខុនោ**
អមានុសី រតី ហោតិ សម្មា ធម្មំ វិបស្សតោ ។

សេចក្តីត្រេកអរ ដែលមិនមែនជារបស់មនុស្ស រមែងមានដល់ភិក្ខុអ្នកចូលទៅកាន់ផ្ទះស្ងាត់ អ្នកមានចិត្តរម្ងាប់ អ្នកឃើញធម៌ដោយប្រពៃ ។

៣៧៤.. **យតោ យតោ សម្មសតិ ខន្ធានំ ឧទយព្វយំ**
លភតិ បីតិបាមោជ្ជំ អមតំ តំ វិជានតំ ។

ភិក្ខុពិចារណា **ការកើតឡើង** និង **ការវិនាសខន្ធ**ទាំងឡាយ ក្នុងកាលណា ក្នុងកាលនោះ **ភិក្ខុ**នោះរមែងបាន **បីតិ** និង **បាមោជ្ជៈ** បីតិ និង បាមោជ្ជៈ នោះឈ្មោះថាជា **អមតធម៌** របស់បណ្ឌិត អ្នកដឹងធម៌ទាំងឡាយ ។

៣៧៥.. តត្រាយមាទិ ភវតិ ឥធ បញ្ញស្ស ភិក្ខុនោ
ឥន្ទ្រិយគុត្តិ សន្តុដ្ឋី បាតិមោក្ខេ ច សំវរោ
មិត្តេ ភជស្សុ កល្យាណេ សុទ្ធាជីវេ អតន្ទិតេ ។

គុណ ៣ ប្រការនេះ គឺ ការរក្សាឥន្ទ្រិយ, សេចក្តីសន្តោស, ការសង្រួមក្នុងបាតិមោក្ខ, ជាខាងដើមនៃព្រះនិព្វាននោះ តែងមានដល់ភិក្ខុអ្នកមានបញ្ញាក្នុងសាសនានេះ (ម្នាល ភិក្ខុ) អ្នកចូរគប់រកកល្យាណមិត្ត អ្នកមានព្យាយាមជាគ្រឿងរស់ដោយបរិសុទ្ធ ជាអ្នកមិនខ្ជិលច្រអូស ។

៣៧៦.. បដិសន្ថារវុត្យស្ស អាចារកុសលោ សិយា
តតោ បាមោជ្ជពហុលោ ទុក្ខស្សន្តំ ករិស្សសិ ។

ភិក្ខុគប្បីជាអ្នកប្រព្រឹត្តធ្វើ បដិសន្ថារៈ គប្បីជាអ្នកឈ្លាសក្នុង អាចារៈ ព្រោះហេតុទាំងពីរនោះ អ្នកនឹងមានបាមោជ្ជៈច្រើន នឹងធ្វើទីបំផុតទុក្ខបាន ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ **វត្តជេតពន**ទ្រង់ប្រារព្ធ **ភិក្ខុច្រើនរូប** ។ ☞ បណ្តាបទព្រះគាថាទាំងនេះ ដែល **ព្រះបរមសាស្តា** ទ្រង់សម្តែងដោយអាការយ៉ាងនេះ កាលចប់ព្រះគាថាមួយ ៗ ភិក្ខុមួយរយ ៗ សម្រេច **ព្រះអរហត្ត** មួយអន្លើដោយ**បដិសម្ភិទា**ទាំងឡាយ លើអាសនៈដែលខ្លួនអង្គុយនោះឯង ។

៣៧៧.. វស្សិកា វិយ បុប្ផានិ មទ្ទវានិ បមុញ្ចតិ
ឯវំ រាគញ្ច ទោសញ្ច វិប្បមុញ្ចេថ ភិក្ខវោ ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីជម្រុះ រាគៈ និង ទោសៈ ចេញ ដូចម្លិះជម្រុះ ផ្កាម្លិះទាំងឡាយ ដែលស្វិតហើយ ដូច្នោះ ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្ដាទ្រង់គង់នៅ **វត្តជេតពន**ទ្រង់ប្រារព្ធ **ភិក្ខុ** ប្រមាណ ៥០០ រូប ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុទាំងអស់នោះ តាំងនៅក្នុង **ព្រះអរហត្ត** ។

៣៧៨.. **សន្តកាយោ សន្តវាចោ សន្តមនោ សុសមាហិតោ**
វន្តលោកាមិសោ ភិក្ខុ ឧបសន្តោ វុច្ចតិ ។

ភិក្ខុអ្នកមានកាយរម្ងាប់ មានវាចារម្ងាប់ហើយ មានចិត្តរម្ងាប់ហើយ មានចិត្តតម្កល់មាំហើយ មានអាមិសៈក្នុងលោក ខ្ជាក់ចោលហើយ ទើប **តថាគត** ហៅថា អ្នកស្ងប់រម្ងាប់ ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្ដាទ្រង់គង់នៅ **វត្តជេតពន**ទ្រង់ប្រារព្ធ **ព្រះសន្ត-‌-កាយត្ថេរ** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ព្រះថេរៈអង្គនេះ តាំងនៅក្នុង **ព្រះអរហត្ត** ។

៣៧៩.. **អត្តនា ចោទយត្តានំ បដិមំសេតមត្តនា**
សោ អត្តគុត្តោ សតិមា សុខំ ភិក្ខុ វិហាហិសិ ។
៣៨០.. **អត្តា ហិ អត្តនោ នាថោ អត្តា ហិ អត្តនោ គតិ**
តស្មា សញ្ញម អត្តានំ អស្សំ ភទ្រំវ វាណិជោ ។

អ្នកចូរដាស់តឿនខ្លួន ដោយខ្លួនឯង ចូរពិនិត្យខ្លួន ដោយខ្លួនឯង ម្នាលភិក្ខុ អ្នកនោះ បើមានស្មារតី រក្សាខ្លួនទុកហើយ នឹងនៅជាសុខ ។ មែនពិត ខ្លួនជាទីពឹងរបស់ខ្លួន ខ្លួនឯងជាគតិរបស់ខ្លួន ព្រោះហេតុនោះ អ្នកចូរ រវាំងខ្លួន ដូចពាណិជ រវាំងសេះដ៏ល្អ ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ**វត្តជេតពន** ទ្រង់ប្រារព្ធ **ព្រះនង្គល-**
-កូដត្ថេរ ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ
មាន **សោតាបត្តិផល** ជាដើម ។

៣៨១.. **បាមោជ្ជពហុលោ ភិក្ខុ បសន្នោ ពុទ្ធសាសនេ**
អធិគច្ឆេ បទំ សន្តំ សង្ខារូបសមំ សុខំ ។

ភិក្ខុអ្នកក្រាស់ដោយសេចក្តីរីករាយ ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា រមែងបាននូវបទដ៏ស្ងប់ ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្តីសុខ ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ **វត្តវេឡុវ័ន** ទ្រង់ប្រារព្ធ **ព្រះវក្ក-**
-លិត្ថេរ ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ព្រះវក្កលិត្ថេរ សម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ ។ **ព្រះបរមសាស្តា** ទ្រង់តាំងលោកទុកក្នុងតំណែង ដ៏លើសជាងសាវកទាំងឡាយ អ្នកមានចិត្តស៊ប់សួនដោយសទ្ធា (**សទ្ធាធិមុត្ត**) ។

៣៨២.. **យោ ហវេ ទហរោ ភិក្ខុ យុញ្ជតិ ពុទ្ធសាសនេ**
សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។

ភិក្ខុណានៅក្មេងៗ ប្រឹងប្រែងក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះរមែងញុំាងលោកនេះឱ្យភ្លឺស្វាងបាន ដូចព្រះចន្ទដែលរះផុតអំពីពពក ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ **វត្តបុព្វារាម** ទ្រង់ប្រារព្ធ **សុមន-**
-សាមណេរ ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

(ចប់ **ភិក្ខុវគ្គ** ទី ២៥ = មាន **២៣** គាថា)

ជំពូកទី ២៦

ព្រាហ្មណវគ្គ

(Brāhmaṇa Vagga)

The Brāhmaṇa

(Versets sur le Brahmane)

(មាន ៤១ គាថា)

(ពី គាថា ទី ៣៨៣ ➩ ដល់ គាថា ទី ៤២៣)

៣៨៣.. ឆិន្ទ សោតំ បរក្កម្ម កាមេ បនុទ ព្រាហ្មណ
សង្ខារានំ ខយំ ញត្វា អកតញ្ញូសិ ព្រាហ្មណ ។

ម្នាលព្រាហ្មណ៍ អ្នកចូរខំប្រឹងកាត់តណ្ហាដូចខ្សែទឹក ចូរបន្ទោបង់កាមទាំងឡាយចេញ, ម្នាលព្រាហ្មណ៍ អ្នកស្គាល់ច្បាស់នូវការអស់សង្ខារទាំងឡាយហើយ ឈ្មោះថាជាអ្នកដឹងព្រះនិព្វាន ដែលបច្ច័យតាក់តែងមិនបាន ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ **វត្តជេតពន** ទ្រង់ប្រារព្ធ **ព្រាហ្មណ៍**អ្នកច្រើនដោយសេចក្តីជ្រះថ្លា ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៣៨៤.. យទា ទ្វយេសុ ធម្មេសុ បារគូ ហោតិ ព្រាហ្មណោ
អថស្ស សព្វេ សំយោគា អត្ថំ គច្ឆន្តិ ជានតោ ។

កាលណា ព្រាហ្មណ៍អ្នកដល់ត្រើយ ក្នុងធម៌ ២ប្រការ គឺ **សមថ-**
-ធម៌ និង **វិបស្សនាធម៌** ក្នុងកាលណោះ **កិលេស** គ្រឿងប្រកបសត្វទុកទាំងអស់ របស់ព្រាហ្មណ៍អ្នកដឹងនោះ រមែងដល់នូវការតាំងនៅមិនបាន ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ **វត្តជេតពន** ទ្រង់ប្រារព្ធ **ភិក្ខុ**ច្រើនរូប ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុទាំងនោះ តាំងនៅក្នុង **ព្រះអរហត្ត** ។

៣៨៥.. យស្ស បារំ អបារំ វា បារាបារំ ន វិជ្ជតិ
វីតទ្ទរំ វិសញ្ញុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

ត្រើយក្តី ទីមិនមែនត្រើយក្តី, ត្រើយនិងទី មិនមែនត្រើយក្តី មិនមាន ដល់បុគ្គលណា (សេចក្តីប្រកាន់អាយតនៈ មិនមានដល់បុគ្គលណា) **តថាគត** ហៅបុគ្គលនោះ ដែលជាអ្នកមានសេចក្តីក្រវល់ក្រវាយ អស់ហើយ ជាអ្នក ប្រាសចាកកិលេស ថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ **វត្តជេតពន** ទ្រង់ប្រារព្ធ **មារ** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៣៨៦.. **ឈាយឹ វិរជមាសីនំ កតកិច្ចំ អនាសវំ**
ឧត្តមត្ថំ អនុប្បត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

តថាគត ហៅបុគ្គលអ្នកចម្រើនឈាន មានធូលី គឺកាមអស់ហើយ អ្នកអង្គុយនៅឯកឯង អ្នកមានសោឡសកិច្ចធ្វើស្រេចហើយ មិនមានអាសវៈ ដល់នូវប្រយោជន៍ ដ៏ខ្ពង់ខ្ពស់ដោយលំដាប់ហើយនោះ ថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ **វត្តជេតពន** ទ្រង់ប្រារព្ធ **ព្រាហ្មណ៍** ម្នាក់ ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ព្រាហ្មណ៍នោះ តាំងនៅក្នុង **សោតាបត្តិផល** ។

៣៨៧.. **ទិវា តបតិ អាទិច្ចោ រត្តិមាភាតិ ចន្ទិមា**
សន្នទ្ធោ ខត្តិយោ តបតិ ឈាយី តបតិ ព្រាហ្មណោ
អថ សព្វមហោរត្តឹ ពុទ្ធោ តបតិ តេជសា ។

ព្រះអាទិត្យរុងរឿង ក្នុងវេលាថ្ងៃ, ព្រះចន្ទរុងរឿង ក្នុងវេលាយប់ ក្សត្រទ្រង់ប្រដាប់ពេញយសហើយ រមែងរុងរឿង, សមណព្រាហ្មណ៍

អ្នកមានឈាន រមែងរុងរឿង ឯ **ព្រះសម្ពុទ្ធ** រមែងរុងរឿងដោយតេជះ រហូតថ្ងៃ និង យប់ ទាំងអស់ ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅក្នុងប្រាសាទរបស់ឧបាសិកាឈ្មោះ **មិគារមាតា** ទ្រង់ប្រារព្ធ **ព្រះអានន្ទត្ថេរ** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៣៨៨._ **ពាហិតបាបោ ហិ ព្រាហ្មណោ**
សមចរិយា សមណោតិ វុច្ចតិ
បព្វាជយមត្តនោ មលំ
តស្មា បព្វជិតោតិ វុច្ចតិ ។

អ្នកដែលមានបាបបន្សាត់ហើយ ឈ្មោះថា **ព្រាហ្មណ៍**, អ្នកដែល **តថាគត** ហៅថា **សមណៈ** ព្រោះការប្រព្រឹត្តរម្ងាប់ អ្នកដែលបណ្តេញមន្ទិល នៃខ្លួន ហេតុនោះទើប **តថាគត** ហៅថា **បព្វជិត** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ **វត្តជេតពន**ទ្រង់ប្រារព្ធ **បព្វជិត** មួយរូប ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា បព្វជិតនោះ តាំងនៅក្នុង **សោតាបត្តិផល** ។

៣៨៩._ **ន ព្រាហ្មណស្ស បហរេយ្យ នាស្ស មុញ្ចេថ ព្រាហ្មណោ**
ធិ ព្រាហ្មណស្ស ហន្តារំ តតោ ធិ យស្ស មុញ្ចតិ ។

ព្រាហ្មណ៍ មិនគប្បីប្រហារព្រាហ្មណ៍ទេ (ចំណែក) ព្រាហ្មណ៍ (ដែលត្រូវគេប្រហារហើយ) មិនគប្បីចងពៀរចំពោះព្រាហ្មណ៍នោះ **តថាគត** តិះ-ដៀលព្រាហ្មណ៍ ដែលប្រហារព្រាហ្មណ៍ ព្រាហ្មណ៍ណា ចងពៀរចំពោះព្រាហ្ម--ណ៍នោះ **តថាគត** តិះដៀលព្រាហ្មណ៍នោះ ក្រៃលែងជាងនោះ ទៅទៀត ។

៣៩០.. ន ព្រាហ្មណស្សេតទកិញ្ចិ សេយ្យោ
យទានិសេធោ មនសោ បិយេហិ
យតោ យតោ ហឹសមនោ និវត្តតិ
តតោ តតោ សម្មតិមេវ ទុក្ខំ ។

ការហាមឃាត់ចិត្ត ចាកអារម្មណ៍ជាទីស្រឡាញ់ របស់ព្រាហ្មណ៍នោះ មិនមែនប្រសើរបន្តិចបន្តួចទេ ចិត្តដែលគិតបៀតបៀនគេ ងាកចេញចាកវត្ថុណា ៗ សេចក្តីទុក្ខព្រោះវត្ថុនោះ ៗ ក៏រម្ងាប់ទៅបាន ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ **វត្តជេតពន**ទ្រង់ប្រារព្ធ **ព្រះសារី-**
-បុត្រ ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេច អរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៣៩១.. យស្ស កាយេន វាចាយ មនសា នត្ថិ ទុក្កតំ
សំវុតំ តីហិ ឋានេហិ តមហំ ព្រូមិ ព្រាហ្មណំ ។

អំពើអាក្រក់ ដោយទ្វារកាយ ទ្វារវាចា ទ្វារចិត្ត របស់បុគ្គលណា មិនមានទេ **តថាគត** ហៅបុគ្គល ដែលបានសង្រួមដោយឋានទាំង ៣ នោះ ថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ **វត្តជេតពន**ទ្រង់ប្រារព្ធ **ព្រះនាងមហាបជាបតិគោតមី** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេច អរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៣៩២.. យម្ហា ធម្មំ វិជានេយ្យ សម្មាសម្ពុទ្ធទេសិតំ
សក្កច្ចំ តំ នមស្សេយ្យ អគ្គិហុត្តំវ ព្រាហ្មណោ ។

បុគ្គលចេះធម៌អាថ៌ ដែល **ព្រះសម្មាសម្ពុទ្ធ** ទ្រង់សម្តែងហើយ អំពីសំណាក់គ្រូណា គប្បីនមស្ការគ្រូនោះ ដោយគោរព ដូច **ព្រាហ្មណ៍** ដែលគោរពការបូជាភ្លើងដូច្នោះដែរ ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ **វត្តជេតពន**ទ្រង់ប្រារព្ធ **ព្រះសារី-បុត្តត្ថេរ** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៣៩៣.. **ន ជដាហិ ន គោត្តេហិ ន ជច្ចា ហោតិ ព្រាហ្មណោ**
យម្ហិ សច្ចញ្ច ធម្មោ ច សោ សុចី សោ ច ព្រាហ្មណោ ។

បុគ្គលដែលឈ្មោះថា **ព្រាហ្មណ៍** ព្រោះផ្នួងសក់ ក៏មិនមែន ព្រោះ **គោត្រ** ក៏មិនមែន ព្រោះ **ជាតិ**ក៏មិនមែន, **សច្ចៈ**ផង **ធម៌**ផង មានក្នុងបុគ្គលណា បុគ្គលនោះឈ្មោះថា អ្នកស្អាតផង បុគ្គលនោះឈ្មោះថា **ព្រាហ្មណ៍** ផង ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ **វត្តជេតពន**ទ្រង់ប្រារព្ធ **ជដិល**ម្នាក់ ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផល ទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៣៩៤.. **កិន្តេ ជដាហិ ទុម្មេធ កិន្តេ អជិនសាដិយា**
អព្ភន្តរន្តេ គហនំ ពាហិរំ បរិមជ្ជសិ ។

នែអ្នកអប្បប្រាជ្ញាអើយ អ្នកមានប្រយោជន៍អ្វី ដោយការទុកផ្នួងសក់ អ្នកមានប្រយោជន៍អ្វី ដោយការទ្រទ្រង់សំពត់ស្បែកខ្លា បើសន្តានខាងក្នុង

របស់អ្នក សឹងសាំញ៉ាំដោយ **រាគាទិក្កិលេស** អ្នកឈ្មោះថាដុសខាត់តែកាយខាងក្រៅទេ ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្ដាទ្រង់គង់នៅ **កូដាគារសាលា** ទ្រង់ប្រារព្ធ **ព្រាហ្មណ៍**អ្នកកុហកម្នាក់ ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៣៩៥.. **បំសុកូលធរំ ជន្តុំ កិសន្ធមនិសន្ថតំ**
ឯកំ វនស្មឹ ឈាយន្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

តថាគត ហៅបុគ្គលអ្នកទ្រទ្រង់សំពត់បំសុកូល មានកាយស្គម មានខ្លួនរវាមដោយសរសៃ ជាបុគ្គលឯកឯង ចម្រើនឈានក្នុងព្រៃនោះ ថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្ដាទ្រង់គង់នៅ **ភ្នំគិជ្ឈកូដ** ទ្រង់ប្រារព្ធ **នាងកិសា-គោតមី** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៣៩៦.. **ន ចាហំ ព្រាហ្មណំ ព្រូមិ យោនិជំ មត្តិសម្ភវំ**
ភោវាទី នាម សោ ហោតិ ស វេ ហោតិ សកិញ្ចនោ
អកិញ្ចនំ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។

តថាគត នឹងហៅអ្នកកើតអំពីកំណើត អ្នកកើតក្នុងផ្ទៃនៃព្រាហ្មណីជាមាតា ថាជាព្រាហ្មណ៍ ក៏ទេ បុគ្គលនោះគ្រាន់តែបាននាមថា **ភោវាទី** (អ្នកពោលថាចម្រើន) ព្រោះបុគ្គលនោះឯង ជាអ្នកមានកិលេសគ្រឿងកង្វល់នៅឡើយ **តថាគត** ហៅបុគ្គលអ្នកមិនមានកិលេសគ្រឿងកង្វល់ អ្នកមិនមានសេចក្ដីប្រកាន់មាំនោះឯង ថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ**វត្តជេតពន** ទ្រង់ប្រារព្ធ **ព្រាហ្មណ៍**ម្នាក់ ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ព្រាហ្មណ៍នោះ បានសម្រេច **សោតាបត្តិផល**។

៣៩៧.. **សព្វសំយោជនំ ឆេត្វា យោ វេ ន បរិតស្សតិ**
សង្គាតិគំ វិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណាកាត់សញ្ញោជនៈទាំងអស់បាន មិនតក់ស្លុត **តថាគត** ហៅបុគ្គលនោះ ដែលគ្មានកិលេសជាគ្រឿងជំពាក់ អ្នករួចស្រឡះចាកកិលេស ថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ**វត្តជេតពន** ទ្រង់ប្រារព្ធ **ឧគ្គសេន**។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៣៩៨.. **ឆេត្វា នន្ធឹ វរត្តញ្ច សន្ទានំ សហានុក្កមំ**
ឧក្ខិត្តបលិឃំ ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។

តថាគត ហៅបុគ្គល ដែលកាត់សេចក្តីក្រោធ ដូចព្ជួរផង កាត់តណ្ហា ដូចព្រ័ត្រផង កាត់ទិដ្ឋិ ៦២ ដូចទី “ត” ព្រមទាំងអនុស័យ ដូចអ្នកដើរតាមផង អ្នកមានអវិជ្ជា ដូចសសរខឿនដកចោលហើយ អ្នកត្រាស់ដឹង **សច្ចៈ ៤** នោះឯង ថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ**វត្តជេតពន** ទ្រង់ប្រារព្ធ **ព្រាហ្មណ៍** ២នាក់។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុ ៥០០ រូប បានសម្រេច **ព្រះអរហត្តផល** ។

៣៩៩.. **អក្កោសំ វធពន្ធញ្ច   អទុដ្ឋោ យោ តិតិក្ខតិ**

ខន្តីពលំ ពលានីកំ   តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា មិនប្រទូស្ត អត់សង្កត់ពាក្យជេរផង ការបៀតបៀន និងការចងផងបាន ទើប **តថាគត** ហៅ បុគ្គលដែលមានខន្តិជាពលៈ មានខន្តិជារេហ៍ពលនោះឯង ថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ **វត្តវេឡុវ័ន** ទ្រង់ប្រារព្ធ **អក្កោសកភារទ្វាជព្រាហ្មណ៍** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៤០០.. **អក្កោធនំ វតវន្តំ   សីលវន្តំ អនុស្សទំ**

ទន្តំ អន្តិមសារីរំ   តមហំ ព្រូមិ ព្រាហ្មណំ ។

តថាគត ហៅ បុគ្គលដែលមិនមានសេចក្តីក្រោធ មានធុតង្គវត្តមានចតុប្បារិសុទ្ធសីល មិនមានតណ្ហាគ្រឿងប៉ោងចិត្ត មានឥន្ទ្រិយទូន្មានហើយ មានសរីរៈឋិតនៅក្នុងទីបំផុតនោះ ថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ **វត្តជេតពន** ទ្រង់ប្រារព្ធ **ព្រះសារី-បុត្តត្ថេរ** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៤០១.. **វារិ បោក្ខរបត្តេវ   អារគ្គេរិវ សាសបោ**

យោ ន លិម្បតិ កាមេសុ   តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា មានចិត្តមិនបានជាប់នៅ ក្នុងកាមទាំងឡាយ ដូចទឹកលើស្លឹកឈូក ឬដូចគ្រាប់ស្ពៃលើចុងដែកស្រួច **តថាគត** ហៅ បុគ្គលនោះថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ **វត្តជេតពន** ទ្រង់ប្រារព្ធ **ព្រះនាង-ឧប្បលវណ្ណាថេរី** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៤០២.. **យោ ទុក្ខស្ស បជានាតិ ឥធេវ ខយមត្តនោ**
បន្នភារំ វិសញ្ញុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា ក្នុងសាសនានេះឯង ដឹងច្បាស់នូវការអស់ទុក្ខរបស់ខ្លួន **តថាគត** ហៅ បុគ្គលនោះ ដែលមានខន្ធភារៈ ដាក់ចុះហើយ ដែលរួចស្រឡះចាកកិលេសទាំងឡាយ ថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ **វត្តជេតពន** ទ្រង់ប្រារព្ធ **ព្រាហ្មណ៍**មួយរូប ។☞ ក្នុងកាលចប់ព្រះធម្មទេសនាព្រាហ្មណ៍នោះតាំងនៅក្នុង **សោតាបត្តិផល**។

៤០៣.. **គម្ភីរបញ្ញំ មេធាវឹ មគ្គាមគ្គស្ស កោវិទំ**
ឧត្តមត្ថំ អនុប្បត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

តថាគត ហៅបុគ្គលអ្នកមានប្រាជ្ញាជ្រៅ មានប្រាជ្ញាជាគ្រឿងទម្លាយកិលេស អ្នកឈ្លាសក្នុងផ្លូវ និង មិនមែនផ្លូវ បានសម្រេចប្រយោជន៍ ដ៏ខ្ពង់ខ្ពស់នោះ ថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្ដាទ្រង់គង់នៅ **វត្តជេតពន** ទ្រង់ប្រារព្ធ **ព្រះនាងខេមាភិក្ខុនី** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផល ទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៤០៤.. **អសំសដ្ឋំ គហដ្ឋេហិ អនាគារេហិ ចូភយំ**
អនោកសារឹ អប្បិច្ឆំ តមហំ ព្រូមិ ព្រាហ្មណំ ។

តថាគត ហៅ បុគ្គលដែលមិនច្រឡំ ដោយជនទាំងឡាយ ពីរពួក គឺ គ្រហស្ថ, បព្វជិត, ជាអ្នកត្រាច់ទៅ ដោយមិនមានសេចក្ដីអាល័យ **មាន សេចក្ដីប្រាថ្នាតិច**នោះ ថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្ដាទ្រង់គង់នៅ **វត្តជេតពន** ទ្រង់ប្រារព្ធ **ព្រះតិស្សត្ថេរ** អ្នកមានប្រក្រតីនៅក្នុងញកភ្នំ ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បាន សម្រេចអរិយផល ទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៤០៥.. **និធាយ ទណ្ឌំ ភូតេសុ តសេសុ ថាវរេសុ ច**
យោ ន ហន្តិ ន ឃាតេតិ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា ដាក់ចុះនូវអាជ្ញា ក្នុងសត្វទាំងឡាយ ដែលនៅតក់ស្លុតក្ដី ដែលមាំមួន គឺមិនមានតក់ស្លុតក្ដី មិនបៀតបៀនដោយខ្លួនឯង មិនប្រើគេ ឱ្យបៀតបៀន **តថាគត** ហៅបុគ្គលនោះ ថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្ដាទ្រង់គង់នៅ **វត្តជេតពន** ទ្រង់ប្រារព្ធ **ភិក្ខុ**មួយរូប ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៤០៦.. **អវិរុទ្ធំ វិរុទ្ធេសុ អត្តទណ្ឌេសុ និព្វុតំ**
សាទានេសុ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។

តថាគត ហៅបុគ្គលអ្នកដែលមិនខឹង ចំពោះពួកជនដែលខឹងហើយ អ្នករំលត់ចំពោះពួកជន ដែលមានអាជ្ញាក្នុងខ្លួន អ្នកមិនមានសេចក្តីប្រកាន់ ចំពោះពួកជនដែលមានសេចក្តីប្រកាន់នោះ ថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ**វត្តជេតពន** ទ្រង់ប្រារព្ធ **សាមណេរ**ទាំងឡាយ ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៤០៧.. **យស្ស រាគោ ច ទោសោ ច មានោ មក្ខោ ច បាតិតោ**
សាសបោរិវ អារគ្គា តមហំ ព្រូមិ ព្រាហ្មណំ ។

រាគៈ ទោសៈ មានៈ និង **មក្ខៈ** ដែលបុគ្គលណា បានជម្រុះចេញហើយ ដូចគ្រាប់ស្ពៃដែលជ្រុះចុះ អំពីចុងដែកស្រួច **តថាគត** ហៅបុគ្គលនោះ ថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា**នេះកាលព្រះសាស្តាទ្រង់គង់នៅ**វត្តវេឡុវ័ន** ទ្រង់ប្រារព្ធ **ព្រះមហា-បន្ថកត្ថេរ** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៤០៨.. **អក្កកសំ វិញ្ញាបនឹ គិរំ សច្ចំ ឧទីរយេ**
យាយ នាភិសជេ កញ្ចិ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា ពោលពាក្យមិនអាក្រក់ ពាក្យជាហេតុឱ្យដឹងសេចក្តីបាន ជាពាក្យពិត ជាពាក្យដែលមិនធ្វើអ្នកណា ឱ្យទាស់ចិត្ត **តថាគត** ហៅ បុគ្គលនោះ ថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ **វត្តវេឡុវ័ន** ទ្រង់ប្រារព្ធ **ព្រះបិ-លិន្ទវច្ឆត្ថេរ** ។☞ ក្នុងកាលចប់ព្រះធម្មទេសនាជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៤០៩.. **យោធ ទីឃំ វ រស្សំ វា អណុំ ថូលំ សុភាសុភំ**
លោកេ អទិន្នំ នាទិយតិ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា មិនកាន់យករបស់វែងឬខ្លី តូចឬធំ ល្អឬអាក្រក់ ដែលគេមិនបានឱ្យហើយក្នុងលោកនេះ **តថាគត** ហៅ បុគ្គលនោះ ថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ **វត្តជេតពន** ទ្រង់ប្រារព្ធ **ភិក្ខុ**មួយរូប ។☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៤១០.. **អាសា យស្ស ន វិជ្ជន្តិ អស្មឹ លោកេ បរម្ហិ ច**
និរាសយំ វិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

អ្នកណា មិនមានសេចក្តីប្រាថ្នា ក្នុងលោកនេះផង ក្នុងលោកខាងមុខផង **តថាគត** ហៅបុគ្គលនោះ ដែលមិនមានសេចក្តីប្រាថ្នា ដែលផុតស្រឡះចាកកិលេស ថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ **វត្តជេតពន** ទ្រង់ប្រារព្ធ **ព្រះសារី-**
-បុត្រ ។☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ
មាន **សោតាបត្តិផល** ជាដើម ។

៤១១.. **យស្សាលយា ន វិជ្ជន្តិ អញ្ញាយ អកថង្កថី**
អមតោគធំ អនុប្បត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

អ្នកណា មិនមានសេចក្តីអាល័យ គឺតណ្ហា មិនមានសេចក្តីសង្ស័យ ក្នុងអ្វីសោះ ព្រោះដឹងច្បាស់ធម៌ **តថាគត** ហៅបុគ្គលនោះ ដែលមានចិត្ត ចុះសិប់កាន់ **ព្រះនិព្វាន** ដែលមានព្រះអរហត្តផលដល់ហើយ ដោយ លំដាប់ ថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ **វត្តជេតពន** ទ្រង់ប្រារព្ធ **ព្រះមហា-**
-មោគ្គល្លាន ។☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំង
ឡាយ មាន **សោតាបត្តិផល** ជាដើម ។

៤១២.. **យោធ បុញ្ញញ្ច បាបញ្ច ឧភោ សង្គំ ឧបច្ចគា**
អសោកំ វិរជំ សុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា ក្នុងលោកនេះ លះបង់បុណ្យ និង បាប ទាំងពីរ និង កិលេស ជាគ្រឿងជំពាក់ (មានរាគៈជាដើម) ចេញហើយ **តថាគត** ហៅ បុគ្គលនោះ ដែលជាអ្នកមិនមានសេចក្តីសោក មានធូលី គឺកិលេសអស់ ហើយ ជាអ្នកបរិសុទ្ធ ថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា** នេះ កាលព្រះសាស្ដាទ្រង់គង់នៅ **វត្តបុព្វារាម** ទ្រង់ប្រារព្ធ **ព្រះរេវត-**
-ត្ថេរ ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ
មាន **សោតាបត្តិផល** ជាដើម ។

៤១៣.. **ចន្ទំវ វិមលំ សុទ្ធំ វិប្បសន្នមនាវិលំ**
នន្ទីភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ ។

តថាគត ហៅបុគ្គល ដែលមិនមានសេចក្ដីសៅហ្មង ដូចព្រះចន្ទ្រ ប្រាសចាកមន្ទិល ជាអ្នកបរិសុទ្ធ មានចិត្តជ្រះថ្លា មិនកករល្អក់ អស់សេចក្ដីត្រេកអរក្នុងភពហើយនោះ ថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា** នេះ កាលព្រះសាស្ដាទ្រង់គង់នៅ **វត្តជេតពន** ទ្រង់ប្រារព្ធ **ព្រះចន្ទា-**
-ភត្ថេរ ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនាជនជាច្រើនបានសម្រេចអរិយផលទាំង ឡាយ
មាន **សោតាបត្តិផល** ជាដើម ។

៤១៤.. **យោមំ បលិបថំ ទុគ្គំ សំសារំ មោហមច្ចគា**
តិណ្ណោ បារគតោ ឈាយី អនេជោ អកថង្កថី
អនុបាទាយ និព្វុតោ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា កន្លងផ្លូវវ៉ាង គឺ *រាគៈ* និង *ភក់* ដែលគេឆ្លងបានដោយកម្រ គឺ **កិលេស** និង **សង្សារវដ្ដ** និង **មោហៈ**ទាំងនេះបាន ជាអ្នកឆ្លងអន្លង់ទាំង ៤ បានដល់ត្រើយ គឺ **ព្រះនិព្វាន** ជាអ្នកមានឈាន មិនញាប់ញ័រដោយតណ្ហា មិនមានសេចក្ដីសង្ស័យ មិនប្រកាន់មាំ ជាអ្នករលត់កិលេសហើយ **តថាគត** ហៅបុគ្គលនោះ ថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្ដាទ្រង់គង់នៅក្នុងព្រៃឈ្មោះ **កុណ្ឌធាន** ក្នុងដែន **កុណ្ឌិកោលិយៈ** ទ្រង់ប្រារព្ធ **ព្រះសីវលី** ។☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៤១៥.. **យោធ កាមេ បហន្ត្វាន អនាគារោ បរិព្វជេ**
កាមភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា ក្នុងលោកនេះ បានលះបង់កាមទាំងឡាយ ជាអ្នកមិនមានផ្ទះ គេចចេញចាកកាមបាន **តថាគត** ហៅបុគ្គលនោះ ដែលអស់កាមភពហើយ ថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្ដាទ្រង់គង់នៅក្នុង **វត្តជេតពន** ទ្រង់ប្រារព្ធ **ព្រះសុន្ទរសមុទ្ទត្ថេរ** ។☞ ក្នុងកាលចប់ព្រះធម្មទេសនា **ព្រះថេរៈ** បានសម្រេច ព្រះ-អរហត្ត ហើយហោះឡើងទៅកាន់វេហាស៍ ដោយកម្លាំងឫទ្ធិ៍ ទម្លុះមណ្ឌលពពកចេញ ហើយ សរសើរព្រះសរីរៈព្រះបរមសាស្ដាហើយ ចុះមកថ្វាយបង្គំព្រះដ៏មានព្រះភាគ ។

៤១៦.. **យោធ តណ្ហំ បហន្ត្វាន អនាគារោ បរិព្វជេ**
តណ្ហាភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា ក្នុងលោកនេះ បានលះបង់តណ្ហាហើយ ជាអ្នកមិនមានផ្ទះ គេចចេញចាកតណ្ហាបាន **តថាគត** ហៅបុគ្គល ដែលអស់តណ្ហា និង ភព ហើយនោះ ថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្ដាទ្រង់គង់នៅក្នុង **វត្តវេឡុវ័ន** ទ្រង់ប្រារព្ធ **ព្រះជោតិកត្ថេរ** ។☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយមាន **សោតាបត្តិផល** ជាដើម ។

៤១៧.. ហិត្វា មានុសកំ យោគំ ទិព្វំ យោគំ ឧបច្ចគា
សព្វយោគវិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា លះកិលេសជាគ្រឿងប្រកប ដែលជារបស់មនុស្ស កន្លងកិលេសជាគ្រឿងប្រកប ដែលជារបស់ទិព្វបានហើយ **តថាគត** ហៅបុគ្គលដែលផុតស្រឡះចាកកិលេស ជាគ្រឿងប្រកបទាំងពួងនោះ ថាជាព្រាហ្មណ៍។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ **វត្តវេឡុវ័ន** ទ្រង់ប្រារព្ធ **ភិក្ខុ-អ្នកធ្លាប់ជាអ្នករបាំទី ១** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៤១៨.. ហិត្វា រតឹ អរតិញ្ច សីតិភូតំ និរូបធឹ
សព្វលោកាភិភុំ វីរំ តមហំ ព្រូមិ ព្រាហ្មណំ ។

តថាគត ហៅ **បុគ្គល** ដែលលះបង់ សេចក្តីត្រេកអរក្នុងកាមគុណ និងមិនត្រេកអរក្នុងកិរិយានៅក្នុងព្រៃ ជាអ្នកមានចិត្តត្រជាក់ មិនមានឧបក្កិលេសគ្របសង្កត់លោកទាំងពួង មានសេចក្តីព្យាយាមនោះ ថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ **វត្តវេឡុវ័ន** ទ្រង់ប្រារព្ធ **ភិក្ខុ-អ្នកធ្លាប់ជាអ្នករបាំទី ២** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៤១៩.. ចុតឹ យោ វេទិ សត្តានំ ឧបបត្តិញ្ច សព្វសោ
អសត្តំ សុគតំ ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា ដឹងច្បាស់ចុតិ និង បដិសន្ធិរបស់ពួកសត្វ ដោយអាការទាំងពួងបាន **តថាគត** ហៅ បុគ្គលដែលជាអ្នកមិនជាប់នៅក្នុងកាម អ្នកមានដំណើរល្អ ដោយសេចក្តីប្រតិបត្តិ អ្នកត្រាស់ដឹងនូវសច្ចៈ ៤ នោះថាជា ព្រាហ្មណ៍ ។

៤២០.. **យស្ស គតឹ ន ជានន្តិ ទេវា គន្ធព្វមានុសា**
ខីណាសវំ អរហន្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

ទេវតា គន្ធព្វ និង ពួកមនុស្សទាំងឡាយ មិនដឹងគតិ របស់បុគ្គលណា **តថាគត** ហៅបុគ្គល ដែលជាអ្នកមានអាសវៈអស់ហើយ ជាព្រះអរហន្ត នោះ ថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ **វត្តជេតពន** ទ្រង់ប្រារព្ធ **ព្រះវង្គី-សត្ថេរ**។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៤២១.. **យស្ស បុរេ ច បច្ឆា ច មជ្ឈេ ច នត្ថិ កិញ្ចនំ**
អកិញ្ចនំ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា មិនមានសេចក្តីកង្វល់ ក្នុងកាលមុនផង ក្នុងកាលជាខាងក្រោយផង ក្នុងកាលជាកណ្តាលផង **តថាគត** ហៅបុគ្គល ដែលជាអ្នកមិនមានកង្វល់ មិនមានសេចក្តីប្រកាន់នោះ ថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ **វត្តវេឡុវ័ន** ទ្រង់ប្រារព្ធ **ព្រះនាងធម្មទិន្នាថេរី** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៤២២.. ឧសភំ បវរំ វីរំ មហេសឹ វិជិតាវិនំ
អនេជំ ន្ហាតកំ ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។

តថាគត ហៅ **វីរបុរស** អ្នកអង់អាច អ្នកប្រសើរ អ្នកស្វែងរកគុណដ៏ធំ ឈ្នះមារ មិនមានកិលេសជាគ្រឿងញាប់ញ័រ ងូតលាងកិលេស ត្រាស់ដឹងសច្ចៈនោះ ថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ **វត្តជេតពន** ទ្រង់ប្រារព្ធ **ព្រះអង្គុ-លិមាលត្ថេរ** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

៤២៣.. បុព្វេនិវាសំ យោ វេទិ សគ្គាបាយញ្ច បស្សតិ
អថោ ជាតិក្ខយំ បត្តោ អភិញ្ញា វោសិតោ មុនិ
សព្វវោសិតវោសានំ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា ដឹងច្បាស់ខន្ធបញ្ចកៈ ដែលខ្លួនធ្លាប់នៅអាស្រ័យ ក្នុងកាលមុនផង ឃើញច្បាស់ឋានសួគ៌ និង អបាយភូមិផង មួយទៀត បានសម្រេចធម៌ ជាគ្រឿងអស់ជាតិ ជាអ្នកប្រាជ្ញ ស្រេចកិច្ចហើយ ព្រោះអភិញ្ញា **តថាគត** ហៅបុគ្គល ដែលជាអ្នកប្រព្រឹត្ត **ព្រហ្មចរិយធម៌** ចប់សព្វគ្រប់ហើយនោះ ថាជា **ព្រាហ្មណ៍** ។

☸ **ព្រះពុទ្ធគាថា**នេះ កាលព្រះសាស្តាទ្រង់គង់នៅ **វត្តជេតពន** ទ្រង់ប្រារព្ធបញ្ហា **ទេវហិតព្រាហ្មណ៍** ។ ☞ ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើន បានសម្រេចអរិយ-ផលទាំងឡាយ មាន **សោតាបត្តិផល** ជាដើម ។

(ចប់ **ព្រាហ្មណវគ្គ** ទី ២៦ = មាន **៤១** គាថា)

ធម្មបទគាថា ចប់ដោយបរិបូណ៌

= មាន **៤២៣** គាថា

= ចែកចេញជា **២៦** ជំពូក (វគ្គ)

= ប្រារព្ធដោយរឿង មាន៣០២ រឿង

សូមសាធុជនទាំងឡាយ អនុមោទនា រីករាយជ្រះថ្លា សិក្សាស្វាធ្យាយ **ព្រះគាថាធម្មបទ** ជាបន្ទាត់ផ្ទៀងផ្ទាត់ តម្រង់ជីវិតឱ្យបានប្រកបដោយគុណធម៌ មានពន្លឺរស្មី ត្រចះត្រចង់ ប្រាសចាកពីគំនរងងឹត គឺអវិជ្ជា ដែលគ្របសង្កត់ចិត្តសន្តាន ហើយរើខ្លួនចាកចេញពីវដ្តៈ ដ៏អួរអាប់វិលវល់នេះ !

ដោយសេចក្តីមេត្តា និង ការគោរពដ៏ខ្ពង់ខ្ពស់

អំពីខ្ញុំព្រះករុណា-ខ្ញុំ, អ្នករចនា រៀបរៀង និង ផ្ទៀងផ្ទាត់

ព្រហ្ម-មេត្តា គតិបណ្ឌិតោ (ហៅ **ជយទរិន្ទ**)

ឯកសារពិគ្រោះ

១.- គម្ពីរព្រះត្រៃបិដក និង ធម្មបទដ្ឋកថាបាលី
២.- វចនានុក្រមខ្មែរ .... សម្ដេចព្រះសង្ឃរាជ ជួន-ណាត
៣.- បទានុក្រមធម្មបទ..................... ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥៣៧
៤.- សទ្ទានុក្រមព្រះពុទ្ធសាសនា ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥៥៤
៥.- គាថាធម្មបទប្រែ .... ភិក្ខុវិនយធរោមហា យិន-នឿន
៦.- អដ្ឋកថា ខុទ្ទកនិកាយ គាថាធម្មបទ .... ភិក្ខុសុវណ្ណថេរោ លឹម-ធន់
៧.- ធម្មបទគាថាធិប្បាយ .... ភិក្ខុភទ្ទវំសោ សួរ-ស៊ឹម
៨.- គាថាធម្មបទ .... ភិក្ខុបញ្ញាវរោ ស៊ុយ-សុវណ្ណ
៩.- *The Dhammapada* .... Ven. Narada Thera
១០.- *The Dhammapada* .... K. Sri Dhammananda (1992)
១១.- *Illustrated Dhammapada - Treasury of Truth* (*Lao, French, English & Pali Version*) .... Ven. Weragoda Sārada Māha Thēro
១២.- *Dhammapada a Pratical Guide to Right Living* .. Ven. Buddharakkhita
១៣.- *The Buddha & His Teachings* .... Ven. Narada Thera
១៤.- *L'Enseignement du Bouddha* .... Ven. Dr. Walpola Rahula
១៥.- *Le Bouddhisme en Quelques mots* .... Ven. Narada Thera
១៦.- Web site : www.buddhanet.net/dhammapada/index.htm
១៧.- Web site : http://www.tipitaka.net/pali/dhp/
១៨.- Web site : http://www.dhammadelaforet.org
១៩.- Web site : http://www.dhammapada.de
២០.- Web site : http://www.bps.lk



ឯកឧត្តបាលី-ប្រែ

ឯកឧត្តបាលី-ប្រែ

ស្រង់ចាក សុត្តន្តបិដក អង្គុត្តរនិកាយ ឯក-ទុកនិបាត

(បិដកលេខ ៤០ / ទំព័រ ៥៣-៥៨)

(១៤៦) ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ

១).. រត្តញ្ញូនំ យទិទំ អញ្ញាកោណ្ឌញ្ញោ ។

២).. មហាបញ្ញានំ យទិទំ សារីបុត្តោ ។

៣).. ឥទ្ធិមន្តានំ យទិទំ មហាមោគ្គល្លានោ ។

៤).. ធុតវាទានំ យទិទំ មហាកស្សបោ ។

៥).. ទិព្វចក្ខុកានំ យទិទំ អនុរុទ្ធោ ។

៦).. ឧច្ចាកុលិកានំ យទិទំ ភទ្ទិយោ កាឡិគោធាយបុត្តោ ។

៧).. មញ្ជុស្សរានំ យទិទំ លកុណ្ឌកភទ្ទិយោ ។

៨).. សីហនាទិកានំ យទិទំ បិណ្ឌោលភារទ្វាជោ ។

៩).. ធម្មកថិកានំ យទិទំ បុណ្ណោ មន្តានីបុត្តោ ។

១០).. សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ វិភជន្តានំ យទិទំ មហាកច្ចានោតិ ។

(វគ្គោ បឋមោ)

(១៨៦) ម្នាលភិក្ខុទាំងឡាយ,

១)._ បណ្ដាពួកភិក្ខុអ្នកដឹងរាត្រី ដែលជាសាវករបស់**តថាគត** ស្រេចនឹង **អញ្ញាកោណ្ឌញ្ញៈ** ប្រសើរជាងគេ ។

២)._ បណ្ដាពួកភិក្ខុ អ្នកមានប្រាជ្ញាច្រើន ស្រេចនឹង **សារីបុត្ត** ។

៣)._ ពួកភិក្ខុ អ្នកមានឫទ្ធិ ស្រេចនឹងមហា **មោគ្គល្លាន** ។

៤)._ ពួកភិក្ខុ អ្នកពោលពាក្យកំចាត់បង់កិលេស ស្រេចនឹង**មហាកស្សបៈ**

៥)._ ពួកភិក្ខុ អ្នកមានទិព្វចក្ខុ ស្រេចនឹង **អនុរុទ្ធ** ។

៦)._ ពួកភិក្ខុ អ្នកមានត្រកូលខ្ពស់ស្រេចនឹង **ភទ្ទិយកាឡិគោធាយបុត្ត**

៧)._ ពួកភិក្ខុ អ្នកមានសំឡេងពីរោះ ស្រេចនឹង **លកុណ្ឌកភទ្ទិយៈ** ។

៨)._ ពួកភិក្ខុ អ្នកបន្លឺសីហនាទ ស្រេចនឹង **បិណ្ឌោលភារទ្វាជៈ** ។

៩)._ ពួកភិក្ខុ ជាធម្មកថិក ស្រេចនឹង **បុណ្ណមន្តានីបុត្ត** ។

១០)._ ពួកភិក្ខុ អ្នកចែកសេចក្ដីធម៌ ដែល**តថាគត** សំដែងដោយសង្ខេប ឱ្យពិស្ដារបាន ស្រេចនឹង **មហាកច្ចានៈ** ។

(ចប់ វគ្គទី១)

(១៤៧) ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ

១).. មនោមយំ កាយំ អភិនិម្មិនន្តានំ យទិទំ ចុល្លបន្ថកោ ។

២).. ចេតោវិវដ្ដកុសលានំ យទិទំ ចុល្លបន្ថកោ ។

៣).. បញ្ញាវិវដ្ដកុសលានំ យទិទំ មហាបន្ថកោ ។

៤).. អរណវិហារីនំ យទិទំ សុភូតិ ។

៥).. ទក្ខិណេយ្យានំ យទិទំ សុភូតិ ។

៦).. អារញ្ញកានំ យទិទំ រេវតោ ខទិរវនិយោ ។

៧).. ឈាយីនំ យទិទំ កង្ខារេវតោ ។

៨).. អារទ្ធវីរិយានំ យទិទំ សោណោ កោលិវិសោ ។

៩).. កល្យាណវាក្ករណានំ យទិទំ សោណោ កុដិកណ្ណោ ។

១០).. លាភីនំ យទិទំ សីវលី ។

១១).. សទ្ធាធិមុត្តានំ យទិទំ វក្កលីតិ ។

(វគ្គោ ទុតិយោ)

(១៤៧) ម្នាលភិក្ខុទាំងឡាយ,

១).. បណ្ដាពួកភិក្ខុ អ្នកនិមិត្តកាយសម្រេចតាមចិត្តបាន ដែលជាសាវក របស់ **តថាគត** ស្រេចនឹង **ចូឡបន្ថកៈ** ប្រសើរជាងគេ ។

២).. ពួកភិក្ខុ អ្នកឈ្លាសក្នុងការបើកចិត្ត ស្រេចនឹង **ចូឡបន្ថកៈ** ។

៣).. ពួកភិក្ខុ អ្នកឈ្លាសក្នុងការបើកប្រាជ្ញា ស្រេចនឹង **មហាបន្ថកៈ** ។

៤).. ពួកភិក្ខុ អ្នកនៅដោយឥតកិលេស ស្រេចនឹង **សុភូតិ** ។

៥).. ពួកភិក្ខុ អ្នកគួរដល់ទក្ខិណាទាន ស្រេចនឹង **សុភូតិ** ។

៦).. ពួកភិក្ខុ អ្នកនៅក្នុងព្រៃ ស្រេចនឹង **រេវតខទិរវនិយៈ** ។

៧).. ពួកភិក្ខុ អ្នកបានឈាន ស្រេចនឹង **កង្ខារេវតៈ** ។

៨).. ពួកភិក្ខុអ្នកមានព្យាយាមបរិបូណ៌ ស្រេចនឹង**សោណកោលិវិសៈ**។

៩).. ពួកភិក្ខុ អ្នកពោលពាក្យពីរោះ ស្រេចនឹង **សោណកុដិកណ្ណៈ** ។

១០).. ពួកភិក្ខុអ្នកមានលាភ ស្រេចនឹង **សីវលី** ។

១១).. ពួកភិក្ខុ អ្នកមានសទ្ធាស៊ប់ ស្រេចនឹង **វក្កលិ** ។

(ចប់ វគ្គទី២)

(១៤៨) ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ

១)..សិក្ខាកាមានំ យទិទំ រាហុលោ ។

២)..សទ្ធាបព្វជិតានំ យទិទំ រដ្ឋបាលោ ។

៣)..បឋមំ សលាកំ គណ្ហន្តានំ យទិទំ កុណ្ឌធានោ ។

៤)..បដិភាណវន្តានំ យទិទំ វង្គីសោ ។

៥)..សមន្តប្បាសាទិកានំ យទិទំ ឧបសេនោ វង្គន្តបុត្តោ ។

៦)..សេនាសនបញ្ញាបកានំ យទិទំ ទព្វោ មល្លបុត្តោ ។

៧)..ទេវតានំ បិយមនាបានំ យទិទំ បិលិន្ទវច្ឆោ ។

៨)..ខិប្បាភិញ្ញានំ យទិទំ ពាហិយោ ទារុចីរិយោ ។

៩)..ចិត្តកថិកានំ យទិទំ កុមារកស្សបោ ។

១០)..បដិសម្ភិទប្បត្តានំ យទិទំ មហាកោដ្ឋិតោតិ ។

(វគ្គោ តតិយោ)

(១៤៨) ម្នាលភិក្ខុទាំងឡាយ,

១)._ បណ្ដាពួកភិក្ខុ អ្នកស្រឡាញ់សិក្ខា ដែលជាសាវករបស់ **តថាគត** ស្រេចនឹង **រាហុល** ប្រសើរជាងគេ ។

២)._ ពួកភិក្ខុ អ្នកបួសដោយសទ្ធា ស្រេចនឹង **រដ្ឋបាល** ។

៣)._ ពួកភិក្ខុ អ្នកចាប់ស្លាកដំបូងបង្អស់ ស្រេចនឹង **កុណ្ឌធាន** ។

៤)._ ពួកភិក្ខុ អ្នកមានបដិភាណ ស្រេចនឹង **វង្គីសៈ** ។

៥)._ ពួកភិក្ខុអ្នកមានសេចក្ដីជ្រះថ្លាគ្រប់គ្រាន់ ស្រេចនឹង **ឧបសេនវង្គន្តបុត្ត**,

៦)._ ពួកភិក្ខុ អ្នកក្រាលសេនាសនៈ ស្រេចនឹង **ទព្វមល្លបុត្ត** ។

៧)._ ពួកភិក្ខុ ជាទីស្រឡាញ់ ជាទីគាប់ចិត្ត របស់ទេវតាទាំងឡាយ ស្រេចនឹង **បិលិន្ទវច្ឆៈ** ។

៨)._ ពួកភិក្ខុ អ្នកត្រាស់ដឹងរហ័ស ស្រេចនឹង **ពាហិយទារុចីរិយៈ** ។

៩)._ ពួកភិក្ខុ អ្នកចេះសំដីដ៏វិចិត្ត ស្រេចនឹង **កុមារកស្សបៈ** ។

១០)._ ពួកភិក្ខុ អ្នកបានបដិសម្ភិទា ស្រេចនឹង **មហាកោដ្ឋិតៈ** ។

(ចប់ វគ្គទី៣)

(១៤៩) ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ

១)..ពហុស្សុតានំ យទិទំ អានន្ទោ ។

២)..សតិមន្តានំ យទិទំ អានន្ទោ ។

៣)..គតិមន្តានំ យទិទំ អានន្ទោ ។

៤)..ធិតិមន្តានំ យទិទំ អានន្ទោ ។

៥)..ឧបដ្ឋាកានំ យទិទំ អានន្ទោ ។

៦)..មហាបរិសានំ យទិទំ ឧរុវេលកស្សបោ ។

៧)..កុលប្បសាទកានំ យទិទំ កាឡុទាយិ ។

៨)..អប្បាពាធានំ យទិទំ ពក្កុលោ ។

៩)..បុព្វេនិវាសំ អនុស្សរន្តានំ យទិទំ សោភិតោ ។

១០)..វិនយធរានំ យទិទំ ឧបាលិ ។

១១)..ភិក្ខុនោវាទកានំ យទិទំ នន្ទកោ ។

១២)..ឥន្ទ្រិយេសុ គុត្តទ្វារានំ យទិទំ នន្ទោ ។

១៣)..ភិក្ខុឱវាទកានំ យទិទំ មហាកប្បិនោ ។

១៤)..តេជោធាតុកុសលានំ យទិទំ សាគតោ ។

១៥)..បដិភាណេយ្យកានំ យទិទំ រាធោ ។

១៦)..លូខចីវរធរានំ យទិទំ មោឃរាជាតិ ។

(វគ្គោ ចតុត្ថោ)

(១៤៩) ម្នាលភិក្ខុទាំងឡាយ,

១).. បណ្ដាពួកភិក្ខុ អ្នកចេះដឹងច្រើន ដែលជាសាវករបស់ **តថាគត** ស្រេចនឹង **អានន្ទ** ប្រសើរជាងគេ ។

២).. ពួកភិក្ខុ អ្នកមានស្មារតី ស្រេចនឹង **អានន្ទ** ។

៣).. ពួកភិក្ខុ អ្នកមានគតិ ស្រេចនឹង **អានន្ទ** ។

៤).. ពួកភិក្ខុ អ្នកមានប្រាជ្ញា ស្រេចនឹង **អានន្ទ** ។

៥).. ពួកភិក្ខុ ជាឧបដ្ឋាក ក៏ស្រេចនឹង **អានន្ទ** ដែរ ។

៦).. ពួកភិក្ខុ អ្នកមានបរិស័ទច្រើន ស្រេចនឹង **ឧរុវេលកស្សបៈ** ។

៧).. ពួកភិក្ខុ អ្នកញុំាងត្រកូលឱ្យជ្រះថ្លា ស្រេចនឹង **កាឡុទាយិ** ។

៨).. ពួកភិក្ខុ អ្នកគ្មានអាពាធ ស្រេចនឹង **ពក្កុលៈ** ។

៩).. ពួកភិក្ខុ អ្នករឭកឃើញបុព្វេនិវាស ស្រេចនឹង **សោភិតៈ** ។

១០).. ពួកភិក្ខុ អ្នកទ្រទ្រង់វិន័យ ស្រេចនឹង **ឧបាលិ** ។

១១).. ពួកភិក្ខុ អ្នកឱ្យឱវាទភិក្ខុនី ស្រេចនឹង **នន្ទកៈ** ។

១២).. ពួកភិក្ខុ អ្នករក្សាទ្វារក្នុងឥន្ទ្រិយទាំងឡាយ ស្រេចនឹង **នន្ទៈ** ។

១៣).. ពួកភិក្ខុ អ្នកឱ្យឱវាទភិក្ខុ ស្រេចនឹង **មហាកប្បិន** ។

១៤).. ពួកភិក្ខុ អ្នកឈ្លាសវៃក្នុងតេជោធាតុ ស្រេចនឹង **សាគតៈ** ។

១៥).. ពួកភិក្ខុ អ្នកឈ្លាសវៃក្នុងបដិភាណ ស្រេចនឹង **រាធៈ** ។

១៦).. ពួកភិក្ខុ អ្នកទ្រទ្រង់ចីវរសៅហ្មង ស្រេចនឹង **មោឃរាជ** ។

(ចប់ វគ្គទី៤)

(១៥០) ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ភិក្ខុនីនំ

១)..រត្តញ្ញូនំ យទិទំ មហាបជាបតី គោតមី ។

២)..មហាបញ្ញានំ យទិទំ ខេមា ។

៣)..ឥទ្ធិមន្តីនំ យទិទំ ឧប្បលវណ្ណា ។

៤)..វិនយធរានំ យទិទំ បដាចារា ។

៥)..ធម្មកថិកានំ យទិទំ ធម្មទិន្នា ។

៦)..ឈាយិនីនំ យទិទំ នន្ទា ។

៧)..អារទ្ធវីរិយានំ យទិទំ សោណា ។

៨)..ទិព្វចក្ខុកានំ យទិទំ សកុលា ។

៩)..ខិប្បាភិញ្ញានំ យទិទំ ភទ្ទា កុណ្ឌលកេសា ។

១០)..បុព្វេនិវាសំ អនុស្សរន្តីនំ យទិទំ ភទ្ទា កបិលានី ។

១១)..មហាភិញ្ញាបត្តានំ យទិទំ ភទ្ទា កច្ចានា ។

១២)..លូខចីវរធរានំ យទិទំ កិសាគោតមី ។

១៣)..សទ្ធាធិមុត្តានំ យទិទំ សិគាលមាតាតិ ។

(វគ្គោ បញ្ចមោ)

(១៥០) ម្នាលភិក្ខុទាំងឡាយ,

១).. បណ្ដាពួកភិក្ខុនី អ្នកដឹងរាត្រី ដែលជាសាវិការបស់ **តថាគត** ស្រេចនឹង **មហាបជាបតីគោតមី** ប្រសើរជាងគេ ។

២)..ពួកភិក្ខុនី អ្នកមានប្រាជ្ញាច្រើន ស្រេចនឹងនាង **ខេមា** ។

៣)..ពួកភិក្ខុនី អ្នកមានឫទ្ធិ ស្រេចនឹងនាង **ឧប្បលវណ្ណា** ។

៤).. ពួកភិក្ខុនី អ្នកទ្រទ្រង់វិន័យ ស្រេចនឹងនាង **បដាចារា** ។

៥).. ពួកភិក្ខុនី ជាធម្មកថិកា ស្រេចនឹងនាង **ធម្មទិន្នា** ។

៦).. ពួកភិក្ខុនី អ្នកមានឈាន ស្រេចនឹងនាង **នន្ទា** ។

៧)..ពួកភិក្ខុនី អ្នកមានព្យាយាមបរិបូណ៌ ស្រេចនឹងនាង **សោណា** ។

៨).. ពួកភិក្ខុនី អ្នកមានទិព្វចក្ខុ ស្រេចនឹងនាង **សកុលា** ។

៩).. ពួកភិក្ខុនីបានត្រាស់ដឹងរហ័ស ស្រេចនឹងនាង**ភទ្ទាកុណ្ឌលកេសា**។

១០).. ពួកភិក្ខុនីអ្នករឭកឃើញបុព្វេនិវាស ស្រេចនឹងនាង**ភទ្ទាកបិលានី**។

១១).. ពួកភិក្ខុនីអ្នកបានអភិញ្ញាដ៏ធំ ស្រេចនឹងនាង **ភទ្ទាកច្ចានា** ។

១២).. ពួកភិក្ខុនីអ្នកទ្រទ្រង់ចីវរដ៏សៅហ្មង ស្រេចនឹងនាង **កិសាគោតមី**។

១៣).. ពួកភិក្ខុនី អ្នកមានសទ្ធាស៊ប់ ស្រេចនឹងនាង **សិគាលមាតា** ។

(ចប់ វគ្គទី ៥)

(១៥១) ឯតទគ្គំ ភិក្ខវេ មម សាវកានំ ឧបាសកានំ

១).. បឋមំ សរណំ គច្ឆន្តានំ យទិទំ តបុស្សភល្លិកា វាណិជា ។

២).. ទាយកានំ យទិទំ សុទត្តោ គហបតិ អនាថបិណ្ឌិកោ ។

៣).. ធម្មកថិកានំ យទិទំ ចិត្តោ គហបតិ មច្ឆិកសណ្ឌិកោ ។

៤).. ចតូហិ សង្គហវត្ថូហិ បរិសំ សង្គណ្ហន្តានំ យទិទំ ហត្ថកោ

អាឡវកោ ។

៥).. បណីតទាយកានំ យទិទំ មហានាមោ សក្កោ ។

៦).. មនាបទាយកានំ យទិទំ ឧគ្គោ គហបតិ វេសាលិកោ ។

៧).. សង្ឃុបដ្ឋាកានំ យទិទំ ឧគ្គតោ គហបតិ ។

៨).. អវេច្ចប្បសន្នានំ យទិទំ សូរោ អម្ពដ្ឋោ ។

៩).. បុគ្គលប្បសន្នានំ យទិទំ ជីវកោ កោមារភច្ចោ ។

១០).. វិស្សាសកានំ យទិទំ នកុលបិតា គហបតីតិ ។

(វគ្គោ ឆដ្ឋោ)

(១៥១) ម្នាលភិក្ខុទាំងឡាយ,

១)..- បណ្ដាពួកឧបាសកអ្នកដល់សរណៈជាបឋម ដែលជាសាវ័ករបស់ **តថាគត** ស្រេចនឹង តបុស្សពាណិជ និង ភល្លិកពាណិជ ប្រសើរជាងគេ ។

២)..- ពួកឧបាសកជាទាយក (អ្នកឱ្យទាន) ស្រេចនឹង សុទត្តគហបតី គឺ អនាថបិណ្ឌិកសេដ្ឋី ។

៣)..- ពួកឧបាសកជាធម្មកថិក ស្រេចនឹង ចិត្តគហបតី ដែលនៅក្នុងស្រុក មច្ឆិកសណ្ឌៈ ។

៤)..- ពួកឧបាសកអ្នកសង្គ្រោះបរិស័ទ ដោយ **សង្គហវត្ថុ ៤** ប្រការ ស្រេចនឹង ហត្ថកអាឡវក ។

៥)..- ពួកឧបាសក អ្នកឱ្យភោជនមានរសដ៏ឧត្ដម ស្រេចនឹង មហានាមសក្កៈ។

៦)..- ពួកឧបាសក អ្នកឱ្យភោជនជាទីគាប់ចិត្ត ស្រេចនឹង ឧគ្គគហបតី អ្នកនៅក្នុងក្រុងវេសាលី ។

៧)..- ពួកឧបាសក អ្នកបំរើសង្ឃ ស្រេចនឹង ឧគ្គតគហបតី។

៨)..- ពួកឧបាសក អ្នកជ្រះថ្លាមិនកម្រើក ស្រេចនឹង សូរអម្ពដ្ឋ។

៩)..- ពួកឧបាសកអ្នកញ៉ាំងបុគ្គលឱ្យជ្រះថ្លា ស្រេចនឹង ជីវកកោមារភច្ច។

១០)..- ពួកឧបាសកអ្នកចេះនិយាយ ឱ្យអ្នកដទៃស្និទ្ធស្នាល ស្រេចនឹង នកុលបិតាគហបតី ។

(ចប់ វគ្គទី៦)

(១៥២) ឯកមិទំ ភិក្ខវេ មម សាវិកានំ ឧបាសិកានំ

១)..បឋមំ សរណំ គច្ឆន្តីនំ យទិទំ សុជាតា សេនានិធីតា ។

២)..ទាយិកានំ យទិទំ វិសាខា មិគារមាតា ។

៣)..ពហុស្សុតានំ យទិទំ ខុជ្ជុត្តរា ។

៤)..មេត្តាវិហារិនីនំ យទិទំ សាមាវតី ។

៥)..ឈាយិនីនំ យទិទំ ឧត្តរា នន្ទមាតា ។

៦)..បណីតទាយិកានំ យទិទំ សុប្បវាសា កោលិយធីតា ។

៧)..គិលានុបដ្ឋាកីនំ យទិទំ សុប្បិយា ឧបាសិកា។

៨)..អវេច្ចប្បសន្នានំ យទិទំ កាតិយានី ។

៩)..វិស្សាសិកានំ យទិទំ នកុលមាតា គហបតានី ។

១០)..អនុស្សវប្បសន្នានំ យទិទំ កាលី ឧបាសិកា កុររឃរិកាតិ ។

(វគ្គោ សត្តមោ)

(១៥២) ម្នាលភិក្ខុទាំងឡាយ,

១).. បណ្ដាពួកឧបាសិកា អ្នកដល់នូវសរណៈជាបឋម ដែលជាសាវិកា របស់តថាគត ស្រេចនឹង នាងសុជាតាសេនានិធីតា ប្រសើរជាងគេ ។

២)..ពួកឧបាសិកាជាទាយិកា (អ្នកឱ្យទាន) ស្រេចនឹងនាង វិសាខាមិគារមាតា ។

៣)..ពួកឧបាសិកា អ្នកចេះដឹងច្រើន ស្រេចនឹងនាង ខុជ្ជុត្តរា។

៤).. ពួកឧបាសិកា អ្នកនៅដោយមេត្តា ស្រេចនឹងនាង សាមាវតី ។

៥).. ពួកឧបាសិកា អ្នកមានឈាន ស្រេចនឹងនាង ឧត្តរានន្ទមាតា ។

៦).. ពួកឧបាសិកា អ្នកឱ្យទានថ្លៃថ្នូរ ស្រេចនឹងនាង សុប្បវាសាកោលិយធីតា ។

៧)..ពួកឧបាសិកា អ្នកបម្រើជម្ងឺ ស្រេចនឹងនាងសុប្បិយាឧបាសិកា ។

៨).. ពួកឧបាសិកា អ្នកជ្រះថ្លាមិនកម្រើក ស្រេចនឹងនាងកាតិយានី ។

៩).. ពួកឧបាសិកា អ្នកចេះធ្វើឱ្យអ្នកដទៃស្និទ្ធស្នាល ស្រេចនឹងនាង នកុលមាតាគហបតានី ។

១០).. ពួកឧបាសិកា អ្នកជ្រះថ្លាតាមពាក្យដែលឮត ៗ គ្នា ស្រេចនឹងនាង កាលីឧបាសិកាកុររឃរិកា (កុលឃរិកា)។

(ចប់ វគ្គទី៧)

សទ្ធម្មវគ្គ

(សុត្តន្តបិដក អង្គុត្តរនិកាយ បញ្ចកនិបាត)

... ន ខោ អានន្ទ សុករំ បរេសំ ធម្មំទេសេតុំ បរេសំ អានន្ទ ធម្មំ ទេសេន្តេន បញ្ច ធម្មេ អជ្ឈត្តំ ឧបដ្ឋាបេត្វា បរេសំ ធម្មោ ទេសេតព្វោ ។ កតមេ បញ្ច ។...

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា : ម្នាលអានន្ទ ការសំដែងធម៌ដល់ជនដទៃ មិនអាចធ្វើបានដោយងាយទេ, ម្នាលអានន្ទ កាលភិក្ខុសំដែងធម៌ដល់ជនដទៃ គប្បីតម្កល់ **ធម៌ ៥** យ៉ាង ឱ្យមានក្នុងខ្លួនសិន ទើបគួរសំដែងធម៌ដល់ជនដទៃ ។ **ធម៌ ៥** យ៉ាង ដូចម្តេចខ្លះ ?

☸ ភិក្ខុត្រូវសំដែងធម៌ដល់បុគ្គលដទៃ ដោយតាំងចិត្តថា :

១.- **អនុបុព្វិកថំ កថេស្សាមីតិ បរេសំ ធម្មោ ទេសេតព្វោ**

អាត្មាអញ នឹងសំដែង នូវ **អនុបុព្វីកថា** ១,

២.. **បរិយាយទស្សាវី កថំ កថេស្សាមីតិ បរេសំ ធម្មោ ទេសេតព្វោ** *អាត្មាអញនឹងសំដែងដោយលើកអាងហេតុ-ផល ១,*

៣.. **អនុទយតំ បដិច្ច កថំ កថេស្សាមីតិ បរេសំ ធម្មោ ទេសេតព្វោ** អាត្មាអញនឹងសំដែងពាក្យដោយអាស្រ័យសេចក្តីអាណិត (ដល់អ្នកស្តាប់) ១,

៤.. **ន អាមិសន្តរោ កថំ កថេស្សាមីតិ បរេសំ ធម្មោ ទេសេតព្វោ** *អាត្មាអញនឹងមិនសំដែង ព្រោះហេតុ នៃ **អាមិស** ១,*

៥.. **អត្តានញ្ច បរញ្ច អនុបហច្ច កថំ កថេស្សាមីតិ បរេសំ ធម្មោ ទេសេតព្វោ** *អាត្មាអញនឹងសំដែង ដោយមិនបានបៀតបៀនខ្លួនឯង និង បុគ្គលដទៃ ១ ។*

ម្នាល **អានន្ទ** ការសំដែងធម៌ដល់ជនដទៃ មិនអាចធ្វើបានដោយងាយទេ, ម្នាលអានន្ទ កាលភិក្ខុសំដែងធម៌ដល់ជនដទៃ ត្រូវតម្កល់ **ធម៌ ៥** យ៉ាងនេះ ឱ្យមានក្នុងខ្លួនសិន ទើបគួរសំដែងធម៌ដល់ជនដទៃ ។

☞ **ព្រះដ៏ មានព្រះភាគ** ទ្រង់ត្រាស់ថា : ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយ **ធម៌ ៥ យ៉ាង** កាលស្តាប់ **ព្រះសទ្ធម្ម** គួរដើម្បីឈានចុះកាន់ **និយាម** (**គឺ មគ្គ**) ជាសភាពដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយបាន ។

ការប្រកបដោយ **ធម៌ ៥ យ៉ាង** ដូចម្តេចខ្លះ ? គឺ :

១.. **មិនមើលងាយពាក្យពោល** ១,

២.. **មិនមើលងាយបុគ្គលអ្នកពោល** ១,

៣.. **មិនមើលងាយខ្លួនឯង** ១,

៤.. **មានចិត្តមិនរវើរវាយស្តាប់ធម៌** ១,

៥.. **មានចិត្តនឹងនួន នៅក្នុងអារម្មណ៍តែមួយ គឺ យកចិត្តទុកដាក់ ដោយឧបាយប្រាជ្ញា** ១ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយ **ធម៌ ៥ យ៉ាង** នេះឯង កាលស្តាប់ **ព្រះសទ្ធម្ម** ទើបគួរដើម្បីឈានចុះកាន់និយាម ជាសភាពដ៏ប្រពៃ ក្នុង **កុសលធម៌** ទាំងឡាយបាន ។

☞ **ព្រះដ៏ មានព្រះភាគ** ទ្រង់ត្រាស់ថា : *ម្នាលភិក្ខុទាំងឡាយ **ធម៌ ៥** យ៉ាងនេះ ប្រព្រឹត្តទៅដើម្បីឱ្យ **ព្រះសទ្ធម្ម** ឋិតថេរ មិនសាប-សូន្យ មិនអន្តរធានទៅ ។* **ធម៌ ៥** យ៉ាង ដូចម្ដេចខ្លះ ។

ម្នាលភិក្ខុទាំងឡាយ, ភិក្ខុទាំងឡាយ ក្នុងសាសនានេះ :

១.- **សក្កច្ចំ ធម្មំ សុណន្តិ ស្ដាប់ធម៌ដោយគោរព** ១,

២.- **សក្កច្ចំ ធម្មំ បរិយាបុណន្តិ រៀនធម៌ដោយគោរព** ១,

៣.- **សក្កច្ចំ ធម្មំ ធារេន្តិ ទ្រទ្រង់ធម៌ដោយគោរព** ១,

៤.- **សក្កច្ចំ ធតានំ ធម្មានំ អត្ថំ ឧបបរិក្ខន្តិ ពិចារណាអត្ថនៃធម៌ដែលខ្លួនទ្រទ្រង់ហើយ ដោយគោរព** ១,

៥.- **សក្កច្ចំ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មំ បដិបជ្ជន្តិ ដឹងអត្ថ ដឹងធម៌ហើយ ប្រតិបត្តិធម៌តាមសមគួរដល់ធម៌ដោយគោរព** ១ ។

*ម្នាលភិក្ខុទាំងឡាយ **ធម៌ ៥** យ៉ាង នេះឯង ប្រព្រឹត្តទៅដើម្បីឱ្យ **ព្រះសទ្ធម្ម** ឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។*

(ស្រង់ចាក សុត្តន្ត. អង្គុត្តរ. បញ្ចកនិបាត : បិដក ល. ៤៥ / ទំ. ៩២-១១២)

☸ បញ្ចន្នំ រតនានំ បាតុភាវោ ទុល្លភោ លោកស្មឹ
ការកើតប្រាកដ នៃ រតនៈ ៥ យ៉ាង រកបានដោយកម្រក្នុងលោក

ការកើតប្រាកដ នៃ រតនៈ ៥ យ៉ាង រកបានកម្រក្នុងលោក តើដូចម្តេចខ្លះ ? គឺ :

១.. **ការកើតប្រាកដនៃ ព្រះតថាគត ជា អរហន្តសម្មាសម្ពុទ្ធ រកបានដោយកម្រក្នុងលោក** ១,

២.. **បុគ្គលដែលចេះសំដែងធម្មវិន័យ ដែល ព្រះតថាគត ប្រកាសហើយ រកបានដោយកម្រក្នុងលោក** ១,

៣.. **បុគ្គលដែលដឹងច្បាស់លាស់ នូវ ធម្មវិន័យ ដែល ព្រះតថាគតប្រកាសហើយ សំដែងហើយ រកបានដោយកម្រក្នុងលោក** ១,

៤.. **បុគ្គលដែលដឹងច្បាស់លាស់ នូវ ធម្មវិន័យ ដែល ព្រះតថាគតប្រកាសហើយ សំដែងហើយ ប្រតិបត្តិនូវធម៌តាមធម៌ រកបានដោយកម្រក្នុងលោក** ១,

៥.. **កតញ្ញូកតវេទីបុគ្គល រកបានដោយកម្រក្នុងលោក** ១ ។

☸ បញ្ចហិ អង្គេហិ សមន្នាគតា វាចា សុភាសិតា

វាចាដែលប្រកបដោយ **អង្គ៥** យ៉ាង ឈ្មោះថា **សុភាសិត**

ម្នាលភិក្ខុទាំងឡាយ វាចាដែលប្រកបដោយ **អង្គ ៥** ឈ្មោះថា **សុភាសិត** មិនមែនជាទុព្ភាសិត ជាវាចាមិនប្រកបដោយទោសផង ដែលពួកអ្នកប្រាជ្ញ មិនគប្បីតិះដៀលផង ។

វាចា ដែលប្រកបដោយ **អង្គ ៥** តើដូចម្តេច ? គឺ :

១._ **វាចា ដែលពោលប្រកបតាមកាល** ១,

២._ **វាចា ដែលពោលពិត** ១,

៣._ **វាចា ដែលពោលទន់ភ្លន់** ១,

៤._ **វាចា ដែលពោលប្រកបដោយប្រយោជន៍** ១,

៥._ **វាចា ដែលពោលប្រកបដោយមេត្តាចិត្ត** ១ ។

(ស្រង់ចាក **ព្រាហ្មណវគ្គ** សុត្តន្ត. អង្គុត្ត. : បិដក ៤៥ / ទំ. ១៨៨_២៣៦)

☸ បញ្ចា អានិសំសា ធម្មស្សវនេ

អានិសង្ស ៥ យ៉ាង នៃការស្តាប់ព្រះសទ្ធម្ម

ម្នាលភិក្ខុទាំងឡាយ **អានិសង្ស** នៃ ការស្តាប់ព្រះសទ្ធម្មនេះ មាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាង គឺអ្វីខ្លះ ? គឺ :

១.- **អ្នកស្តាប់ តែងបានស្តាប់រឿង មិនទាន់បានស្តាប់** ១,

២.- **រឿងណាដែលធ្លាប់ស្តាប់ហើយ តែមិនទាន់ចូលចិត្តច្បាស់ នឹងចូលចិត្តច្បាស់ឡើងបាន** ១,

៣.- **កំចាត់បង់សេចក្តីសង្ស័យចេញបាន** ១,

៤.- **ធ្វើសេចក្តីឃើញឱ្យត្រង់បាន** ១,

៥.- **ចិត្តអ្នកស្តាប់ រមែងជ្រះថ្លា** ១ ។

☸ ទោសរបស់បុគ្គល ពោលធម៌ដោយសំឡេងច្រៀងវែង

ម្នាលភិក្ខុទាំងឡាយ **ទោស** របស់បុគ្គល ពោលធម៌ ដោយសំឡេងច្រៀងវែងនេះ មាន ៥ យ៉ាង ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ? គឺ :

១.. **ខ្លួនឯង ក៏ត្រេកអរក្នុងសំឡេងនោះ** ១,

២.. **ជនទាំងឡាយដទៃ ក៏ត្រេកអរក្នុងសំឡេងនោះ** ១,

៣.. **គហបតីទាំងឡាយ ពោលទោសថា ពួកយើងច្រៀងយ៉ាងណា ពួកសមណសក្យបុត្តិយ៍ទាំងនេះ ក៏ច្រៀងយ៉ាងនោះដែរ** ១,

៤.. **បុគ្គលពេញចិត្ត ក្នុងការសូត្ររលាក់រលែកសំឡេង រមែងខូចសមាធិ** ១,

៥.. **ពួកជនខាងក្រោយនឹងដល់នូវទិដ្ឋានុគតិ** (យកតម្រាប់តាម)១។

(ស្រង់ចាក **គិមិលវគ្គ** សុត្តន្ត. អង្គុត្ត. : បិដក ល. ៤៥ / ទំ. ២៣៨_២៤៥)

☸ បញ្ច អានិសំសា សមវត្តនិវាសេ

អានិសង្ស ៥ យ៉ាង នៃការញុំាងជីវិតរស់នៅ ដោយល្មម ៗ

ម្នាលភិក្ខុទាំងឡាយ **អានិសង្ស ៥** យ៉ាងនេះ រមែងមានដល់ **បុគ្គលនៅតែល្មម** ៗ ។ អានិសង្ស ៥ យ៉ាង គឺអ្វីខ្លះ ? គឺ :

១.- **មិនមានទ្រព្យសម្បត្តិច្រើន មិនសន្សំទ្រព្យសម្បត្តិច្រើន** ១,

២.- **មិនមានភេសជ្ជៈច្រើន មិនសន្សំភេសជ្ជៈច្រើន** ១,

៣.- **មិនមានកិច្ចការច្រើន មិនត្រូវធ្វើកិច្ចការច្រើន ជាអ្នកឈ្លាសក្នុងការងារទាំងឡាយ** ១,

៤.- **មិនច្រឡូកច្រឡំដោយពួកគ្រហស្ថ និង បព្វជិត មិននៅរួមជាមួយនឹងគ្រហស្ថ ដ៏មិនសមគួរ** ១,

៥.- **កាលបើចៀសចេញពីអាវាសនោះទៅ ចៀសចេញទៅទាំងមិនអាឡោះអាល័យ** ១ ។

ម្នាលភិក្ខុទាំងឡាយ **អានិសង្ស ៥** យ៉ាងនេះ រមែងមានក្នុងបុគ្គលនៅតែល្មម ៗ ។

(ស្រង់ចាក **ឱឃចារិកវគ្គ** សុត្តន្ត. អង្គុត្ត. : បិដក ល. ៤៥ / ទំ. ២៥៥-២៦៣)

☸ បញ្ច ធម្មា ភាវេតព្វា : ធម៌ ៥ យ៉ាង គួរចំរើន...

ដើម្បីដឹងច្បាស់នូវ **ឧបក្កិលេស** ១៧ យ៉ាង : **រាគៈ** (តម្រេក), **ទោសៈ** (សេចក្តីប្រទូស្តក្នុងអារម្មណ៍), **មោហៈ** (វង្វេងក្នុងអារម្មណ៍), **កោធៈ** (ខឹងក្រេវក្រោធ), **ឧបនាហៈ** (ចងសេចក្តីក្រោធទុក), **មក្ខៈ** (រមិលគុណ), **បលាសៈ** (លើកខ្លួន), **ឥស្សា** (ប្ញស្យា), **មច្ឆរិយៈ** (កំណាញ់), **មាយា** (លាក់ពុតល្បិចកល), **សាថេយ្យៈ** (អំនួតអួតអាង), **ថម្ភៈ** (រឹងត្អឹង), **សារម្ភៈ** (ប្រកួតប្រជែង), **មានៈ** (ប្រកាន់ខ្លួន), **អតិមានៈ** (មើលងាយអ្នកដទៃ), **មទៈ** (ស្រវឹង), **បមាទៈ** (ប្រាសចាកសតិ) ។

ម្នាលភិក្ខុទាំងឡាយ **ធម៌ ៥** យ៉ាង គួរចំរើន ដើម្បីដឹងច្បាស់ នូវ **ឧបក្កិលេស** ១៧ ពួក ។ ធម៌ **៥** យ៉ាង គឺអ្វីខ្លះ ? គឺ :

១.. **អសុភសញ្ញា សំគាល់ឃើញថាមិនស្អាត** ១,

២.. **មរណសញ្ញា សំគាល់ឃើញក្នុងសេចក្តីស្លាប់** ១,

៣.. **អាទីនវសញ្ញា សំគាល់ឃើញថាមានទោស** ១,

៤.. **អាហារេ បដិកូលសញ្ញា** សំគាល់ឃើញថាគួរខ្ពើម ក្នុងអាហារ ១,

៥.. **សព្វលោកេ អនភិរតសញ្ញា** សំគាល់ឃើញថាមិនគួរត្រេកអរ **ក្នុងលោកទាំងពួង** ១ ។

☞ ម្នាលភិក្ខុទាំងឡាយ **ធម៌ ៥** យ៉ាងនេះ គួរចំរើន ដើម្បីដឹងច្បាស់នូវ **ឧបក្កិលេស ១៧** ។

☞ ម្នាលភិក្ខុទាំងឡាយ **ធម៌ ៥** យ៉ាង ម្យ៉ាងទៀត ក៏គួរចំរើន ដើម្បីដឹងច្បាស់ នូវ **ឧបក្កិលេស ១៧** ផងដែរ ។

ធម៌ ៥ យ៉ាងនោះ គឺអ្វីខ្លះ ? គឺ :

១.. **អនិច្ចសញ្ញា សំគាល់ឃើញថាមិនទៀង** ១,

២.. **អនិច្ចេ ទុក្ខសញ្ញា** សំគាល់ឃើញថាជាទុក្ខ ក្នុងរបស់មិនទៀង ១,

៣.. **ទុក្ខេ អនត្តសញ្ញា** សំគាល់ឃើញថា មិនមែនរបស់ខ្លួន ក្នុងរបស់ជាទុក្ខ ១,

៤.. **បហានសញ្ញា** សំគាល់ឃើញ ក្នុងធម៌ជាគ្រឿងលះ ១,

៥.. **វិរាគសញ្ញា** សំគាល់ឃើញ ក្នុងធម៌ជាគ្រឿងនឿយណាយ ១ ។

(ស្រង់ចាក **វគ្គាសង្គហិតា សុត្តន្តា** សុត្តន្ត. អង្គុត្ត. : បិ. ៤៥ / ទំ. ២៨៣-២៩៦)

☸ **រូបា សទ្ទា គន្ធា រសា ផស្សា ធម្មា ច កេវលា**
ឥដ្ឋា កន្តា មនាបា ច យាវតត្ថីតិ វុច្ចតិ ....(១)

រូប សំឡេង ក្លិន រស សម្ផស្ស ធម្មារម្មណ៍ ទាំងអស់ ជាទីប្រាថ្នា ជាទីស្រឡាញ់ និង ជាទីពេញចិត្ត លោកពោលថា មាននៅដរាបណា អារម្មណ៏ទាំងនុ៎ះ សត្វលោក ព្រមទាំងទេវលោក សន្មតថាជាសុខ (ដរាបនោះ) អារម្មណ៏ទាំងនោះ តែងរលត់ទៅក្នុង**ព្រះនិព្វាន**ណា **ព្រះនិព្វាន**នោះ ពួកសត្វលោកទាំងនោះ សន្មតថាជាទុក្ខវិញ ។ *ការរលត់នូវ **សក្កាយ** គឺ ខន្ធ ទាំង ៥ **ព្រះអរិយៈ**ទាំងឡាយ ឃើញថាជាសុខពិត ការឃើញ (របស់ព្រះអរិយៈ) អ្នកយល់នេះ ជាទំនាស់នឹងសត្វលោកទាំងពួង ។*

ពួកជនពាលដទៃ ពោលនូវវត្ថុកាមណាថាជាសុខ **ព្រះអរិយៈ**ទាំងឡាយ ពោលនូវវត្ថុកាមនោះថាជាទុក្ខ, ពួកជនពាលដទៃ ពោលនូវព្រះនិព្វានណាថាជាទុក្ខ ព្រះអរិយៈទាំងឡាយ ដឹងច្បាស់នូវព្រះនិព្វាន នោះ ថាជាសុខ, អ្នកចូរឃើញនូវ “**និព្វានធម៌**” ដែលដឹងបានដោយក្រ ពួកអ្នកមិនដឹង វង្វេងហើយក្នុងធម៌នុ៎ះ ។ សេចក្តីងងឹតធ្វើនូវភាពខ្វាក់ តែងប្រាកដដល់ពួកជនពាល ដែលអវិជ្ជាបិទបាំង មិនឃើញនូវ**ព្រះនិព្វាន**, ឯ**ព្រះនិព្វាន**ដូចជាពន្លឺ រមែងបើកបង្ហាញដល់ពួកសប្បុរសអ្នកឃើញ ពួកជន អ្នកមិនឈ្លាសវៃនូវធម៌ គឺព្រះនិព្វាន រមែងមិនដឹងច្បាស់ (នូវព្រះនិព្វាន សូម្បីមាន) ក្នុងទីជិតឡើយ ។ **ព្រះនិព្វាន**នេះ ពួកជនពាលដែលមានភវរាគៈ គ្របសង្កត់ហើយ កំពុងអន្ទោលទៅតាមខ្សែក្នុងភព កើតហើយក្នុងកន្លែងរបស់មារ មិនងាយនឹងត្រាស់ដឹងបានឡើយ ។ នរណាហ្ន៎ វៀរលែងតែ**ព្រះអរិយៈ**ចេញ គួរនឹងត្រាស់ដឹងនូវ **ព្រះនិព្វាន**បាន **ព្រះអរហន្ត** ទាំងឡាយ មិនមានអាសវធម៌ បរិនិព្វានហើយ ព្រោះបានត្រាស់ដឹងដោយប្រពៃ នូវ**ព្រះនិព្វាន** ។

---

(១) **ទ្វយតានុបស្សនាសូត្រ** : សុត្តន្ត. ខុទ្ទក. សុត្តនិបាត (បិ. ៥៤ / ទំ. ២៦២)។

ឧទ្ទិសកថា

~ ឥទំ វោ ញាតីនំ ហោតុ　　សុខិតា ហោន្តុ ញាតយោ

ទាន នេះ ចូរមានដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយបានដល់នូវសេចក្តីសុខ![(១)] ។

__កុសលផលបុណ្យ__ ដែលកើតឡើងអំពី “__ធម្មទាន__”នេះយើងខ្ញុំ សូមឧទ្ទិសជូនចំពោះ លោក_អ្នក ដ៏មានគុណទាំងឡាយ មានមាតា_បិតា ជីដូនជីតា បុព្វការីជន ព្រះគ្រូឧបជ្ឈាយាចារ្យ ព្រមទាំងញាតកាក្នុងសង្សារវដ្តទាំងអស់ សូមលោកអនុមោទនា ត្រេកអរចំពោះគុណកុសលចេតនា និង បុញ្ញកិរិយានេះ, លុះបានអនុមោទនាត្រេកអររួចហើយ សូមបានប្រកបដោយសម្មាទិដ្ឋិ មានបញ្ញាយល់ឃើញត្រូវ សម្រេចនូវសេចក្តីសុខ តាមគន្លង មាគ៌ា នៃ “__ព្រះធម៌ព្រះសម្មាសម្ពុទ្ធ__”ចុះ !

ឥទំ វតនោបុញ្ញំ អាសវក្ខយាវហំ ហោតុ អនាគតេ កាលេ !

វីបុណ្យ ដែលកើតឡើងអំពីកម្លាំងសទ្ធា_កុសលចេតនា ក្នុងធម្មទាននេះ សូមឱ្យបានជាបច្ច័យ នាំមកនូវធម៌ជាទីអស់ទៅនូវអាសវក្កិលេស សន្សំឧបនិស្ស័យចេញចាកវដ្តៈ និង ការបដិបត្តិរួចចាកទុក្ខ បានដល់ត្រើយនាយពោលគឺ **ព្រះនិព្វាន** ក្នុងអនាគតកាល កុំបីឃ្លៀងឃ្លាតឡើយ !

---

(១) សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ “**តិរោកុឌ្ឌកណ្ឌ**” (បិដកលេខ៥២, ទំព័រ១៣)។

ព្រះសមណគោតម ព្រះបរមសាស្ដា
ដ៏ទ្រង់ប្រកបដោយមហាបុរិសលក្ខណៈ
យោ ធម្មំ បស្សតិ សោ មំ បស្សតិ
អ្នកណាឃើញធម៌ អ្នកនោះឃើញតថាគត
ធម្មបូជាពីក្រុមធម្មាមគ្គៈ
ឆ្នាំ មមី ឆស័ក ព.ស.២៥៥៨

ធម្មារាមោ ធម្មរតោ
ធម្មេ ឋិតោ ធម្មវិនិច្ឆយញ្ញូ
នេវាចរេ ធម្មសន្ទោសវាទំ
តច្ចេហិ នីយេថ សុភាសិតេហិ ។

បុគ្គល គួរជាអ្នកមានធម៌ជាទីត្រេកអរ
ត្រេកអរក្នុងធម៌ ឋិតនៅក្នុងធម៌
ចេះវិនិច្ឆ័យនូវធម៌ មិនគួរប្រព្រឹត្ត
នូវពាក្យដែលប្រទូស្តចំពោះធម៌
គប្បីញុាំងកាលឱ្យអស់ទៅ
ដោយសុភាសិតទាំងឡាយ
ដែលពិតៗ !

ធម្មេ ច យេ អរិយប្បវេទិតេ រតា
អនុត្តរា តេ វចសា មនសា កម្មុនា ច
តេ សន្តិសោរច្ចសមាធិសណ្ឋិតា
សុតស្ស បញ្ញាយ ច សារមជ្ឈគូតិ ។

... ជនពួកណា ត្រេកអរក្នុងធម៌
ដែលអរិយបុគ្គលសម្តែងហើយ
ជនពួកនោះ រមែងប្រសើរ
ដោយវចីកម្ម មនោកម្ម
និង កាយកម្ម
ជនពួកនោះ
រមែងឋិតនៅ
ក្នុងសេចក្តីស្ងប់ស្ងាត់
ស្ងប់ស្ងៀម និង សមាធិ
ហើយបានដល់នូវខ្លឹម
នៃការស្តាប់ផង នៃប្រាជ្ញាផង ។
(ស្រង់ចាក **កឹសីលសូត្រ**
សុត្តន្ត. ខុទ្ទក. សុត្តនិបាត
បិ. ៥៤/ ទំ. ១០៥ - ១០៦)

"ធម្មបទគាថា"
ឃ្លាំងមរតកអរិយសច្ចធម៌
សិក្សាបដិបត្តិ អភិវឌ្ឍបញ្ញាស្មារតី
ដើម្បីការរស់នៅជាមួយជីវិតមួយ
ដ៏ប្រកបដោយគុណធម៌ !

The Dhammapada
Treasury of Truth
a Practical Guide
to Right Living.

© ឥស្សរភាពនៃវិចារណញ្ញាណ

Collected Designed & Edited by
Pruhm Metta JayaVarin Dr.